# អង្គរក្សស្រីស្រស់ ម្ចាស់បេះដូង

នាងត្រូវបញ្ជាឲ្យទៅការពារ ព្រះនាង តែហេតុអ្វីបានជាទៅមើលថែ ប្រមុខស្ដីទីវ័យក្មេង
ទៅវិញ តើនាងការពារគេដូចម្ដេចទៅ ហើយក៏
ត្រូវការពារបេះដូងរបស់ខ្លួនឲ្យបានផងដែរ ?
"ខ្ញុំរីករាយរៀបការ...បើបានប៉ះពាល់នាងនៅពេលនេះ"
មិខាអ៊ីល បន្លឺសំឡេង
ពេលទាញដៃរបស់នាងឲ្យផុតពីចង្កាដែលមានពុកចង្ការបស់ខ្លួន
ហើយស្រវាចាប់ដៃទាំងពីររបស់នាងជាប់
ដែលធ្វើឲ្យនាងក្រមុំមានអារម្មណ៍ថាចុកសឹងតែហើយ។
"តែខ្ញុំមិនរៀប..."
នាងបដិសេធភ្លាម មិនឲ្យគេធ្វើអ្វីលើសពីនេះបាន។
"សោកស្ដាយផង
នាងអស់សិទ្ធិបដិសេធហើយ...យើងនឹងរៀបការជាមួយគ្នាតាមការទាមទាររបស់នាង"
និយាយចប់បុរសមាត់ក្ដៅពេលស្អាត ក៏ឱនទៅបិទបបូរមាត់របស់នាង
ថើបនាងដោយការទាមទារ ខណៈដែលដៃទាំងពីរលែងកដៃរបស់នាង
តែលូកទៅឱបចង្កេះ
ទាញរាងកាយស្រឡូនមកឱបរឹតនឹងដើមទ្រូងធំទូលាយដោយសាច់ដុំដ៏រឹងមាំនោះ
ដោយភាពស្និទ្ធស្នាល។

Come to join us
www.facebook.com/yuveakvey
Tel:010687767

អង្គរក្សស្រីស្រស់ ម្ចាស់បេះដូង
S@rkA



# ១

ឃ្វីន, ក្រុមហ៊ុនបម្រើសេវាកម្មឯកជន...

ហេឃ្យុ ចុះពីឡានតាក់ស៊ី ហើយអូសវ៉ាលិសតូចមួយដើរសំដៅអគារប្រាំជាន់នៅខាងមុខ ដែលមិនសូវមានមនុស្សម្នាច្រើន។ អគារមួយនេះទោះនៅតំបន់ពាណិជ្ជកម្មតែខ្សត់មនុស្ស និងបង្កប់ដោយកាមេរ៉ាទូរទស្សន៍ជុំវិញអគារ។

នាងប្រើកាតពិសេស បើកទ្វារទៅជួបសន្តិសុខការពារសុវត្ថិភាពអគារ ត្រូវត្រួតពិនិត្យដោយម៉ាស៊ីនស្វ័យប្រវត្ត តាំងពីខ្លួនមនុស្សរហូតដល់វ៉ាលិស។

វ៉ាលិសនោះត្រូវរឹបអូសពេលឆ្លងផុតចំណុចទីពីរ ដោយឲ្យតែនាងប៉ុណ្ណោះចូលទៅដល់ចំណុចទីបី ហើយត្រូវចុះជណ្តើរយន្តទៅក្រោមដី។

នាងត្រូវចុះដល់ទៅប្រាំជាន់ ទើបដើរកាត់បន្ទប់ធ្វើការជាច្រើនកាត់បុគ្គលិកដែលកំពុងមមាញឹក ទើបចូលទៅដល់បន្ទប់ធ្វើការរបស់**ថៅហ្វាយ**។

ប៉ែក ដាចង ជាឈ្មោះរបស់អ្នកបង្គាប់បញ្ជាធំបំផុតនៅអង្គភាពនេះ ដែលស្ត្រីចាស់អាយុហាសិបឆ្នាំទៅហើយ ប៉ុន្តែនៅស្អាតនៅក្មេងគួរឲ្យចាប់អារម្មណ៍ ជាពិសេសសរសៃសក់ពណ៌ល្បាយអាចម៍ខ្លាពេញមួយក្បាល។

នៅមុខបន្ទប់របស់ ប៉ែក ដាចង មានលេខាឈ្មោះថា កូ យុណាញញឹមញញែមរាក់ទាក់អ្នកដែលដើរកាត់។

"សួស្តី អ្នកនាង គីម មកទាំងព្រឹកតែម្តង"

"ត្រូវដាស់តាំងពីម៉ោងពីរទៀបភ្លឺឲ្យមកបង្ហាញខ្លួន"

ចម្លើយនោះ ធ្វើឲ្យលេខារហ័សចុចប៊ូតុងបើកទ្វារឲ្យភ្លាម។

"អញ្ចើញ បើត្រូវដាស់តាំងពីម៉ោងពីររំលងអធ្រាត្រ ច្បាស់ជាមានការងារសំខាន់"

យុណា និយាយហើយក៏បួញមាត់ឲ្យដើរចូល។

នៅក្នុងនោះ...ប៉ែក ដាចង កំពុងអង្គុយចាំនៅតុធ្វើការ។

"មកហើយឬ...អ៊ំា យកការងារថ្មីទៅ"

ម៉ាដាម ប៉ែក និយាយ ព្រមទាំងហុចសំណុំឯកសារឲ្យ ទើបនាងចូលអង្គុយកៅអីទល់មុខ ទាញវាមកបើកមើល។

រូបថតដំបូងដែលនាងឃើញ គឺព្រះអង្គម្ចាស់រូបសង្ហាតើរ៉ហ្វិចរកកន្លែងឲ្យទាស់គ្មាន។

"មិខាអ៊ីល អាប់ឌុលឡោះ ឧស្មាន់"

នាងអានឈ្មោះនៅក្រោមរូបភាព ហើយក្រឡេកមើលថៅហ្វាយ។

"ជាញាតិសាច់ឆ្ងាយរបស់ព្រះរាជា អាស់សាន អាប់ឌុលឡោះឧស្មាន់ ដែលសោយព្រះទិវង្គតទៅហើយ នៃរាជាណាចក្រសាគីស្ថានជាប់សមុទ្រខ្សាច់សាហារ៉ា តែពេលនេះនៅប្រទេសយើង ត្រូវការអង្គរក្សឲ្យប្អូនស្រី ដែលនឹងមកកម្សាន្តនៅទីនេះ"

"ប៉ុណ្ណឹងឬដែលម៉ាដាមហៅខ្ញុំតាំងពីម៉ោងពីររំលងអធ្រាត្រ ?"

"ទ្រង់ត្រូវការអង្គរក្សថ្មីដៃឯកឲ្យទៅការពារអនាគតព្រះរាជិនី វាមិនមែនជារឿងតូចតាចទេ ហើយដែលទ្រង់ជួលយើង ព្រោះជឿជាក់ថ្វីដៃឃ្វីន របស់យើងគ្រប់គ្នា ជូនអីរួចរាល់ការងារល្អម ហើយខ្ញុំក៏ត្រូវការនាង

ដែរ ខ្លាចក្រុមការងារផ្សេងមកឆក់យកទៅបាត់"

ហេតុផលរបស់ម៉ាដាម ទោះសមហេតុផល ប៉ុន្តែនាងនៅតែមិនបាត់ខឹងដដែល ពេលគិតថាទម្រាំត្រឡប់ទៅដល់ខុនដូរបស់ខ្លួនវិញ ក៏យប់ជ្រៅណាស់ទៅហើយ បែរជាត្រូវទូរសព្ទតាមហៅឲ្យងើបមើលសារ។

"ហើយឯណារូបថតរបស់ហ្ស៊ីកា?" នាងសួរ ពេលឃើញនៅក្នុងសំណុំឯកសារគ្មានរូបផ្សេង។

"នាងត្រូវទៅបង្ហាញខ្លួន បន្ទាប់ពីនោះ ហ្ស៊ីក មិខាអ៊ីល ម្នាក់នេះនឹងបញ្ជាការងារទាំងអស់"

"មានន័យថាការធ្វើការនេះស្ថិតនៅលើគេ...យូរប៉ុណ្ណា?"

"មិនបានកំណត់ពេលវេលា ស្រេចតែនាងថាធ្វើការឲ្យគេពេញចិត្តប៉ុណ្ណា បើមិនពេញចិត្តនឹងត្រូវបញ្ជូនមកវិញភ្លាម"

"អូខេ ត្រូវទៅថ្ងៃនេះមែនទេ?"

នាងសួរ ព្រមទាំងងើបឈរត្រៀមខ្លួនរួចជាស្រេច។

"សុំសំណុំឯកសារវិញ" ម៉ាដាមប្រាប់ ដែលកូនចៅក៏ធ្វើតាមភ្លាមដោយមិនអែនអន។

"ពេលនេះគេបញ្ជូនឡានមកយកហើយ រង់ចាំនៅមុខអគារ"

"ចាំ កន្លែងដែលត្រូវទៅស្ថានទូតសាគីស្ថានឬអត់?"

"ជាផ្ទះបុរាណជាប់នឹងស្ថានទូតដែលគេជួល... សូមឲ្យសំណាងល្អគីម ហេយ្សូ"

"ចាំ"

ហេយ្សូ ធ្វើដំណើរយ៉ាងស្វាហាប់ចេញពីអគារប្រាំជាន់នោះ ដោយនៅមុខអគារមានឡានមែកហ្សីដេសពណ៌ខ្មៅមួយគ្រឿងនៅចាំ ដោយអ្នកបើកឡានឈរកាន់រូបថតរបស់នាង ហើយបើកទ្វារឲ្យភ្លាមពេលនាងអូសវ៉ាលិសមកដល់។

អ្នកបើកឡានយកវ៉ាលិសទៅដាក់នៅគូថឡាន ហើយនាំនាងចាកចេញទៅ។

**រូបថតច្បាស់គ្រប់ប៉ុស្តិ៍គ្រប់ឥរិយាបថរបស់នាងក្រមុំ ត្រូវបញ្ជូនមក**ដល់ដៃព្រះអង្គម្ចាស់កំលោះ ដែលទទួលខុសត្រូវរឿងនេះ...

មិខាអ៊ីល មើលរូបថតនាងគ្រប់ឥរិយាបថ ទាំងថតចំពីមុខ ថតពីចំហៀង ដែលផ្ញើមកតាមរយៈឧបករណ៍អេឡិចត្រូនិចមានល្បឿនលឿននៅក្នុងផ្ទះធំដែលគេកំពុងធ្វើការ។

កែវភ្នែកមុតស្រួចលម្អដោយរោមភ្នែកវែង ងរមិនចាញ់មនុស្សស្រីប៉ប្រិចជាច្រើនដងពេលបានឃើញនាងពេញភ្នែក និងមិនចង់ជឿទេថានាងត្រូវបញ្ជូនមកធ្វើជាអង្គរក្សសម្រាប់រឿងនេះ។

នាងស្អាតពេកហើយ អាចនិយាយបានថាស្អាតដល់ថ្នាក់មិនគួរឲ្យជឿ មិនថាមើលពីត្រង់ណា ទាំងរាងរៅ ទាំងមុខមាត់។

បែបនេះគួរតែយកទៅទុកក្នុងហារ៉េមផ្ទាល់ខ្លួន ជាងបណ្តោយឲ្យដើរក្រឡឹងរាំងដោយតួនាទីជាអង្គរក្ស។

មិខាអ៊ីល គិត និងលាក់ស្នាមញញឹមនៅក្រោមទឹកមុខរាបស្មើរបស់ខ្លួន ធ្វើឲ្យមានស្នាមខ្ចួចកើតឡើងនៅត្រង់ថ្ពាល់ ខណៈដែលដើរទៅឈរនៅមាត់បង្អួចធំ សម្លឹងមើលផ្លូវដែលមានដើមឈើធំៗបែកមែកសាខានៅអមសងខាងផ្លូវ លាតសន្ធឹងមកដល់ផ្ទះបុរាណមួយខ្នងនេះ។

"ខ្ញុំឈ្មោះ ហ៊ុលសែន ជាលេខារបស់ ហ្ស៊ីក មិខាអ៊ីល ទ្រង់រង់ចាំនៅខាងក្នុង...ក្នុងបន្ទប់ធ្វើការ..."



បុរសដែលពាក់គ្រឺហ្សៀពណ៌ខ្មៅ ចេញមកទទួលនាងដល់ឡាន យករូបថតរបស់នាងពីអ្នកបើកឡានមកកាន់ និងមើលដោយការពិចារណាថាមិនខុសមនុស្ស ហើយនាំដើរចូលទៅក្នុងផ្ទះ។

ហេយ្យូ ដើរកាត់មុខបន្ទប់កញ្ចក់ដែលមានមនុស្សពីរបីនាក់ឈរប្រចាំការ គិតថាជាអ្នកយាម ទោះនៅក្នុងឈុតគ្រឺហ្សៀដូចគ្នាក៏ដោយ ហើយពេលដើរចូលដល់បន្ទប់ធំនៅកណ្ដាលផ្ទះ ក៏ទៅដល់ទ្វារបន្ទប់ដែលមានមនុស្សប្រុសតែងខ្លួនដូចទាហានអារ៉ាប់បុរាណកំពុងឈរយាម បន្ទាប់មកទើបអាចចូលទៅរកព្រះអង្គម្ចាស់បាន អាចនិយាយបានថាឆ្លងកាត់ច្រើនដំណាក់កាលតែម្ដង ទម្រាំបានជួបចៅហ្វាយថ្មីរបស់ខ្លួន។

ហ៊ុលសែន លេខានិងជាអង្គរក្សរបស់ព្រះអង្គម្ចាស់ បើកទ្វារឲ្យនាងចូលទៅជួបចៅហ្វាយរបស់ខ្លួនតែម្នាក់ឯង ដោយរឹបអូសយកវ៉ាលិសរបស់នាងមកខាងក្រៅ។

ពេលចូលមកក្នុងបន្ទប់រាងកាយរបស់ហេយ្យូក៏ប៉ះនឹងអាកាសធាតុត្រជាក់របស់ម៉ាស៊ីនត្រជាក់ និងមើលឃើញបុរសមាឌធំ រាងខ្ពស់ស្រឡះស្មាធំទូលាយ គ្រងឈុតពណ៌ស មានកន្សែងពណ៌ខ្មៅក្រវាត់ចង្កេះ និងមានខ្សែពណ៌ខ្មៅក្រវាត់ឈ្នួតក្បាល មានពណ៌ដូចអាវ។

តែអ្វីក៏មិនដូចមុខមាំគួរឲ្យមើល ដែលភ្នែករបស់គេកំពុងតែមើលមកពេលនាងដើរទៅរក។

កែវភ្នែកមុតស្រួចនោះសម្លឹងមើលមកដោយការត្រួតពិនិត្យតាំងពីក្បាលដល់ចុងជើង តាំងពីជំហានដំបូងដែលចូលមកក្នុងបន្ទប់ធ្វើការធំទូលាយ រហូតដល់ទៅឈរនៅទល់មុខ បុរសដែលសង្ហាដូចទេវបុត្រច្បុតសួគ៌ា។

នៅក្នុងរូបថតថាសង្ហាហើយ ដល់មកបានឃើញដោយផ្ទាល់



សម្បុរសម្បកស្អាតជាងមនុស្សស្រីមួយចំនួនទៅទៀត ធ្វើឲ្យនាងក្រមុំនិយាយមិនចេញច្រើននាទីតែម្ដង។

នាងឈរភាំងមើលគេយ៉ាងយូរ ដូចព្រះអង្គម្ចាស់វ័យក្មេងដែលមើលនាងយូរដូចគ្នា បន្ទាប់មកទើបនិយាយ។

"អ្នកនាងគឺ គីម ហេយ្យូ...មានឈ្មោះភាសាអង់គ្លេសទេ?"

ពេលត្រូវសួរបែបនេះ នាងក្រមុំក៏គ្រវីក្បាល។

"អ៊ីចឹងអ្នកនាងឲ្យខ្ញុំហៅបែបណា...ហៅឈ្មោះពេញ ហៅនាមត្រកូល ឬហៅចុងឈ្មោះ?"

"ហៅ យ្យូ ក៏បាន..."

"អូខេ...ពេលនេះយើងនិយាយការងារ ដែលអ្នកនាងត្រូវទទួលខុសត្រូវ...ហ្ស៊ីការរបស់យើង ទ្រង់នឹងយាងមកដល់ថ្ងៃនេះ ហើយមិនប៉ុន្មានម៉ោងទៀត អ្នកនាងត្រូវធ្វើជាអង្គរក្សឲ្យទ្រង់រយៈពេលដប់ប្រាំថ្ងៃដែលទ្រង់គង់នៅទីនេះ...គិតថាគ្មានបញ្ហាអីទេមែនទេ?"

គេផ្អាកនិយាយ ហើយបែរខ្លួនដើរក្រឡឹងតុទៅយករូបថតរបស់ព្រះអង្គម្ចាស់ក្សត្រីមកហុចឲ្យ ទើប ហេយ្យូ មើលដោយការយកចិត្តទុកដាក់ ចងចាំភិនភាគឲ្យបានច្បាស់តាំងពីក្បាលដល់ចុងជើង។

"ញ៉ាំអីហើយឬនៅ?" គេសួរ និងក្រឡេកមើលនាង។

"ផឹកតែកាហ្វេ"

"អ៊ីចឹងយើងទៅញ៉ាំអាហារថ្ងៃត្រង់ទៅ នឹងអាលនិយាយគ្នារឿងការងារ"

គេប្រាប់ ហើយដើរនាំមុខចេញពីបន្ទប់ នាងក្រមុំក៏ដើរតាមដោយកាន់រូបថតព្រះអង្គម្ចាស់ក្សត្រីទៅជាមួយដែរ។



ពេលមកដល់តុអាហារ មានអ្នកចាំបម្រើជួយទាញកៅអីឲ្យគេ រួម

ទាំងនាងដែរ។

"ញាំបាយរួច យើងនឹងទៅទទួលហ្សីកា រ៉ែននី..."

គេនិយាយជាមួយនាងសាមញ្ញៗមិនប្រាប់ឲ្យដឹងថាគេជាអ្នកណាត្រូវជាអ្វីនឹងព្រះអង្គម្ចាស់ក្សត្រី និងមានឋានៈធំដុំប៉ុណ្ណា។

**ទម្រាំតែ ហេយ្យូ ដឹងថាព្រះអង្គម្ចាស់ក្សត្រី រ៉ែននី ព្រះធីតានៃ** ព្រះមហាក្សត្រ អាស់សាន ទ្រង់យាងមកដោយយន្តហោះផ្ទាល់ព្រះអង្គគឺពេលទៅដល់ព្រលានយន្តហោះ ដោយចូលទៅអង្គុយចាំនៅក្នុងបន្ទប់ទទួលភ្ញៀវវីអាយភី។

ខណៈដែលដើរតាមគ្នាចូលបន្ទប់វីអាយភី នាងក៏ក្រឡេកឃើញមនុស្សម្នាក់ ដែលគេក៏គេចភ្នែកភ្លាម ទើបវាធ្វើឲ្យនាងចងចិញ្ចើម តាមមើលទាល់តែបាត់ពីភ្នែក និងប្រាប់ខ្លួនឯងថានៅទីនេះច្បាស់ជាមានអីមិនប្រក្រតី ប៉ុន្តែតើអ្វីទៅដែលវាមិនប្រក្រតី?

នាងរកមើលភាពខុសប្រក្រតីនោះពីមនុស្សដែលដើរតាម ហ្សីក មិខាអ៊ីល មកទទួលព្រះរាជដំណើររបស់ព្រះអង្គម្ចាស់ក្សត្រី មិនថាជាលេខាដែលមានឈ្មោះថា ហ៊ុលសែន ឬអ្នកឯទៀតដែលមានមិនប៉ុន្មាននាក់ប៉ុណ្ណោះ។

"យន្តហោះចុះចតហើយទាន..."

អ្នកដែលយាមនៅមាត់ទ្វារ ចូលមករាយការណ៍ ធ្វើឲ្យអ្នកដែលទើបតែមកដល់ ត្រូវងើបឈរត្រង់ខ្លួនដើរចេញទៅជាជួរ រួមទាំង ហេយ្យូ ដែរ ដែលដើរក្រោយគេ ប៉ុន្តែពេលដើរបានមួយសន្ទុះ ក៏ត្រូវរៀបចំឲ្យដើរជាប់នឹង ហ្សីក មិខាអ៊ីល ដោយស្វ័យប្រវត្ត។

# ២

**ហេយ្យូ ដើរតាមក្បួនដោយមិនមាត់មិនក រហូតដល់ជិតដល់ឡាន** ដែលចតចាំក៏នឹកឃើញរឿងមួយ ដែលវាធ្វើឲ្យនាងទប់ដំណើរ ស្របពេលដែលឡានបើកទ្វារទាំងសងខាង ហើយអ្នកដែលនាងមិនស្គាល់ក៏លេចមុខពីរនាក់ ដោយមានអាវុធក្នុងដៃ។ ពេលនោះឯងដែលនាងរត់បំបុក មិខាអ៊ីល មួយទំហឹងឲ្យគេដេកដួល ដោយទ្រោបនៅពីលើគេបែបនោះ ស្របពេលដែលដៃទាញកាំភ្លើងបាញ់ពួកដែលបាញ់មករកពួកនាង។

នាងដឹងថាវាប្រថុយណាស់ដែលធ្វើបែបនេះ ប៉ុន្តែពេលនេះនាងធ្វើអីមិនបានក្រៅពីធ្វើបែបហ្នឹង ខណៈដែលអ្នកដើរតាមពីក្រោយក៏ទាញកាំភ្លើងបាញ់តទល់ដើម្បីការពារចៅហ្វាយនិងខ្លួនឯង។

សំឡេងកាំភ្លើង ឮឲ្យទ្រហឹងពេញព្រលានយន្តហោះមួយខណៈនោះ បន្ទាប់មកក៏ស្ងប់ស្ងាត់ពេលខ្មាន់កាំភ្លើងទាំងពីរដាច់ខ្យល់ស្លាប់ក្នុងថ្លុកឈាម ខណៈដែលមនុស្សរបស់ ហ្សីក ក៏ដួលដែរ។

គ្រាប់កាំភ្លើងរបស់ពួកវា ជះមកចំដងខ្លួនរបស់កូនចៅទាំងអស់មានតែ ហ្សីក មិខាអ៊ីល ម្នាក់ប៉ុណ្ណោះដែលមិនអី ព្រោះត្រូវនាងក្រមុំទ្រោបពីលើ។

ហេយ្យូ ត្រូវបាញ់ តែគ្រាប់ជាប់នឹងអាវក្រោះទាំងអស់។



ពេលស្ងប់សំឡេងកាំភ្លើង ពួកគេក៏សម្លឹងមើលខ្មាន់កាំភ្លើងដែល

ដេកស្លូកស្លឹងក្នុងថ្លុកឈាម មើលឲ្យច្បាស់ថាពួកវាងាប់មែនទែន។

ហ៊ុលសែន ត្រូវបាញ់ចំដៃឆ្វេង ដើរអូសខ្លួនឯងទៅមើលពីរនាក់នោះឲ្យច្បាស់ ដោយមានជំនួយការពីរនាក់ទៅជាមួយ។ ពេលមើលច្បាស់ហើយថាពួកវាងាប់ ក៏ងាកមករាយការណ៍ ដែលពេលនេះ ហ្សីកកំលោះកំពុងទាញ ហេយ្យូ ឲ្យងើបឈរ។

"ត្រូវត្រង់ណាទេ ?"

មិខាអ៊ីល សួរដោយការព្រួយបារម្ភ។

"ត្រូវអាវក្រោះទាំងអស់...សំណាងល្អ"

នាងតប និងបើកអាវក្រោះ ទាញគ្រាប់ឲ្យមើល។

ពេលនោះម្នាក់ៗត្រួតពិនិត្យខ្លួនឯង ហើយក៏ដកដង្ហើមធំ ជូរទ្រូងខ្សាកដែលអាចរួចផុតពីហេតុការណ៍រន្ធត់នេះបាន។ បន្ទាប់មក ហ៊ុលសែន ក៏ទូរសព្ទសុំឡានថ្មី ព្រោះមិនច្បាស់ទេថាឡានចាស់អាចទុកចិត្តបានប៉ុណ្ណា ដែលវាក៏ដូចការគិត ព្រោះមិនប៉ុន្មាននាទីក្រោយមកឡាននោះក៏ផ្ទុះ។

**ព្រះអង្គម្ចាស់ក្សត្រី រ៉េននី អនាគតសម្តេចព្រះមហាក្សត្រីនៃរាជាណាចក្រ សាគីស្ថាន** មិនមែនជាក្មេងស្រីដូចដែល ហេយ្យូ គិត។ ពេលបានជួបមុខ ទ្រង់ជាស្រីក្រមុំ តែងខ្លួនតាមសម័យលោកខាងលិច មិននៅសល់ភាពជាសមុទ្រខ្សាច់ឲ្យឃើញ។

កែវភ្នែកមុតស្រួចដែលត្រូវតុបតែងដោយគ្រឿងសម្អាង មើលគ្រប់គ្នា ហើយមកឈប់ត្រង់ ហេយ្យូ បន្ទាប់មកក៏ហួសទៅរកព្រះអង្គម្ចាស់រូបសង្ហា។

"ព្រះរៀមជាទីស្រឡាញ់"

ហេយ្យូ ស្តាប់សំឡេងហៅ និងការដើរទៅចំទើតជើងលើកដៃឱបក ហ្សីកកំលោះ ដែលរូបភាពនោះក៏ធ្វើឲ្យគ្រប់គ្នាប៉ប្រិចភ្នែក។

មែនហើយ តាមដែលធ្លាប់ឃើញ ស្រីៗមកពីសមុទ្រខ្សាច់ តែងតែស្លួនឬកស្លួនពាដោយសម្លៀកបំពាក់បិទបាំងជិតខ្លួន ទាំងអាបាយ៉ាហ៊ិយ៉ាប ឯអ្នកដែលតែងខ្លួនតាមពួកលោកខាងលិចមានតិចណាស់។

"រ៉េននី" មិខាអ៊ីល បេះដៃរបស់នាងចេញពី.ករបស់ខ្លួន ព្រមទាំងសួរនាំ "យ៉ាងម៉េចដែរ...ការធ្វើដំណើររលូនមែនទេ ?"

"ចា៎ រលូនណាស់" ព្រះអង្គម្ចាស់ក្សត្រីតប និងញញឹមដាក់គេ។

"នេះជាអង្គរក្សថ្មីរបស់ ហ្សីកា កំលុងពេលស្នាក់នៅទីនេះ... ឈ្មោះ គីម ហេយ្យូ ហៅងាយៗថា យ្យូ"

ហ្សីក ណែនាំអង្គរក្សឲ្យសាច់ញាតិបានស្គាល់ជាភាសាអង់គ្លេស។

នៅខណៈនោះគ្មានអ្នកណានិយាយពីរឿងបាញ់គ្នាផ្អើលព្រលានយន្តហោះដូចអម្បាញ់មិញគ្មានរឿងអ្វីកើតឡើង ទោះព្រះអង្គម្ចាស់ក្សត្រីទតឃើញ ហ៊ុលសែន មានបង់រុំរបួសនៅដៃឆ្វេងក៏ដោយ ប៉ុន្តែមិនបានសួរនាំ។

"ទៅអង្គុយជាមួយអ្នកបើកឡានជំនួសខ្ញុំ ហើយប្រយ័ត្នខ្លួន"

ពេលដើរមកដល់ឡានដែលចតចាំពីរគ្រឿង ហ៊ុលសែន ក៏ខ្សឹបប្រាប់ ហេយ្យូ បន្ទាប់មកក៏ដើរទៅអង្គុយនៅឡានមួយទៀត ទុកឲ្យនាងធ្វើតួនាទីជំនួសខ្លួនគូជាមួយអ្នកបើកឡាន ដោយមានព្រះអង្គម្ចាស់ក្សត្រី និងព្រះអង្គម្ចាស់អង្គុយនៅបាំងក្រោយ។

ពេលកំពុងធ្វើដំណើរ ហេយ្យូ ក៏មើលមុខអ្នកបើកឡានមុនគេ តែគេមិនមើលមុខនាង ចាប់អារម្មណ៍តែការងាររបស់ខ្លួនប៉ុណ្ណោះ ដែលវាក៏ល្អ...នាងគិត។ បន្ទាប់មកឡានក៏បើកចេញពីព្រលានយន្តហោះ សំដៅ



សណ្ឋាគារដែលជាទីគង់ប្រថាប់របស់ព្រះអង្គម្ចាស់ក្សត្រី។

ពេលមកដល់សណ្ឋាគារ ហេយ្យូ ត្រូវដើរតាមព្រះអង្គម្ចាស់ក្សត្រីបង្កើយ ដែលក្បែរនោះមាន មិខាអ៊ីល ដែរ ទើបធ្វើឲ្យព្រះអង្គម្ចាស់ក្សត្រីដែលងាកមករកព្រះញាតិវង្ស ទតឃើញល្មម។

ហេយ្យូ មើលឃើញព្រះនេត្រមួយគូនោះមិនសព្វព្រះទ័យមួយរំពេច បន្ទាប់មកក៏ស្រវាឱបដៃ មិខាអ៊ីល បណ្តើរគ្នាដើរមុខ ហាក់ដូចខ្លាចនាងដណ្តើម ឬធ្វើខ្លួនស្មើឋានៈ។

ពួកគេឡើងជណ្តើរយន្តទៅដល់បន្ទប់ដែលកក់ មានអង្គរក្សយាមកាមត្រៀបត្រា។

"អង្គរក្សរបស់អនុជក៏មានច្រើន...ព្រះរៀមទៅរកអ្នកណាមកទៀតឲ្យទើសទែង"

ព្រះអង្គម្ចាស់ក្សត្រីមានព្រះសវនីយ៍ដាក់មិខាអ៊ីលពេលទ្រង់យាងចូលមកក្នុងបន្ទប់ដែលត្រូវគង់ប្រថាប់ ដោយ ហេយ្យូ ឈរនៅឆ្ងាយ។

នាងសម្លឹងមើលទៅជុំវិញខ្លួន ដោយសង្កេតមើល ខ្លាចថាមានអ្វីខុសប្រក្រតីទៀត។

"នាងនឹងមើលថែ ហ្ស៊ីកា បានគ្រប់កន្លែង ដែលមនុស្សប្រុសទៅជាមួយមិនបាន" មិខាអ៊ីល ប្រាប់ហេតុផល។

"អនុជមើលថែខ្លួនឯងបាន...នាំនាងចេញទៅ មិនអីចឹងអនុជនឹងចាត់ការខ្លួនឯង"

ប្រយោគនេះឯង ដែលធ្វើឲ្យព្រះអង្គម្ចាស់វៃក្មេងងាកមកមើលមុខរបស់ព្រះអង្គម្ចាស់ក្សត្រីចំៗ។

"ម៉េចក៏និយាយបែបនេះ"

"ប្រាប់ហើយតើថាមិនចូលចិត្ត...ឈប់ជួល បញ្ជូនទៅវិញឲ្យផុតពីមុខ..."

"ស្អីដែលថាចាត់ការដោយខ្លួនឯង ?"

"គឺ...ដូចជាអង្គរក្សរបស់អនុជចាប់នាងបោះចេញពីអគារនេះ...ឬធ្វើយ៉ាងណាក៏បាន មិនឲ្យអនុជឃើញនាងទៀត..."

សម្តីរបស់ព្រះអង្គម្ចាស់ក្សត្រី ធ្វើឲ្យ ហ្ស៊ីក ភាំងយូរគួរសម។

"សរុបទៅ ព្រះរៀមជូនដំណើរដល់ត្រឹមហ្នឹង"

និយាយចប់ ហ្ស៊ីក ក៏បែរខ្លួនដើរចេញ។

"ចុះស្អែក...ព្រះរៀមទៅជាមួយអនុជទេ ?"

"មិនទំនេរ ស្អែកមានការងារច្រើន...ទៅដោយខ្លួនឯងទៅ មិនមែនមិនធ្លាប់មកទីនេះឯណា"

"តែអនុជចង់ឲ្យព្រះរៀមទៅជាមួយ"

"មិនបាន ព្រះរៀមត្រូវធ្វើការ"

ហ្ស៊ីក មិខាអ៊ីល តបដោយទឹកមុខមាំ ហើយដើរចេញពីបន្ទប់ដោយខ្សឹបប្រាប់ ហ៊ុលសែន ឲ្យមកប្រាប់ ហេយ្យូ ទើបវាធ្វើឲ្យនាងមិងមាំងមួយខណៈ បន្ទាប់មកទើបដើរតាម ហ៊ុលសែន យ៉ាងលឿន ហើយដើរតាម ហ្ស៊ីក ចូលជណ្តើរយន្ត។

ពេលឡើងឡានត្រឡប់ទៅវិញ នាងក៏ត្រូវរៀបចំឲ្យអង្គុយអម ហ្ស៊ីក នៅបាំងក្រោយ ដោយមាន ហ៊ុលសែន អង្គុយនៅបាំងមុខ។

"ម៉េចក៏ឲ្យខ្ញុំទៅវិញ...ហ្ស៊ីកា មិនសព្វព្រះទ័យឬ ?"

សំណួររបស់នាងធ្វើឲ្យមិខាអ៊ីលត្រូវងាកមកមើលមុខស្រស់ស្អាតរបស់អង្គរក្សស្រីមិនដាក់ភ្នែក។



"ល្អហើយ នាងនឹងបានមកធ្វើការឲ្យខ្ញុំជំនួស ហ្ស៊ីកា ហ្នឹងអី...ក្រុមអង្គរក្សរបស់ខ្ញុំ តាមពិតទៅមានតែបីនាក់ប៉ុណ្ណោះ មាននាងម្នាក់

ទៀតឲ្យគ្រប់ប្អូននាក់ក៏ល្អ"

"បញ្ជូនខ្ញុំទៅវិញក៏បាន...មានការងារផ្សេងកំពុងរង់ចាំខ្ញុំ...ខ្ញុំមិនអត់ការងារទេ" នាងដាក់សំណើភ្លាមពេលយល់។

"ដឹងហើយរឿងហ្នឹង ម៉ាដាម ប៉ែក ប្រាប់ខ្ញុំថាមនុស្សពូកែដូចនាងមានគេចាំដណ្ដើមប្រើការ កុំទៅវិញអី ខ្ញុំសម្រេចចិត្តហើយ មិនផ្លាស់ប្ដូរទេ ហើយអរគុណច្រើនរឿងដែលជួយកាលពីរសៀល"

ហ្ស៊ីក សម្លឹងមើលមុខនាងដោយខ្សែភ្នែកដែល ហេឃ្យូ មើលមិនធ្លុះ ទើបត្រូវងាកមុខចេញដោយការមិនសប្បាយចិត្ត។

ពេលមកដល់ផ្ទះបុរាណ នាងក៏ត្រូវនាំទៅកាន់បន្ទប់សម្រាកដែលនៅជាប់នឹងបន្ទប់របស់ ហ្ស៊ីក។

"នៅបានទេ ?"

ហ៊ុលសែន បញ្ជាមិត្តភក្ដិឈ្មោះ ហ្វាឌែល ឲ្យនាំនាងមកបន្ទប់ចំណែកគេទៅលាងរបួស។

"ស្រួលខ្លួនណាស់ ទោះតូច តែតុបតែងស្អាតដល់ហើយ"

"ងូតទឹកតែងខ្លួនហើយចុះទៅប្រជុំជាមួយពួកយើង រឿងកាលពីរសៀល បើគ្មានអ្នកនាង យើងអាចនឹងបាត់បង់ ហ្ស៊ីក ទៅហើយ...អរគុណច្រើន"

"មិនអីទេ មួយម៉ោងទៀតខ្ញុំចុះទៅ"

នាងក្រមុំដកដង្ហើមធំ។

នាងមិនស្ដាយ ដែលមិនបានធ្វើជាអង្គរក្សការពារព្រះអង្គម្ចាស់ក្សត្រី ព្រោះការធ្វើការឲ្យអ្នកជួលដែលមិនពេញចិត្ត វាជារឿងលំបាកចិត្តមួយ តែមិនគិតថាចុះឡើងៗបានធ្វើជាអង្គរក្សឲ្យចៅហ្វាយរូបសង្ហាដែលមានឋានៈជាព្រះអង្គម្ចាស់ទៅវិញ។



ពេលគិតដល់រឿងនេះ ចិញ្ចើមរបស់នាងជ្រួញចូលគ្នាដោយការសង្ស័យថាព្រះអង្គម្ចាស់ធ្វើអីអ្នកណា ទើបត្រូវលបប្រហារបែបនេះ។ ចាត់ទុកថាថ្ងៃនេះសំណាងល្អណាស់ ព្រោះបើនាងមិនឃើញខ្សែភ្នែករបស់ម្នាក់នោះ និងប្រុងប្រយ័ត្នខ្លួនឲ្យបានល្អ ព្រះអង្គម្ចាស់ប្រហែលត្រូវបាញ់សម្លាប់បាត់ទៅហើយ ព្រោះគ្មានអ្នកណាជួយទាន់ ឯនាងក៏សំណាងល្អដែរដែលពាក់អាវក្រោះគ្រប់ពេលវេលា គ្រប់ទីកន្លែង។

សំណាងល្អថ្ងៃនេះនៅតែសំណាងល្អ...នាងប្រាប់ខ្លួនឯង បន្ទាប់មកក៏ចាត់ចែងធុរៈផ្ទាល់ខ្លួនឲ្យរួចរាល់ក្នុងរយៈពេលមួយម៉ោង តាមដែលបានសុំ។

"សម្រេចថាឲ្យ ឃ្យូ តាមការពារ ហ្ស៊ីក គូជាមួយនឹង ហ៊ុលសែន ចំណែក ហ្វាឌែល និង ដានៀល កាន់តួនាទីដដែល"

ពេលសរុបការងាររួចរាល់ មិខាអ៊ីល ក៏ចូលមកក្នុងបន្ទប់ សម្លឹងមើលអង្គរក្សរបស់ខ្លួនគ្រប់គ្នា។

"និយាយគ្នាយល់ហើយមែនទេ ?"

"បាទ ទាន" ហ៊ុលសែន តប "យើងដាក់ ឃ្យូ នៅជិតទ្រង់បំផុត ព្រោះនាងរវៀសជាងពួកយើង"

ហ្ស៊ីក វ៉ៃយក្មេងឈរស្ដាប់ដោយមិនមាត់មិនក ហាក់ដូចព្រមទទួលយកនាងចំពោះរឿងនេះ ព្រោះមានគំរូឲ្យឃើញកាលពីរសៀល។

"ហើយមានអ្នកណាឃ្លានដែរទេ ?"

"ពួកយើងទទួលទានរួចហើយ ពេល ហ្ស៊ីក ជូនដំណើរ ហ្ស៊ីកា មានតែ ឃ្យូ ម្នាក់ប៉ុណ្ណោះដែលមិនទាន់មានអីចូលពោះ" ហ៊ុលសែន នៅតែជា ហ៊ុលសែន ដែលជាអ្នករាយការណ៍។





Scanned by CamScanner

"ខ្ញុំដែរ តោះអីចឹង ចុងភៅរៀបចំអាហារពេលល្ងាចឲ្យហើយ មានអ្នកណាចង់ទៅចូលរួមទេ ខ្ញុំមិនចូលចិត្តទទួលទានអាហារម្នាក់ឯង វាកណ្ដោចកណ្ដែង"

មិខាអ៊ីល បបួលកូនចៅរបស់ខ្លួនទាំងអស់ ព្រោះមិនគិតថាអ្នកទាំងនេះជាអ្នកដទៃដែលត្រូវប្រកាន់ឋានៈវណ្ណៈ ខុសពីព្រះអង្គម្ចាស់ឯទៀតនៅរាជវាំង។

អាហារពេលល្ងាចមានទាំងអាហារកូរ៉េ និងអាហារអារ៉ាប់ តែត្រូវប្រាប់ថាជាអាហារចម្រុះទើបត្រូវ ព្រោះចុងភៅមកពីបារាំង រៀបចំអាហារអន្តរជាតិជាច្រើនឲ្យភ្លក្ស ដែលបានទទួលការស្វាគមន៍ដ៏ល្អពីអ្នកទទួលទាន ព្រោះអាហារដែលត្រូវលើកមកដាក់លើតុ អស់គ្រប់បាន គ្មាននៅសេសសល់ ទោះអ្នកខ្លះប្រាប់ថាទទួលទានរួចហើយក៏ដោយ។

ទោះអាហារមួយពេលនោះកន្លងផុតទៅយ៉ាងរលូន តែសម្រាប់ហេយ្យូ នៅតែមានបញ្ហាក្នុងចិត្ត ព្រោះចង់ដឹងថានរណាត្រូវការសម្លាប់ហ្សឹក ព្រោះទង្វើនៅព្រលានយន្តហោះថ្ងៃនេះ វាព្រហើនមិនខ្លាចច្បាប់ទម្លាប់។

ទើបការងារដែលនាងត្រូវបំពេញចាប់ពីពេលនេះទៅ វាមិនងាយនោះទេ ព្រោះត្រូវប្រយុទ្ធនឹងសេចក្ដីស្លាប់គ្រប់ពេលវេលា ដូចដែល ហ្សឹកកំពុងប្រឈមហើយមើលទៅទ្រង់ដូចមិនញញើតអីបន្តិចនឹងគ្រោះថ្នាក់ដែលកំពុងរង់ចាំ។

# ៣

"ខ្លាចទេ ?"

ព្រះអង្គម្ចាស់សួរ ពេលនៅតុអាហារសល់មនុស្សតែពីរនាក់ ដោយអ្នកឯទៀតងើបចេញអស់ទៅហើយ។

"ខ្លាចខ្លះដែរ...ខ្លាចការពារទ្រង់មិនបានល្អ"

"ខ្ញុំមើលក្នុងប្រវត្តិ នាងជាអតីតប៉ូលិសស្រី"

"ចា៎"

"ហើយម៉េចក៏លាឈប់ ?"

"រឿងវាវែងឆ្ងាយនឹកដល់វាហើយនៅតែរំជួលចិត្ត...សុំមិននិយាយបានទេ"

"ក្នុងឯកសារប្រាប់ថា ដៃគូរបស់នាងបន្លំខ្លួនធ្វើជាឈ្មួញទិញគ្រឿងញៀន ហើយត្រូវបាញ់ស្លាប់"

អ្នកកំលោះនៅតែនិយាយបន្ត ដោយសម្លឹងមើលនាងមិនដាក់ភ្នែក ធ្វើឲ្យអ្នកត្រូវសម្លឹងដកដង្ហើមធំ។

"ការពិតអ្នកដែលគួរស្លាប់គឺខ្ញុំ មិនមែនគេ"

"គេជាសង្សាររបស់នាងឬ ទើបខូចចិត្តដល់ថ្នាក់នេះ ដល់ថ្នាក់ធ្វើការបន្តមិនបាន សុំច្បាប់មួយខែពីរហើយនៅសុំឈប់ទៀត"



ហ្សឹក និយាយបិទផ្លូវ ដោយនៅតែមើលនាង ទើប ហេយ្យូ គេច

ភ្នែក។

"របាយការណ៍ក្នុងឯកសារនោះលម្អិតដល់ម្លឹងផង"

"ខ្ញុំសុំសេចក្ដីលម្អិតពីគេ ចង់ស្គាល់នាងឲ្យច្បាស់មុនពេលបញ្ជូនទៅឲ្យ ហ្សីកា"

"តែពេលនេះមិនបាននៅជាមួយព្រះអង្គម្ចាស់ក្សត្រីផង"

"ទីនេះក៏ដូចគ្នា អង្គរក្សរបស់យើងតិច កំពុងចង់រកបន្ថែម តែមិនទាន់បានរក..."

មិខាអ៊ីល និយាយមិនទាន់ចប់ស្រួលបួលផង គ្រាប់កាំភ្លើងក៏ហោះចូលមកតាមបង្អួចបន្ទប់អាហារ ធ្វើឲ្យនាងក្រមុំបោលសម្រុកទៅរកគេលឿនដូចព្យុះ ធ្វើឲ្យកៅអីដួលបះជើងទាំងពីរ ហើយនាងងើយមើលប្រភពគ្រាប់កាំភ្លើងភ្លាម។

ពេលនោះនាងមិនបានចាប់អារម្មណ៍ទេថា រាងកាយរបស់ខ្លួនសង្កត់លើអ្នកកំលោះ ពេលទាញកាំភ្លើងនោះឯងទើបឈ្ងោកមើលគេឃើញមុខសង្ហានៅក្រោមដើមទ្រូងទន់ល្មើយរបស់ខ្លួន។

សំឡេងកាំភ្លើងដែលបន្លឺឡើងផ្ទួនៗនៅខាងក្រៅ ធ្វើឲ្យដឹងថា ហ្វាឌែល ហ៊ុលសែន និងអ្នកឯទៀតកំពុងបាញ់តដៃខ្មាន់កាំភ្លើងដែលព្រហើនហ៊ានមកសម្លាប់ដល់កន្លែង ដែលប្រហែលមិនមែនមនុស្សតែម្នាក់នោះទេ។

ពេលដឹងខ្លួន ហេយ្យូ ក៏រហ័សនាំខ្លួនឯងចេញឲ្យឆ្ងាយពីគេដោយការអឹមអៀន ប៉ុន្តែរក្សាគម្លាតនៅជិត មិនទៅណាឆ្ងាយ អ្នកណាចង់តាមចាប់ខ្មាន់កាំភ្លើងក៏ទៅៗ តែនាងត្រូវនៅការពារសុវត្ថិភាពឲ្យគេ រហូតដល់គ្រប់យ៉ាងនៅជុំវិញខ្លួនស្ងប់ស្ងាត់។

នាងក្រមុំងាកទៅមើលព្រះអង្គម្ចាស់ម្ដងទៀត ឃើញកែវភ្នែកមុតស្រួចសម្លឹងមើលមកមុនទៅហើយ ទើបធ្វើឲ្យថ្ពាល់ក្ដៅភាយៗពេលនឹកដល់ហេតុការណ៍អម្បាញ់មិញដែលគ្មានចេតនា។

ហើយពេលនោះសំឡេងបើកទ្វារក៏បន្លឺឡើង ដោយមាន ហ៊ុលសែន ជាអ្នកដើរចូលមក។

"ហ្សីក!!"

គេឧទានដោយការព្រួយបារម្ភ តែ មិខាអ៊ីល បែរជាងើបឈរឃើតៗដោយមិនភ្លេចដៀងមើលអង្គរក្សស្រីដោយស្វ័យប្រវត្ត។

"មិនអីទេ...ខ្ញុំ...មិនអីទេ"

គេបញ្ជាក់ឲ្យគ្រប់គ្នាបានដឹង ហើយអ្នកទាំងនោះក៏នាំគ្នាសប្បាយចិត្ត ដែលយ៉ាងហោចណាស់ ហេយ្យូ អាចការពារជីវិតព្រះអង្គម្ចាស់ពេលដែលពួកគេកំពុងដេញតាមប្រមាញ់ខ្មាន់កាំភ្លើងនៅខាងក្រៅ។

"ពួកវាមកប៉ុន្មាននាក់?"

"គិតថាពីរនាក់ តែរត់បាត់ទៅហើយ មានម្នាក់ត្រូវរបួស ឃើញតំណក់ឈាមតាមផ្លូវ"

"មើលទៅមិនគួរឲ្យទុកចិត្ត វាអាចលើសពីពីរក៏ថាបាន"

"ប្ដឹងទៅស្ថានទូត ឲ្យប៉ូលិសមកឆែកឆេរឲ្យសព្វ ពិនិត្យក្នុងផ្ទះនេះឲ្យអស់"

"អាចទៅរួចទេដែលសុំឲ្យទ្រង់ទៅស្នាក់នៅកន្លែងផ្សេងយប់នេះ"

សំណើរបស់នាង ធ្វើឲ្យមនុស្សប្រុសទាំងអស់ងាកមើលមុខគ្នាជាការពិភាក្សា។

"អូខេ នៅមានកន្លែងសាគួរសម្រាប់យើងស្នាក់នៅច្រើន..." ហ្សីក មើលមុខនាងហើយឆ្លើយ។

"យកកន្លែងដែលគ្មានអ្នកណាដឹងបានទេ?"



ហេតុផលរបស់នាង ធ្វើឲ្យព្រះអង្គម្ចាស់មើលមកដោយការពិចារណា។

"នាងចង់ប្រាប់ខ្ញុំថា យើងមានដង្កូវក្នុងសាច់ដែរឬ?"

"ខ្ញុំគ្រាន់តែត្រូវការឲ្យទ្រង់មានសុវត្ថិភាពប៉ុណ្ណោះ កន្លែងដែលទ្រង់ស្គាល់ ក៏មានអ្នកដទៃស្គាល់ដែរ តែកន្លែងដែលខ្ញុំស្គាល់ គ្មានអ្នកដទៃស្គាល់ទេ"

សំណើរបស់នាង ធ្វើឲ្យគ្រប់គ្នាងាកមើលមុខគ្នាជាការពិភាក្សាម្តងទៀត។

យប់នោះ បន្ទាប់ពីព្រមព្រៀងគ្នាហើយ បុរសសមុទ្រខ្សាច់ទាំងឡាយក៏យល់ព្រមឲ្យ ហេយ្យូ នាំចេញពីផ្ទះធំនោះ ដោយមាន ហ៊ុលសែន ជាអ្នកបើកឡានទូពណ៌ប្រផេះ គ្មានស្លាកលេខ ដោយ ហ្សីក ផ្លាស់ប្តូរការតែងខ្លួនជាសម្លៀកបំពាក់ធម្មតា ដើម្បីមិនឲ្យក្លាយជាចំណីភ្នែកអ្នកដទៃ។

នាងក្រមុំប្រើភាពជំនាញជាម្ចាស់ស្រុក នាំគ្រប់គ្នាជិះឡានកាត់ព្រៃជ្រៅ ទៅដល់ផ្ទះមាត់ទឹកមួយខ្នង ដែលតេរឲ្យគេមកបោសសម្អាតរួចរាល់ហើយ។

"នេះជាកន្លែងណា?"

"ផ្ទះចាស់...ខ្ញុំធ្លាប់នៅទីនេះតាំងពីតូច រហូតដល់ម៉ាក់ស្លាប់"

នាងនិយាយឲ្យគេស្តាប់ និងលោតចុះពីឡាន ដើរនាំមុខចូលទៅក្នុងផ្ទះ។

ក្លិនក្រអូបរបស់ផ្កាឈើនៅតាមដងផ្លូវ ធ្វើឲ្យនឹកដល់ការដើរទស្សនាផ្កានៅក្នុងសួន ជាងការរត់គេចពីការដេញប្រមាញ់។

ពេលភ្លើងគ្រប់អំពូលត្រូវបើកបំភ្លឺ ភ្ញៀវក៏ញញឹមពេញចិត្ត។

"ផ្ទះស្អាតណាស់...គួរតែរស់នៅស្រួល"

ព្រះអង្គម្ចាស់សរសើរ ដោយភ្នែកសម្លឹងមើលទៅជុំវិញផ្ទះពណ៌សមានទំហំធំ។

"អញ្ជើញ...អញ្ជើញខាងក្នុង"

"ខ្ញុំនៅខាងក្រៅល្អជាង...នៅយាមកាមដែរ" ហ៊ុលសែន ប្រាប់។

"ចូលមកមើលខាងក្នុងឲ្យសព្វល្អជាង...មានបន្ទប់ទឹកទាំងខាងក្នុងនិងខាងក្រៅ ចូលចិត្តត្រង់ណាប្រាប់ម៉ោ..."

"ម៉ាក់របស់នាងចែកឋានយូរហើយឬនៅ?" មិខាអ៊ីល សួរពេលបណ្តើរគ្នាពិនិត្យមើលផ្ទះ។

"ទើបតែបានមួយឆ្នាំ ខ្ញុំខានមកទីនេះតាំងពីពេលនោះ នៅតែខុនដូជិតកន្លែងធ្វើការ...យប់នេះចង់ឲ្យស្នាក់នៅទីនេះសិន ស្អែកចាំគិតគ្នាទៀតថាត្រូវធ្វើយ៉ាងណា ទ្រង់មិនរើសអើងទេមែនទេ?"

"មិនរើសអើងទេ... ជាកិត្តិយសទៅវិញទេដែលនាំមកនៅផ្ទះបែបនេះ" ហ្សីក តប ដោយមើលមុខនាងមិនដាក់ភ្នែក។

"អីចឹងអញ្ជើញ...ទ្រង់សម្រាកនៅបន្ទប់នេះបាន..បន្ទប់របស់ខ្ញុំ ខ្ញុំទៅនៅបន្ទប់ម៉ាក់"

"អរគុណ...យ្យូ...អរគុណច្រើន"

ពេល ហ្សីក និយាយហើយ ទើបនាងដើរចេញពីបន្ទប់ ទុកឲ្យគេនៅក្នុងនោះម្នាក់ឯង។

តាមពិតគេមិនបាច់ធ្វើតាមផែនការរបស់នាងក៏បាន ស្នាក់នៅផ្ទះម៉ូដបុរាណនោះដដែលក៏បាន ប៉ុន្តែប្រហែលត្រូវដេកបើកភ្នែកភ្លឹះៗពេញមួយយប់។



គំនិតរបស់ ហេយ្យូ អ្នកដែលត្រូវការសម្លាប់គេ ត្រូវតែនៅជិតខ្លួន

គេ ស្គាល់គេច្បាស់ ទើបស្គាល់ផ្ទះសម្រាកជាប់នឹងស្ពានទូតបែបនោះ ហើយឡើងតាមរបងចូលទៅសម្លាប់គេ។

ពេលនេះស្ទើរតែមិនទុកចិត្តអ្នកនៅជិតខ្លួនគេទៀត សូម្បីតែ ហ៊ុលសែន ប៉ុន្តែការនាំគេតែម្នាក់មកទីនេះជាមួយ ក៏គិតថាគួរតែមានសុវត្ថិភាពមួយកម្រិត។

នាងក្រមុំគិត ខណៈដែលដើរចូលបន្ទប់របស់ម្តាយ ហើយផ្តួលខ្លួនដេកលើពូក ដោយគិតថាសម្រាកមួយស្រឡេត ចាំចេញទៅមើលគេ។

ហេឃ្យូ ប្រាប់ខ្លួនឯងបែបនោះ ហើយក៏លង់លក់ទៅ ដោយមិនដឹងទេថាពេលលង់លក់នោះ មិខាអ៊ីល បានដើរចេញពីបន្ទប់មកពិនិត្យជុំវិញផ្ទះម្តងទៀត ហើយនិយាយជាមួយអង្គរក្សជំនិត។

"លើកនេះ ពួកវាចង់សម្លាប់ឲ្យបានទាន...វាមិនត្រូវការឲ្យទ្រង់ត្រឡប់ទៅវិញ" ហ៊ុលសែន ឲ្យយោបល់។

"ការពិត ខ្ញុំក៏មិនចង់ត្រឡប់ទៅវិញដែរ គ្រាន់តែចង់ធ្វើជាទូតនៅទីនេះប៉ុណ្ណោះ ប៉ុន្តែមិនត្រឡប់ទៅវិញបានយ៉ាងម៉េច បើ រ៉ននី មិនព្រមឡើងគ្រងរាជ្យសោះ និងទំនើងទៀតផង"

ព្រះអង្គម្ចាស់និយាយទាំងតានតឹងចិត្ត ព្រមទាំងទាញទូរសព្ទដៃមកមើលតាមទម្លាប់ ពេលឃើញម៉ាស៊ីនបិទហើយក៏ញាត់ចូលហោប៉ៅវិញ។

"សាកនៅឲ្យស្ងៀមមួយរយៈមើល៍ ទីនេះគួរតែរស់នៅសុខស្រួល"

មិខាអ៊ីល និយាយរអ៊ូៗ ភ្នែកសម្លឹងមើលទៅជុំវិញខ្លួនដែលងងឹតក៏ពិតមែន តែស្ងប់ ដែលសំខាន់ក្លិនផ្កាចម្រុះពូជដែលកំពុងបំភាយក្លិនធ្វើឲ្យមានអារម្មណ៍ធូរស្រាលបានដោយមិនគួរឲ្យជឿ។

ព្រះអង្គម្ចាស់បែរខ្លួនដើរចេញពីមុខផ្ទះទៅក្រោយផ្ទះ ដែលមានរានហាលជាប់នឹងមាត់ទឹក។

គេអង្គុយនៅត្រង់នោះយូរគួរសម គិតនេះគិតនោះតែម្នាក់ឯង និងនឹកដល់មុខរបស់ម្ចាស់ផ្ទះ ដែលមានអាជីពផ្ទុយពីសម្រស់របស់នាងហៅមិនឮ។

មិនចង់ជឿទេថានាងបានជួយជីវិតរបស់គេកាលពីរសៀល ហើយពេលនេះក៏នាំមកលាក់ខ្លួនក្នុងផ្ទះរបស់នាងទៀតផង។

អ្នកកំលោះនឹកដល់ពេលដែលនាងហក់មករកទាំងភ្នែន ធ្វើឲ្យដួលដល់ទៅពីរដង ដោយរាងស្រឡៅស្រឡូននោះសង្កត់លើខ្លួនរបស់គេដោយអចេតនា។

គេដកដង្ហើមធំ ពេលដែលនឹកដល់ក្លិនខ្លួនក្រអូបប្រហើរចេញពីដើមទ្រូងដែលបុកនឹងមុខរបស់គេមួយទំហឹង ហើយក៏ត្រូវបិទភ្នែកទប់ស្នាមញញឹមឲ្យឃើញតែស្នាមខួចនៅលើថ្ពាល់។ គេដឹងថាវាជាឧបទ្ទវហេតុ គ្មានអ្នកណាចង់ឲ្យវាកើតឡើងបែបនោះ ប៉ុន្តែវាក៏ធ្វើឲ្យកើតអារម្មណ៍ម្យ៉ាងដែលមិនធ្លាប់មាន ហើយអារម្មណ៍នោះក៏ធ្វើឲ្យគេតាមនាងមកដល់ទីនេះដោយគ្មានលក្ខខណ្ឌ។

ជួនកាលគេគួរតែបញ្ចប់រឿងរ៉ាវស្មុគស្មាញនៅជុំវិញខ្លួន ហើយមករស់នៅទីនេះមួយរយៈតាមការគិត។

...

ថ្ងៃថ្មី...

ព្រោះចូលដេកយប់ជ្រៅគួរសម ទើប មិខាអ៊ីល ភ្ញាក់ពីដេកនៅថ្ងៃខ្ពស់។ គេដើរទៅឈរនៅមាត់បង្អួច ឃើញម្ចាស់ផ្ទះងើបពីទឹកល្ហម។

នាងមិនឃើញគេ តែគេឃើញនាងពេញភ្នែក ដែលរូបភាពនៅចំពោះមុខ ក៏សណ្តំឲ្យគេឈរផ្ទឹងនៅត្រង់នោះ មិនអាចដើរចេញទៅណា



បាន។

កែវភ្នែកមុតស្រួចសម្លឹងមើលនាងច្បូតទឹកពីសក់វែង ដែលពីម្សិលបួងមានរបៀប តែពេលនេះត្រូវទម្លាក់រំសាយ ទទឹកសំដិលខ្លួនលើខ្នងសខ្ចី។

រាងកាយទាំងមូលស្រោបដោយសម្លៀបបំពាក់ស្តើងជម្មតា រឹបជាប់សាច់ព្រោះទទឹក បង្ហាញរាងរៅឲ្យឃើញ។

នាងចុះទៅលេងទឹកទាំងព្រឹក ប្រហែលចូលចិត្ត...គេគិតពេលឃើញនាងពាក់អាវឃ្លុំងូតទឹកសមនឹងដងខ្លួន ពេលទាញខោអាវដែលទទឹកនោះទម្លាក់នៅចុងជើង ពេលចងខ្សែអាវរួចរាល់ ទើបទាញយកវាទៅបោកក្នុងទឹក ហើយរលាស់ហាល បន្ទាប់មកក៏អង្គុយត្រង់ជណ្តើរនោះ ដូចកំពុងរង់ចាំនរណាយ៉ាងអ៊ីចឹង។

មិខាអ៊ីល ឈរមើលនាងយ៉ាងយូរ មិនឃើញនាងដើរទៅណា ទើបដើរចេញពីបន្ទប់ទៅរក។

ហេឃ្សូ ភ្ញាក់ព្រើតពេលឃើញព្រះអង្គម្ចាស់ដើរមករក ដែលនាងតែងខ្លួនគ្មានរបៀប ទើបងើបឈរ ស្របពេលនោះទូកលក់អាហារក៏ចុចស៊ីផ្លេបង្វែរក្បាលចូលមកកំពង់ផ្ទះរបស់នាង ទើបនាងងាកទៅរក។

"អ៊ូ...ហេឃ្សូ បាត់ទៅណា បិទទ្វារផ្ទះរាប់ឆ្នាំ ខ្ញុំនឹកដល់ហើយ"

លោកយាយអ្នកលក់រាក់ទាក់ ស្របពេលដែលទូកនោះចតនឹងកំពង់ល្មម ដោយមាននាងចុះទៅជួយចាប់ក្បាលរបស់វា។

"អំា ញ៉ាំអីប្រាប់ម៉ោ...ថ្ងៃនេះមានច្រើនមុខ"

យាយអ្នកលក់នៅតែនិយាយប៉ប៉ាច់ប៉ប៉ោច ដោយភ្នែកសម្លឹងមើលបុរសដែលឈរនៅក្រោយខ្នង។

"អ្នកណាគេ សង្សារឬ អី រៀបការពីអង្កាល់ហ្នឹង ?"

"មិនមែនទេ...មិនមែន ចៅហ្វាយ...អ្នកជួលខ្ញុំ" នាងបដិសេធខណៈដែលអ្នកឈរក្រោយខ្នងសើចញឹមៗ ព្រោះយល់សំណួរ តែលាក់អារម្មណ៍ពេញចិត្តបានល្អ។

"អ៊ីចឹងឬ ហើយញ៉ាំអី ប្រាប់ម៉ោ"

"យាយមានអីខ្លះថ្ងៃនេះ ?"

"មានច្រើនមុខណាស់ ទាំងបង្អែម ទាំងចម្អាប មើលខ្លួនឯង ពេញចិត្តមួយណា យកមួយហ្នឹង"

"យកគ្រប់មុខយាយ ម៉ាល្មមញ៉ាំបីនាក់"

នាងកម្ម៉ង់ និងងាកទៅមើលអ្នកដែលឈរជ្រែងហោប៉ៅនៅក្រោយខ្នង និងមើលមកដោយខ្សែភ្នែកមានពន្លឺប្លែកៗ ធ្វើឲ្យនាងមិនចង់មើលមុខគេសោះ។



# ៤

ហេយ្យ ម៉ីម្នាទៅតែងខ្លួនឲ្យមានរបៀប ហើយចេញមករៀបចំអាហារដាក់ថាស ដួសបាយក្តៅៗដែលនាងដាំពេញឆ្នាំងដាក់ចាន ចាក់កាហ្វេក្តៅៗដាក់ពែង យកនំប៉័ងដែលអាំងក្តៅៗដាក់ចាន ហើយលើកដាក់លើតុ។

ពេលនាងរៀបចំម្ហូបអាហាររួចរាល់ ហ៊ុលសែន ក៏ដើរចេញពីបន្ទប់ទឹកល្មម។ គេប្រហែលដេកលក់នៅតុទទួលភ្ញៀវនៅខាងក្រៅ ដែលមានកៅអីវែងអាចដេកបាន។

"អញ្ជើញ អាហារពេលព្រឹករួចរាល់ហើយ វាមិនអាចមិនដូចចុងភៅបារាំង តែវាក៏ធ្វើឲ្យយើងឆ្អែតក្រពះបានមួយពេល" នាងប្រាប់។

ពួកគេទទួលទានអាហារដោយមិនមាត់មិនក ដោយញ៉ាំម្ហូបអស់គ្រប់មុខ ហើយពេលរួចរាល់ ហ៊ុលសែន ក៏ចេញទៅយាមនៅមុខផ្ទះតាមតួនាទី ទុកឲ្យព្រះអង្គម្ចាស់នៅជាមួយនាងតែពីរនាក់។

"មនុស្សចាស់នោះធ្វើអាហារឆ្ងាញ់ រសជាតិឆ្ងាញ់ទាំងអស់"

អ្នកកំលោះសរសើរ។

"មួយរយៈក្រោយនេះខ្ញុំមិនសូវបានធ្វើម្ហូបញ៉ាំដោយខ្លួនឯង ពេលម៉ាក់ចែកឋានក៏ទិញគេញ៉ាំស្រាប់"

"នេះជាអាហារពេលព្រឹក ចុះអាហារពេលថ្ងៃ ?"

"មានទូកមីទូកគុយទាវអុំកាត់មុខផ្ទះ ឯល្ងាចមានស្នេកសាច់ជ្រូកឆ្ងាញ់ បើចង់ប្តូរបរិយាកាស ខ្ញុំនឹងនាំទៅផ្សារទឹកជិតៗនេះ អុំទូកទៅ ធ្លាប់អុំទូកដែរទេ ?"

"ធ្លាប់ ប្រណាំងខេណូនៅកាណាដា"

ចម្លើយរបស់គេធ្វើឲ្យនាងបិទស្នាមញញឹម ហើយងក់ក្បាល។

"បើអុំខេណូបាន គួរតែអុំទូកធម្មតាបានដែរ"

នាងសរុប ហើយងាកមករកអ្នកនិយាយគ្នា ឃើញគេសម្លឹងមើលមកដោយខ្សែភ្នែកប្លែកៗ ហើយមើលទៅកំពង់ទឹក។

នាងងើបរៀបចានឆ្នាំងយកទៅលាងភ្លាម ដើម្បីគេចឲ្យផុតពីខ្សែភ្នែកនោះ បន្ទាប់មកក៏ដើរចូលបន្ទប់ លើកសក់បួង ទើបដើរមករកគេវិញ។

មិខាអ៊ីល ចេញទៅអង្គុយនៅមាត់ទឹក ដោយត្រង់នោះមានប៉ៅអីចាស់មួយ តែស្អាតអាចប្រើការបាន។ គេអង្គុយក្រោមសំយាបទើបមិនក្តៅ និងបានគិតរឿងផ្ទាល់ខ្លួនដែរ។ នាងដើរហួសទៅដល់មុខផ្ទះរកមើល ហ៊ុលសែន ហើយហុចកែវនិងដបទឹកត្រជាក់ឲ្យ បន្ទាប់មកក៏មកឃ្លាំងមើលចៅហ្វាយនៅមាត់ទឹកតាមតួនាទី។

នាងមើលគេដែលម្តងអង្គុយត្រង់ខ្លួន ម្តងដេកសំដិល យូរគួរសមទើបគេដើរចូលផ្ទះ។

"ខ្ញុំស្មានថានាងទៅណាបាត់ហើយ" គេសួរភ្លាមពេលឃើញមុខ។

"ខ្ញុំទៅណាបាន ក្រៅពីនៅជិតលោក"

ចម្លើយរបស់នាង ធ្វើឲ្យព្រះអង្គម្ចាស់ដឹងថានាងជាអ្នកណា គេជាអ្នកណា។



"ឯណាថានាំទៅផ្សារទឹក ត្រូវអុំទូក ចុះឯណាទូក ?"

"នៅក្រោមផ្ទះ"

នាងឆ្លើយ ព្រមទាំងដើរនាំមុខចេញទៅយ៉ាងលឿន ដោយមិនភ្លេចងៀងមើលអ្នកដែលពាក់អាវយឺត និងខោទាន់សម័យដែលដើរតាមក្រោយ។

ហ៊ុលសែន ឃើញបែបនោះក៏ដើរមករកភ្លាម។

"ទ្រង់ចង់ទៅណា ?"

"ទៅផ្សារទឹក...ម៉ោះ"

ហេយ្យូ បបួល ព្រោះ ហ៊ុលសែន ត្រូវទៅជាមួយដែរ។

"បើជាខាងនោះ យើងនឹងឃើញតែវាលខ្សាច់ធំល្វឹងល្វើយ គ្មានទឹកច្រើនបែបនេះទេ ទីនេះស្ងប់ណាស់ មិនដូចផ្ទះរបស់យើង"

មិខាអ៊ីល ងាកទៅនិយាយរកនាង ដែលពេលនោះពួកគេអង្គុយនៅលើទូក។

ហ៊ុលសែន អង្គុយនៅខាងមុខ មិខាអ៊ីល អង្គុយកណ្ដាល ឯ ហេយ្យូ អង្គុយនៅកន្សៃ ព្រោះនាងស្គាល់ផ្លូវ ដឹងថាត្រូវទៅណា។

មិនយូរប៉ុន្មានពួកគេក៏មកដល់ផ្សារទឹកដែលនៅជិតផ្ទះ ដោយទូកលក់ផ្លែឈើស្ទើរយទៅហើយ ព្រោះថ្ងៃខ្ពស់ណាស់ដែរ តែហាងអាហារនៅខាងលើនៅតែបើកដំណើរការ។

"ថ្ងៃណាស់ហើយ អ្នកលក់តាមទូកជិតអស់ទៅហើយ តែពេលព្រឹកអ៊ូអរណាស់ យើងមកពីព្រឹកទើបល្អ"

នាងរៀបរាប់ពេលដើរកាត់កំលោះអារ៉ាប់ទាំងពីរឡើងគោក ដោយមិនភ្លេចសង្កេត ហ៊ុលសែន មួយភ្លែតដែរ។ គេពាក់អាវធំមួយជាន់ទៀត ព្រោះត្រូវលាក់កាំភ្លើងមិនឲ្យអ្នកណាឃើញ ដូចនាងដែរ ចំណែកព្រះអង្គម្ចាស់វិញរាងស្រួលខ្លួន ប្រហែលគ្មានអាវុធជាប់ខ្លួនទេដឹង... នាងគិត ហើយនាំទៅរកហាងនានា មានលក់ទាំងអាហារ ទាំងភេសជ្ជៈ



វត្ថុអនុស្សាវរីយ៍ប្លែកៗ ទាក់ទាញចិត្តភ្ញៀវ។

ទីនេះនៅឆ្ងាយពីភាពអ៊ូអរ ពេលដែលដើរបានមិនយូរប៉ុន្មាន អាកប្បកិរិយាប្រុងប្រយ័ត្នខ្លួនរបស់ ហ៊ុលសែន ក៏ផ្លាស់ប្ដូរ ចំណែកព្រះអង្គម្ចាស់ ប្រហែលដឹងតាំងពីដំបូងម្ល៉េះថានាងនាំពួកគេមកឆ្ងាយពីការតាមប្រមាញ់ហើយ ទើបឈរមើលហាងលក់វត្ថុអនុស្សាវរីយ៍បានយូរ។

ពួកគេបណ្ដើរគ្នាមិនយូរប៉ុន្មាន មិខាអ៊ីល ក៏រកហាងដែលពេញចិត្តបាន មានតុកៅអីឲ្យអង្គុយទទួលទានជាប់មាត់ទឹក អាចមើលឃើញទូកដែលអុំទៅអុំមក ទិញផ្លែឈើឬអាហារពីទូកទាំងនោះបានតាមចិត្ត។

"ខ្ញុំឃើញផ្សារនេះតែក្នុងរូប មិនដែលបានមកសោះ ព្រោះគ្មានពេល នេះមិនប៉ុន្មានថ្ងៃទៀតត្រូវត្រឡប់ទៅវិញជាមួយ រ៉ននី ហើយ ត្រូវទៅរៀបចំឲ្យនាងឡើងគ្រងរាជ្យឲ្យរួចរាល់ ហើយចាំមកជាថ្មី...ជួនកាល ...អាចមិនត្រឡប់ទៅវិញ"

សម្ដីរបស់គេធ្វើឲ្យ ហ៊ុលសែន ងាកខ្វាប់ទៅមើលដោយមិនចង់ជឿ ប៉ុន្តែខ្សែភ្នែករបស់អង្គរក្សជំនិត ធ្វើឲ្យនាងក្រមុំដឹងថាគេងឿងឆ្ងល់ដែលចៅហ្វាយសម្រេចចិត្តបែបនេះ។

"ហ្ស៊ីកាព្រមឬទាន ?"

"ជីវិតជារបស់ខ្ញុំ ហ៊ុលសែន នៅកណ្ដាលចំណោមអ្នកដែលចង់សម្លាប់យើងគ្រប់ជំហាន ពេលខ្លះវាក៏គួរឲ្យធុញ"

"បើគ្មានទ្រង់ តើហ្ស៊ីកាធ្វើយ៉ាងណា ?"

"ម្ដាយមិនសម្លាប់កូនខ្លួនឯងទេ"



ចម្លើយរបស់ មិខាអ៊ីល ធ្វើឲ្យកូនចៅត្រូវបិទមាត់ ឯ ហេយ្យូ ដែលអង្គុយស្ដាប់ដោយមិនមាត់មិនកយូរហើយ អាចប៉ាន់ប្រមាណបាន ទោះ

មិនច្បាស់លាស់ក៏ដោយ។

បន្ទាប់មកពួកគេក៏កម្ម៉ង់អាហារដែលចង់ទទួលទាន មានច្រើនមុខដែលលក់នៅជុំវិញខ្លួន មកដាក់លើតុ ហើយទទួលទានអស់រលីង ដោយមាន ហ៊ុលសែន ជាអ្នកម៉ៅ ព្រោះកុម្ម៉ង់ច្រើនជាងគេ។

កំលុងពេលនោះ ហេយ្យូ ក៏មើលអ្នកនៅជុំវិញខ្លួនតាមចរិតដែលជាអតីតប៉ូលិស និងជាអង្គរក្ស តែមិនឃើញថាមានអ្វីខុសពីធម្មតា ចំណែក ហ៊ុលសែន ក៏ធ្វើបែបនោះដែរ។

ពេលទទួលទានអាហាររួចរាល់ មិខាអ៊ីល ក៏ដើរលេងបន្ត ចូលហាងលក់ទំនិញជាច្រើន ដូចចង់មើលឲ្យច្បាស់មុនពេលសម្រេចចិត្តទិញ តែក៏មិនឃើញទិញអី។

"នាងមិនត្រូវការអីទេឬ?"

គេងាកទៅសួរ ហេយ្យូ ក៏គ្រវីក្បាល ព្រោះកំពុងធ្វើការ ម៉េចនឹងអាចធ្វើចរិតកំពុងស៊ីបភីងបានទៅ...នាងគិត និងដើរតាមគេដោយមិនមាត់មិនក រហូតមកដល់ទូកដែលចតនៅកំពង់។

គ្រប់ពេល ទឹកមុខរបស់ព្រះអង្គម្ចាស់មានការរិះគិត ធ្វើឲ្យអង្គរក្សទាំងពីរមិនហ៊ានហាមាត់សួរនាំ រហូតមកដល់ផ្ទះ។

ពេលឡើងពីទូក មិខាអ៊ីល ក៏ទាញទូរសព្ទពីហោប៉ៅ បំណងបញ្ជាការទៅស្ថានទូត តែត្រូវនាងនិយាយកាត់។

"ទូរសព្ទនឹងប្រាប់ទីតាំងថាយើងនៅឯណា កុំទាន់អាលបើកល្អជាង ហើយនៅឡាន ខ្ញុំបារម្ភថាមានបំពាក់រ៉ាដាឬអត់"

"បើមាន វាមកតាំងពីយប់ម្លេះ"

ហេតុផលរបស់ ហ៊ុលសែន ជឿជាក់បាន។

"ខ្ញុំគិតថាវាអាចបំពាក់នៅក្រោមឡានប្រចាំតំណែងរបស់ ហ្សីក ជាង"

ហេតុផលបន្ទាប់មក ក៏ធ្វើឲ្យពួកគេងាកមើលមុខគ្នា។

"ហើយថ្ងៃនេះ ទ្រង់ចង់ធ្វើអី?"

"ត្រូវត្រឡប់ទៅវិញដូចដែលនិយាយហ្នឹង"

ចម្លើយរបស់ ហ្សីក ធ្វើឲ្យកូនចៅដកដង្ហើមធំ។

**ពេលមកដល់គោលដៅ ហើយឃើញមុខលេខារបស់លោក** អគ្គរាជទូត មិខាអ៊ីល ក៏សួរនាំ។

"ថ្ងៃនេះហ្សីកាទ្រង់យាងទៅណា?"

"កោះជេជូ ក្រាបទូល ហើយនេះរបាយការណ៍របស់ទ្រង់ពេលគង់នៅទីនេះ" លេខាឈ្មោះ អាន់ឌុលឡា ហុចរបាយការណ៍ដែលជាសំណុំឯកសារស្តើងឲ្យភ្លាម។

"នេះសុទ្ធតែជារឿងទៅដើរលេង ពិធីជប់លៀងនៅស្ថានទូតរបស់យើងអាទិត្យក្រោយ ម៉េចក៏ថាមិនមក កម្មវិធីសំខាន់ផង"

លេខាមិនហ៊ានមាត់ក ព្រោះមិនអាចធ្វើអីបាន ទើបព្រះអង្គម្ចាស់ទាញទូរសព្ទមកបើក តេរទៅរកព្រះអង្គម្ចាស់ក្សត្រីភ្លាម។

(ព្រះរៀម...)

សំឡេងរអ៊ូរទាំរបស់ព្រះអង្គម្ចាស់ក្សត្រី បន្លឺតាមទូរសព្ទ។

"នៅឯណា?"

ស្តាប់ហ្សីក និយាយជាមួយព្រះអង្គម្ចាស់ក្សត្រីដោយមិនប្រើរាជសព្ទមួយម៉ាត់ ធ្វើឲ្យ ហេយ្យូ ងឿងឆ្ងល់ជាលើកទីពីរ ព្រោះតាំងពីជួបគ្នាលើកដំបូងក៏បែបនេះ។



(នៅលើយន្តហោះ កំពុងទៅកោះជេជូ)

"អាទិត្យក្រោយមានកម្មវិធីនៅស្ថានទូត...ជាកម្មវិធីធំ ត្បៀវពន្លឺមកត្រៀបត្រា ហ្សីកាត្រូវចូលរួមដែរ តែក្នុងរបាយការណ៍មិនឃើញដាក់"

(ព្រះរៀមនៅហើយតើ ហេតុអីអនុជត្រូវទៅចូលរួម)

"ហ្សីកាត្រូវមកចូលរួម...យល់ទេ ត្រូវចេះធ្វើតួនាទីដោយខ្លួនឯង កុំគិតតែដើរលេងបែបនេះ មិនបានទេ"

សម្តីគ្រប់ម៉ាត់ហាក់ដូចបងប្រុសកំពុងស្តីឲ្យប្អូនស្រី គួរឲ្យប្រណែនព្រះអង្គម្ចាស់ក្សត្រីមែនទែន ដែលមានបងប្រុសរូបសង្ហា និងព្រួយបារម្ភពីប្អូនស្រីបែបនេះ។

ខ្សែភ្នែករបស់ ហេយ្យូ ផ្លាស់ប្តូរពេលគិតដូច្នោះ ដែលពេលនោះ មិខាអ៊ីល ក៏ងាកមកមើលនាងល្មម ទើបពួកគេត្រូវភ្លឹកមើលគ្នាមួយខណៈ។

បន្ទាប់ពីនិយាយជាមួយព្រះអង្គម្ចាស់ក្សត្រីចប់ ព្រះអង្គម្ចាស់ក៏ដើរចូលបន្ទប់ធ្វើការ ដោយមានអង្គរក្សក្រមុំឈរនៅមុខបន្ទប់ ខណៈដែល ហ៊ុលសែន ចូលទៅតាម។

មិនយូរប៉ុន្មានក៏មានមន្ត្រីពាក់ព័ន្ធ មកសួរនាំរឿងការលបបាញ់កាលពីម្សិល រួមទាំងប៉ូលិសតំបន់ដែរ។

គ្រប់យ៉ាងគួរតែដំណើរការតាមក្បួនច្បាប់ បើ ហេយ្យូ មិនក្រឡេកទៅឃើញឡានប្រចាំតំណែងរបស់ព្រះអង្គម្ចាស់ និងអ្នកបើកឡាននៅក្នុងឈុតគ្រ័រហ្សេ ងាកមុខចេញពីនាងភ្លាមពេលឃើញ។

ទៀតហើយ...នាងមិនចូលចិត្តប្រផ្នូលបែបនេះទេ។

នាងក្រមុំងាកទៅមើលឡានភ្លាមពេលឃើញអ្នកបើកឡាន បន្ទាប់មកក៏រកមើល ហ្សាខែល និង ដានៀល ដែលនៅមិនឆ្ងាយ ហើយឲ្យសញ្ញាឲ្យគេមកឈរជំនួស ដោយប្រាប់ថាខ្លួនឯងទៅបន្ទប់ទឹក ប៉ុន្តែជាតុពិត



នាងដើរមិនទាន់ដល់បន្ទប់ទឹកផង ក៏លោតចេញតាមរានហាលឡើងមកផ្លូវមុខវិញ។

នាងរកមើលអ្នកបើកឡាន និងដើរតាមស្ងាត់ៗ ព្រោះសកម្មភាពរបស់គេគួរឲ្យចាប់អារម្មណ៍មែនទែន ជាពិសេសពេលលើកដៃចាប់ត្រចៀក ដូចសង្កត់របស់ម្យ៉ាងឲ្យជាប់ ដើម្បីស្តាប់ឲ្យច្បាស់...មែនហើយ ដើម្បីស្តាប់ឲ្យច្បាស់...នាងគិត ហើយបែរក្រោយដើរទៅវិញភ្លាម។





Scanned by CamScanner

# ៥

"អ្នកបើកឡានឈ្មោះអី ?"

ពេលមកដល់ នាងក៏សួរ ហ្វាខែល មុនគេ។

"រុលហាន..." ហ្វាខែល តបហើយក៏សួរវិញភ្លាម "មានអីឬ ?"

"គេធ្វើការទីនោះយូរហើយឬ ?"

"មួយឆ្នាំហើយ ជំនាញរឿងផ្លូវនៅទីនេះគ្រប់ខ្សែ"

"ថ្ងៃនេះ ហ្ស៊ីក យាងទៅណាទេ ?"

នាងសួរ ហើយពេលលើកដៃមើលនាឡិកា ឃើញថាម៉ោងមួយកន្លះទៅហើយ។

"ពេលល្ងាចមានកម្មវិធីជប់លៀងនៅស្ថានទូតព័រទុយហ្គាល់ ប៉ុន្តែអាចមិនទៅចូលរួម បើ ហ្ស៊ីក មានការងាររវល់"

"តែបើទៅត្រូវប្រើឡាន..." នាងថា "តើត្រួតពិនិត្យរបៀបរៀបរយហើយឬនៅ ?"

"រុលហាន ជាអ្នកត្រួតពិនិត្យ គេត្រូវទទួលខុសត្រូវរឿងឡាន"

នាងក្រមុំមិនតប តែងក់ក្បាលជាការទទួលដឹង ហើយសម្លឹងមើលឡានដែលចតចាំដោយការរិះគិត។

មិនយូរប៉ុន្មានមន្ត្រីទាំងឡាយក៏ចេញពីបន្ទប់ ដោយមាន ហ៊ុលសែន ដែរ ដែលគេដើរមកខ្សឹបប្រាប់នាង។

"បន្តិចទៀតយើងត្រូវទៅចូលរួមកម្មវិធីជប់លៀង ហ្ស៊ីក ឲ្យនាងឡើងទៅត្រៀមខ្លួន មានសម្លៀកបំពាក់ស្អាតៗសម្រាប់ចូលរួមទេ ?"

"សម្លៀកបំពាក់ស្អាតៗ ធ្វើឲ្យទើសទែងក្នុងការធ្វើការ លាក់អីមិនជិតទេ តែខ្ញុំមានគ្រ័រហ្សេពណ៌ស ប្រើបានគ្រប់កម្មវិធី តុបតែងមុខធ្វើសក់



តែបន្តិចបន្តួចប៉ុណ្ណោះ"

"អ៊ីចឹងយើងកុម្ម៉ង់ឲ្យ...ពីហាងទំនិញនៅជិតៗនេះ..." ហ្វាខែល ដាក់សំណើ។

"កុំអី សំពត់រ៉ូបអស់នោះភាគច្រើនបង្ហាញសាច់បង្ហាញឈាម លោកចង់ឲ្យខ្ញុំលាក់កាំភ្លើងនៅត្រង់ណា ?"

"ត្រង់នេះហ្នឹងអី" ដានៀល ដែលឈរស្តាប់យូរមកហើយ និងគិតតែសម្លឹងមើលនាង ក៏ចង្អុលភ្លៅ ធ្វើឲ្យនាងអស់សំណើច។

"នោះជារឿងកុន...កាំភ្លើងដែលខ្ញុំប្រើ លាក់ត្រង់នេះមិនបានទេ"

និយាយចប់ នាងក៏យកអាវុធដែលអាចផ្ទុកគ្រាប់បានដប់ប្រាំគ្រាប់មកមើល វាធំមិនអាចសៀតនឹងភ្លៅបាន។

"មិនអីទេ កុំបារម្ភអី ខ្ញុំផាត់មុខធ្វើសក់ឲ្យទំនងបន្តិច ធានាថាសង្ហាមិនចាញ់ពួកលោក"

នាងនិយាយលេងដាក់ពួកគេ ហើយក៏ឡើងទៅបន្ទប់ដោយទឹកមុខមិនរសាយភាពខ្វល់ខ្វាយអីបន្តិច ព្រោះអ្នកបើកឡានម្នាក់នោះច្បាស់ជាមានអីមិនស្រួល។

ពីរម៉ោងក្រោយមក អង្គរក្សក៏ផ្លាស់ប្តូរគ្នាទៅទទួលទានអាហាររួចរាល់ ព្រោះដឹងថាក្នុងកម្មវិធី ពួកគេគ្មានសិទ្ធិទទួលទាន រហូតដល់ម៉ោងប្រាំបី បុរសគ្រងឈុតប្រចាំជាតិ សតាំងពីលើដល់ក្រោម ក្រវាត់ចង្កេះដោយខ្សែខ្មៅ ប៉ុន្តែអ៊ីកាល់ដែលពាក់ពីលើគូត្រាពណ៌ស មិនមែនខ្សែក្រងពណ៌ខ្មៅធម្មតាៗនោះទេ វាមានពណ៌មាសស្អាតប្លែកភ្នែក និងប្រាប់ពីតំណែងដែលមិនធម្មតារបស់អ្នកប្រើប្រាស់បានច្បាស់ ក៏ដើរចុះពីជាន់លើ ដោយភ្នែកសម្លឹងរកមើលអង្គរក្សក្រមុំមុនគេ បន្ទាប់មកក៏ដើរសំដៅឡាន។



"ហេតុអី ហ្សីក មិនប្រើរាជសព្ទពេលនិយាយជាមួយ ហ្សីកា ?"

នាងសួរ ហ្វាខែល ភ្លាមពេលមានឱកាសជិះឡានមួយទៀតតាមពីក្រោយ ដោយលើកនេះ ហ៊ុលសែន ជាអ្នកជិះឡានគូជាមួយអ្នកបើកឡានរបស់ ហ្សីក ព្រោះមុខរបួសរបស់គេធូរស្រាលហើយ។

"ទ្រង់ជាបងប្អូននឹងគ្នា" ហ្វាខែល តប "ហ្សីក ជាកូនរបស់ស្នំកើតមុន ការពិតអាចឡើងគ្រងរាជ្យផង បើមិនផ្លាស់ប្ដូរច្បាប់រដ្ឋធម្មនុញ្ញឲ្យ ហ្សីកា ដែលជាព្រះរាជធីតាពីព្រះមហេសីឡើងគ្រងរាជ្យកាលពីមិនប៉ុន្មានឆ្នាំមុន"

គេអធិប្បាយខ្លីៗឲ្យយល់ ខណៈដែលនាងក្រមុំគិតតែសម្លឹងមើលឡានខាងមុខ ដោយគិតនៅក្នុងចិត្តថា បើអ្នកបើកឡាននៅក្នុងឡាននោះដែរ មិនគួរណាមានគ្រោះថ្នាក់។

នាងគិត ខណៈដែលឡានទាំងពីររត់តាមគ្នានៅក្នុងល្បឿនលឿនរហូតទៅដល់គោលដៅ។

អ្នកបើកឡានរបស់ ហ្សីក មិនដឹងទេថាត្រូវនាងតាមឃ្លាំមើលគ្រប់ពេលវេលារហូតដល់មិខាអ៊ីលចុះពីឡាននៅមុខកម្មវិធីអមដោយអង្គរក្សបួននាក់ ឯ ហេឃ្យូ ត្រូវថយចេញឆ្ងាយមួយកម្រិត ទុកឲ្យ ហ៊ុលសែន ធ្វើតួនាទីដើរតាមប្រកៀក ហ្សីក ជំនួស ព្រោះមានអារម្មណ៍ថាការថយឲ្យឆ្ងាយ វានឹងធ្វើឲ្យនាងសង្កេតការណ៍នៅជុំវិញខ្លួនបានល្អជាង។

ពេលនាងថយបានមួយជំហាន អគ្គរដ្ឋទូតរបស់ព័រទុយហ្គាល់ ក៏មកទទួល ហ្សីក និងនិយាយគ្នាមួយសន្ទុះ ក៏ហុចក្រដាសមួយសន្លឹកឲ្យអញ្ជើញភ្ញៀវចូលទៅក្នុងកម្មវិធី។

ហេឃ្យូ ងាកតាមភ្លាម ពេលបានឮថាពួកគេនាំគ្នាទៅនិយាយនៅបន្ទប់ណា ប្រើពេលវេលាមិនលើសពីកន្លះម៉ោង ដោយមានតំណាង



របស់ភាគីទាំងសងខាង គឺទូតរបស់ព័រទុយហ្គាល់ និង ហ្សីក ប៉ុណ្ណោះ។

ដានៀល ត្រូវបញ្ជូនឲ្យទៅពិនិត្យវេទិកាដែលនឹងត្រូវឡើងនិយាយនៅវេលាបន្ទាប់ ឆ្លាស់គ្នានឹង ហេឃ្យូ ចំណែក ហ៊ុលសែន នៅតែដើរតាម ហ្សីក។

ពេលវេលាបន្ទាប់មក ភ្ញៀវទាំងអស់ក៏ត្រូវអញ្ជើញឲ្យទៅចូលរួមនៅក្នុងបន្ទប់ប្រជុំពិសេសនោះ។

ការពិតបន្ទប់នោះ បើគ្មានកញ្ចក់ថ្លាតូចវែងដាក់ជាប់គ្នា មើលធ្លុះអគារខាងក្រោយក៏ល្អ ប៉ុន្តែក្នុងពេលដែលវាត្រូវច្នៃម៉ូដបែបនេះទៅហើយ វាក៏ធ្វើឲ្យបារម្ភ និងមិនទុកចិត្ត។ សម្រាប់បុគ្គលសំខាន់ៗគ្រប់រូបដែលឈរនៅលើខឿននោះ ជាពិសេសនៅពេលរាត្រីមានពន្លឺភ្លើងចែងចាំង។

ពេលភ្ញៀវពន្លឺនៅក្នុងឈុតរាត្រីចូលទៅអង្គុយរួចរាល់ ម្ចាស់កម្មវិធី គឺទូតព័រទុយហ្គាល់ ក៏ឡើងបើកកម្មវិធី ដោយនិយាយពីគោលបំណងនៃការបើកកម្មវិធីលើកនេះ ដោយអញ្ជើញព្រះអង្គម្ចាស់ មិខាអ៊ីល ឡើងនិយាយជាករណីជាពិសេស។

សំឡេងទះដៃបន្លឺឡើង អមដោយសំឡេងហ៊ោដោយការពេញចិត្តពេញថ្លើមនឹងភាពសង្ហាត្រូវចិត្តត្រូវភ្នែករបស់ ហ្សីក ដែលមាននៅក្នុងសង្គមបច្ចុប្បន្ន។

ហ៊ុលសែន ឈរនៅក្រោយខ្នង ហ្សីក ចំណែក ហេឃ្យូ ក៏ទៅឈរនៅជ្រុងម្ខាងទៀត ចំណែក ដានៀល និង ហ្វាខែល ឈរនៅខាងមុខម្នាក់ម្ខាង។

គ្រប់គ្នាដឹងច្បាស់ថា លើវេទិកាថ្ងៃនេះមានចំណុចខ្សោយសំខាន់ តែមិនអាចផ្លាស់ប្ដូរអ្វីបាន ដោយ ហេឃ្យូ ដៀងមើលកញ្ចក់ដែលនាងមិនទុកចិត្តនោះគ្រប់ពេលវេលា និងសម្លឹងមើលអគារកញ្ចក់នោះដែរ។





Scanned by CamScanner

នាងភាវនាឲ្យខ្លួនឯងចេះតែប្រុងប្រយ័ត្ន ការពិតទៅវាគ្មានអីកើតឡើងទេ...នាងប្រាប់ខ្លួនឯង ខណៈដែល មិខាអ៊ីល កំពុងនិយាយ អ្នកនៅខាងក្រោមក៏យកចិត្តទុកដាក់ស្ដាប់យ៉ាងស្ងៀមស្ងាត់។

ហើយនាទីបន្ទាប់មក កញ្ចក់ក៏បែកលាន់ប្រាវ ស្របពេលដែល ហេយ្យូ ស្ទុះទៅបោលបំបុកព្រះអង្គម្ចាស់ឲ្យខ្ទាតចេញ តាមដោយគ្រាប់កាំភ្លើងបាញ់ចំក្បាលមេក្រូបែកខ្ចាយ ឆាសដើមទ្រូងរបស់ ហ្សុីក ទៅត្រូវស្មា បាញ់ឈាមក្រហមប្រាល។

ហេយ្យូ និង ហ៊ុលសែន អូស មិខាអ៊ីល ចុះពីខឿនចេញទៅខាងក្រៅជាបន្ទាន់ ដោយមាន ហ្វាខែល ទូរសព្ទហៅឡានដែលចត។

"យកឡានរបស់យើង...របស់ ហ្សុីក មិនយក" ហេយ្យូ ស្រែកប្រាប់ ទើប ហ្វាខែល ប្ដូរមុខសញ្ញាភ្លាម។

មិនយូរប៉ុន្មាន ពួកគេក៏ចេញមកក្រៅ ដោយមានឡានមួយរត់មកចតចាំ។ ពេលឡានរត់ចេញមក នាងក៏ឈ្ងោកមើលឡានរបស់ ហ្សុីក ដែលនៅចតកន្លែងដដែល ឃើញអ្នកបើកឡានរត់តាមតែមិនទាន់ ហើយឡានរបស់នាងក៏រត់មកដល់ផ្លូវធំ បើកសំដៅទៅមន្ទីរពេទ្យ។

"ទៅមន្ទីរពេទ្យរបស់ ឃ្វីន"

នាងប្រាប់អ្នកបើកឡាន ហើយទូរសព្ទទៅរាយការណ៍ប្រាប់ទីនោះជាបន្ទាន់ឲ្យត្រៀមការណ៍ចាំ ហើយប្រាប់ផ្លូវដល់អ្នកបើកឡាន ព្រោះមិនត្រូវការឲ្យអ្នកណាដឹងរឿងអីទៀត។

ភ្លាមនោះ ពេលដែលឡានពណ៌ខ្មៅធំរបស់ស្ថានទូតរត់ចូលទៅ សន្តិសុខដែលយាមនៅមាត់ផ្លូវក៏ទាញទ្វារដែកពណ៌សចេញ បើកផ្លូវឲ្យចូលមន្ទីរពេទ្យ ហើយទាញបិទវិញ ដោយរនាំងបិទផ្លូវនោះមានដាក់តួអក្សរប្រាប់ថា ប្រយ័ត្នគ្រោះថ្នាក់ ការដ្ឋានកំពុងសាងសង់ មិនឲ្យអ្នកណាចូលកន្លែងនេះបានទៀត។

ទាំងគ្រូពេទ្យទាំងគិលានុបដ្ឋាយិកា រង់ចាំទទួលអ្នកជំងឺបន្ទាន់ ពេលទៅដល់ក៏វះកាត់ភ្លាម។

ហ៊ុលសែន ដើរទៅដើរមកនៅមុខបន្ទប់វះកាត់ ដោយឆ្លាស់គ្នានឹង ហេយ្យូ ព្រមទាំងរិះគិតដែរ រហូតដល់គ្រូពេទ្យដើរចេញពីបន្ទប់មកប្រាប់។

"អ្នកជំងឺរួចផុតពីគ្រោះថ្នាក់ហើយ ឲ្យសម្រាកបួនប្រាំថ្ងៃទៀត អាចត្រឡប់ទៅផ្ទះបាន" និយាយចប់ គ្រូពេទ្យពូកែដែលត្រូវអញ្ជើញមកតែពេលមានអ្នកជំងឺ ក៏ដើរចេញទៅ ទុកឲ្យគិលានុបដ្ឋាយិការុញអ្នកជំងឺចូលបន្ទប់ពិសេស ដែលរៀបចំចាំរួចជាស្រេច។

"ម៉េចក៏ទៅជាអីចឹង ?" ហេយ្យូ សួរ ហ៊ុលសែន ភ្លាម។

"ទៅជាយ៉ាងម៉េច ?" ហ៊ុលសែន សួរវិញ។

"ម៉េចក៏លោកបណ្ដោយឲ្យព្រះអង្គម្ចាស់ ត្រូវគេលបសម្លាប់ជារៀងរាល់ថ្ងៃបែបនេះ បើបណ្ដោយបែបនេះទៀត ថ្ងៃណាមួយច្បាស់ជាត្រូវមែនទែន លោកមិនដឹងមូលហេតុមកពីស្អីទេឬ ?" នាងសួរ និងសម្លឹងមើលគេដោយមិនចង់ជឿ។

"ខ្ញុំនិយាយស្អីមិនបាន...ស្រេចតែលើព្រះអង្គម្ចាស់ក្នុងពេលដែលទ្រង់ស្ម័គ្រចិត្តនៅគឺត្រូវតែនៅ"

"ហេតុអី...ដើម្បីអ្នកណា ជួយប្រាប់បន្តិចបានទេ ដើម្បីហ្សុីកាឬ ?"

"ដើម្បីមនុស្សសំខាន់ជាងនោះ"

"អ្នកណា ?"

"ព្រះរាជាដែលចូលព្រះទិវង្គតទៅហើយ ព្រះអង្គម្ចាស់សន្យានឹង



ទ្រង់ហើយ"

ចម្លើយនោះធ្វើឲ្យនាងក្រមុំធ្វើភ្នែកព្រិចៗមិនយល់ តែក៏មិនដឹងថាសួរអ្នកណាទើបច្បាស់ជាងនេះ។

ពួកគេបណ្ដើរគ្នាដើរចូលបន្ទប់អ្នកជំងឺភ្លាម ពេលគិលានុបដ្ឋាកនាំគ្នាចេញទៅអស់។

ហ្សុីក មិនទាន់ដឹងខ្លួន ទើប ហ៊ុលសែន ថយទៅអង្គុយនៅកៅអីវែងកៀនជញ្ជាំង ប៉ុន្តែនាងដាក់គូថនៅលើកៅអីក្បែរគ្រែ។

ពេលវេលាចេះតែដើរទៅមុខ រហូតដល់ព្រឹក ហ៊ុលសែន ក៏ចេញទៅត្រួតពិនិត្យនៅក្រៅអគារ ចំណែក ហេឃ្សូ ក៏ចាត់ការធុរៈផ្ទាល់ខ្លួន ហើយចេញមកយាមកាមអ្នកជំងឺ រហូតដល់គេដឹងខ្លួន។

ពេល មិខាអ៊ីល បើកភ្នែកក៏ឃើញនាងមុនគេ។ នាងកំពុងតែអង្គុយសម្លឹងមើលទៅក្រៅបង្អួច ដែលវាជាអាការៈភ្លេចខ្លួនលើកដំបូងឲ្យគេបានឃើញ។

អ្នកកំលោះមើលនាងមិនដាក់ភ្នែកមើលអាកប្បកិរិយាដែលសម្លឹងមើលទៅខាងក្រៅដោយខ្សែភ្នែកទទេស្អាត ដែលមិនគួរណាអាចទៅរួច រហូតដល់គេកម្រើកខ្លួន ទើបនាងងាកមករកភ្លាម និងឱនមកសួរដោយការព្រួយបារម្ភ។

"យ៉ាងម៉េចហើយ ឈឺខ្លាំងទេ?"

"ឈឺខ្លះដែរ សុំទឹកបន្តិច"

គេនិយាយតិចៗដូចខ្សឹប តែនាងបានឮច្បាស់ ទើបចាក់ទឹកដាក់កែវ ជួយគ្រាហ៍គេឲ្យងើបបន្តិច ទាញខ្នើយកល់ឲ្យ។

សកម្មភាពនោះ ធ្វើឲ្យពួកគេត្រូវនៅជិតគ្នា ប្រសព្វភ្នែកគ្នាដោយអចេតនា តែនាងក្រមុំក៏រហ័សហុចកែវទឹកឲ្យ។

ពេលនោះទ្វារបន្ទប់ក៏ត្រូវបើក គិលានុបដ្ឋាយិកាក៏រុញរទេះអាហារចូលមក។

ពេល ហ៊ុលសែន ដើរចូលមក ហេឃ្សូ ក៏ដើរចេញទៅក្រៅ ដើម្បីគេចវេះពីការប្រឈមមុខនឹងព្រះអង្គម្ចាស់។

នាងដឹងច្បាស់ថាខ្លួនគ្មានសិទ្ធិសួរ ឬបញ្ចេញយោបល់ ក្រៅពីធ្វើតាមបញ្ជានិងតួនាទីរបស់ខ្លួនប៉ុណ្ណោះ ដូច្នេះហើយនៅឲ្យឆ្ងាយពីគេ វាជារឿងល្អបំផុតនៅពេលនេះ។

នាងឈរនៅខាងក្រៅបានមិនយូរប៉ុន្មាន ហ៊ុលសែន ក៏ចេញមកតាម។

"តួនាទីបញ្ចុកអាហារអ្នកជំងឺជារបស់នាង មិនមែនខ្ញុំ"

ពេលប្រាប់ហើយ គេក៏ដើរទៅអង្គុយលើកៅអីនៅមុខបន្ទប់ធ្វើព្រងើយ ទើបនាងក្រមុំត្រូវដើរចូលបន្ទប់ម្ដងទៀត ដែលវាជាការពិតដូចដែល ហ៊ុលសែន និយាយ អ្នកជំងឺលើកដៃមិនបាន តើម៉េចនឹងអាចញ៉ាំបាយបានទៅ ឯគិលានុបដ្ឋាយិកាក៏ចេញទៅបាត់ហើយ។

ហេឃ្សូ ដើរទៅអង្គុយនៅលើគ្រែទល់មុខអ្នកជំងឺ ហើយដួសស៊ុបផ្សិតបញ្ចុកអ្នកជំងឺម្ដងមួយម៉ាត់ៗ ដោយមើលមុខសង្ហាខាបព្រលឹងស្រីៗគ្រប់គ្នាដោយខ្សែភ្នែករិះគិត រហូតដល់ស៊ុបអស់ពីចាន ដោយមិនបាននិយាយគ្នា។





Scanned by CamScanner

## ៦

"នាងសង្ស័យថាខ្ញុំនៅធ្វើជាផ្ទាំងស៊ីបឲ្យគេសម្លាប់ធ្វើអីមែនទេ?"

គេចាប់ផ្ដើមនិយាយពេលដាក់កែវទឹកចុះ ដោយ ហេយ្យ មិនតប តែងើបចុះពីគ្រែមកឈរក្បែររង់ចាំស្ដាប់។

"ឡើងមកអង្គុយលើគ្រែវិញម៉ោ ខ្ញុំចូលចិត្តឲ្យនាងបង្ហាញភាពសាមញ្ញៗ ជាងធ្វើឲ្យខ្ញុំមានអារម្មណ៍ថាយើងឆ្ងាយគ្នាមួយយោជន៍បែបនោះ...ឡើងមកអង្គុយដូចអម្បាញ់មិញម៉ោ"

គេងាកខ្លួន ហើយក៏ពេបមាត់ព្រោះឈឺមុខរបួស ដើម្បីឲ្យនាងឡើងមកអង្គុយក្បែរ ទើបនាងក្រមុំត្រូវធ្វើតាមដោយគ្មានលក្ខខណ្ឌ ព្រោះមិនមែនជាមនុស្សរឿងច្រើន។

"ហ៊ុលសែន មិនបាននិយាយរឿងខ្ញុំឲ្យនាងស្ដាប់ខ្លះទេឬ?"

គេសួរ ហាក់ដូចដឹងថានាង និង ហ៊ុលសែន ត្រូវតែនិយាយគ្នាពីរឿងនេះ។

"ខ្ញុំមិនចង់គ្រងរាជ្យ... ខ្ញុំចង់រស់នៅឲ្យមានសេចក្ដីសុខប៉ុណ្ណោះ ឪពុករបស់ខ្ញុំជាព្រះរាជា ដែលមិនធ្លាប់មានសេចក្ដីសុខពេញមួយជីវិតរបស់ទ្រង់"

នាងស្ដាប់គេដោយមិនមាត់មិនក មិនបញ្ចេញយោបល់។

"ទ្រង់ឲ្យខ្ញុំសន្យាថា ត្រូវមើលថៃ រ៉ននី ទាល់តែឡើងគ្រងរាជ្យមុនពេលទ្រង់សោយទិវង្គត"

"ចុះម្ដាយរបស់ ហ្ស៊ីក?"

"ម៉ាក់ស្លាប់ច្រើនឆ្នាំហើយ...ជិតដប់ឆ្នាំហើយ"

"ទ្រង់ត្រូវឈរធ្វើជាផ្ទាំងស៊ីបឲ្យគេសម្លាប់ រង់ចាំឲ្យ ហ្ស៊ីកា ឡើងគ្រងរាជ្យឬ?"

"តាមសន្យា"

"ហើយ ហ្ស៊ីកា ឡើងគ្រងរាជ្យមិនបានឬ បើគ្មានទ្រង់?"

"ហ្ស៊ីកា មិនចូលចិត្តធ្វើការ ចូលចិត្តដើរលេង និងទំនើងណាស់ ត្រូវលើកពេលរាជាភិសេកម្ដងហើយម្ដងទៀត"

"អ៊ីចឹងទ្រង់ជាប្រមុខរដ្ឋស្ដីទីជំនួសព្រះមហាក្សត្រ!"

នាងឧទាន ខណៈដែលប្រមុខរដ្ឋស្ដីទីធ្វើមុខជម្មតា។

"ស្ដាប់ៗទៅគួរតែអ៊ីចឹង ទោះព្រះរាជិនីគួរកាន់តំណែងនេះ ព្រោះអ៊ីចឹងហើយទើបទ្រង់ត្រូវតាមប្រមាញ់"

"បើគ្មានមនុស្សរបស់ព្រះមហាក្សត្រក្ដោបក្ដាប់អំណាចធំ... អ៊ុំម៉ាមនឹងក្ដោបក្ដាប់អំណាចទាំងអស់...សម្ដេចព្រះមហាក្សត្រីនិង ហ្ស៊ីកា ក៏ធ្វើអីមិនបាន"

"អ៊ីចឹងតើ...ចុះបើ ហ្ស៊ីកា ឡើងគ្រងរាជ្យរួចរាល់?"

"ខ្ញុំនឹងដកថយ ទុកឲ្យ ហ្ស៊ីកា ធ្វើការ"

"វាងាយបែបហ្នឹងឬ?"

"វាគួរតែងាយបែបហ្នឹងតាំងពីយូរហើយ"



"ធ្វើឲ្យទ្រង់ត្រូវរស់នៅក្បែរមាត់មច្ចុរាជទាល់តែ ហ្ស៊ីកា ឡើងគ្រងរាជ្យ ឬចេះធ្វើការ"

"ប្រហែលអ៊ីចឹង" គេសរុប ទើបនាងដកដង្ហើមធំ ហើយចុះពីគ្រែដើរចេញឲ្យឆ្ងាយ។

"ទ្រង់នឹងសុគតនៅថ្ងៃណាមួយ បើបណ្ដោយឲ្យវាបែបនេះ"

"មនុស្សយើងត្រូវតែស្លាប់"

មិខាអ៊ីល និយាយដូចថាឲ្យខ្លួនឯង ហើយពួកគេក៏សម្លឹងមើលមុខគ្នា និងដកដង្ហើមធំពេលដឹងថាមិនទាន់មានផ្លូវចេញនៅពេលនេះ។

ប្រាំថ្ងៃក្រោយមក ពេលត្រឡប់ទៅស្ថានទូតវិញ ដោយគ្មានអ្នកណាដឹងទេថាព្រះអង្គម្ចាស់ មិខាអ៊ីល រងរបួសធ្ងន់ស្រាលកម្រិតណា ព្រោះព័ត៌មានត្រូវបានបិទ ហ្ស៊ីកា ក៏យាងមករកភ្លាម។

"ព្រះរៀមទៅណា ដឹងទេថាអនុជតាមរកស្ទើរគាស់ផែនដីហើយ" ព្រះអង្គម្ចាស់ក្សត្រីសួរ ហើយមើល ហេយ្ស៊ូ និងសួរដោយមិនពេញព្រះទ័យថា "អេំ...នាងនៅតែនៅទៀតឬ?"

"នាងជាមនុស្សរបស់ព្រះរៀម...តែថាមកក៏ល្អហើយ រៀមចង់ឲ្យ ហ្ស៊ីកា ដឹងថាត្រូវធ្វើយ៉ាងណានៅថ្ងៃជប់លៀង"

ហ្ស៊ីក និយាយចប់ក៏ដើរនាំមុខចូលបន្ទប់ធ្វើការ ដោយឲ្យគ្រប់គ្នារង់ចាំនៅខាងក្រៅ។

ពេលវេលាកន្លងផុតទៅមួយម៉ោង មុនពេលព្រះអង្គម្ចាស់ក្សត្រីយាងត្រឡប់ទៅវិញ ក៏សម្លឹងមុខ ហេយ្ស៊ូ។

"ដានៀល" ព្រះអង្គម្ចាស់ក្សត្រីហៅ។

"ក្រាបទូល"



"យកស្រីម្នាក់នេះចេញពីទីនេះ...ចេញឲ្យផុតពីមុខយើង"

ពេលបញ្ជាហើយ ទ្រង់នឹងយាងចេញទៅភ្លាម បើ ដានៀល មិនទូលថា ៖

"ទូលបង្គំគ្មានសមត្ថភាព...ព្រះអង្គម្ចាស់ជាចៅហ្វាយរបស់នាងក្រាបទូល"

"អេំ...យើងបញ្ជា"

"សូមប្រទានទោសដល់ទូលបង្គំ ទូលបង្គំច្បាស់ជាស្លាប់មិនខាន បើព្រះអង្គម្ចាស់ដឹងថាធ្វើអ្វីដោយគ្មានការអនុញ្ញាតពីទ្រង់"

"បើពួកឯងមិនធ្វើ...យើងនឹងចាត់ការដោយខ្លួនឯង"ព្រះអង្គម្ចាស់-ក្សត្រីត្រាស់ដោយព្រះទ័យក្រេវក្រោធ។

"ចង់ធ្វើអី!" សំឡេងរបស់ ហ្ស៊ីក បន្លឺឡើងនៅមាត់ទ្វារ តែ ហ្ស៊ីការ៉ននី មិនតប ទ្រង់ដើរប៉ាត់រញ៉ាត់ចេញទៅបាត់។

យប់នោះ ហេយ្ស៊ូ ត្រូវចូលសម្រាករាងយប់ជ្រៅ។ នាងងូតទឹកលឿនដូចព្យុះ ព្រោះចង់សម្រាកពេញបន្ទុក ទាំងដែលមិនបានធ្វើការហត់នឿយអីផង តែវាហត់ចិត្តទៅវិញទេ។

អាកប្បកិរិយារបស់ព្រះអង្គម្ចាស់ក្សត្រី ធ្វើឲ្យនាងគិតច្រើនគួរសមធ្វើឲ្យមិនចង់នៅទីនេះ។

ពេលដើរចេញពីបន្ទប់ទឹក ក៏មានការ៉ុងមួយគ្របខ្លួនភ្លាម ដោយគ្មានឱកាសបានការពារខ្លួនឯង។ នាងប្រឹងរើបម្រះអស់ពីកម្លាំង តែមិនអាចជួយខ្លួនឯងបាន ត្រូវលីចេញទៅក្រៅ ហើយត្រូវទម្លាក់លើដី និងតាមដោយដៃជើងរបស់អ្នកទាំងនោះ ដោយមើលមិនឃើញថាអ្នកណាជាអ្នកណា។



ការប្រឹងរើបម្រះអស់ពីកម្លាំងកំហែងនោះ ធ្វើឲ្យមេខ្លោងទាញ

កាំភ្លើងវាយក្បាលរបស់នាងខ្លាំងៗម្តងហើយម្តងទៀត ទាល់តែនាងស្ងាត់មាត់។

ពេលនោះទ្វារមួយដែលនៅជិតក៏ត្រូវបើក ស្របពេលដែល មិខាអ៊ីល ដើរចេញមកដោយការសង្ស័យ។

ពេលឃើញព្រះអង្គម្ចាស់ អ្នកកាន់កាំភ្លើងនោះក៏ទម្លាក់កាំភ្លើងដោយស្វ័យប្រវត្ត និងឱនក្រាបដោយការភ័យខ្លាច។

មិខាអ៊ីល ដើរមកបើកមើលក្នុងការ៉ុងភ្លាម ហើយងើយមើលអ្នកនៅក្រោមការបង្គាប់បញ្ជាដោយការមិនពេញចិត្ត។

"ឯងធ្វើស្អី!"

"ជា...ជាព្រះរាជបញ្ជារបស់ ហ្សីកា ក្រាបទូល...ឲ្យយកនាងទៅឲ្យផុតពីទីនេះ ក្រាបទូល..."

"នាងជាមនុស្សរបស់យើង ឯងក៏ដឹងមិនអីចឹង!"

ហ្សីក គ្រហឹមដាក់ និងមើលដោយខ្សែភ្នែកសោះកក្រោះ។

"តែហ្សីកា..."

"ទៅចុះ...ចាំយើងចាត់ការ..."

ម្នាក់នោះស្ទុះស្ទារត់ចេញពីទីនោះភ្លាម ខណៈដែល ហ៊ុលសែន ក៏បង្ហាញខ្លួននៅពេលនោះដែរ ទើបត្រូវចៅហ្វាយនាយសម្លឹងមុខ ដែលធ្វើឲ្យញ័រឆ្អឹងខ្នងតែម្តង។

"ឯងសហការជាមួយពួកនោះ?"

អ្នកកំលោះសួរអង្គរក្សជំនិតដោយការមិនពេញចិត្ត។

"ជាព្រះរាជបញ្ជា..." ហ៊ុលសែន តបទាំងមិនសប្បាយចិត្ត។

"ម៉េចក៏ធ្វើ...ទាំងដែលឯងដឹងថានាងជាមនុស្សរបស់យើង!"

មិខាអ៊ីល គំហកដាក់មុខ ហ៊ុលសែន ដោយកំហឹងដែលបរិយាយ



មិនត្រូវ។

"ស្រីម្នាក់នេះកើតស្អីមិនបានទេ...មិនអីចឹង ឯងមិនអាចនៅជាមួយខ្ញុំបានតទៅទៀតទេ បានឮទេ ហ៊ុលសែន!"

ហ៊ុលសែន មើលមុខចៅហ្វាយដោយមិនចង់ជឿ ប៉ុន្តែពេលឃើញ ហ្សីក ទាញការ៉ុងនោះចេញឲ្យផុតពីជើងរបស់ ហេយ្យូ និងលើកបីនាងដើរចូលក្នុងបន្ទប់ ក៏ត្រូវដកដង្ហើមធំ ព្រោះយល់ថាអ្វីជាអ្វី។

ហ្វាខែល និង ដានៀល ក៏ដើរមករក និងមើលមុខដោយដឹងហើយថាត្រូវធ្វើយ៉ាងណាចាប់ពីពេលនេះទៅ បើហេតុការណ៍វាផ្លាស់ប្តូរបែបនេះ។

មិខាអ៊ីល បីនាងក្រមុំចូលបន្ទប់ ដោយដាក់នាងនៅលើគ្រែថ្មមៗដោយការប្រុងយ័ត្ន ទាញអាវឃ្លុំងូតទឹកចងឲ្យរួចរាល់ បន្ទាប់មកក៏ឈរមើលមិនដាក់ភ្នែកអស់ជាច្រើនដង្ហើម រហូតដល់នាងដឹងខ្លួន ងើបមកមើលគេដោយការភ្ញាក់ផ្អើល។

"មានអីកើតឡើង?"

"មានមនុស្សចង់ចាប់ជំរិតនាង តែពួកយើងជួយទាន់" អ្នកកំលោះប្រាប់ ហើយក៏បែរខ្នងដើរសំដៅទ្វារ។

"ហ្សីកា មែនទេ?"

មិខាអ៊ីល មិនឆ្លើយ តែងាកមកមើលមុខនាង។

"ខ្ញុំនឹងមិនឲ្យហេតុការណ៍បែបនេះកើតឡើងទៀតទេ"

"ឲ្យខ្ញុំទៅមិនងាយជាងឬ ព្រះរាជបញ្ជារបស់ហ្សីកា នឹងធ្វើឲ្យយើងឈ្លោះគ្នាឯង"

"ណ្ហើយ! ចាំខ្ញុំចាត់ការ"

និយាយចប់គេក៏បែរខ្លួនដើរសំដៅទ្វារម្តងទៀត ហើយអ្វីក៏មិនដឹង



ដែលធ្វើឲ្យ ហេយ្យូ រត់ទៅទាញដៃអាវរបស់គេលឿនដូចព្យុះ ទោះនៅវិលមុខជេងជោងក៏ដោយ ទើប មិខាអ៊ីល ឱនមើលដៃរបស់នាងដែលទាញអាវរបស់ខ្លួន។

"ឲ្យខ្ញុំទៅៗ សូមអង្វរ វានឹងធ្វើឲ្យ ហ្ស៊ីកា មិនពេញព្រះទ័យ វានឹងបំផ្លាញភាពស្មោះត្រង់របស់យើង...ខ្ញុំទៅ...វាងាយជាង"

នាងប្រាប់បែបនោះ ដោយភ្លេចទៅថាពេលនេះខ្លួនឯងគួរឲ្យមើលគួរឲ្យគយគន់កម្រិតណា ទាំងសក់វែងរំសាយដែលរាយប៉ាយគ្របខ្នងគ្របស្មាក្តោបមុខស្រស់ស្អាត ឯអាវឃ្លុំដែលរាងធំរលុង និងជីវរបស់វាញែកចេញពីគ្នា បង្ហាញគល់ទ្រូងដោយម្ចាស់វាមិនដឹងខ្លួន។

មិខាអ៊ីល មើលនាង ហើយងាកមុខចេញ ដោយមិនភ្លេចរុញនាងចេញដែរ តែនាងបែរជាស្រវាចាប់ដៃម្ខាងនោះ ធ្វើឲ្យការអត់ធ្មត់របស់អ្នកកំលោះដល់ទីបញ្ចប់ ត្រូវទាញនាងមកឱប ដោយដៃម្ខាងទៀតចាប់ចង្ការបស់នាងជាប់។

ហេយ្យូ ទៅជាញ័របេះដូងពេលត្រូវទាញមកឱបបែបនេះ ថែមទាំងភ្ញើយចង្កាឲ្យនាងងើយទៅរក ខណៈនោះក៏ឱនមកថើបបបូរមាត់យ៉ាងលឿន ដោយមិនឲ្យនាងត្រៀមខ្លួន។

"ខ្ញុំមិនព្រមឲ្យនាងចាកចេញពីខ្ញុំទេ...ស្តាប់ឲ្យច្បាស់ ខ្ញុំមិនព្រម!"

ពេលប្រាប់រួចហើយ ព្រះអង្គម្ចាស់ក៏ដើរចេញទៅ ខណៈដែលអង្គរក្សក្រមុំនៅតែឈរធ្មឹង មិនយល់ និងស្មានមិនដល់ រហូតដល់ទ្វារបន្ទប់ត្រូវបិទ ទើបនាងលើកដៃប៉ះបបូរមាត់ទាំងមិងមាំង ភ្នែកក៏សម្លឹងមើលទ្វារនោះដោយធ្វើអីមិនត្រូវ។

ព្រះអង្គម្ចាស់ក្សត្រី រ៉េននី មិនស្មានថាព្រះរៀមម្ដាយទីទៃ សម្រុក



មកដល់ក្រឡាបន្ទំទាំងអធ្រាត្របែបនេះ ដោយទាហានអង្គរក្សនាំគ្នាដកថយ ឯភីលៀងក៏នាំគ្នាបើកទ្វារឲ្យជាបន្ទាន់ឲ្យព្រះអង្គម្ចាស់ចូលទៅក្នុងក្រឡាបន្ទំ និងទាញទ្វារបិទដោយមិនឲ្យអ្នកណាបានឮរឿងរ៉ាវដែលបងប្អូនកំពុងនិយាយគ្នា។

"មានការអីព្រះរៀម ?"

ព្រះអង្គម្ចាស់ក្សត្រីសួរដោយទឹកមុខមិនដឹងខ្យល់អី។

"រៀមមកប្រាប់ ហ្ស៊ីកា ថា កុំទៅរញ៉េរញ៉ៃនឹងអង្គរក្សរបស់រៀម កុំប៉ះពាល់នាងទៀតជាដាច់ខាត...មិនអីចឹង..."

"មិនអីចឹងស្អីព្រះរៀម គ្រាន់តែជាអង្គរក្សគ្មានតម្លៃម្នាក់ ព្រះរៀមដល់ថ្នាក់យាងមកទីនេះទាំងអធ្រាត្រផង" ព្រះអង្គម្ចាស់ក្សត្រីថាឲ្យវិញ។

"អង្គរក្សគ្មានតម្លៃម្នាក់នោះ ជួយជីវិតរៀមពីរដងហើយ បើនាងកើតស្អីនោះ ឬបាត់ខ្លួនដោយគ្មានស្លាកស្នាម...រៀមនឹងឈប់ជួយហ្ស៊ីកា...គ្រប់យ៉ាងអញ្ជើញទ្រង់ចាត់ការដោយខ្លួនឯង ...រៀមនឹងលែងរវេរវល់ទៀត"

និយាយចប់ មិខាអ៊ីល ក៏បែរខ្លួនដើរចេញទៅ ទុកឲ្យ ហ្ស៊ីកា តាមមើលដោយភាពស្រឡាំងកាំង ហើយបន្ទាប់មកក៏តន្ត្រំជើងព្រោះមិនពេញព្រះទ័យ។



# ៧

ព្រឹកថ្ងៃបន្ទាប់ព្រះអង្គម្ចាស់ក្សត្រីយាងត្រឡប់ទៅសណ្ឋាគារភ្លាម ដោយមិនសោយព្រះក្រយា ជាការប្រឆាំងនឹងបងប្រុសឲ្យដឹងណាណី ដោយ ហ៊ុលសែន ជាអ្នកមកខ្សឹបប្រាប់ព្រះអង្គម្ចាស់នៅក្នុងបន្ទប់ពេលគេភ្ញាក់។

"ឯងបណ្តោយឲ្យវាចូលមកយក យ្យ...ម៉េចក៏ឯងធ្វើបែបហ្នឹង ហ៊ុលសែន!"

ហ្សុីក សួរប្រធានក្រុមអង្គរក្សរបស់ខ្លួនដោយការសង្ស័យ ដោយនៅតែមិនពេញចិត្តរហូតដល់នាទីនេះ។

"គេថានឹងបញ្ជូននាងទៅក្រុមហ៊ុនឃ្វីនវិញដោយមិនឲ្យមានរបួសមួយសរសៃសក់ ទើបខ្ញុំព្រម"

"ចុះបើនាងស្លាប់...តើឯងយកអ្នកណាមកឲ្យខ្ញុំ!"

សំណួរដែលពោរពេញទៅដោយកំហឹងនោះ ធ្វើឲ្យ ហ៊ុលសែន និយាយមិនចេញ។

"សុំទោសទាន...ពួកខ្ញុំនឹងមិនព្រមឲ្យរឿងបែបនេះកើតឡើងទៀត



ទេ"

ពាក្យសុំទោសនិងការធានាដោយទឹកមុខមាំនោះ ធ្វើឲ្យ មិខាអុីល ដកដង្ហើមធំ។

"ហើយពេលនេះនាងនៅឯណា?"

"រង់ចាំនៅមុខបន្ទប់"

"ថ្ងៃនេះមានមនុស្សចូលច្រើន ស្អែកថ្ងៃកម្មវិធី ត្រូវប្រុងប្រយ័ត្នឲ្យបានល្អ កុំឲ្យអ្នកណាសម្រុកចូលមកបានទៀត"

"បាទទាន" ហ៊ុលសែន ទទួលបញ្ជាហើយក៏ដើរចេញទៅ។

ពេញមួយថ្ងៃនោះ ហេឃ្យ មិនព្រមចូលទៅជិតព្រះអង្គម្ចាស់ទៀតរហូតដល់ពេលល្ងាច ដានៀល ក៏យកប្រអប់ជាច្រើនមកឲ្យនាង។

"ស្អីហ្នឹង?"

"យកទៅមើលទៅ" ដានៀល ប្រាប់ហើយក៏ដើរទៅឈរឲ្យឆ្ងាយទុកឲ្យនាងបើកប្រអប់មើលដោយការសង្ស័យ ហើយក៏ប៉ប្រិចភ្នែកដោយការងឿងឆ្ងល់នៅវេលាបន្ទាប់។

មែនហើយ...វាជាសម្លៀកបំពាក់ដែលត្រូវពាក់ចូលរួមក្នុងកម្មវិធីរាត្រីថ្ងៃស្អែកនេះឯង ត្រូវចេញម៉ូដនិងកាត់ដេរយ៉ាងប្រណីត ធ្វើឲ្យនាងសម្លឹងមើលវាដោយភាពស្រឡាំកាំង។

"ច្បាស់ជាស្អាត បើនាងពាក់..." ហ្វាឌែល គាំទ្រ និងមើលមកដោយចង់ឃើញនាងពាក់វានៅពេលនេះ។

"មិនបានទេ បើមានហេតុការណ៍កើតឡើង ខ្ញុំរត់ដេញចាប់ពួកនោះម៉េចនឹងទាន់ទៅ"

"យើងត្រូវការឲ្យនាងមើលថៃ ហ្សុីក នៅក្នុងកម្មវិធីជំនួស ហ៊ុលសែន"



"មិនបានទេ"

នាងនៅតែបញ្ជាក់ និងមិនផ្លាស់ប្តូរខ្លួនឯងតាមការគាំទ្រទាំងនោះ ហើយលើកប្រអប់សម្លៀកបំពាក់ស្បែកជើងទៅទុក។

**រាត្រីសំខាន់មកដល់ ហេឃ្យូ ពាក់អាវគ្រ័រហេ្សពណ៌ស សំពត់ខ្មៅ** សម្រុងត្រឹមជង្គង់ ផាត់មុខធ្វើសក់សមរម្យ ទុកអាវុធតាមកន្លែងដែលវាគួរនៅដោយគ្មានអ្នកណាឃើញ ហើយចេញមកឈរចាំនៅមុខបន្ទប់របស់ ហ្សុីក ជាមួយអង្គរក្សដទៃទៀត។

"អ៊ា...ម៉េចក៏មិនពាក់ឈុតស្អាត?"

ហ៊ុលសែន រាក់ទាក់មុនគេ ឯអ្នកឯទៀតក៏ធ្វើតាម រហូតដល់ មិខាអ៊ីល ដើរចេញពីបន្ទប់ប្រជុំដោយឈុតប្រចាំជាតិពណ៌សសុទ្ធ និងកងរឹតពណ៌ខ្មៅឆ្លាស់មាសសរសៃតូចៗ ដែលលេចធ្លោដោយរូបសម្បត្តិខាងក្រៅពិបាកនឹងរកគូប្រជែង។

ត្រឹមឃើញនាងប៉ុណ្ណោះ កែវភ្នែកមុតស្រួចដែលសម្លឹងមើលមក ក៏ងាកចេញ ធ្វើដូចមិនចាប់អារម្មណ៍ មិនរាក់ទាក់ ក្រៅពីដើរនាំមុខដោយមិនមាត់មិនក ដោយមានអង្គរក្សទាំងអស់តាមហែហម។

"នាងរករឿងដាក់ខ្លួន"

ហ៊ុលសែន ខ្សឹបប្រាប់ ហើយដើរទៅមុខយ៉ាងលឿន ធ្វើឲ្យនាងឈ្ងោកមើលខ្លួន ប៉ុន្តែនៅតែអះអាងថាខ្លួនឯងតែងខ្លួនសមរម្យសម្រាប់កម្មវិធីហើយ។

នាងដើរតាម ហ្សុីក គ្រប់ជំហាន តាំងពីឈរទទួលភ្ញៀវរាប់មិនអស់ដែលភ្ញៀវនីមួយៗតុបតែងខ្លួនស្អាតថ្លៃថ្នូរ ដោយភាគច្រើនជាឈុតសកលមិនសូវមានឈុតប្រចាំជាតិ រហូតដល់ ហ៊ុលសែន ស្រវាយកសាំប៉ាញមួយកែវត្រួតពិនិត្យភ្លាមដោយវិធីបុរាណ គឺប្រើម្ជុលប្រាក់ ហើយហុចឲ្យនាង។

"របស់ ហ្សុីក" គេខ្សឹបប្រាប់ ខណៈដែលនាងមានទឹកមុខសង្ស័យ "នេះហើយរបស់ដែលចូលចិត្តជាពិសេស មិនផឹកស្អីផ្សេងក្រៅពីសាំប៉ាញនៅគ្រប់ករណី"

ហេឃ្យូ ធ្វើមុខដូចចង់បង្អាប់ តែក៏យកកែវសាំប៉ាញនោះទៅហុចឲ្យ។

ព្រះអង្គម្ចាស់សង្ហាក្រឡេកមើលនាងមួយភ្លែត ហើយមើលសាំប៉ាញនៅក្នុងដៃ មុននឹងទទួលយកមកជិបបន្តិច។

នាងគេចពីខ្សែភ្នែកមុតស្រួចដែលមើលនោះ មើលទៅក្រោយខ្នងដើម្បីឲ្យបេះដូងដែលលោតញាប់វាស្ងប់ ហើយសួរខ្លួនឯងថានាងកើតអីគ្រាន់តែត្រូវមើលបន្តិចបន្តួចសោះ។

ហេឃ្យូ មើលភ្ញៀវទាំងស្រីទាំងប្រុសដែលផ្លាស់ប្តូរគ្នាមករាក់ទាក់ និងនិយាយជាមួយ ហ្សុីក រូបសង្ហា រហូតដល់ព្រះអង្គម្ចាស់ក្សត្រីស្តេចយាង។

នៅក្នុងកម្មវិធីគ្មានត្រែគ្មានភ្លេងដូចនៅក្នុងព្រះរាជវាំង ប៉ុន្តែវត្តមានរបស់ទាហានអង្គរក្សនៅក្នុងឯកសណ្ឋានទាក់ទាញភ្នែក ដែលចូលមកមុន ធ្វើឲ្យគ្រប់គ្នាងាកទៅមើលដោយស្វ័យប្រវត្ត ទាមទារការចាប់អារម្មណ៍ពីមនុស្សម្នាក់ទៅមនុស្សម្នាក់នៅក្នុងកម្មវិធីទាំងមូល។

មិខាអ៊ីល ដើរទៅឱនគំនាប់ព្រះអង្គម្ចាស់ក្សត្រី ហើយលូកដៃទៅរក ដើម្បីឲ្យទ្រង់ចាប់ដៃរបស់គេ នាំចូលក្នុងកម្មវិធីឲ្យសមនឹងកិត្តិយសឲ្យបំភ្លេចទៅថាយប់ថ្ងៃមុនទើបតែងរង៉ក់ដាក់គ្នា ដោយគ្មានអ្នកណាព្រមចាញ់អ្នកណា។





Scanned by CamScanner

ទាំងអង្គរក្សរបស់ព្រះអង្គម្ចាស់ក្សត្រី និងអង្គរក្សរបស់ព្រះអង្គម្ចាស់សុទ្ធតែនាំគ្នាធ្វើការតាមតួនាទី ធ្វើជាភ្នែកជាច្រមុះជាអ្នកការពារចៅហ្វាយនាយពេញកម្មវិធីជប់លៀងរបស់ស្ថានទូតនៅរាត្រីនេះ។

ព្រះអង្គម្ចាស់នាំព្រះអង្គម្ចាស់ក្សត្រីទៅជួបអង្គទូតសំខាន់ទាល់តែគ្រប់គ្នា ណែនាំឲ្យទ្រង់បានស្គាល់អ្នកទាំងនោះតាមការចាំបាច់ ថែមទាំងអញ្ជើញឲ្យទៅចូលរួមពិធីរាជាពិសេក ដែលនឹងរៀបចំឡើងនៅប៉ុន្មានថ្ងៃខាងមុខ ដែលនឹងត្រូវអញ្ជើញនិងប្រកាសជាលាយលក្ខណ៍អក្សរនៅវេលាបន្ទាប់។

ខណៈដែលកំពុងដើរតាម ជាញឹកញាប់ដែល ហេយ្យូ ចាប់បានថាព្រះអង្គម្ចាស់ក្សត្រីតែងតែដៀងព្រះនេត្រទតនាង។ ទោះដឹងថាទ្រង់មិនពេញព្រះទ័យ ប៉ុន្តែនាងមិនអាចនៅឆ្ងាយពីព្រះអង្គម្ចាស់បាន ព្រោះវាជាតួនាទី ដែលពេលនោះ ហ៊ុលសែន ដកថយទៅឆ្ងាយទៅហើយ ប៉ុន្តែពេលនាងងាកទៅឃើញរបស់មួយដោយចៃដន្យ នោះគឺស្រមោលចុងស្រួចរបស់កាំបិត ដូច្នេះហើយលឿនដូចភ្នែកឃើញ នាងក៏ស្រវាចាប់ដៃអ្នករត់តុប្រចាប់ខ្លាំងៗ មិនឲ្យចុងកាំបិតនោះទៅដល់ខ្លួនរបស់ ហ្ស៊ីក ហើយថយកែងអុកចង្ការបស់វាខ្លាំងៗ។

សកម្មភាពរបស់នាងកើតឡើងលឿនខ្លាំងណាស់ ពេលនោះ ហ៊ុលសែន និងអ្នកឯទៀតក៏ស្ទុះមកជួយ ទើបត្រូវគេចពីចុងកាំបិតដែលតាមមកពីរបីទៀត ដោយមិនគួរឲ្យជឿថាស្ថិតនៅក្រោមការការពារយ៉ាងតឹងរ៉ឹង នៅតែមានការព្យាយាមលបប្រហារបែបនេះកើតឡើងទៀត។

បន្ទាប់ពីភាពចលាចលនោះស្ងប់ ភ្ញៀវទាំងឡាយក៏ត្រឡប់ទៅវិញព្រោះខ្លាចថាខ្លួនឯងអសុវត្ថិភាព ទើបពិធីជប់លៀងដ៏អធិកអធមត្រូវបានបញ្ចប់នៅក្នុងពេលដ៏ខ្លី។

"មានអីកើតឡើង ព្រះរៀម?" ព្រះអង្គម្ចាស់ក្សត្រីត្រាស់សួរភ្លាមពេលចូលមកក្នុងបន្ទប់ធ្វើការរបស់ មិខាអ៊ីល។

"គ្រាន់តែជាការលបសម្លាប់ធម្មតា"

"លើកទីបីហើយ...មែនទេ ព្រះរៀមប្រាប់ថាស្រីម្នាក់នោះជួយព្រះរៀមពីរដងហើយ លើកនេះគឺលើកទីបី នៅក្នុងពេលមិនប៉ុន្មានថ្ងៃ"

សវនីយ៍របស់ទ្រង់ ដូចចង់ប្រាប់ថាទើបតែដឹងរឿងគ្រោះថ្នាក់ដែលបងប្រុសម្តាយទីទៃកំពុងប្រឈម។

ពេលព្រះអង្គម្ចាស់ស្ងប់ស្ងាត់ ទើបព្រះអង្គម្ចាស់ក្សត្រីដើរសំដៅទ្វារ ហើយហៅអង្គរក្សទាំងអស់ចូលបន្ទប់ភ្លាម។

"ហ៊ុលសែន...រឿងលបសម្លាប់នេះកើតឡើងយូរហើយឬនៅ?"

ទ្រង់សួរដោយព្រះភក្ត្រតានតឹង។

"កើតឡើងយូរហើយ ក្រាបទូល...កាលមុនកើតឡើងយូរៗម្តងពេលយើងភ្លេចខ្លួន តែឥឡូវនេះញឹកញាប់ណាស់"

"នាងឃើញវាជាលើកទីបីហើយ?" ព្រះអង្គម្ចាស់ក្សត្រីងាកទៅសួរ ហេយ្យូ ទាំងមិនចង់សួរអីមួយម៉ាត់។

"ព្រះមេ...មានការលបប្រហារបែបប្រចាំថ្ងៃតែម្តង"

"អីចឹងពេលនេះព្រះរៀមកំពុងគ្រោះថ្នាក់"

"ព្រះមេ...គ្រប់ជំហាន"

ចម្លើយដ៏ច្បាស់លាស់របស់នាងក្រមុំ ធ្វើឲ្យគ្រប់គ្នាដកដង្ហើមធំ។

"នេះជារឿងស្អីហ្នឹង? ប្រាប់មកព្រះរៀម"

សំណួររបស់ព្រះអង្គម្ចាស់ក្សត្រីគ្មានចម្លើយ ពេល មិខាអ៊ីល មិនព្រមបើកមាត់។



"ព្រះរៀមក៏ដឹងថាអនុជល្ងង់ អនុជរកចម្លើយដោយខ្លួនឯងមិន

បាន បើព្រះរៀមមិនប្រាប់"

ព្រះអង្គម្ចាស់ក្សត្រីមានសវនីយ៍ដោយព្រះទ័យតានតឹង និងព្រួយបារម្ភជាខ្លាំងនឹងការលបប្រហារនេះ។

"នេះជាមូលហេតុដែលរៀមត្រូវចាត់ការឲ្យទ្រង់រាជាភិសេកឆាប់ៗ នឹងមានទំនួលខុសត្រូវនោះអី"

ហ្ស៊ីក តប ទាំងដែលមិនចង់ឲ្យអ្នកណាបានដឹងរឿងនេះ ដែលចម្លើយនេះ ធ្វើឲ្យព្រះអង្គម្ចាស់ក្សត្រីស្ងប់ស្ងាត់យ៉ាងយូរ។

"បើអនុជរាជាភិសេក តើព្រះរៀមនឹងមានសុវត្ថិភាពឬ?"

ព្រះអង្គម្ចាស់ក្សត្រីត្រាស់សួរដោយការសង្ស័យ។

"ទ្រង់នឹងបានទទួលខុសត្រូវលើការងារទាំងអស់ រៀមអស់តួនាទីអស់អ្នកតាមសម្លាប់"

និយាយហើយ ហ្ស៊ីក ក៏ស្ងប់ស្ងាត់។

"អនុជមិនយល់"

"បន្តិចទៀតនឹងយល់ ត្រៀមខ្លួនត្រៀមចិត្តឲ្យបានល្អបើធ្វើបានដោយមិនយកពេលទៅដើរលេង រៀមចង់ឲ្យទ្រង់ទទួលការងារបន្ទាប់ពីរៀមមួយថ្ងៃមួយល្អជាង ពេលរាជាភិសេកហើយនឹងធ្វើបន្តបាន ដោយមិនបាច់មកសួរនាំទៀត"

សម្តីរបស់បងប្រុសដែលមិនធ្លាប់និយាយអីឲ្យដឹង ធ្វើឲ្យព្រះអង្គម្ចាស់ក្សត្រីយល់។

"ការរាជាភិសេករបស់អនុជ នឹងជួយព្រះរៀមបានឬ?"

"កាន់តែលឿនគឺកាន់តែល្អ"

ចម្លើយនេះច្បាស់លាស់ណាស់។

"ចុះហេតុអីបានជាព្រះរៀមមិនធ្លាប់ប្រាប់ ហេតុអី?"

"ប្រាប់ច្រើនដងហើយ តែទ្រង់មិនធ្លាប់ស្តាប់ ទ្រង់ទំនើងមិនធ្លាប់ស្តាប់អ្នកណា"

ហ្ស៊ីក និយាយពេល ហ្ស៊ីកា យាងមកឈរចំពោះមុខ និងទតព្រះនេត្រមើលបុរសដែលទ្រង់ជឿជាក់មករហូត។

"អូខេ ព្រះរៀម ចាប់តាំងពីថ្ងៃស្អែកទៅ អនុជនឹងទទួលយកការងារទាំងអស់ពីទ្រង់"

ព្រះអង្គម្ចាស់ក្សត្រីប្រាប់បងប្រុស ហើយងាកទៅទតគ្រប់គ្នាដោយទត ហេយ្យូ ក្រោយគេ។

"អ៊ីចឹងយប់នេះអនុជស្នាក់នៅទីនេះ...ព្រះរៀមប្រហែលមិនថាអី"

"ទ្រង់មានសិទ្ធិប្រថាប់នៅទីណាក៏បាន" ហ្ស៊ីក តប។

"អរគុណព្រះរៀម ចាប់ពីថ្ងៃស្អែកទៅ ព្រះរៀម..."

ព្រះសវនីយ៍របស់អ្នកព្រះអង្គម្ចាស់ក្សត្រី ដូចចង់ប្រាប់គ្នា មិនមែនប្រាប់តែបងប្រុស មុននឹងយាងចេញពីបន្ទប់នោះ។

ពេលនោះគ្រប់គ្នាដកដង្ហើមធំ ហាក់ដូចលើកភ្នំចេញពីទ្រូងយ៉ាងអ៊ីចឹង។

ហេយ្យូងាកមើលព្រះអង្គម្ចាស់ម្តងទៀតដោយប្រសព្វនឹងកែវភ្នែកមុតស្រួចដែលមើលមកមុនទៅហើយ ខណៈដែលអ្នកឯទៀតដើរចេញពីបន្ទប់។

"ឈប់..."

នាងត្រូវហៅពេលដើរចេញក្រោយគេ ស្របពេលដែលព្រះអង្គម្ចាស់មកឈរនៅចំពោះមុខ។



"នាងមានកំហុស...រ៉ូបនោះខ្ញុំទិញឲ្យ ម៉េចមិនពាក់?"

"ខ្ញុំត្រូវធ្វើការ វាមិនសក្តិសមនឹងខ្ញុំទេ ទ្រង់យកទៅចែកឲ្យអ្នកផ្សេង

ទៅ"

"ហ៊ាស! នាងនិយាយថាខ្ញុំ ចែក ឬ?"

"ចាំ ប្រហែលចែកឲ្យគ្រប់គ្នាស្មើៗគ្នាមែនទេ...ចៃដន្យខ្ញុំមិនចូលចិត្តរបស់ចែក"

នាងតបហើយក៏បែរខ្លួនប្រុងដើរចេញ តែត្រូវចាប់ទាញដៃឲ្យងាកមកវិញដូចយប់នោះ។

"ចុះបើមិនចែក...បើទិញឲ្យនាងតែម្នាក់?"

សំណួរនិងពន្លឺភ្នែកនោះប្រាកដប្រជា ធ្វើឲ្យនាងត្រូវឆ្លើយតាមការគិត។

"មិនអាចទៅរួចទេ ព្រះអង្គម្ចាស់...មិនអាចទៅរួចទេ"

នាងតប ហើយបេះដៃគេចេញ បន្ទាប់មកក៏ដើរសំដៅទ្វារ។

"ម៉េចក៏មិនអាចទៅរួច?"

សំណួរចុងក្រោយ នាងបានឮ តែមិនព្រមងាកទៅឆ្លើយ ដោយធ្វើត្រចៀកប៉ោត ហើយពេលដើរផុតទ្វារក៏ទាញវាបិទ។

ហេយ្យុ ដកដង្ហើមធំ ពេលបញ្ជាក់ប្រាប់ខ្លួនឯងថាវាមិនអាចទៅរួចពិតមែន។

# ៨

ថ្ងៃបន្ទាប់មក ព្រះអង្គម្ចាស់ក្សត្រីក៏យាងមកបន្ទប់ព្រះរាជកិច្ចទាំងព្រឹក មន្ត្រីរត់មកប្រាប់អង្គរក្សនៅមុខបន្ទប់ ធ្វើឲ្យ ហ៊ុលសែន មានទឹកមុខមិនស្រួលភ្លាម ព្រោះគេមិនចូលចិត្តទៅដាស់ថៅហ្វាយ មិនថាករណីអីក៏ដោយ។

គេដឹងថាព្រះអង្គម្ចាស់ស្រេកសនឹងគ្រប់យ៉ាងនៅជុំវិញខ្លួន ទើបចង់ឲ្យបានសម្រាកខ្លះ ប៉ុន្តែគ្រប់គ្នាក៏ត្រូវបើកភ្នែកធំៗពេលទ្វារបន្ទប់ត្រូវបើកហើយ មិខាអ៊ុល ក៏ដើរចេញមក ដោយត្រៀមខ្លួនរួចរាល់សម្រាប់ការងារនៅថ្ងៃនេះ។

អ៊ីចឹងមានន័យថា គេភ្ញាក់ដំណាលនឹងគ្រប់គ្នាទេដឹងនៅថ្ងៃនេះទាំងដែលទើបតែឆ្លងផុតគ្រោះថ្នាក់វិះតែស្លាប់កាលពីយប់។

"ព្រះអង្គម្ចាស់ក្សត្រី ស្តេចយាងទាន" ហ៊ុលសែន រាយការណ៍។

"គេតេរមកប្រាប់ហើយ តោះ"

ព្រះអង្គម្ចាស់ប្រាប់កូនចៅ តែភ្នែកបែរជាសម្លឹងមើលមនុស្សស្រីដែលឈរមើលគេដោយមិនមាត់មិនក ហើយដើរចេញទៅ។



ខណៈដែលដើរតាមថៅហ្វាយ ហេយ្យូ ក៏ងាកទៅមើលមេផ្ទះម្នាក់ដែលដើរឡើងជណ្តើរល្មម។

នាងដើរហួសទៅហើយ ប៉ុន្តែមានអ្វីម៉្យាងទាញនាងឲ្យងាកទៅមើលវិញ ឃើញមេផ្ទះម្នាក់នោះដើរកាត់បន្ទប់របស់ ហ្សុីក ហើយឈប់នៅត្រង់នោះ ប៉ុន្តែមួយភ្លែតក្រោយមកក៏ដើរហួស ពេលឃើញថាមានអ្នកយាមពីរនាក់នៅមុខបន្ទប់។

ពេលបត់នៅត្រង់កាច់ជ្រុងបន្ទប់ នាងក៏ឈប់ដើរ ដោយឲ្យសញ្ញា ហ៊ុលសែន ទៅមុន ចំណែកខ្លួនឯងក៏លាក់ខ្លួននៅត្រង់នោះ យូរតែម្តងទម្រាំតែមេផ្ទះម្នាក់នោះដើរមកវិញ ហើយចូលទៅសម្អាតបន្ទប់ដោយអ្នកយាមបើកទ្វារឲ្យ។

នាងឈរនៅត្រង់នោះមួយដង្ហើមទៀត ទើបដើរចេញមកដោយការរិះគិត រហូតដល់បន្ទប់ធ្វើការនៅខាងក្រោម ហើយពេលឃើញ ដានៀល ទើបសួរគេ។

"តាមធម្មតា មេផ្ទះម្នាក់ណាចូលសម្អាតបន្ទប់របស់ ហ្សុីក ?"

"ជាមេផ្ទះជនជាតិកូរ៉េខាងត្បូង ប្រើការយូរហើយ មិនធ្លាប់មានបញ្ហា" ដានៀល តប និងមើលមុខនាងដោយការចាប់អារម្មណ៍ភ្លាម "មានអីឬ ?"

"ចង់បានប្រវត្តិរូបរបស់មេផ្ទះទាំងអស់"

"អូខេ" ដានៀល ងក់ក្បាល ហើយយកឯកសារពាក់ព័ន្ធនឹងបុគ្គលិកទាំងអស់មកហុចឲ្យនាង។

ហេយ្យូ ចាប់អារម្មណ៍ប្រវត្តិអ្នកបើកឡានក៏បើកមើលមុនគេ បន្ទាប់មកមើលប្រវត្តិរបស់មេផ្ទះ។

"ម្នាក់ណាដែលបោសសម្អាតបន្ទប់ ហ្សុីក ជាប្រចាំ ?" នាងសួរ



ដានៀល។

"ម្នាក់នេះ មេផ្ទះ អ៊ូ"

នាងក្រម៉ុចងចិញ្ចើមមើលរូបមេផ្ទះដែលមាននាមត្រកូលថា អ៊ូ ហើយគិតទៅដល់មេផ្ទះដែលឃើញអម្បាញ់មិញ។

មេផ្ទះ អ៊ូ មានរាងជាត់ជាងអ្នកដែលនាងឃើញ ខណៈដែលមេផ្ទះម្នាក់នោះមើលទៅរហ័សរហួន រឹងមាំជាងមេផ្ទះ អ៊ូ ទៅទៀត។

"ហើយថ្ងៃនេះមេផ្ទះ អ៊ូ មកឬអត់ ?"

នាងសួរ ព្រោះដឹងថាពេលចប់ម៉ោងធ្វើការ គ្រប់គ្នាក៏ត្រូវចេញពីស្ថានទូត មានតែវេនយាមដែលចាំបាច់និងសំខាន់ប៉ុណ្ណោះ ដែលនឹងត្រូវអនុញ្ញាតឲ្យនៅបន្ត។

ដានៀល ទាញទូរសព្ទនៅលើតុមកឆែកមើលភ្លាម ហើយងាកមកប្រាប់។

"អ៊ុំស្រី អ៊ូ ឈឺពីរថ្ងៃហើយ តែមានអ្នកមកជំនួស"

"ខ្ញុំទៅមើលបន្ទប់ ហ្សុីក សិន"

ពេលនោះ ហ៊ុលសែន ចេញមកល្មម ពេលឃើញអាកប្បកិរិយារបស់នាងក៏សួរនាំ។

"ចង់ទៅណា ?"

"នាងសង្ស័យអ្នកបោសសម្អាត" ដានៀល តបជំនួស ធ្វើឲ្យអ្នកសួរចងចិញ្ចើម។

"អាចគ្មានអីក៏ថាបាន"

"សុំទៅមើលសិនល្អជាង"

និយាយហើយនាងក៏ដើរសំដៅបន្ទប់របស់ ហ្សុីក ជាបន្ទាន់។ ពេលទៅដល់ឃើញសល់តែអ្នកយាមម្នាក់ក៏សួរនាំ។



"ម្នាក់ទៀតទៅណា ?"

"ខ្ញុំសង្ស័យគេឈឺពោះ រត់ទៅរត់មកពីរដងហើយ"

"ចុះលោក ?"

"ខ្ញុំ...មិនកើតអីទេ"

ហេយ្យូ មិនសួរនាំបន្ត តែបើកទ្វារចូលបន្ទប់ភ្លាម។

ផ្នែកខាងក្រៅជាបន្ទប់ទទួលភ្ញៀវ តុបតែងយ៉ាងវិចិត្រ គ្រឿងសង្ហារឹមថ្លៃៗ តែមិនប្រណិតដូចនៅវាជដំណាក់ បន្ទាប់មកក៏មើលទៅតុអាហារ កន្លែងអង្គុយលេង បន្ទាប់មកទៀតក៏ងាកទៅមើលបន្ទប់ដេកធំដែលមិនធ្លាប់ចូល។

នាងដើរលបៗដោយការប្រុងប្រយ័ត្ន មិនឲ្យអ្នកនៅខាងក្នុងដឹងខ្លួន ហើយដើរចូលបន្ទប់ទឹកនៅខាងក្នុង ឃើញមេផ្ទះកំពុងតែធ្វើអីទៅលើឧបករណ៍ក៏មិនដឹង តែដែលច្បាស់ មេផ្ទះម្នាក់នោះមិនមែនមេផ្ទះ អូ។

ពេលឃើញនាង មេផ្ទះម្នាក់នោះក៏ផ្អាកសកម្មភាពភ្លាម ហើយងាកមកមើលនាងដោយខ្សែភ្នែកដូចមិនមែនមេផ្ទះ ឬអ្នកធ្វើការងារផ្ទះអីបន្តិច ដែលនាងមើលមិនខុស ពេលម្នាក់នោះលោតមករកលឿនដូចព្យុះលឿនជាងមេផ្ទះធម្មតាធ្វើបានទៅទៀត។

ស្រីម្នាក់នោះស្រវាចាប់ករបស់ ហេយ្យូ ដោយដៃម្ខាងទៀតទាញកាំបិតរ៉ឺស័រចេញពីហោប៉ៅអាវការពារប្រឡាក់ ដែល ហេយ្យូ ដឹងថាកាំបិតនោះវាមិនមែនជាកាំបិតធម្មតា ប៉ុន្តែមុនពេលចុងរបស់វាប៉ះសាច់របស់នាង នាងក៏ស្រវាចាប់ដៃម្នាក់នោះទាញឲ្យផុតពីខ្លួន ដោយកម្លាំងដែលខ្លាំងជាង ហើយក៏ដឹងថាស្រីម្នាក់នេះមិនមែនជាមេផ្ទះ ព្រោះកម្លាំងដៃដែលច្របាច់កនោះឯង ដៃដែលកាន់កាំបិតក៏រឹង មិនព្រមលែង ធ្វើឲ្យនាងលើកជើងអុកចុងជើងរបស់ស្រីម្នាក់នោះ ដោយស្បែកជើងកែងរឹងមួយទំហឹង ទើបអាចបង្វែរចុងកាំបិតចេញផុតបានបន្តិច តាមដោយការលើកម្រាមដៃពីរចាក់ភ្នែកទាំងសងខាង ធ្វើឲ្យដៃរបស់ម្នាក់នោះរសាយពីករបស់នាងដោយស្វ័យប្រវត្ត ជាឱកាសឲ្យនាងប្រើកម្លាំងទាំងអស់ដែលមាន សង្កត់ចុងកាំបិតដែលបែរទៅរកដងខ្លួនរបស់ម្នាក់នោះ មុតកប់ដងតែម្តង។

ហេយ្យូ ចាប់ដៃមេផ្ទះក្លែងក្លាយទាញចុងកាំបិតចេញមកវិញយឺតៗ ហើយរង់ចាំទាល់តែម្នាក់នោះដួលខ្ពោក។

ពេលនោះ ហ្វាឌែល ក៏លេចមុខមកល្មម គេមើលអ្នកដែលដេកស្តូកស្តឹងក្នុងថ្លុកឈាម ហើយងាកទៅមើលម៉ាស៊ីនទឹកក្តៅដែលត្រូវដោះចោល និងបន្ទាប់ពីងាកមកមើលនាង គេក៏ត្រួតពិនិត្យចរន្តអគ្គិសនីទាំងអស់នៅក្នុងបន្ទប់ទឹក។

អ្នកយាមនៅមុខបន្ទប់ត្រូវហៅឲ្យមកមើលសាកសពនោះ និងឃើញថាវាមិនមែនមនុស្សស្រី ដែលចម្លើយដ៏ច្បាស់លាស់នោះ ធ្វើឲ្យពួកគេងាកមើលមុខគ្នាតែម្តង។

**រឿងទាំងអស់ដឹងដល់ត្រចៀក មិខាអ៊ីល នៅវេលាបន្ទាប់។** គេមិនបានចូលមកមើលដោយខ្លួនឯង តែបញ្ជូន ដានៀល មក ហើយហៅ ហេយ្យូ ទៅជួប។

នាងក្រមុំត្រឡប់មកប្រចាំការនៅមុខបន្ទប់នោះរហូតដល់អធ្រាត្រ ពិនិត្យមើលអាហារ និងភេសជ្ជៈគ្រប់ពេល ដោយមិនមើលរំលងស្អីទាំងអស់។

ហ៊ុលសែន ដើរចេញដើរចូលដូចលេងល្ខោន រហូតដល់ ដានៀល និង ហ្វាឌែល មកដល់ក៏ផ្លាស់វេនគ្នា ចំណែកនាងក្រមុំអង្គុយនៅកន្លែង



ដដែល ប៉ុន្តែនាងមិនបានអង្គុយដកដង្ហើមចោល ពេលនេះនាងកំពុងសិក្សាប្រវត្តិរបស់អ្នកបើកឡានឲ្យលម្អិត។

ក្នុងពេលដែលធ្វើឲ្យចាប់អារម្មណ៍ហើយ វាជាសញ្ញាតិញ្ញាណរបស់នាងដែលខំមិនព្រមលែង។

នាងមើលប្រវត្តិអ្នកបើកឡានយ៉ាងលម្អិត ហើយដាក់ឯកសារចុះដោយការរិះគិត ដោយមិនទាន់សម្រេចចិត្តបាន។

ពេលយប់ម៉ោងប្រាំបី ព្រះអង្គម្ចាស់ក្សត្រីយាងចេញទៅមុន ដោយត្រឡប់ទៅកាន់សណ្ឋាគារ។

"ចប់ទេថ្ងៃនេះ ?" នាងលួចសួរ ហ៊ុលសែន។

"បានតែបីក្រសួងធំៗសំខាន់ៗ"

"អ៊ីចឹងត្រូវចំណាយពេលថ្ងៃស្អែកទៀត"

"បានឮថាលែងមកហើយ រហូតដល់ស្តេចយាងត្រឡប់ទៅវាំងវិញ"

"ហ៊ឹម ?" នាងធ្វើមុខមិងម៉ាំង ហើយកាន់តែម៉ាំងពេលឃើញកាបូបរបស់របរប្រើប្រាស់របស់ មិខាអ៊ីល ដែល ហ្វាខែល យួរមក។

"ទៅណា ?"

"មិនដឹង" ហ្វាខែល តប ហើយយួរកាបូបចេញទៅ ឯដៃម្ខាងទៀតកាន់សម្លៀកបំពាក់។

នាងក្រមុំតាមមើល ហ្វាខែល ដែលដើរចូលបន្ទប់ធ្វើការនោះដោយមិនមាត់មិនក ហើយមិនយូរប៉ុន្មាន ព្រះអង្គម្ចាស់ក៏ដើរចេញពីបន្ទប់នោះដោយសម្លៀកបំពាក់ធម្មតា អាវយឺតខោជើងវែងសាមញ្ញៗដែលអង្គរក្សយកទៅឲ្យ។

ហេយ្យូ ដើរតាមគ្រប់គ្នាទាំងមិងម៉ាំង មិនដឹងថាទៅណា ដោយមិនយកឡានពីស្ថានទូតប្រើប្រាស់ តែនាំគ្នាដើរទៅដល់ផ្លូវធំ ហើយហៅតាក់ស៊ី។

"នាងត្រូវទៅជាមួយ ហ្សុីក" ហ៊ុលសែន ងាកមកប្រាប់ពេលដើរមកឈរក្បែរ។

"ទៅណា ?"

"ទៅផ្ទះរបស់នាង"

តាក់ស៊ីមួយគ្រឿងរត់មកចត មិខាអ៊ីល ចូលទៅមុន ដោយនាងក្រមុំបើកទ្វារខាងមុខប្រុងឡើង តែត្រូវ ហ៊ុលសែន ទាញមកក្រោយ និងបើកទ្វារ សង្កត់ក្បាលនាងឲ្យចូលទៅអង្គុយក្បែរចៅហ្វាយ ថែមទាំងបិទទ្វារឲ្យទៀតផង។

"ទៅណាដែរ ?" អ្នកបើកតាក់ស៊ីសួរ តែ មិនខាអ៊ីល មិនតប គេងាកទៅមើលមុខនាង។

"ទៅ..." នាងប្រាប់ពេលតាក់ស៊ីបើកចេញទៅបានមួយសន្ទុះ ហើយងាកមើលអ្នកអង្គុយក្បែរ ប្រសព្វភ្នែកគ្នាមួយភ្លែតក៏ងាកចេញ ពេលដឹងខ្លួនថាស៊ូនឹងពន្លឺភ្នែកនោះមិនបាន។

នាងដឹងដូចដែលគេដឹងថា ពេលនេះនៅស្ថានទូតមួយនោះ ព្រះអង្គម្ចាស់ មិខាអ៊ីល ពិបាកឈរជើង។

នាងនៅស្ងៀមដូចដែលគេនៅស្ងៀម រហូតមកដល់ពាក់កណ្តាលផ្លូវ មិនទាន់ចូលខេត្តជាប់ក្រុងធំផង នាងក៏ប្រាប់ឲ្យតាក់ស៊ីចត ហើយឡើងតាក់ស៊ីថ្មី សំដៅផ្ទះរបស់ខ្លួន។

អ្នកបើកតាក់ស៊ីយកវ៉ាលិសឲ្យ ហើយព្រះអង្គម្ចាស់ជាអ្នកអូសវ៉ាលិសនោះដើរចូលក្នុងផ្ទះ"



"ឯណាកូនសោ ?"

គេងាកទៅសួរពេលដើរមកដល់ទ្វាររបងទាបដែលនាងចាក់សោ ទើបនាងក្រមុំទាញកូនសោទាំងចង្កោមហុចឲ្យគេបើកទ្វារ ហើយដើរទៅបើកទ្វារផ្ទះ ដោយមានម្ចាស់ផ្ទះដើរតាម។

ការពិតវាជាតួនាទីរបស់នាង ប៉ុន្តែគេទាញវាយកទៅធ្វើដោយខ្លួនឯងទាំងអស់ សូម្បីតែដើរចូលមកក្នុងផ្ទះក៏ជាអ្នកទៅបើកភ្លើង។

ហេយ្យូ លើកដៃមើលនាឡិកា ឃើញថាពេលនេះម៉ោងពីររំលងអធ្រាត្រទៅហើយ ទើបបិទទ្វារដាក់គន្លឹះ ហើយជូនគេទៅមុខបន្ទប់។

មិខាអ៊ីល ចាក់សោរួចរាល់ក៏ហុចកូនសោឲ្យនាង តែមិនដើរចូលបន្ទប់ មួយសន្ទុះក្រោយមកទើបអ្នកកំលោះមើលនាង ហើយនិយាយ។

"មិនទាន់ចង់សម្រាក ចង់ចេញទៅអង្គុយខាងក្រៅ" គេប្រាប់ និងមើលនាងមិនដាក់ភ្នែក។

"មូសសែងល្មម និយាយគ្នានៅខាងក្នុងនេះហើយ"

នាងបែរខ្លួនដើរសំដៅកន្លែងទទួលភ្ញៀវនៅកណ្ដាលផ្ទះ ហើយដាក់គូថលើកម្រាលពូកទន់ល្មើយដែលកុម្ម៉ង់ធ្វើជាពិសេស ទើបអ្នកកំលោះដើរមកអង្គុយលើកម្រាលមួយទៀតដែលនៅក្បែរ។

"ថ្ងៃនេះប្រគល់ការងារក្រសួងធំៗឲ្យព្រះអង្គម្ចាស់ក្សត្រីទៅហើយ ហើយដេញឲ្យត្រឡប់ទៅផ្ទះវិញ ស្អែកប្រហែលទៅពេលរសៀល"

គេនិយាយរអ៊ូៗឲ្យស្ដាប់។



# ៩

"ការពិតខ្ញុំមិនគួរណាប្រាប់អីទេមែនទេ ប៉ុន្តែពេលឃើញមុខនាងហើយវាចង់និយាយឲ្យស្ដាប់គ្រប់រឿង ក៏មិនយល់ដែរថាម៉េចក៏វាទៅជាអីចឹង"

មិខាអ៊ីល និយាយតិចៗ ហើយអង្គុយឲ្យស្រួលបួល។

"ហ៊ុលសែន និយាយរឿងក្នុងបន្ទប់ទឹកឲ្យស្ដាប់ហើយ បើវាចូលទៅបានដល់ថ្នាក់ហ្នឹង ផ្ទះមួយហ្នឹងក៏លែងមានសុវត្ថិភាពដែរ" គេនិយាយរអ៊ូបន្ត "លើកនេះសល់តែការងារមួយ គឺពិធីរាជាភិសេកគ្រងរាជសម្បត្តិ ប៉ុន្តែវានៅតែមានបញ្ហា"

"បញ្ហាអី ?"

"ព្រះអង្គម្ចាស់ក្សត្រីប្រថាប់លើបល្ល័ងនោះបានពេញលេញទាល់តែមានគូអភិសេកបង្ហាញឲ្យប្រជាជនទូទាំងប្រទេស ព្រមទទួលថាជាមនុស្សធំអាចទទួលខុសត្រូវរឿងកិច្ចការស្រុកទេសនិងក្រុមគ្រួសារបាន"

"តើព្រះអង្គម្ចាស់ក្សត្រីមានសង្សារហើយឬនៅ ?"

"គ្មានទេ ហ្នឹងហើយជាបញ្ហា ទោះ..."



អ្នកកំលោះផ្អាកនិយាយ ទុកឲ្យអ្នកស្តាប់សង្ស័យ។ វិនាទីនេះ ព្រះអង្គម្ចាស់ មិខាអ៊ីល នឹកដល់ការចរចារបស់ខ្លួននិងព្រះអង្គម្ចាស់ក្សត្រី នៅក្នុងបន្ទប់ធ្វើការ។

'អនុជមិនយល់ បើព្រះរៀមរៀបការជាមួយអនុជ វាក៏ចប់រឿងនោះតាំងពីយូរហើយ ព្រះរៀមរវល់តែចាំឲ្យអនុជជួបអ្នកដែលពេញចិត្តតែមិនដែលឃើញជួបសោះ'

ព្រះអង្គម្ចាស់ក្សត្រីសួរពេលដើរមកឈរក្បែរគេដែលឈរនៅមាត់បង្អួចនិងគិតថាគួរធ្វើយ៉ាងណាដើម្បីឲ្យទ្រង់អាចគ្រប់គ្រងការងារក្រសួងសំខាន់ៗបានឆាប់។

ហើយពេល មិខាអ៊ីល ស្ងប់ស្ងាត់ព្រះអង្គម្ចាស់ក្សត្រីក៏សម្លឹងមើលបុរសដែលមិនធ្លាប់មាននរណាមានរូបរាងសង្ហា មានសតិបញ្ញា ស្មារតីខ្ពស់ដូចដោយការសោកស្តាយហើយក៏ថយទៅឈរឲ្យឆ្ងាយពេលឃើញខ្សែភ្នែកទទេស្អាតដែលមើលមក និងជាការមើលដោយមិនផ្លាស់ប្តូរជារៀងរហូតតាំងពីដំបូងម្ល៉េះ។

ខាអ៊ីល ផ្តួលខ្លួនដើម្បីងើយភ្លៅរបស់នាងក្រមុំ តែម្ចាស់ភ្លៅទាញខ្នើយផ្អែកមកទ្រាប់ទាន់។

"សង្ស័យអី?" ព្រះអង្គម្ចាស់សួរពេលឃើញទឹកមុខសង្ស័យរបស់ម្ចាស់ផ្ទះ។

"ទ្រង់...ចេះ អឺ...ដេកងើយភ្លៅមនុស្សស្រីដែរឬ?" នាងសួរដោយអត់មិនបាន។

"ថី? វាជារឿងធម្មតាតើ" គេតបហើយបិទភ្នែក។

"អឺ...មែន អី"

ហេយ្យូ ឱនមើល និងចង់សួរថាគេធ្លាប់ដេកងើយភ្លៅមនុស្សស្រីឬ

តែពេលឃើញគេស្ងប់ស្ងាត់ទើបបានត្រឹមតែមើលមិនដឹងថាធ្វើយ៉ាងណា ចង់ដាស់ឲ្យគេចូលទៅដេកក្នុងបន្ទប់ តែមានអ្វីម្យ៉ាងហាមមិនឲ្យនាងធ្វើ តែចង់បណ្តោយឲ្យគេដេកលក់បែបនេះពេញមួយយប់អីចឹងឬ។

នាងសួរខ្លួនឯង ហើយងាកទៅស្រវាយកខ្នើយផ្អែកមួយទៀតមកកល់.កហើយលង់លក់តាមដោយមិនដឹងខ្លួនព្រោះហត់នឿយនិងល្វើយពេញមួយថ្ងៃ។

នាងលង់លក់យូរប៉ុណ្ណាក៏មិនដឹង រហូតដល់គេប្រែខ្លួន ទើបបើកភ្នែកមើលទាំងងងុយពេញបន្ទុក ឃើញគេខិតចេញឆ្ងាយដោយទាញនាងឲ្យកើយដៃរបស់គេម្តង ដោយនាងមិនបានជំទាស់ ព្រោះងងុយពេញបន្ទុកទើបលង់លក់បន្ត។

ថ្ងៃបន្ទាប់

ពេលភ្ញាក់ដឹងខ្លួន បើកភ្នែកឡើង មិខាអ៊ីល ក៏ឃើញថាជិតដល់ថ្ងៃត្រង់ទៅហើយ។ គេងើបអង្គុយ ភ្នែកសម្លឹងរកមើលម្ចាស់ផ្ទះដោយស្វ័យប្រវត្តបន្ទាប់មកក៏ងើបដើរទៅឈរនៅមាត់ទ្វារកញ្ចក់ដែលអាចបើកចេញទៅឈរនៅរានហាលជាប់ទន្លេខាងក្រៅដែលម្តងនោះគេធ្លាប់ឃើញហេយ្យូ ឡើងពីជណ្តើរពីរបីកាំនោះដោយខោអាវទទឹកជោក។ ខោអាវដែលនាងពាក់ហែលទឹកនោះវារឹបនឹងដងខ្លួន បង្ហាញរាងបង្ហាញរៅ ធ្វើឲ្យគេមើលដោយអារម្មណ៍ភ្លើតភ្លើន និងជិតជាមជាប់ភ្នែករហូតមកដល់សព្វថ្ងៃ។

ថ្ងៃនេះក៏អីចឹងដែរ ខុសពីថ្ងៃមុនដែលនាងពាក់អាវឃ្លុំងូតទឹករួចរាល់ទៅហើយ តែថ្ងៃនេះនាងភ្លេច ឡើងមកពីទឹក គិតថារត់ចូលបន្ទប់ទឹក



Scanned by CamScanner

ដើម្បីផ្លាស់ខោអាវ ប៉ុន្តែពេលឡើងផុតជណ្ដើរ ឃើញអ្នកកំលោះបើកទ្វារកញ្ចក់មកឃើញមុនទៅហើយ កែវភ្នែកមុតស្រួចនោះមើលរាងកាយរបស់នាងដោយមិនក្រែងរអែងចិត្តអីបន្តិច មើលតាំងពីក្បាលដល់ចុងជើង ធ្វើឲ្យអ្នកត្រូវមើលអៀនទៅជាធ្វើអ្វីមិនត្រូវ។

"ភ្ញាក់ហើយឬ សុំផ្លាស់ខោអាវសិន"

នាងប្រុងដើរគេច ប៉ុន្តែត្រូវគេចាប់ដៃជាប់ដោយអចេតនា កែវភ្នែកមុតស្រួចនៅតែសម្លឹងស្មាសខ្ចី និងអូសចុះមកក្រោមដោយការពេញចិត្តដែលឃើញនាងនៅក្នុងសភាពបែបនេះ លើសពីមើលមនុស្សស្រីពាក់បីគីនីបិទបាំងសឹងតែមិនជិតទៅទៀត។

"ខ្ញុំចូលចិត្តនាងបែបនេះ"

"អុំ...ចូលចិត្តមើលស្រីៗពាក់ឈុតហែលទឹក" នាងថាឲ្យ ហើយងាកមុខចេញគេចពីខ្សែភ្នែកនោះ។

"មានអ្នកណាខ្លះមិនចូលចិត្ត" គេប្រកែកដោយមិនព្រមដកខ្សែភ្នែកចេញពីនាង។

"ចាំនាំទៅមើលអាងហែលទឹកម្ដុំនេះ មានឲ្យមើលគរគោក"

និយាយចប់នាងក៏ទាញដៃមកវិញ។

"ខ្ញុំមិនចង់មានន័យបែបហ្នឹង ខ្ញុំថា...ខ្ញុំចូលចិត្តនាងបែបនេះទៅវិញទេ"

មិខាអ៊ីល និយាយតិចៗក៏ពិតមែន តែសំឡេងបញ្ជាក់ពីការពិតធ្វើឲ្យអ្នកស្ដាប់ក្ដៅថ្ពាល់។ នាងមិនបានតបត តែប្រើវិធីស្ងាត់ស្ងៀម បេះដៃដែលចាប់ដៃរបស់ខ្លួនចេញ ហើយដើរចូលផ្ទះជាបន្ទាន់។ ខណៈនោះទូកលក់ម្ហូបចំណីរបស់លោកយាយក៏ឆ្លងកាត់ចុចស៊ីផ្លេ ឲ្យដឹងតាំងពីចម្ងាយ។

ខណៈដែលអ្នកកំលោះដើរចុះជណ្ដើរទៅនិយាយជាមួយអ្នកលក់ហេយ្យូ ក៏មីម្នាតែងខ្លួនដោយមិនសិតសក់ព្រោះវាទទឹកជោកទៅហើយ។

"ថ្ងៃនេះលោកយាយយកផ្លែឈើមកលក់ច្រើនមុខ"

គេយកផ្លែឈើដែលទិញពីលោកយាយមកតម្រៀប មិនបូករួមនំចំណីដែលទិញគ្រប់មុខ។

ពួកគេយួរម្ហូបចូលផ្ទះបាយ ពេលអ្នកលក់បើកទូកចេញទៅបាត់ហើយទទួលទានអាហារពេលព្រឹកនៅពេលថ្ងៃត្រង់នោះឯង លើកនេះមិខាអ៊ីល អង្គុយនៅក្បាលតុបែរមុខទៅរកទ្វារកញ្ចក់ដែលបើក មើលឃើញផ្ទៃទឹកជំល្វឹងល្វើយ។

"ខ្ញុំចូលចិត្តផ្ទះមួយនេះដល់ហើយ ចង់មកទីនេះទៀតពេលអស់ភារៈកិច្ច...នាងអនុញ្ញាតទេ ?"

"អូខេ...បើលោកចូលចិត្តនិងចង់មក..."

នាងឆ្លើយដោយមិនបានគិត និងងាកមកមើលគេដែលមើលមកនាងមុនទៅហើយ ខ្សែភ្នែកបែបនោះធ្វើឲ្យនាងដកដង្ហើមធំ និងសួរខ្លួនឯងថាតើធ្វើការជាមួយគេអាចរួចខ្លួនទេបើត្រូវមើលបែបនេះញឹកញាប់។

"ការពិតចង់ចេវទូកទៅផ្សារដូចថ្ងៃនោះទៀត ប៉ុន្តែមើលទៅផ្សារបិទទ្វារហើយទេដឹងថ្មើរណោះ"

"ទៅពេលល្ងាចក៏បានដែរ មានហាងអាហារមាត់ទឹកមួយកន្លែងគេលក់អាហារសមុទ្រ រសជាតិឆ្ងាញ់ណាស់ តម្លៃក៏មិនថ្លៃ"

"អ៊ីចឹងទៅពេលល្ងាច"

"លោកថាហ្ស៊ីកា ស្ដេចយាងត្រឡប់ទៅសាគីស្ពានពេលរសៀលមែនទេ ?" នាងប្ដូររឿង។



"មែនហើយ"

"ចុះបើលោកមិនទៅជាមួយ...តើទ្រង់ធ្វើការយ៉ាងម៉េច ?"

"ឲ្យរដ្ឋមន្ត្រីជួយ គេដឹងការងារច្បាស់អាចជួយបានច្រើន"

"ចុះក្រសួងផ្សេងគ្នា"

"ចាំមានបញ្ហាសឹមរួមក្បាលគ្នាកែខៃពេលក្រោយ"

"ចុះពិធីរាជាភិសេក ?"

"ត្រឡប់ទៅវិញមុនមួយអាទិត្យ ដាក់ផែនការឲ្យហ្ស៊ីកាទៅគ្រប់គ្រងការងារឲ្យហើយ"

"មើលទៅពេលទ្រង់ដឹងថាជីវិតរបស់លោកមានគ្រោះថ្នាក់ ទ្រង់ក៏ក្លាយជាមនុស្សធំនៅក្នុងពេលមួយថ្ងៃ"

"បើដឹងអ៊ីចឹង ឲ្យដឹងតាំងពីយូរម្ល៉េះ មិនបណ្តោយឲ្យដើរលេងខាតពេលឥតប្រយោជន៍"

"ទ្រង់បារម្ភពីបងប្រុស"

ប្រយោគនេះរបស់នាងធ្វើឲ្យ កែវភ្នែកមុតស្រួចដៀងមករកម្តងទៀតធ្វើឲ្យនាងមើលគេវិញដោយការសង្ស័យតែមិនបានទទួលចម្លើយអីក្រៅពីខ្សែភ្នែកនោះងាកទៅវិញ។

"ហ្ស៊ីកាត្រូវមានជីវិតរបស់ទ្រង់ផ្ទាល់ ចាប់ពីពេលនេះទៅ ខ្ញុំគ្រាន់តែជាអ្នកក្រៅប៉ុណ្ណោះ"

"ច្បាស់ហើយថាចង់នៅខាងក្រៅ ?" មិនដឹងថាអ្វីដែលធ្វើឲ្យនាងសួរបែបនេះ។

"គឺនៅខាងក្នុងហើយវាយ៉ាងម៉េច គេចពីស្លាប់គ្មានល្អសថ្ងៃ"

"ខ្ញុំមិនសូវយល់ថា បើលោកដកថយមកនៅខាងក្រៅហើយ មានសុវត្ថិភាព"

"ចាំតែមើលទៅ...ម្ដុំនេះ ក្រៅពីទូកលក់អាហារហើយនៅមានស្អី



ទៀតទេ ?"

"ចម្ការ...ចម្ការផ្លែឈើធំៗ ចង់ទៅទេ ?"

"អត់ទេ ចង់នៅស្ងាត់ៗ ស្រួលខ្លួនជាង ចង់ចុះទៅហែលទឹកលេងដូចនាង"

"អ៊ីចឹងចាំថ្ងៃជ្រេបន្តិចទៅ"

"ហែលទឹកជាមួយគ្នាទេ ?"

"ចាំ"

"ហើយត្រូវទៅសាគីស្ថានជាមួយគ្នាដែរ"

"ចាំ ?" លើកនេះនាងសួរដោយស្រឡាំងកាំងយូរគួរសម។

"ម៉ាដាម ប៉ែក មិនបានប្រាប់ឬថាទម្រាំតែឈប់ជួល"

"គឺ...ប្រាប់...តែមិនគិតថាបានទៅដល់ទីនោះ"

"ត្រូវតែទៅ គ្រប់យ៉ាងរៀបចំរួចហើយ...របស់សំខាន់ត្រូវប្រើមិនមែនបត់ទុក ព្រោះខ្ញុំមិនធ្លាប់ទិញខោអាវឲ្យមនុស្សស្រី...នាងជាស្រីដំបូង" គេនិយាយនិងសម្លឹងមើលមុខនាងមិនដាក់ភ្នែក។

"ឯកសណ្ឋានដែលខ្ញុំត្រូវប្រើត្រូវដូចអង្គរក្សដទៃទៀត"

"តែងខ្លួនស្អាតៗក៏ល្អដែរ នឹងបានមើលមិនដឹងថាជាអង្គរក្ស ខ្ញុំប្រុងប្រយ័ត្នខ្លួនបានល្អជាងពាក់ឯកសណ្ឋាន"

"មិនសូវទំនង ខោអាវវែងៗវាធ្វើឲ្យទើសទែង"

"មានអារម្មណ៍ទើសទែងឬ ?"

"ចាំ"

"អ៊ីចឹងស្លៀកពាក់ក្រៅម៉ោងធ្វើការ"

ហេឃ្សូ ចង់ដឹងថាមានពេលក្រៅម៉ោងធ្វើការនៅពេលណា តែនាងមិនមាត់មិន.ក ពេលទូកភេសជ្ជៈចុចស៊ីផ្លេឲ្យដឹងតាំងពីចម្ងាយ។





Scanned by CamScanner

"គេលក់អី ?"

អ្នកកំលោះសួរ ពេលដឹងហើយថាស៊ីផ្លែនេះជាសញ្ញាអី។

"ភេសជ្ជៈ.....មានគ្រប់យ៉ាងលើកលែងស្រាមានជាតិអាល់កុល"

"ល្អដែរ"

"ហើយនៅមានច្រើនមុខទៀត នំចំណី អ្នកដែលលក់នៅផ្សារពេលត្រឡប់មកផ្ទះវិញក៏ឆៀងចូលតាមផ្ទះអ្នកភូមិ"

"ខ្ញុំចង់មានជីវិតស្ងប់បែបនេះយូរហើយ" មិខាអ៊ីល សរុប ដោយភ្នែកសម្លឹងមើលនាង ហើយងាកទៅមើលផ្ទៃទឹក។

"តែអ្នកខ្លះបែរជាចូលចិត្តជីវិតប្រឈមនឹងគ្រោះថ្នាក់ដូចលោក"

"ប្រឈមនឹងសេចក្តីស្លាប់គ្រប់នាទីវាមិនសប្បាយទេ ហើយនាងគិតយ៉ាងម៉េចបានជាធ្វើការបែបនេះ ?"

នាងក្រមុំស្តាប់ហើយនៅស្ងៀម ព្រោះមិនដឹងថាឆ្លើយតបយ៉ាងណា។

"ចង់ស្លាប់តាមសង្សារឬយ៉ាងម៉េច ?"

"មិនមែនទេ ទំនាក់ទំនងខ្ញុំនិងគេមិនដល់ដំណាក់កាលនោះ"

"តែការស្លាប់របស់គេធ្វើឲ្យនាងចង់ស្លាប់តាមមែនទេ បានជាមកធ្វើការបែបនេះ"

"បានប្រាក់ច្រើន ហើយក៏ឆាប់ស្លាប់"

"អីចឹងសរុបទៅមិនខុស"

មិខាអ៊ីល និយាយនិងសម្លឹងមើលមុខនាងមិនដាក់ភ្នែក មិនព្រមងាកទៅណា ធ្វើឲ្យនាងដកដង្ហើមធំ។

# ១០

ពេលរសៀល ហេឃ្យូ ក៏ផ្លាស់ខោអាវជាអាវយឺតនិងខោខ្លីនាំគេហែលទឹក។

មិខាអ៊ីល ស្លៀកខោហែលទឹកតែមួយប៉ុណ្ណោះ និងមើលទៅមានការពេញចិត្តជាខ្លាំងដែលបានហែលទៅហែលមកនៅក្នុងទន្លេ។ យូររាប់ម៉ោងតែម្តង មិនព្រមឡើង ខណៈដែលនាងក្រមុំមានអារម្មណ៍ថាមិនស្រួលខ្លួនដែលត្រូវត្រាំទឹកយូរ។

នាងប្រាប់ខ្លួនឯងថាទ្រាំលែងបានហើយ ទើបថយឲ្យឆ្ងាយពីគេចង់ឡើងពីទឹក ប៉ុន្តែមិនទាន់ដល់កំពង់ផង ក៏ត្រូវប្រគៀវកាច់ពាក់កណ្តាលខ្លួន វាធ្វើឲ្យនាងលង់ទឹកស្ទើរតែភ្លាមៗ អស់កម្លាំងនឹងងាកទៅសុំជំនួសដែលនេះជាហេតុហួសវិស័យសម្រាប់នាង។

ប៉ុន្តែមុនពេល ហេឃ្យូ បានលិចទៅបាត់ក្នុងទឹក ក៏ត្រូវចាប់ទាញលឿនដូចព្យុះ នោះហើយដែលធ្វើឲ្យនាងឈ្លក់ទឹកឲ្យទាល់តែបាន។



នាងក្អកយ៉ុងៗ ខណៈដែលត្រូវអូសឡើងជណ្តើរទាំងគ្មានកម្លាំងកំហែង។

ហេយ្យ មិនធ្លាប់គិតថាខ្លួនឯងនឹងស្លាប់នៅក្នុងទឹករាក់បែបនេះ នេះបង្ហាញឲ្យដឹងថារាងកាយដែលគិតថារឹងមាំនៅពេលនេះវាចុះខ្សោយដោយមិនដឹងខ្លួន។

នាងត្រូវបីឡើងពីទឹក ដាក់លើក្តារក្រាលដោយការប្រុងប្រយ័ត្ន និងមិនអាចកម្រើកទៅណារួច ខណៈដែល មិខាអ៊ីល ដើរចូលទៅក្នុងផ្ទះ ហើយពេលចេញមកវិញ ក៏យកកន្សែងពោះគោដែលប្រើជំនួសភួយសម្រាប់គេ តែមិនបានប្រើមកដណ្តប់ឲ្យនាង ហើយទាញអាវយឺតនោះចេញភ្លាមលេងឲ្យ ហេយ្យ ស្រឡាំងកាំងធ្វើអ្វីមិនត្រូវក្រៅពីធ្វើភ្នែកព្រិចៗ ឯដៃនោះក៏លូកមករកខ្នង ធ្វើឲ្យនាងស្រវាចាប់.កអាវរបស់គេភ្លាម។

"នេះលោកចង់ធ្វើស្អី ?"

"ជួយនាងហ្នឹងអី នាងគិតថាខ្ញុំរំលោភនាងឬ"

ទាំងសំណួរដែលខ្សែភ្នែកដែលមើលមកធ្វើឲ្យនាងភាំងព្រលែងដៃពីចាប់.កអាវរបស់គេដោយស្វ័យប្រវត្ត បណ្តោយឲ្យគេដោះអាវក្នុងនិងទាញវាចេញពីខ្លួនគ្រវាត់ចោល បន្ទាប់មកអូសដៃមករកចង្កេះខោ។

"ម៉ាស្សាសាច់ដុំឲ្យខ្ញុំសិន" នាងឡូឡានិងរុញគេចេញខ្លាំងៗ។

"យកខោអាវទទឹកចេញសិន ឲ្យខ្លួនវាស្ងួតសិន"

គេប្រកែក និងទាញខោទាំងពីរជាន់ចេញពីខ្លួនរបស់នាងនៅក្រោមកន្សែងពោះគោនោះ ធ្វើឲ្យថ្ពាល់របស់នាងក្រមុំឡើងក្រហមព្រោះខ្មាសធ្វើអ្វីមិនត្រូវ បន្ទាប់មកក៏ត្រូវបីចូលផ្ទះ ដាក់លើកម្រាលអង្គុយលេង។

បន្ទាប់មកគេក៏ជូតខ្លួននាងឲ្យស្ងួតនឹងកន្សែងនោះ ទាល់តែខ្លួនប្រាណកក់ក្តៅ ទើបចាប់ចុងជើង ទាញសរសៃឲ្យ។

នាងឈឺដល់ថ្នាក់ពេបមាត់ មិនស្មានថាអ្នកដែលធ្លាប់នៅដែនទឹកត្រូវបណ្តោយឲ្យអ្នកនៅដែនខ្សាច់ជួយធ្វើសរសៃឲ្យ តែរឿងហ្នឹងវាកើតឡើងរួចទៅហើយ។

មិខាអ៊ីល មើលថែបានល្អ ទាល់តែរាងកាយនាងកក់ក្តៅ បបូរមាត់ឡើងក្រហមខុសពីអម្បាញ់មិញដែលស្លេកស្លាំង ឯចុងជើងនៅក្រោមបាតដៃរបស់គេក៏ឡើងក្តៅឧណ្ហៗ។

កំលុងពេលដែលត្រូវមើលថែ វាធ្វើឲ្យ ហេយ្យ មានអារម្មណ៍ថាស្រួលខ្លួនដល់ថ្នាក់ប្រាប់មិនត្រូវ ពេលជើងត្រូវម៉ាស្សាយូរ ក៏ចង់ដេក។

"យ៉ាងម៉េចដែរ ស្រួលខ្លួនហើយមែនទេ ?"

គេខិតមកជិតតាំងពីអង្កាល់ សំឡេងដែលឮជិតត្រចៀក ធ្វើឲ្យភ្នែកព្រឹមៗនោះប្រឹងបើក ហើយក៏បិទម្តងទៀតដោយមិនបដិសេធ រហូតដល់ត្រូវលើកបីចេញពីត្រង់នោះទៅដាក់លើកម្រាលពូកក្នុងបន្ទប់ដេក។

ពេលខ្នងប៉ះនឹងពូកនាងក៏បើកភ្នែកធំៗប៉ុន្តែវាយឺតពេលទៅហើយ ពេលបបូរមាត់ក្តៅឧណ្ហៗនោះតាមមកបិទបបូរមាត់របស់នាង។

នាងប្រឹងរុញស្មាធំទូលាយនោះចេញ តែមិនបានផលព្រោះត្រូវគេទ្រោបមកលើពាក់កណ្តាលខ្លួនទៅហើយ ដៃរឹងមាំទាំងពីរក៏ឱបជាប់ ឲ្យដើមទ្រូងនៃបនិត្យជិតគ្នា ស្របពេលដែលអណ្តាតជ្រែកចូលមកក្នុងប្រអប់មាត់ដើម្បីជួសជងយករសជាតិដែលលាក់នៅក្នុងនោះ។

មិនថា ហេយ្យ ពូកែខ្លាំងក្លាយ៉ាងណា មានញាណពិសេសដែលអាចជួយគេបានច្រើនដង ប៉ុន្តែនាងមិនធ្លាប់មានបទពិសោធន៍ផ្នែកនេះមិនថាឃ្លាមួយណាក៏ដោយ។

មិខាអ៊ីល ថើបនាងខ្លាំងៗ ហើយដកបបូរមាត់ចេញ ចងចិញ្ចើមដោយមិនចង់ជឿ។

"នេះ...មិនចេះថើបឬ ?"

នាងគ្រវីក្បាលនិងរើបម្រះខ្លាំងៗ លើកនេះជើងមិនរឹងទើបអាច





Scanned by CamScanner

មានកម្លាំងជួយខ្លួនឯងបាន ដោយភ្លេចទៅថានៅក្រោមភួយនោះ គ្មានអ្វីបិទបាំងខ្លួនប្រាណ។

ពេលលើកជើងបម្រុងអុកឆ្អឹងជំនីរបស់គេ ទើបនាងនឹកឃើញ ប៉ុន្តែមុននឹងបានធ្វើអ្វីបន្ត ក៏ត្រូវគេឱនមកថើបម្តងទៀតដែលពោរពេញដោយអារម្មណ៍ ដែលលើកនេះវាធ្វើឲ្យអ្នកត្រូវថើបទន់ខ្លួនល្មក អារម្មណ៍ហោះហើរទៅឆ្ងាយ មិនដឹងថាបាតដៃក្តៅឧណ្ហៗនោះកំពុងស្ទាបអង្អែលភ្លៅដែលគ្មានភួយបិទបាំងដោយការពេញចិត្ត ហើយអូសវាមកលើមកដល់ដើមទ្រូងននលគកនិងអូសទៅរកខ្នងខណៈដែលបបូរមាត់ដេញចុះតាំងពីចង្កា ក មុខមកដល់គល់ទ្រូងដែលមានភួយបិទបាំងប្របេះៗ បន្ទាប់មកក៏ងើយមកប្រសព្វភ្នែកជាមួយ ដូចត្រូវការសួរការស្ម័គ្រចិត្តរបស់នាងម្តងទៀត។

ពេលនោះឯងទើបនាងភ្ញាក់ស្មារតី ក្លាយជាចម្លើយឲ្យគេបានដឹងទើប មិខាអ៊ីល ព្រមព្រលែងដៃពីនាង ហើយថយឲ្យឆ្ងាយដោយការមិនពេញចិត្ត។

គេលើកដៃដូចព្រមទទួលយកការសម្រេចចិត្តរបស់នាង ហើយដើរចេញពីបន្ទប់នោះដោយមិនមាត់មិន.ក ដោយជួយបិទទ្វារឲ្យថ្នមៗ។

ហេឃ្យូ ងើបអង្គុយដកដង្ហើមដង្ហក់ លើកដៃស្ទាបទ្រូងខាងឆ្វេងរបស់ខ្លួនដែលពេលនេះបេះដូងកំពុងលោតញាប់។ មិនចង់ជឿទេថាបេះដូងវាលោតខ្លាំងដល់ថ្នាក់នេះពេលគេចូលមកជិត ហើយបង្ហាញពីតម្រូវការរបស់នាងបែបហ្នឹង។

មែនហើយ វាគ្រាន់តែជាតម្រូវការរបស់មនុស្សប្រុស ដោយគ្មានស្នេហាពាក់ព័ន្ធ ហើយនាងក៏មានស្មារតីអាចបដិសេធគេ។

នាងដកដង្ហើមធំម្តងទៀត បន្ទាប់មកក៏ងើបតែងខ្លួនភ្លាមដើម្បីនាំ



គេទៅហាងអាហារពេលល្ងាច ហើយក៏គិតមិនទាន់ចេញដែលថាគួរធ្វើយ៉ាងណាបន្ត។

**ពួកគេចេវទូកតាមដងទន្លេ ទៅដល់ហាងលក់អាហារពេលល្ងាច** ដែលដាក់លក់នៅតាមមាត់ទឹក។

នាងក្រមុំអ៊ុំទូកចូលចតដោយឲ្យអ្នកកំលោះដើរនាំមុខយកខ្សែទៅចងនឹងបង្គោល ហើយងាកមកហុចដៃឲ្យនាង។

ហេឃ្យូមើលដៃនោះមួយភ្លែតបន្ទាប់មកក៏ហុចដៃឲ្យគេទាញឡើងគោក ហើយបណ្តើរគ្នាទៅរើសកន្លែងអង្គុយ។

គ្រប់គ្នានៅក្នុងហាងសុទ្ធតែងាកមកមើលគេ ព្រោះរូបរាងភិនភាគសង្ហារកអ្នកណាជៀបមិនបាន មិនថាមើលពីជ្រុងណា មុខមាត់របស់មិខាអ៊ីល ក៏គីរហ្វិកត៍ នាងដឹងច្បាស់ពេលអង្គុយមើលគេដោយមិនមាត់មិន.ក ព្រមទាំងដកដង្ហើមធំញឹកញាប់។

ប្រាកដណាស់ ទង្វើរបស់គេពីរសៀលធ្វើឲ្យផ្នែកដ៏ជ្រៅនៅក្នុងបេះដូងរបស់នាងរញ្ជួយ ធ្វើឲ្យគិតច្រើនគួរសមនៅក្នុងការធ្វើការបន្តឲ្យគេ ឬបញ្ឈប់គ្រប់យ៉ាងនៅទីនេះ...មិនឲ្យទៅដល់ទីនោះទាន់។

នាងកុម្ម៉ង់អាហារសាមញ្ញពីរមុខ ឯគេកុម្ម៉ង់ច្រើនមុខ ដើម្បីភ្លក្សមើលរសជាតិ និងកុម្ម៉ង់សូដាផឹកជំនួសទឹក។

ជាញឹកញាប់ដែលនាងដឹងថា មិខាអ៊ីល សម្លឹងមើលមកខ្លួនហាក់ដូចរង់ចាំឲ្យនាងមើលគេ តែនាងមិនព្រមមើលអ្នកកំលោះចំ ទើបអាហារមួយពេលនេះគ្មានរសជាតិដូចរាល់ដង ទាំងដែលវាជាអាហារឆ្ងាញ់ បន្ទាប់មកក៏អ៊ុំទូកត្រឡប់ទៅផ្ទះវិញ នៅក្រោមរាត្រីងងឹតដោយអាស្រ័យភាពស្ទាត់ជំនាញនិងការស្គាល់ផ្លូវច្បាស់។



"លោកឡើងទៅមុនទៅ ខ្ញុំចងទូក" នាងប្រាប់ពេលគេចុះពីទូក។

"អត់" គេឆ្លើយតែមួយម៉ាត់ ហើយជួយអូសទូកទៅចង។

"ថី ?" សំឡេងរបស់ មិខាអ៊ីល បន្លឺឡើងពេលនាងបែរខ្លួនដើរឡើងផ្ទះ ទើបនាងក្រមុំឈប់ដើរ តែមិនងាកមករក។

"រឿងកាលពីរសៀលវាធ្ងន់ធ្ងរពេក ធ្វើឲ្យនាងមិនចង់និយាយរកខ្ញុំ ...មិនចង់មើលមុខខ្ញុំ ?"

សំណួរ និងការដែលគេដើរមកឈរក្រោយខ្នងវាធ្វើឲ្យនាងឆ្លើយមិនត្រូវ។

"លោកមានតំណែងឋានៈតួនាទីខ្ពស់បំផុត នៅក្នុងប្រទេសរបស់លោក គ្រប់យ៉ាងដែលលោកធ្លាប់បានវាងាយ ធ្វើឲ្យលោកគិតថាមនុស្សស្រីគ្រប់រូបដែលលោកត្រូវការត្រូវតែយកបានងាយៗមែនទេ"

ពេលឆ្លើយហើយនាងក៏ឡើងជណ្ដើរចូលទៅក្នុងផ្ទះភ្លាម។

"នេះនិយាយឲ្យខ្ញុំងាយយល់បន្តិចបានទេ ?"

មិខាអ៊ីល ដើរតាម ហើយទាញនាងឲ្យងាកមកប្រឈមមុខពេលដើរផុតទ្វារធំ ទើបនាងសម្លឹងមើលមុខគេមិនដាក់ភ្នែក និយាយឲ្យគេយល់។

"កុំចូលមកជិតខ្ញុំបែបនេះទៀត មិនអីចឹងលើកនេះខ្ញុំនឹងលេងលោកឲ្យបែកមុខ"

នាងសរុបហើយបែរខ្លួនដើរចេញ តែអ្នកកំលោះមិនព្រម។

"នែ៎...ខ្ញុំធ្វើខុសដល់ថ្នាក់ហ្នឹងផង ?" គេសួរព្រោះនៅតែមិនយល់។

"លោកមិនបានស្រឡាញ់ខ្ញុំ"

"អីចឹងបើស្រឡាញ់គឺមិនខុស ?" គេត្បកសួរនិងមើលមុខនាងមិនដាក់ភ្នែក។

"ឈប់និយាយពីអ្វីដែលមិនអាចទៅរួចទៅ ហើយខ្ញុំក៏សម្រេចចិត្តរួចហើយថានឹងធ្វើការឲ្យលោក ដល់ថ្ងៃដែលលោកត្រឡប់ទៅប្រទេសលោកវិញ ខ្ញុំមិនទៅដល់សាគីស្ថានទេ"

ហេយ្យ គិតថាខ្លួនឯងប្រាប់គេច្បាស់លាស់ហើយ ទើបបែរខ្លួនដើរចេញពីត្រង់នោះ។

នាងចូលបន្ទប់ ងូតទឹកងូតភក់ ផ្លាស់ខោអាវ ដើរលបៗចេញពីបន្ទប់ គិតថាមកត្រួតពិនិត្យ បិទទ្វារបិទបង្អួចផ្ទះឲ្យរួចរាល់សឹមចូលដេក ប៉ុន្តែពេលចេញមកដល់ទ្វារ ក៏មានពន្លឺភ្លើងពិលរត់កាត់មុខមួយភ្លែត ដែលធ្វើឲ្យនាងចងចិញ្ចើម។

ផ្លូវដើរចូលផ្ទះត្រូវឆ្លងកាត់សួនផ្កានិងងងឹត តើនរណាកាន់ពិលឆ្លុះមើលផ្លូវ ?

ដៃរបស់នាងលឿនជាងការគិតទៅទៀត ទាញទ្វារបិទដាក់គន្លឹះភ្លាម ហើយរត់ទៅបិទភ្លើង និងគោះទ្វារហៅអ្នកកំលោះ។

"យើងត្រូវចេញពីទីនេះហើយ...ឆាប់ឡើង"

និយាយចប់នាងក៏ងាកទៅបើកទ្វាររានហាល នាំអ្នកកំលោះចុះតាមជណ្ដើរមាត់កំពង់ ទៅសម្ងំនៅក្នុងទឹក។

មិនយូរបង្ហាញស្រមោលស្ងង់ៗរបស់មនុស្សក៏បង្ហាញខ្លួននៅមុខផ្ទះតែគួរឲ្យប្លែកដែលវាមកតែម្នាក់ឯងទើបនាងឡើងជណ្ដើរមកវិញព្រោះគិតថាវាអាចមិនមែនជាមនុស្សដែលតាមមកសម្លាប់ មិខាអ៊ីល តែជាចោរធម្មតា។

ពេលគិតឃើញដូច្នោះហើយទើបនាងចូលក្នុងផ្ទះវិញ ដើរទៅបើកភ្លើងដើម្បីប្រឈមមុខនឹងចោរដែលហ៊ានចូលមកក្នុងផ្ទះរបស់នាង។



ក្មេងប្រុសម្នាក់នោះងាកខ្ទាប់មករកនាងដោយមានកាំបិត និង

ពិលនៅក្នុងដៃ ពេលឃើញថាម្ចាស់ផ្ទះជាមនុស្សស្រី ក៏បោះពិលចោល និងកាន់កាំបិតដើរមករកយ៉ាងអង់អាច។

ខណៈនោះ មិខាអ៊ីល ក៏ដើរចូលមក មើលចោរឈាមរាវដោយទឹកមុខប្រាកដប្រជា និងដើរសំដៅទៅរកវា ទើបចោរឈាមរាវឈរមើលពួកគេម្តងម្នាក់ដោយការរិះគិត បន្ទាប់មកក៏ហាក់រកអ្នកកំលោះ។

វាចង់ចាក់គេហើយទៅចាត់ការស្រីម្នាក់នោះតែវាមិនងាយដូចការគិត ព្រោះត្រូវ មិខាអ៊ីល រៀសកាំបិតរបូតពីដៃខ្ទាតទៅឆ្ងាយ ហើយប្រគេនដៃប្រគេនជើងឲ្យវាឡើងទក់សាច់ មិនយូរប៉ុន្មានអាចោរចង្រៃនោះក៏ដួលខ្តោក សន្លប់បាត់មាត់ ទើបគេអៀវវាទៅបោះចោលនៅមាត់ផ្លូវ ហើយដើរចូលផ្ទះវិញ បិទទ្វារដាក់គន្លឹះ ហើយងាកមករកនាង។

"មិនស្មានថាលោកការពារខ្លួនឯងបានល្អបែបនេះ" នាងមើលមុខគេដោយការសរសើរ។

"ស៊ូនឹងចោរជម្មតាវាគ្មានបញ្ហា វាមិនមែនជាឃាតករដែលយើងធ្វើឲ្យភ្ញាក់ស្មៀតបាន"

"ប៉ុន្តែលោកការពារខ្លួនឯងបាន"

"មែន" គេងក់ក្បាល "តែស៊ូអ្នកអាជីពដូចនាងឬក្រុម ហ៊ុលសែន មិនបាន អូខេ យើងនិយាយគ្នាតាមសម្រួលបានទេ"

"យើងគ្មានអីនិយាយគ្នាទេ"

"មាន ច្រើនទៀតផង ដំបូងគឺនាងចោទថាខ្ញុំថើបនាងដោយមិនបានស្រឡាញ់ នាងយល់ច្រឡំមួយរយភាគរយ"

"អ៊ីចឹងមានន័យថាលោកថើបខ្ញុំ លោកកំពុងសុំខ្ញុំរៀបការ ?" នាងងាកមកសម្លក់សម្លឹងគេ ហើយសំណួរនោះធ្វើឲ្យ មិខាអ៊ីល ភាំង។

"មិនមែន...អើយ៎ មែនគឺ...ខ្ញុំចាប់អារម្មណ៍នាង ហើយចង់ឲ្យយើងបានសិក្សាស្វែងយល់ពីគ្នាជាងនេះ"

"ការសិក្សារបស់លោកគឺចូលមកប៉ះពាល់ខ្ញុំឬ? ការធ្វើបែបហ្នឹងរបស់លោកគឺត្រូវការរៀបការតែម្យ៉ាង ដូច្នេះហើយបើមិនចង់រៀបការ កុំចូលមកជិតខ្ញុំទៀតយល់ទេ"

និយាយចប់នាងក៏បែរខ្លួនដើរចូលបន្ទប់ខ្លួនឯង ដោយងាកទៅមើលគេមួយភ្លែតទាំងកំហឹង បន្ទាប់មកក៏បិទទ្វារលាន់ភ្លាំង ទុកឲ្យអ្នកកំលោះឈរនៅត្រង់នោះ ច្រើននាទីតែម្តង ទម្រាំតែគិតឃើញ និងសម្លឹងមើលទ្វារបន្ទប់ដែលត្រូវនាងបិទដាក់មុខ។

"អូខេ បើត្រូវការទំនុកចិត្តដល់ម្លឹង"

មិខាអ៊ីល និយាយរអ៊ូៗ ហើយដើរចូលបន្ទប់ដេករបស់ខ្លួន បិទទ្វារលាន់ក្ទុងក្ទាំងដូចគ្នា។



## ១១

### ព្រឹកថ្ងៃថ្មី

ពេលទម្លាក់ជើងចូលទឹកទន្លេហើយ ហេយ្យូ ក៏ត្រូវទាញវាមកវិញដោយចិត្តរារែក ព្រោះខ្លាចត្រូវប្រគ្រៀវកាច់ដូចកាលពីម្សិលទៀត ដែលវាមិនធ្លាប់មានរឿងបែបនោះកើតឡើងចំពោះនាងតាំងពីកើតមក វាដូចសញ្ញាគ្រោះថ្នាក់ដែលត្រូវប្រុងប្រយ័ត្ន មិនបណ្តោយឲ្យកើតឡើងទៀត ដែលមានន័យថានាងចុះទឹកមិនបានទៀតទេ តែនាងត្រូវព្រមចាញ់អ៊ីចឹងឬ? ព្រមឲ្យរោគប្រគ្រៀវរារាំងមិនឲ្យនាងចុះទឹកមួយជីវិតអ៊ីចឹងឬ?

ពេលនោះនាងអង្គុយតែម្នាក់ឯងនៅមាត់ជណ្តើរកំពង់ទឹក យោលជើងលេងក្នុងទឹកដោយចិត្តរារែក ដោយមួយតួខ្លួនមានតែសារុងចោមពុងមួយប៉ុណ្ណោះ សក់វែងត្រូវទម្លាក់ពេញខ្នង ធ្វើឲ្យមុខស្រស់ស្អាតដូចមុខក្មេងស្រីរពីសម្នាក់ មិនមែនអង្គរក្សថ្មីដែលល្អរបស់ ឃ្វីន ក្រុមហ៊ុនបម្រើសេវាកម្មឯកជនមានកេរ្តិ៍ឈ្មោះបោះសំឡេង។

តែនាទីបន្ទាប់មក នាងក៏សម្រេចចិត្តសម្រូតខ្លួនចុះទឹក មុជលេង



ទាល់តែពេញចិត្តនៅក្បែរជណ្តើរ គិតថាបើមានអីកើតឡើង នឹងស្ទុះទៅឱបសសរផ្ទះ ឬមិនអ៊ីចឹងក៏ជណ្តើរ វានឹងទាន់ពេល ប៉ុន្តែអ្វីដែលភ័យខ្លាចក៏កើតឡើងឲ្យទាល់តែបាន ពេលជើងទាំងពីរត្រូវប្រគ្រៀវកាច់ ធ្វើឲ្យកម្រើកមិនរួចពាក់កណ្តាលខ្លួនទៀតហើយ។

នាងសង្កេតស្រាប់ទៅហើយ ពេលវាកើត ក៏ហក់ទៅរកជណ្តើរផ្ទះភ្លាម តែភ្លាត់ស្នៀត ស្រវាចាប់មិនទាន់ ព្រោះមានរលកប្រានឲ្យនាងចេញឆ្ងាយពីជណ្តើរ ហើយទាញពន្លិច។

នាងដកដង្ហើមដង្ហក់ ពេលការព្យាយាមជួយខ្លួនឯងមានបញ្ហា តែពេលនោះមានដៃមួយលូកមកទាញ អូសនាងទៅរកគេ ហើយលើកដាក់លើស្មាបានយ៉ាងងាយ នាំទៅដាក់លើក្តារក្រាលដោយការប្រុងប្រយ័ត្ន បន្ទាប់មកក៏ដើរទៅរកកន្សែងពោះគោមកដណ្តប់ឲ្យ និងទាញសារុងចេញពីរាងកាយទៅពាក់នឹងរនាំងរានហាល ហើយងាកមកលើកបីនាងដែលមានកន្សែងដណ្តប់តែមួយប៉ុណ្ណោះ ទៅដាក់លើកម្រាលក្នុងបន្ទប់អង្គុយលេង ដោយខ្លួនឯងក៏អង្គុយក្បែរ។

មិខាអ៊ីល មើលនាងដោយកែវភ្នែកមុតស្រួច ដែលធ្វើឲ្យនាងក្រមុំត្រូវងាកមុខចេញ មិនចង់មើលមុខគេចំ។

"ពីម្សិលនាងនិយាយមែនទេថាបើប៉ះពាល់នាង ត្រូវតែរៀបការ"

គេសួរនិងមើលមុខនាងមិនដាក់ភ្នែក តែនាងមិនឆ្លើយ។

"ខ្ញុំចង់នាងថា ខ្ញុំទទួលយកសំណើនោះ...យើងនឹងភ្ជាប់ពាក្យជាមួយគ្នាមុនពេលទៅសាគីស្ថាន"

"អ្នកណាប្រាប់ថាខ្ញុំនឹងភ្ជាប់ពាក្យជាមួយលោក?"

នាងសួរ ពេលគេយកកន្សែងជូតចុងជើងឲ្យដោយកាយវិការទន់ភ្លន់ ហើយម៉ាស្សាឲ្យទាល់តែវាឡើងក្តៅឧណ្ហៗ។



"ខ្ញុំថានាងខ្វះកាល់ស្យូម ទើបឧស្សាហ៍ប្រគ្រៀវ ត្រូវទៅរកពេទ្យ"

"កុំមកចេះ លោកប្រុងប្រយ័ត្នខ្លួនឯងឲ្យបានល្អទៅ"

នាងប្រកែក រិះតែភ្លេចទៅថាខណៈនេះខ្លួនឯងគ្មានអ្វីជាប់ខ្លួនក្រៅពីកន្សែងដណ្តប់ជំនួសភួយ។

"យើងនឹងភ្ជាប់ពាក្យនៅទីនេះ ហើយទៅរៀបការនៅស្រុកខ្ញុំ"

"អ្នកណារៀបការជាមួយលោក" នាងឆ្លលចុងច្រមុះ សម្លឹងមើលគេដោយទឹកមុខប្រាកដប្រជា។

"នាង"

មិខាអ៊ីល ឲ្យចម្លើយ ហើយត្រសុលទៅអង្គុយបៀត លោមុខសង្ហាទៅជិត។

"នែ៎...កុំឲ្យសោះ"

នាងស្តីឲ្យដោយទឹកមុខកាច និងលើកដៃរុញចង្កាដែលកោរពុកមាត់ពុកចង្ការួចរាល់ បន្សល់ទុកតែគល់របស់វារ៉េះៗ។

"ខ្ញុំរីករាយរៀបការ...បើបានប៉ះពាល់នាងនៅពេលនេះ"

មិខាអ៊ីល បន្ថយសំឡេង ពេលទាញដៃរបស់នាងឲ្យផុតពីចង្កាដែលមានពុកចង្ការបស់ខ្លួន ហើយស្រវាចាប់ដៃទាំងពីររបស់នាងជាប់ដែលធ្វើឲ្យនាងក្រមុំមានអារម្មណ៍ថាចូលស៊ិងគេហើយ។

"តែខ្ញុំមិនរៀប..."

នាងបដិសេធភ្លាម មិនឲ្យគេធ្វើអ្វីលើសពីនេះបាន។

"សោកស្តាយផង នាងអស់សិទ្ធិបដិសេធហើយ...យើងនឹងរៀបការជាមួយគ្នាតាមការទាមទាររបស់នាង"

និយាយចប់បបូរមាត់ក្តៅពណ៌ស្អាត ក៏ឱនទៅបិទបបូរមាត់របស់នាង ថើបនាងដោយការទាមទារ ខណៈដែលដៃទាំងពីរលែងកដៃរបស់



នាង តែលូកទៅឱបចង្កេះ ទាញរាងកាយស្រឡៅស្រឡូនមកឱបរឹតនឹងដើមទ្រូងធំទូលាយដោយសាច់ដុំរឹងមាំនោះដោយភាពស្និទ្ធស្នាល។

នាងក្រមុំភ្លេចខ្លួនដោយសារការថើបនោះមួយខណៈ បណ្តោយឲ្យចុងអណ្តាតខ្លួនឯងត្រូវកេរ និងដួសដងយកភាពផ្អែមល្ហែមទាល់តែពេញចិត្ត ឯម្រាមដៃរឹងមាំអូសទៅរកខ្នង ទម្លាក់ទៅរកត្រគាកមូលក្លំដែលគ្មានអ្វីបិទបាំង។

ពេលភ្ញាក់ស្មារតី នាងក៏ប្រឹងរើបម្រះ និងប្រើយុទ្ធសាស្ត្រដែលមានប្រានគេចេញ ព្រោះពេលនោះអ្នកកំលោះទ្រោបលើនាងពាក់កណ្តាលខ្លួនដូចកាលពីម្សិលយ៉ាងអីចឹងសង្ស័យនាងត្រូវឈប់ហែលទឹកមែនទែនហើយ...ពេល មិខាអ៊ីល ព្រមចាញ់ ថយចេញឲ្យឆ្ងាយដោយទឹកមុខញញឹម និងកែវភ្នែកញ័រទទ្រើតដូចពេញចិត្ត បន្ទាប់មកក៏ដើរចេញទៅដូចដឹងថាត្រូវទៅរកម្ហូបអាហារមួយពេលនេះសម្រាប់គេនិងនាង ដែលអ្នកកំលោះចូលចិត្តទិញអាហារនិងផ្លែឈើគ្រប់ប្រភេទ ដែលយាយអ្នកលក់បណ្តែតទូកមកដល់ តែថ្ងៃនេះមិនមែនមានតែទូកយាយម្នាក់នោះទេ នៅមានទូកពីរគ្រឿងទៀត ជានំចំណីសម្រាប់ញ៉ាំលេង ដែលមានភិនភាគប្លែកភ្នែក និងគួរឲ្យញ៉ាំ។

គេទិញនំចំណីច្រើនពេញតុតែម្តង ពេលនាងតែងខ្លួនរួចរាល់ហើយដើរមកមើល។

នាងឈរមិនស្ងៀម ពេលត្រូវគេចូលមកឈរបៀត និងស្រវាឱបចង្កេះ ហើយក៏ត្រៀមខ្លួនរួចរាល់ដែរ បង្ការបើគេចង់ធ្វើអីផ្តេសផ្តាសលើកនេះនាងនឹងប្រដៅគេឲ្យឈឺខ្លួន។



មិខាអ៊ីល ដូចដឹង គេឱបចង្កេះនាងធម្មតាៗ ឯដៃម្ខាងទៀតជ្រែងហោប៉ៅ។

"នាងធ្វើឲ្យខ្ញុំគិតដល់ក្រុមគ្រួសារជម្មតាៗដែលមានក្ដីសុខ មានតែយើងនិងកូនៗ"

នាងឈរស្ងៀម ស្ដាប់គេនិយាយដោយមិនជឿអីមួយម៉ាត់។

"ពេលត្រឡប់ទៅផ្ទះ ទៅជួបអ្នកដែលសក្ដិសមនឹងលោក លោកនឹងភ្លេច"

នាងនិយាយដោយសំឡេងត្រជាក់ មិនជឿគេអីមួយម៉ាត់។

"មិនជឿឬ?" គេសួរ និងមើលនាងដោយទឹកមុខប្រាកដប្រជា។

"យើងខុសគ្នា និងឆ្ងាយគ្នាពេកហើយ"

"គ្មានអ្វីនៅលើលោកនេះដែលមិនអាចទៅរួចនោះទេ" គេតវ៉ា។

នាងចង់ប្រកែក តែមិនចង់និយាយ ទើបឈរស្ងៀម និងបេះដៃរបស់គេចេញពីចង្កេះរបស់ខ្លួន។

មិខាអ៊ីល លើកដៃម្ខាងនោះ ទាញចិញ្ចៀនពេជ្រមួយគ្រាប់ធំចេញពីកូនដៃរបស់ខ្លួន ហើយយកទៅបំពាក់នឹងម្រាមដៃនាងរបស់ ហេយ្ស៊ូ ដែលវាល្មមម៉ាច់តែម្ដង គួរឲ្យភ្ញាក់ផ្អើល ហើយក្ដោបដៃម្ខាងនោះរបស់នាងជាប់ ពេលនាងប្រុងដោះចិញ្ចៀនចេញ។

"ខ្ញុំសុំភ្ជាប់ពាក្យនាងដោយចិញ្ចៀនមួយវង់នេះ ត្រឡប់ទៅដល់ផ្ទះនឹងប្រកាសជាផ្លូវការឲ្យគ្រប់គ្នាដឹង"

នាងប្រុងបដិសេធ តែក៏នៅស្ងៀមពេលគិតឃើញ...បើគេមិនប្រាកដប្រជា ប្រហែលគ្រាន់តែនិយាយនៅពេលនេះហើយក៏ភ្លេច នាងទៅឡូឡាធ្វើអី ទើបនាងក្រមុំធ្វើព្រងើយ បណ្ដោយឲ្យគេទាញដៃនោះទៅថើបខ្សឹតៗ និងមើលមកនាងដោយខ្សែភ្នែកពោរពេញទៅដោយអត្ថន័យដែលនាងមិនចង់ឃើញ ព្រោះគេខុសពីនាងហៅមិនឮតែម្ដង។

ហេយ្ស៊ូ ងើយមុខមើលគេពេញភ្នែក និងប្រាប់ខ្លួនឯងថា ក្រៅពី



រូបសង្ហាដែលតើហ្វិកត៍ទាំងចិញ្ចើម ភ្នែក ច្រមុះ បបូរមាត់ហើយ នាងមិនជឿគេ។

ពេលគិតឃើញដូច្នេះហើយ ទើបទម្លាក់មុខចុះ បិទបាំងខ្សែភ្នែកខ្លួនឯងមិនឲ្យគេឃើញ ហើយដើរទៅអង្គុយនៅលើកម្រាលទល់មុខ។

"ញ៉ាំបាយទៅ ខ្ញុំឃ្លានហើយ"

នាងប្ដូររឿង ហើយទទួលទានអាហារ។

ពេលល្ងាច

ពេលអ៊ុំទូកទៅហាងអាហារ មិខាអ៊ីល ក៏ទាញទូរសព្ទមកមើលដោយការរិះគិត ថាត្រឡប់ទៅវិញដោយយន្តហោះផ្ទាល់ខ្លួន ឬយន្តហោះធម្មតា ដើម្បីសុវត្ថិភាព។

"ការពិតលោកគួរត្រឡប់ទៅវិញជាមួយ ហ្ស៊ីកា ព្រោះលោកប្រាប់ថាមានអ្នកគាំទ្រឲ្យទ្រង់ឡើងគ្រងរាជ្យ តែត្រូវតែគ្មានលោក ដូច្នេះហើយការនៅជិតទ្រង់ នឹងធ្វើឲ្យលោកមានសុវត្ថិភាព យ៉ាងហោចណាស់ក៏មួយរយៈពេលដែរ"

សំណើរបស់នាង ធ្វើឲ្យ មិខាអ៊ីល មើលមុខ ហើយទម្លាក់មុខចុះ បិទបាំងខ្សែភ្នែកដូចដែលនាងធ្វើ វាធ្វើឲ្យនាងក្រមុំសង្ស័យ។

"លោកដឹងហើយមែនទេ...ហើយម៉េចក៏មិនធ្វើ?" នាងសួរដោយការងឿងឆ្ងល់។

"បើធ្វើ ប្រហែលរៀបការជាមួយ រ៉ននី តាំងពីយូរហើយ"

ចម្លើយនោះធ្វើឲ្យនាងក្រមុំភាំង ស្មានមិនដល់ថាបុរសនៅចំពោះមុខជ្រើសរើសនៅលេងសើចជាមួយនឹងសេចក្ដីស្លាប់ ជាងការយោងអាត្មាឲ្យរស់ដោយការលាក់ខ្លួនក្រោយខ្នងមនុស្សស្រី។



"សុំទោស មិនស្មានថា..."

សម្ដីនោះធ្វើឲ្យនាងមិនចង់ជឿ។ ហេតុអីក៏គេបដិសេធការឡើងទៅកាន់ទីខ្ពស់បែបនោះ មិនយល់សោះ។

មានមនុស្សបែបនេះទៀតឬនៅក្នុងលោកនៃការដណ្ដើម ហែកហួរគ្នាបែបនេះ។

"ថ្ងៃណាមួយ រ៉ននី នឹងបានជួបអ្នកដែលទ្រង់ស្រឡាញ់ ហើយរស់នៅជាមួយគ្នាមួយជីវិត"

ការអធិប្បាយមួយប្រយោគនេះ ធ្វើឲ្យអ្នកស្ដាប់ត្រូវតមាត់។

"ហ្សីកា ចូលចិត្តលោក...ខ្ញុំដឹង"

"ខ្ញុំជាបងប្រុស ទោះមានម្ដាយទីទៃ ក៏នៅតែជាបងប្រុសដដែល"

"តែតាមដែលខ្ញុំដឹង..ច្បាប់នៅប្រទេសរបស់លោកមិនបានហាម"

"ខ្ញុំឃើញ រ៉ននី តាំងពីតូច មិនអាចទៅរួចទេ...អំណាចទិញបេះដូងមិនបាន"

នាងក្រមុំដកដង្ហើមធំ នៅតែគិតថានៅមានមនុស្សបែបនេះនៅសល់ក្នុងលោកទៀត កុំថាឡើយអំណាចអាចទិញបាន សូម្បីប្រាក់បន្តិចបន្តួចក៏អាចទិញបាន។

"ការព្យាយាមតាមប្រមាញ់លោក ប្រហែលមិនមែនព្រោះហេតុផលនយោបាយតែមួយ"

ទីបំផុតនាងក៏ទាយត្រូវ។

"វាអាចជាការមិនពេញចិត្តផ្ទាល់ខ្លួនដែរ ហើយនេះជាហេតុផលសំខាន់ជាងគេ"

នាងងក់ក្បាលពេលពិចារណាឲ្យហ្មត់ចត់។

"នាងប្រហែលបដិសេធរឿងទៅសាគីស្ថានដែរមែនទេ ?"



គេសួរពេលអុំទូកមកដល់ផ្ទះ ធ្វើឲ្យអ្នកដែលដើរនាំមុខឈប់ដើរយូរគួរសម។

ការពិតនាងត្រូវដើរតាមក្រោយគេ ប៉ុន្តែពេលនេះ មិខាអុិល បែរជាឲ្យនាងដើរនាំមុខ។ ចិត្តមួយនាងមិនចង់ទៅជាមួយ តែចិត្តមួយទៀតបែរជាបារម្ភពីគេ មិនអាចបណ្ដោយឲ្យគេទៅប្រឈមនឹងសេចក្ដីស្លាប់តែម្នាក់ឯងបាន ទោះមានអង្គរក្សតាមការពារក៏ដោយ។

"អរគុណដែលមិនចោលគ្នា"

ប្រយោគនោះធ្វើឲ្យនាងទប់ដំណើរម្ដងទៀតនៅមុខបន្ទប់ បន្ទាប់មកក៏បើកទ្វារចូលទៅសម្ងំនៅក្នុងនោះ មិនចេញមកឲ្យឃើញទៀត ភ្លេចតួនាទីរបស់ខ្លួនឯងឲ្យឈឹង។

មិខាអុិល មិនទាក់ទងរកអ្នកណា រហូតដល់ថ្ងៃធ្វើដំណើរ គេនាំនាងឡើងយន្តហោះរបស់ក្រុមហ៊ុនឯកជន ដោយបដិសេធយន្តហោះដែលព្រះអង្គម្ចាស់ក្សត្រីបញ្ជូនមកឲ្យ។

នៅតាមផ្លូវទៅព្រះបរមរាជវាំង ដែលជាដំណាក់របស់អ្នកកំលោះ នាងក្រមុំប្រាប់ខ្លួនឯងដោយសញ្ញាតិញ្ញាណថា កន្លែងឈរជើងរបស់ព្រះអង្គម្ចាស់វ័យក្មេង ត្រូវបង្រួមឲ្យតូចទៅៗហើយ ហើយមិនយូរទេគេនឹងត្រូវខ្ចាតចេញពីដែនដីមួយនេះជាក់ជាមិនខាន ពេលនាងងាកមកមើលខ្លួនត្រង់ត្លឹងរបស់បុគ្គលដែលកំពុងតែដើរទៅខាងមុខ ដោយកាយវិការដូចរាជសីហ៍ មិនមែនកណ្ដុរ។

ពេលចូលមកក្នុងអាណាចក្ររបស់គេ ក៏មានអ្នកចេញមកគោរពដោយការឱនគំនាប់កៅសិបដឺក្រេ ហើយទទួលយកគ្រប់យ៉ាងពីដៃរបស់ចៅហ្វាយនាយ។





Scanned by CamScanner

ហោយ្យូ ប្រុងឈប់នៅមុខបន្ទប់ តែត្រូវគេងាកមកហៅឲ្យទៅជាមួយគ្នា ដើម្បីទៅជួប ហ៊ុលសែន និងអ្នកឯទៀត។

មិខាអ៊ីល ដើរចូលបន្ទប់តែងខ្លួន ពេលចេញមកវិញក៏ស្លៀកពាក់ឈុតប្រចាំជាតិ ដោយមានកងរឹតពណ៌ខ្មៅមាស បញ្ជាក់ពីតំណែងបានច្បាស់។

នាងក្រមុំមើលគេ ហើយប្រាប់ខ្លួនឯងថានេះទៅវិញទេជាសមាសភាពរបស់គេ ទីនេះទៅវិញទេជាកន្លែងរបស់គេ មិនមែនមនុស្សប្រុសធម្មតាៗពេលនៅក្នុងផ្ទះ ក្នុងទឹកដីរបស់នាង។

ព្រះអង្គម្ចាស់ងាកមកឃើញខ្សែភ្នែករបស់នាង ដែលមើលមកហើយក៏មើលមុខគ្នាបែបនោះដោយមិនមាត់មិនក រហូតដល់មានអ្នកមកប្រាប់ថាព្រះអង្គម្ចាស់ក្សត្រីស្ដេចយាង។



## ១២

ព្រះអង្គម្ចាស់ក្សត្រី រ៉ននី ទច់ដំណើរមួយខណៈ ពេលទតឃើញ ហោយ្យូ ឈរនៅក្នុងបន្ទប់នោះដែរ។ ទ្រង់មិនចូលចិត្តនាង តែបដិសេធមិនបានថាស្រីកូរ៉េខាងត្បូងជួយជីវិតព្រះអង្គម្ចាស់បានច្រើនដង។

"អនុជចង់និយាយជាមួយព្រះរៀមតែពីរនាក់"

ទ្រង់ប្រាប់បងប្រុស ដែលគេក៏ងក់ក្បាលជាសញ្ញា ទើបគ្រប់គ្នាចេញទៅក្រៅអស់។

"អនុជនិយាយជាមួយសម្ដេចព្រះមាតាហើយ រឿងព្រះរៀមត្រូវលបប្រហារ"

ចិញ្ចើមរបស់ព្រះអង្គម្ចាស់ជ្រួញចូលគ្នាភ្លាមពេលឮដូច្នេះ។

"និយាយយ៉ាងម៉េច?"

"ឲ្យសម្ដេចព្រះមាតានិយាយជាមួយ អ៊ីម៉ាម និងប្រាប់ទៀតថាព្រះរៀមផ្ទេរអំណាចបីក្រសួងមកឲ្យអនុជហើយ មិនចាំបាច់តាមសម្លាប់ព្រះរៀមទៀត"



"វាមិនមែនមានតែរឿងហ្នឹងទេ មិនថានរណាក៏បញ្ឈប់រឿងនេះមិនបានដែរ អ៊ីម៉ាម ត្រូវការសម្លាប់រៀមព្រោះស្អប់ ដោយគ្មានហេតុផលអីមកទប់គេបាន"

ហេតុផលរបស់បងប្រុស ធ្វើឲ្យព្រះអង្គម្ចាស់ក្សត្រីនៅស្ងៀមយូរគួរសម ទើបនិយាយម្តងទៀត។

"គ្មានវិធីកែខៃទេឬ?"

"វិធីតែមួយគត់ គឺចេញឲ្យផុតពីអំណាចដែលមាន ដោយឲ្យទ្រង់កាន់ការរាជការទាំងអស់ជាមួយសម្តេចព្រះមាតា"

ព្រះអង្គម្ចាស់ក្សត្រីស្តាប់ហើយក៏ងក់ក្បាល។

"តាមដែលអនុជដឹង គឺអាចយល់ហើយថាហេតុអីព្រះរៀមរាំងគេគ្រប់រឿងតាំងពីដំបូង មកដល់ពេលនេះ ព្រះរៀមចង់រត់គេចឬ?"

"សម្តេចព្រះមាតាយល់ស្របនឹងគេគ្រប់រឿង ទើបរៀមចង់បញ្ឈប់ហ្នឹងអី បើចង់បំផ្លាញស្រុកទេសដោយផ្ទាល់ព្រះហស្ត រៀមនឹងបើកផ្លូវ"

"ដោយទុកអនុជចោលតែម្នាក់ឯងឬ?"

"បើទ្រង់មិនព្រម សម្តេចព្រះមាតានឹងធ្វើបានដោយរបៀបណា"

"ចុះបើ អ៊ីម៉ាម មិនចូលចិត្ត?"

"ជឿចុះ គេត្រូវតែព្រមទាំងពីរនាក់ហ្នឹង"

"ព្រះរៀមនិយាយអី ពិបាកយល់ណាស់"

"ទ្រង់នឹងយល់"

"ចុះបើបញ្ឈប់គ្រប់រឿង តើព្រះរៀមចង់ធ្វើយ៉ាងណាបន្ត?"

សំណួរនោះ ធ្វើឲ្យព្រះអង្គម្ចាស់ដើរទៅឈរនៅមាត់បង្អួច សម្លឹងមើលទៅឆ្ងាយ។

"កាលមុនធ្លាប់គិតថាដើរលេងនៅសមុទ្រខ្សាច់មួយជីវិត តែពេល



នេះប្តូរផែនការ"

"ព្រោះអី? ព្រោះស្រីម្នាក់នោះឬ?"

ព្រះអង្គម្ចាស់ក្សត្រីដើរមកឈរក្បែរ និងមើលមុខសង្ហាគ្មានបុរសណាជៀបបាននៅក្នុងគំនិតរបស់ទ្រង់យ៉ាងយូរ។

"អនុជឃើញទ្រង់មើលនាង"

"ពេលទ្រង់ដឹងថាត្រូវធ្វើយ៉ាងណាហើយ អីចឹងស្តេចយាងត្រឡប់ទៅវិញទៅ ត្រៀមព្រះវរកាយសម្រាប់ស្អែកនេះ"

មិខាអ៊ីល និយាយកាត់ ហើយដើរទៅបើកទ្វារ។

ព្រះអង្គម្ចាស់ក្សត្រីងើយមើលមុខគេ បន្ទាប់មកក៏ដើរចេញពីបន្ទប់នោះទៅដោយមិនពេញព្រះទ័យ ហើយពេលចេញមកដល់ខាងក្រៅ ក៏សម្លឹងមើលមុខអង្គរក្សស្រី។

ពេលព្រះនាងយាងទៅបាត់ គ្រប់គ្នាក៏ដើរចូលបន្ទប់នោះវិញ។

"ត្រៀមការធ្វើដំណើរ ហ៊ុលសែន ចប់ពិធី យើងនឹងទៅ ឲ្យគ្រប់គ្នាសប្បាយចិត្តថាយើងមិននៅរាំងអំណាចអ្នកណាទៀត"

មិខាអ៊ីល ប្រាប់ពេលសម្រេចចិត្តដាច់ខាត។

អ៊ីម៉ាម មូជីអាប់សា អង្គុយស្តាប់សម្តេចព្រះមាតារបស់ព្រះអង្គម្ចាស់ក្សត្រីនិយាយទាល់តែចប់ ហើយនៅតែធ្វើព្រងើយយូរគួរសមទើបនិយាយ។

"វាមិនធ្លាប់ឃើញទូលបង្គំនៅក្នុងភ្នែកតាំងពីវាមានអំណាច ធ្វើឲ្យទូលបង្គំមិនចង់ទុកជីវិតវា ហើយពេលនេះពេលវាខ្លាចងាប់ដល់ថ្នាក់រត់គេច តើហេតុអីទូលបង្គំត្រូវបើកផ្លូវឲ្យវា ដើម្បីព្រះអង្គម្ចាស់ក្សត្រី បុត្រីរបស់សម្តេចព្រះមាតាឬ...វាមិនងាយពេកទេឬគ្មានផ្លូវទេសម្តេចព្រះមាតា





Scanned by CamScanner

ទូលបង្គំកាត់ក្ដីជីវិតរបស់វារួចទៅហើយ នោះគឺងាប់!"

**ខណៈនោះដែរ ហ៊ុលសែន និងបក្ខពួកកំពុងតែពិភាក្សាគ្នារឿង** ការងារដែលគ្រប់គ្នាកំពុងធ្វើ។

"ក្នុងពេលដែល ហ្សុីក ដឹងច្បាស់ហើយថាអ្នកណានៅពីក្រោយនៃការបញ្ជាសម្លាប់ ហេតុអីនៅតែធ្វើព្រងើយទៀត?" ដានៀល និយាយរអ៊ូៗដោយការឃ្នើសចិត្ត។

"អានេះស្រេចតែ ហ្សុីក យើងធ្វើអីមិនបាន" ហ្វាខែល ឲ្យយោលបល់។

"ចុះនាង?" ហ៊ុលសែន ងាកទៅសួរនាងក្រមុំ ។

"ការងាររបស់យើងគឺការពារ ហ្សុីក"

"រឿងហ្នឹងវាត្រូវតែអីចឹង តែធ្វើបែបនេះគឺលលេងនឹងសេចក្ដីស្លាប់មិនសប្បាយទេ"

"ខ្ញុំមិនដឹងថានិយាយយ៉ាងណា ក្រៅពីធ្វើតាមតួនាទី"

ខណៈនោះ មិខាអ៊ីល ក៏ដើរចេញពីបន្ទប់ធ្វើការល្មម ពេលឃើញអង្គរក្សរបស់ខ្លួនប្រជុំគ្នាបែបនេះ ក៏មើលមកដោយការសង្ស័យ។

"កំពុងគិតអី?"

"អត់មានទេទាន" ហ្វាខែល តបដោយស្វ័យប្រវត្ត ប៉ុន្តែអ្នកសួរមិនជឿ ទើបសម្លឹងមើលទៅ ហេយ្សុ ហៅនាងឲ្យដើរតាម។

"នាងមិនណេះ"

នាងក្រមុំត្រូវងើបឈរដោយស្វ័យប្រវត្ត មើលមិត្តរួមការងារមួយភ្លែត ហើយដើរទៅរកភ្លាម។

ពេលនាងបិទទ្វារ ព្រះអង្គម្ចាស់ក៏ងាកមកស្រវាចាប់ដៃ ហើយឱន



មុខសង្ហាមកជិត។

"ចិញ្ចៀនទៅណា?"

"ខ្ញុំ...ទុកវា"

"ម៉េចក៏មិនពាក់?"

"អ្នកណាៗក៏ដឹងថាជាចិញ្ចៀនរបស់លោក ខ្ញុំម៉េចនឹងពាក់បានទៅ គេឯងនឹងថាខ្ញុំជាចោរ គ្មានគំនិតកំបុតម្រាមទេ គ្រាន់តែទុកវាក្នុងខ្លួនក៏ខ្លាចសឹងស្លាប់ទៅហើយ"

ចម្លើយច្បាស់លាស់របស់នាង ធ្វើឲ្យអ្នកសួរភាំង តែមិនព្រមលែងដៃអ្នកដែលប្រឹងកន្ត្រាក់ ថែមទាំងស្រវាឱបនាង ហើយឱនទៅនិយាយដាក់ត្រចៀកទៀតផង។

"និយាយអី...អម្បាញ់មិញ?"

នាងប្រឹងក្រាញ លើកដៃរុញដើមទ្រូងរឹងមាំ។

"យើងនិយាយគ្នារឿងរបស់ទ្រង់ ថាព្រមឲ្យគេតាមសម្លាប់ដោយមិនតបត"

"ម៉េចក៏ដឹងថាមិនតបត?" អ្នកកំលោះតប ព្រមទាំងឱនទៅជិតបបូរមាត់ ដោយដៃទាំងពីរឱបចង្កេះរបស់នាងណែន។

"តបតយ៉ាងម៉េច?"

ការសង្ស័យរបស់នាង បានទទួលចម្លើយនៅវេលាបន្ទាប់ ដោយសំឡេងផ្ទុះរបស់គ្រាប់បែក។

នាងក្រមុំបើកភ្នែកធំៗដោយភាពស្រឡាំងកាំង ប្រឹងរើបម្រះដើម្បីឲ្យរបូតពីដៃរបស់គេ ហើយរត់ទៅមើលថាមានអ្វីកើតឡើង ប៉ុន្តែបែរជាត្រូវព្រះអង្គម្ចាស់ឱនមកថើបបបូរមាត់។

វេលានោះ អ្នកនៅមុខបន្ទប់ក៏រត់ទៅតាមសំឡេងគ្រាប់បែក ដើម្បី



Scanned by CamScanner

មើលថាមានអ្វីកើតឡើង ខណៈដែលព្រះអង្គម្ចាស់ឆ្លៀតឱកាសនោះថើបបបូរមាត់នាងទាល់តែពេញចិត្ត ទើបខ្សឹបប្រាប់។

"ខ្ញុំព្រមទទួលខុសត្រូវនាងដោយការរៀបការ ខានស្អែកនឹងប្រកាសពិធីភ្ជាប់ពាក្យ"

"ហ៊ឹម?" នាងធ្វើមុខដូចមិនចង់ជឿ។

"ចាំមើលទៅ" គេតប និងព្រមរសាយរង្វង់ដៃ ចំពេលដែលហ៊ុលសែន គោះទ្វារ ហើយបើកចូលមក។

"កន្លែងធ្វើការរបស់ អ៊ីម៉ាម ជាប់នឹងព្រះរាជដំណាក់ត្រូវបំផ្ទុះ"

មិខាអ៊ីល មិននិយាយអីក្រៅពីដើរចេញឲ្យឆ្ងាយ ទុកឲ្យប្រធានក្រុមអង្គរក្សមើលមកជាការសួរដោយការសង្ស័យ ព្រោះអាកប្បកិរិយាមិនងឿងឆ្ងល់របស់ព្រះអង្គម្ចាស់ វាគួរឲ្យចាប់អារម្មណ៍ណាស់សម្រាប់គេ។ គេស្ទើរតែជឿជាក់ថាទ្រង់ដឹងរឿងច្បាស់ ឬមិនអីចឹង...ហ៊ុលសែនចងចិញ្ចើមពេលដែលគិតថា មិខាអ៊ីល ច្បាស់ជាតបតខ្លះហើយ។

"បញ្ជូនមនុស្សទៅមើលថា អ៊ីម៉ាម មានប្រតិកម្មយ៉ាងណា ហើយត្រឡប់មកវិញនិយាយឲ្យស្ដាប់បន្តិច ល្អទេ"

បញ្ជារបស់ចៅហ្វាយ ធ្វើឲ្យប្រធានក្រុមអង្គរក្សទទួលបញ្ជាដោយទឹកមុខរីករាយ មុននឹងដើរចេញពីបន្ទប់ ទុកឲ្យនាងក្រមុំនិងព្រះអង្គម្ចាស់នៅជាមួយគ្នាតែពីរនាក់ម្ដងទៀត។

ពេលគេងាកមករក នាងក៏ថយក្រោយក្រេស។

"ធ្វើបែបនេះមិនបាន"

"ហេតុអី?" គេសួរ ហើយដេញនាងឲ្យទ័ល។

"គឺយើងមិនទាន់ត្រូវជាស្ដីនឹងគ្នា ខ្ញុំខូចឈ្មោះ កុំ កុំ មិនអីចឹង..." នាងសម្រេចចិត្តប្រើជម៌ក្ដៅទៅលើគេ ហើយពេលគេចូលមកដល់ក៏លើកដៃប្រុងទះតប់ ប៉ុន្តែត្រូវគេស្រវាចាប់ជាប់ ទើបនាងប្រឹងគ្រវែងខ្លួន ដែលលើកនេះក៏ត្រូវទប់ស្កាត់ដោយជង្គង់ចង្វាក់ មិនព្រមឲ្យនាងធ្វើទៀត។

អ្នកកំលោះចាប់នាងជាប់ មិនឲ្យរើបម្រះបាន ហើយជ្រប់មុខនឹងកសខ្ចីពីក្រោយ ឱបបែបនោះយ៉ាងយូរ ទាល់តែនាងព្រមឲ្យឱបតាមសម្រួល ពេលដឹងហើយថាគេអាចយកឈ្នះនាងបានស្រួល។

មិខាអ៊ីល ទប់ស្កាត់នាងបែបនោះបានស្រួល ដោយភាពមាំមួននៃរាងកាយរបស់គេ មិនបានអន់ក្នុងរឿងការពារខ្លួនឯងដូចដែលនាងគិតអីបន្តិច។

"យើងនឹងភ្ជាប់ពាក្យជាមួយគ្នា ខ្ញុំអះអាង ខ្ញុំមិនដោះលែងនាងទេ នាងមានតម្លៃចំពោះខ្ញុំ ជួយខ្ញុំច្រើនដងហើយ"

គេនិយាយរអ៊ូៗ ហើយថើបប្រឡោះករបស់នាងខ្សឹតៗ។

"លោកមិនបានស្រឡាញ់ខ្ញុំ តើរៀបការដើម្បីអី ព្រោះខ្ញុំជួយជីវិតរបស់លោកឬ? វាជាតួនាទីរបស់ខ្ញុំទេ"

ការតវ៉ារបស់នាង ធ្វើឲ្យគេស្ងប់ស្ងាត់ ទើបនាងឆក់ឱកាសនោះនាំខ្លួនឯងចេញពីរង្វង់ដៃនោះ។

"នាងទៅវិញទេដែលមិនបានស្រឡាញ់ មិនមែនខ្ញុំ តែជានាង"



# ១៣

"អ៊ូយ..." មិខាអ៊ីល ឧទាន ដៃក៏រសាយពីរាងកាយរបស់នាងក្រមុំ បើកឱកាសឲ្យនាងបានងើបចេញ ទៅឈរនៅជ្រុងតុម្ខាងទៀត និងសម្លឹងមើលមុខគេដោយទឹកមុខមាំ។

"លោកកំពុងដេញ អ៊ីម៉ាម ឲ្យទ័ល...ដូចដែលគេដេញលោក"

ពេលសួររួចហើយ ហេយ្យូ ក៏ជឿជាក់ចំពោះគំនិតខ្លួនឯង រួមទាំងបានប្រសព្វនឹងភ្នែកមុតស្រួចដែលមើលមក ក៏រឹតតែច្បាស់។

"ខ្ញុំចូលចិត្តនាងត្រង់នេះ" គេងក់ក្បាល។

"ហើយពេលនេះគេយ៉ាងម៉េចហើយ ?"

នាងសួរពេលគិតដល់ពេលដែលគេទទួលទូរសព្ទអម្បាញ់មិញ វាច្បាស់ជាការរាយការណ៍ពី ហ៊ុលសែន។

"គេកំពុងរត់ ដូចដែលខ្ញុំរត់ ប៉ុន្តែសំដៅទៅសមុទ្រខ្សាច់ មិនបានលោតចូលទន្លេដូចដែលយើងធ្វើ"

គេតបដោយកែវភ្នែកមានពន្លឺផ្លេកៗ។



"ការពិតលោកគួរធ្វើយូរណាស់ហើយ"

"ពេលនោះខ្ញុំគិតផ្សេង មិនមែនពេលនេះ តែណ្ហើយចុះ ខ្ញុំគិតថានាងគួរសម្រាក យើងស្រែ្តសច្រើនម៉ោងហើយ តោះទៅសម្រាក"

ពេលគេឲ្យឱកាស ហេយ្យូ ក៏ទៅភ្លាម ប៉ុន្តែដើរមិនបានប៉ុន្មានជំហាន ក៏ត្រូវគេចាប់ថើបម្តងទៀតឲ្យទាល់តែបាន ជាការអនុញ្ញាតឲ្យនាងចេញពីបន្ទប់ និងឲ្យអ្នកផ្សេងចូលមកម្តង។ គេនិយាយជាមួយ ហ៊ុលសែន យ៉ាងណាខ្លះ នាងមិនដឹង ដឹងត្រឹមថាខ្លួនឯងកាន់តែគ្មានសុវត្ថិភាពពេលនៅជាមួយគេ។

តើនាងគួរធ្វើយ៉ាងណាទើបល្អទៅ ពេលតាមគេមកដល់ទឹកដីដោយការព្រួយបារម្ភ ប៉ុន្តែគេបែរជាការពារខ្លួនឯងបានល្អជាងការគិតទៅទៀត...គេបោកនាង។

គេកែប្រែស្ថានការណ៍របស់ខ្លួន ពីក្តាន់ដែលត្រូវរត់គេចពីការប្រមាញ់ ទៅជាខ្លាតាមប្រមាញ់ម្តង វាមានការកែប្រែលឿនខ្លាំងណាស់ អីចឹងមានន័យថាពេលរត់គេច គេត្រៀមខ្លួនទប់ទល់រួចរាល់ហើយ ហើយពេលនេះក៏ចាត់ការបានច្រើនដែរ។

ហេយ្យូ ប្រាប់ខ្លួនឯងថាព្រះអង្គម្ចាស់ មិខាអ៊ីល មិនមែនគ្មានចង្កូមដូចការគិត នាងប្រមាថថ្វីដៃគេពេកហើយ ទើបត្រូវគេកៀងចូលទ្រុងបានដូចពេលនេះ។

ថ្ងៃថ្មី...

គ្រប់គ្នាត្រៀមខ្លួនតាំងពីព្រឹក ព្រោះថ្ងៃនេះជាថ្ងៃរាជាភិសេករបស់ព្រះអង្គម្ចាស់ក្សត្រី រ៉ននី ឡើងគ្រងរាជ្យជាសម្តេចព្រះមហាក្សត្រីនៃរាជាណាចក្រសាគីស្ថាន បន្ទាប់ពីទ្រង់ងរង់ក់អស់រយៈពេលយ៉ាងយូរ។

អង្គរក្សគ្រប់រូបពាក់គ្រឿងហៀតម្លៃថ្លៃ ដែលព្រះអង្គម្ចាស់រៀបចំឲ្យ រួមទាំងគ្រឿងហៀសខ្មៅរបស់ ហោយ្យុ ដែរ។ នាងមិនចាប់អារម្មណ៍សម្លៀក-បំពាក់ស្អាតៗដែលបញ្ជូនមកឲ្យរាប់សិបប្រអប់ គ្មានពេលបើកមើលសូម្បីតែមួយប្រអប់ ព្រោះដឹងថាយ៉ាងណាក៏មិនសក្តិសមនឹងការងាររបស់ខ្លួន។

អង្គរក្សទាំងអស់ រួមទាំង ហោយ្យុ ដែរ បំបែកគ្នាការពារជុំវិញព្រះអង្គម្ចាស់ មិនបូករួមអង្គរក្សដែលត្រូវព្រះអង្គម្ចាស់ក្សត្រីបញ្ជូនមក ធ្វើតួនាទីរបស់ខ្លួនដោយមិនមើលបំណាំគ្នា តែមានគោលបំណងតែមួយប៉ុណ្ណោះ គឺការពារព្រះអង្គម្ចាស់ឲ្យអស់ពីសមត្ថភាព។

ពិធីដ៏អធឹកអធមនៅថ្ងៃនេះ ដំណើរការយ៉ាងរលូនតាំងពីដើមរហូតដល់ចប់ ដោយគ្មានអ្នកណាសួររក អ៊ីម៉ាម នេះមកពីព្រះអង្គម្ចាស់-ក្សត្រីតែងតាំងជំនួយការរបស់ អ៊ីម៉ាម ឡើងធ្វើពិធីជំនួស មិនឲ្យមានខ្វះចន្លោះ ពេលទ្រង់ដឹងថា អ៊ីម៉ាម រត់គេចខ្លួនទៅហើយ។

ចាត់ទុកថាជាការជួយគ្នារវាងបងប្អូនដោយស្វ័យប្រវត្ត ដោយគ្មានការអង្វរករអើទាំងអស់ ជាការជួយអស់ពីសមត្ថភាពពេលទ្រង់ដឹងថាបងប្រុសកំពុងមានគ្រោះថ្នាក់ និងកំពុងតែមានការប្រយុទ្ធគ្នាស្ងាត់ៗជារលកក្រោមទឹកនៅព្រះបរមរាជវាំង រវាងអ្នករក្សាផលប្រយោជន៍របស់ព្រះមហាក្សត្រ និងអ្នកដឹកនាំខាងសាសនា។

គ្រប់យ៉ាងដំណើរការយ៉ាងរលូន ពេលសម្តេចព្រះមហាក្សត្រីស្តេចយាងចុះពីបល្ល័ង្ក បន្ទាប់ពីពាក់មកុដរួចរាល់ យាងកាត់ទាំងព្រះញាតិវង្សានុវង្ស គណៈរដ្ឋមន្ត្រី គណៈទូតទូទាំងពិភពលោក មកដល់ព្រះអង្គម្ចាស់ មិខាអ៊ីល ដែលឈរលោយឡំនឹងព្រះអង្គម្ចាស់ដែលជាស្តេចគ្រាញ់សាមន្តរដ្ឋនៅសាគីស្ថាន។

ទ្រង់មិនបាននិយាយអ្វី ក្រៅពីងក់ក្បាលដាក់ ដូចចង់អរគុណដែលបងប្រុសបានជួយ និងរាក់ទាក់ព្រះអង្គម្ចាស់ទាំងឡាយ ដែលឈរតម្រៀបជួរគ្នា ហើយស្តេចយាងទៅកាន់ទីគង់ប្រថាប់ ពេលល្ងាចក៏យាងមកម្តងទៀត ដែលជាពិធីរៀបចំឡើងជាពិសេស ដើម្បីអបអរការឡើងគ្រងរាជ្យ។

ហ៊ុលសែន និងកូនចៅក្រោមការបង្គាប់បញ្ជា នាំគ្នាដកដង្ហើមធំជូរទ្រូងខ្យាក ពេលគ្រប់យ៉ាងរលូនល្អ ពេលព្រះអង្គម្ចាស់សម្រេចចិត្តវាយបក អ៊ីម៉ាម យ៉ាងខ្លាំងក្លា បន្ទាប់ពីត្រូវដេញប្រមាញ់អស់រយៈពេលយ៉ាងយូរ។

ពួកគេទៅប្រជុំគ្នានៅកន្លែងសម្រាក ដែលជាផ្នែកមួយរបស់ព្រះបរមរាជវាំង ដើម្បីត្រៀមខ្លួនចូលរួមកម្មវិធីជប់លៀងពេលរាត្រី។

"ហ្ស៊ីក ត្រូវការជួបនាង" ហ៊ុលសែន ដើរមកប្រាប់ ពេលឃើញ ហោយ្យុ គិតតែនៅក្រៅបន្ទប់ មិនព្រមចូលទៅក្នុងបន្ទប់ធ្វើការរបស់ព្រះអង្គម្ចាស់។

នាងក្រមុំដកដង្ហើមធំ ហើយដើរទៅឈរស្ងប់ស្ងៀមនៅមុខតុធ្វើការដោយការប្រុងប្រយ័ត្ន ខ្លាចគេកេងចំណេញទៀត។

ព្រះអង្គម្ចាស់រូបសង្ហាក្នុងឈុតកាហ្វិយេពណ៌សស្អាត ដើរវាងតុធ្វើការរបស់ខ្លួន មកឈរក្បែរនាងហើយនិយាយ។

"យប់នេះត្រូវតែងខ្លួនឲ្យស្អាត សម្លៀកបំពាក់បញ្ជូនឲ្យហើយ មិនឃើញឬ?"

"ឃើញហើយ"

"រើសមួយឈុតទៅ"



សំឡេងនោះស្តាប់ទៅកក់ក្តៅ កែវភ្នែកដែលនាងមើលមិនឃើញ

សម្លឹងមើលមកសរសៃសក់និងកញ្ចឹងកដោយមានបំណង។

"មិនបាន"

ពេលនាងឆ្លើយបែបនេះ គេក៏ដកដង្ហើមធំ។

"នេះចង់មិនធ្វើតាមឲ្យបានមែនទេ?"

"ខ្ញុំមានតួនាទី"

"រៀបការហើយនឹងឲ្យលាឈប់"

នាងនៅស្ងៀម មិនតបត។

"ស្អែកប្រកាសភ្ជាប់ពាក្យ ខានស្អែករៀបការ"

ប្រយោគបន្ទាប់របស់ព្រះអង្គម្ចាស់ ធ្វើឲ្យនាងបើកភ្នែកធំៗ តែមិខាអ៊ីល បែរជាសម្លឹងមើលនាងដោយការដាក់ទោស បន្ទាប់មកក៏ដើរចេញពីបន្ទប់ ទុកឲ្យនាងនៅម្នាក់ឯង។

ព្រះអង្គម្ចាស់បាត់ខ្លួនទៅណាក៏មិនដឹងពេញមួយថ្ងៃ ជាមួយនឹងអង្គរក្សប្រុសៗទាំងអស់ លើកលែងតែនាងដែលត្រូវទុកចោលឲ្យយាមបន្ទប់ជាលើកដំបូងតែម្នាក់ឯង មានទាហានអង្គរក្សរបស់ព្រះអង្គម្ចាស់-ក្សត្រីនៅត្រៀបត្រា។

ហេយ្យូ ចេញមកឈរនៅមុខបន្ទប់ មើលឆ្វេងមើលស្ដាំ មិនដឹងថាមនុស្សម្នាបាត់ទៅណាអស់ មិនឃើញប្រាប់អីមួយម៉ាត់ វាដូច មិខាអ៊ីល មានចេតនាកាល់នាងចេញពីតួនាទី ហើយនាងក៏ត្រូវព្រមទទួលស្គាល់នៅពេលនោះថា ការពិតទៅគេមិនត្រូវការនាងឲ្យធ្វើតួនាទីនេះ ត្រឹម ហ៊ុលសែន និងកូនចៅ រួមទាំងគេខ្លួនឯង ក៏អាចមើលថែខ្លួនឯងបានដោយមិនបាច់ពឹងពាក់នាងអីបន្តិច។

ព្រះអង្គម្ចាស់ចាំបាច់ត្រូវទទួលយកនាង ព្រោះព្រះអង្គម្ចាស់ក្សត្រីបដិសេធមិនព្រមទទួលនាងធ្វើជាអង្គរក្សម្នាក់ទៀតរបស់ទ្រង់ទៅវិញទេ

រហូតមកដល់ពេលនេះដែលគេមិនចាំបាច់ប្រើនាងតទៅទៀត។

នាងក្រមុំឈររវេរាមិនយូរប៉ុន្មាន ក៏មានស្រីបម្រើជាច្រើនមកពីរាជដំណាក់របស់ព្រះអង្គម្ចាស់ក្សត្រីមករក ដែលធ្វើឲ្យនាងងឿងឆ្ងល់។

"ពួកខ្ញុំត្រូវបញ្ជាឲ្យមកមើលថែអ្នកនាង"

ស្រីៗបីបួននាក់នោះតុបតែងខ្លួន ដោយឯកសណ្ឋានស្រីបម្រើផ្ទាល់ព្រះអង្គ ដែលដើរតាមព្រះអង្គម្ចាស់ក្សត្រីកាលពីព្រឹកនោះឯង។

"មើលថែរឿងអី?"

"អ្នកនាងត្រូវតែងខ្លួនជាថ្មី ហ្ស៊ីក ចេញរាជបញ្ជាឲ្យពួកយើងមើលថែគូដណ្ដឹងឲ្យទ្រង់ យប់នេះ ហ្ស៊ីក នឹងណែនាំអ្នកនាងក្នុងឋានៈជាគូដណ្ដឹង នៅចំពោះមុខភ្ញៀវពន្លឺដែលមកចូលរួម ទើបពួកយើងត្រូវបញ្ជូនមកទីនេះ មករៀបចំឲ្យអ្នកនាងត្រៀមខ្លួនសម្រាប់កម្មវិធីយប់នេះ"

"ឈប់សិន ប្រហែលមានការយល់ច្រឡំទេដឹង" ហេយ្យូ និយាយហើយក៏ឈានជើងថយក្រោយ។

"ម៉ោះ បើអ្នកនាងឈ្មោះ គីម ហេយ្យូ គឺមិនខុសទេ"

និយាយចប់ ស្រីបម្រើទាំងនោះក៏កៀងនាងឡើងជណ្ដើរ សំដៅបន្ទប់សម្រាក ដោយនាងមិនអាចតវ៉ាបាន ព្រោះនិយាយយ៉ាងណាក៏គ្មានអ្នកណាស្ដាប់នោះឯង។

"សម្រេចថាព្រះរៀមមិនទទួលតំណែងរដ្ឋមន្ត្រីក្រសួងណាទេឬ?"

សម្ដេចមហាក្សត្រីសួរ ពេល ហ្ស៊ីក មិខាអ៊ីល ចូលគាល់ដល់ទីគង់ប្រថាប់។



"ជំនួសការធ្វើទូត ម៉េចក៏ព្រះរៀមមិនធ្វើរដ្ឋមន្ត្រីក្រសួងការបរទេសទៅ?"



Scanned by CamScanner

សំណួរទីពីរតាមមកទៀត។

"ទ្រង់ចង់ទៅកូរ៉េខាងត្បូងជាមួយស្រីម្នាក់នោះឬ?"

មកដល់សំណួរទីបី ទើបព្រះអង្គម្ចាស់ងាកមកមើលមុខអ្នកសួរ ហើយងក់ក្បាល។

"អនុជគិតអីចេះខុស"

សម្តេចព្រះមហាក្សត្រីគិតថារឿងនេះនឹងកើតឡើងតាំងពីថ្ងៃនោះម្ល៉េះ ហើយវាក៏កើតឡើងពិតមែន។

"ភ្ជាប់ពាក្យស្នេហ៍ រៀបការខានស្នេហ៍លក្ខណៈផ្ទៃក្នុងឬ?"

"ទូលបង្គំគ្មានអ្នកណាទេ សល់ខ្លួនមួយ និងសាច់ញាតិមិនប៉ុន្មាននាក់"

គេតបដោយសំឡេងរាបស្មើ។

"ទីបំផុត...អនុជក៏ត្រូវបាត់បង់បងប្រុសមែនឬ?" ទ្រង់សួរដោយមិនចង់ជឿ។

"ទូលបង្គំមិនបានទៅណាទេ ទ្រង់ចង់ទៅកូរ៉េខាងត្បូងពេលណាក៏បាន មានបញ្ហាអីនិយាយគ្នាតាមទូរសព្ទបាន ទូលបង្គំនៅតែផ្តល់ការពិភាក្សាបានជានិច្ច"

វេលានោះព្រះអង្គម្ចាស់ក្សត្រីនៅស្ងៀម សម្លឹងមើលមុខបងប្រុសដូចចង់ចងចាំជារៀងរហូត។

"ទ្រង់មានព្រះបញ្ញាញាណ មិនយូរទេអាចបំពេញរាជកិច្ចបានរលូន ហើយថ្ងៃណាមួយទ្រង់នឹងជួបអ្នកដែលទ្រង់សព្វព្រះទ័យ និងត្រូវការរៀបអភិសេកជាមួយ" ព្រះអង្គម្ចាស់និយាយតិចៗឲ្យបានឮតែពីរនាក់។

"ព្រះរៀមក៏ដឹងថារកអ្នកដែលស្រឡាញ់ស្តេចស្រីពិបាកណាស់ តើ



មានមនុស្សប៉ុន្មាននាក់ដែលសុខចិត្តលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីតួនាទីដ៏ធ្ងន់នេះទៅ"

"ទ្រង់នឹងបានជួប...ទូលបង្គំជឿជាក់"

និយាយហើយ គេក៏ថ្វាយបង្គំលាព្រះមហាក្សត្រីនៃសាគីស្ថានជាលើកដំបូង ព្រោះតាំងពីតូចដល់ធំ មិនធ្លាប់ឱនក្បាលដាក់ប្អូនស្រីម្តាយទីទេ។

ពេលព្រះរៀមដើរចេញផុតពីព្រះរាជដំណាក់ ព្រះមហាក្សត្រីយានីក៏យាងមកដល់។

"មិខាអ៊ីល មកធ្វើអី ត្រូវការគ្រប់គ្រងក្រសួងណាទៀត?"

ទាំងសំឡេងទាំងសំណួររបស់សម្តេចព្រះមាតា សុទ្ធតែមិនធ្លាប់ពេញចិត្តនឹងបុរសដែលទើបតែដើរចេញទៅ។

"ព្រះរៀមប្រគល់ឲ្យអស់ហើយ...បុត្រីទូលព្រះមាតាហើយ"

"ហើយគេមកធ្វើស្អីទៀត ធ្វើដល់ថ្នាក់ អ៊ីម៉ាម រត់បាតជើងសព្រាតទៅហើយ នៅមកធ្វើស្អីទៀត"

"ព្រះរៀមគ្រាន់តែមកលាប៉ុណ្ណោះ ទ្រង់ទៅធ្វើជាទូតប្រចាំនៅកូរ៉េខាងត្បូង"

"ហ៊ឹ! ទៅធ្វើជាទូត ឬគ្រប់គ្រងក្រសួងការបរទេស"

"សម្តេចព្រះមាតា ឈប់យល់ច្រឡំទៅ បើតំណែងព្រះមហាក្សត្រក៏ព្រះរៀមមិនត្រូវការផង ហើយយកតំណែងសេនាបតីទៅធ្វើអី"

"បុត្រីនិយាយស្អី មាតាមិនយល់" ព្រះមហាក្សត្រិយានីមានសវនីយ៍ដោយការសង្ស័យ។

"អ៊ីចឹងសម្តេចព្រះមាតាយល់ទៅ ខ្ញុំម្ចាស់សុំឲ្យព្រះរៀមរៀបការជាមួយខ្ញុំម្ចាស់ តែព្រះរៀមបដិសេធ មិនព្រមឡើងគ្រងរាជ្យ ហើយគាត់



ត្រូវការស្អីទៀតសម្ដេចព្រះមាតា ?"

ការអធិប្បាយនេះវាច្បាស់លាស់ណាស់ធ្វើឲ្យព្រះមហាក្សត្រិយានី ភាំងជាច្រើនដង្ហើមដោយមិនចង់ជឿ។

"មែនឬ ?" ទ្រង់សួរបញ្ជាក់ ប៉ុន្តែសម្ដេចព្រះមហាក្សត្រីលែងមានសវនីយ៍អីទៀត ហើយយាងចេញពីទីគង់ប្រថាប់នោះទៅ។



# ១៤

ហេយ្យូ ត្រូវចាប់ងូតទឹក ខាត់ស្បែកទាល់តែភ្លឺស្អាតផូរផង់ ពាក់កាឡាបៃយ៉ាពណ៌ស្រស់ រំលេចពណ៌ផ្លែក ឃ្លុំហ៊ិយ៉ាបពណ៌សមនឹងពណ៌ស្រស់ចុះពីបន្ទប់មកខាងក្រោម ដែល មិខាអ៊ីល និងអង្គរក្សទាំងឡាយកំពុងរង់ចាំ។

ព្រះអង្គម្ចាស់ងើយមើលនាង តាំងពីឈានជើងជាន់ជណ្ដើរកាំដំបូង រហូតដល់កាំចុងក្រោយ ដោយមិនប៉ប្រិចភ្នែក ធ្វើឲ្យ ហេយ្យូ មានអារម្មណ៍ចង់រមួលជើងម្ដងៗនោះមកពីមិនគិតថាអ្វីដែលគេបាននិយាយនឹងធ្វើមែនទែន។

នាងគិតថាវាជាការនិយាយឲ្យត្បែរចពីមាត់របស់មនុស្សប្រុសម្នាក់ដើម្បីឲ្យមនុស្សស្រីជឿ ហើយក៏ភ្លេចសម្ដីរបស់ខ្លួនឯង។

ហេយ្យូ ឈរមើលមុខមិត្តរួមការងារទាំងឡាយ ដែលមើលមកនាងមិនដាក់ភ្នែកដោយការសរសើរ បន្ទាប់មកពួកគេក៏ធ្វើដំណើរសំដៅទៅព្រះរាជដំណាក់ដែលនៅមិនឆ្ងាយ។



មិនយូរប៉ុន្មានពួកគេក៏ធ្វើដំណើរទៅដល់។ មិខាអ៊ីល នាំនាងចូល

ទៅក្នុងកម្មវិធីក្នុងនាមរបស់ ហ្ស៊ីក មិខាអ៊ីល អាប់ឌុលឡោះ ឧស្មាន់ ឯកអគ្គរដ្ឋទូតរបស់សាគីស្ថាន ប្រចាំកូរ៉េខាងត្បូង និងកញ្ញា គីម ហេយ្យូ ជាគូដណ្ដឹង។

ជាញឹកញាប់ដែលនាងទច់ដំណើរ ចង់ដកថយទៅនៅជាមួយក្រុមអង្គរក្សដូចទម្លាប់ ប៉ុន្តែអ្នកដែលដើរនាំមុខឈរចាំរហូត ហើយលើកចុងក្រោយក៏ត្រូវគេស្រវាទាញដៃឲ្យដើរតាម មិនឲ្យយឺតយ៉ាវបានទៀត ហើយបន្ទាប់ពីនោះ មិនថាដើរកាត់អ្នកណា នាងនឹងត្រូវណែនាំឲ្យអ្នកនោះស្គាល់។

**ពិធីជប់លៀងដំណើរការរហូតដល់សម្ដេចមហាក្សត្រី ស្ដេចយាង** ត្រឡប់ទៅវិញ រួមទាំងព្រះញាតិវង្សានុវង្ស និងអ្នកឯទៀតដែរ។

មិខាអ៊ីល បណ្ដើរគូដណ្ដឹងចេញពីទីនោះដែរ បន្ទាប់ពីសម្ដេចមហាក្សត្រីយាងទៅវិញមិនយូរប៉ុន្មាន ដោយគេចាប់ដៃនាងជាប់ មានអង្គរក្សការពារពីមុខពីក្រោយដោយការសប្បាយចិត្ត ដែលកម្មវិធីសំខាន់ដំណើរការយ៉ាងរលូន គ្មានឧបសគ្គ។

ខណៈពេលធ្វើដំណើរត្រឡប់ទៅវិញនោះឯង ឡានមួយគ្រឿងក៏បើកភ្លើងហ្វាតាមពីក្រោយ ហើយរត់យ៉ាងលឿនមកជិត ព្រមទាំងបាញ់រះមិនដកដៃ។

គ្រប់គ្នាងាកទៅមើល តាំងពីបានឮសំឡេងបន្ថែមល្បឿនខុសពីធម្មតាម្ល៉េះ ពេលវាបើកមកជិតក៏នាំគ្នាគេច និងបាញ់ទៅវិញដោយស្វ័យប្រវត្ត។

ហេយ្យូ កន្ត្រាក់ដៃព្រះអង្គម្ចាស់ឲ្យគេចតាមសញ្ជាតិញ្ញាណរបស់ខ្លួន ហើយប្រើរាងកាយខ្លួនឯងបាំងគេ ឯអ្នកឯទៀតក៏លោតបាំង



ព្រះអង្គម្ចាស់និងនាង ប៉ុន្តែគ្រាប់កាំភ្លើងដែលជះមកដូចចង់ទម្លុះគ្រប់គ្នាទៅរកបុគ្គលសំខាន់ ដែលគ្រាប់កាំភ្លើងនោះមកពីបុគ្គលដែលនាងធ្លាប់សង្ស័យនោះឯង។

អង្គរក្សនិងទាហានមួយចំនួនដួលឲ្យរណោល ឯមួយចំនួនទៀតបាញ់រះវិញ រហូតដល់អ្នកបើកឡានបើកបុកជញ្ជាំង ហើយស្ងប់ស្ងាត់។

អង្គរក្សមួយចំនួនដេញតាមចាប់វា សល់តែក្រុមរបស់នាងដែលមាន ហ៊ុលសែន ជាមេក្រុម នាំគ្នាឈ្ងោកមើលសុវត្ថិភាពព្រះអង្គម្ចាស់លើកលែងតែនាងក្រមុំ។ លទ្ធផលដែលនាងលោតបាំងគេ ធ្វើឲ្យគ្រាប់រត់មកបោះឆ្អឹងជំនីពីរគ្រាប់ផ្ទួនៗ ឈាមហូរដូចទឹក។

"ឃ្យូ!"

សំឡេងស្រែករបស់ព្រះអង្គម្ចាស់បន្លឺឡើង ពេលខ្លួនទន់ល្ហួករបស់នាងក្រមុំដួលនៅក្នុងដៃ មិនបានសន្លប់ភ្លាមៗ តែគ្មានកម្លាំងកំហែង។

"ឲ្យឆាប់ឡើង ហ៊ុលសែន ឲ្យឆាប់ឡើង!"

សំឡេងដុកនោះឮនៅក្បែរត្រចៀក បន្ទាប់មកគ្រប់យ៉ាងក៏រលត់។

**ពេលបើកភ្នែកឡើង ហេយ្យូ មើលឃើញមុខព្រះអង្គម្ចាស់ឱនមក** ជិត មានខ្សែរយឹងរយោងពេញខ្លួន ហើយក៏លង់លក់ម្ដងទៀត។

ពេលភ្ញាក់ដឹងខ្លួនម្ដងទៀត ខ្សែទាំងនោះក៏បាត់ពីខ្លួន សល់តែខ្សែសេរ៉ូមមួយប៉ុណ្ណោះ។ នាងរិះតែដេកលក់ម្ដងទៀតទៅហើយ បើមិនបានឮសំឡេងហៅដែលស្គាល់ច្បាស់ និងមុខសង្ហាដែលឱនមកជិត។

"ឃ្យូ...ដឹងខ្លួនហើយ...ដឹងខ្លួនហើយ"

សំឡេងរបស់ព្រះអង្គម្ចាស់ ធ្វើឲ្យនាងបើកភ្នែកមើលគេឲ្យច្បាស់ព្រមទាំងសួរដោយការព្រួយបារម្ភ។



"ទ្រង់មិនអីទេមែនទេ?"

"មែន ខ្ញុំមិនអីទេ...តែនាងវិញ...យ៉ាប់ណាស់" ហ្ស៊ីក តប និងមើលមុខនាងដោយការព្រួយបារម្ភខ្លាំង។

"មិនអីទេ" នាងប្រាប់គេ ហើយក៏លង់លក់ម្តងទៀត។

នៅក្នុងយល់សប្ត នាងឃើញម្តាយដែលមកតាមហៅនាងត្រឡប់ទៅផ្ទះ។

'ត្រឡប់ទៅផ្ទះយើងវិញទៅកូន ត្រឡប់ផ្ទះរបស់យើង ម៉ាក់កំពុងរង់ចាំ កំពុងរង់ចាំ'

ហើយនាងក៏បើកភ្នែក ឃើញ មិខាអ៊ីល នៅត្រង់នោះដដែល គេមិនបានទុកនាងចោល រួមទាំងក្រុមអង្គរក្សទាំងឡាយ ដែលសុទ្ធតែឈ្ងោកមុខមកមើលនាង ហើយប្រាប់ថា ៖

"ដឹងខ្លួនហើយ ពួកយើងយាមនាងច្រើនថ្ងៃហើយ ពិធីមង្គលការរបស់ ហ្ស៊ីក ត្រូវលើកពេលព្រោះកូនក្រមុំត្រូវគ្រាប់ ដឹងខ្លួនហើយពេលនេះ"

សម្តីនេះជារបស់ ហ៊ុលសែន ដែលឱនមកមើលដោយទឹកមុខព្រួយបារម្ភ។

គ្រូពេទ្យនិងគិលានុបដ្ឋាយិកានាំគ្នាចូលមកនៅវេលាបន្ទាប់ ហើយនាងក៏ត្រូវត្រួតពិនិត្យអាការៈម្តងទៀត តែកម្រើកខ្លួនមិនបាន។

ថ្ងៃបន្ទាប់មកគ្រែរបស់នាងក៏ត្រូវវៃឲ្យក្បាលលើកឡើងខ្ពស់ អាចមើលឃើញគ្រប់គ្នាដែលឈរនៅជុំវិញគ្រែ ដោយ មិខាអ៊ីល នៅជិតជាងគេ។ គេមិននិយាយ គិតតែមើលនាងមិនដាក់ភ្នែក និងដកដង្ហើមធំ។

អាហារពេលដំបូងជាស៊ុបបន្លែរាវៗ ញ៉ាំបានប៉ុន្មានស្លាបព្រាក៏ឆ្អែត ព្រោះចង់ដេកច្រើនជាង។ បីថ្ងៃក្រោយមក នាងក៏គិតតែស៊ីដេកៗ



មិននិយាយស្តី ឯក្រុមអង្គរក្សក៏បាត់ស្រមោល សល់តែ មិខាអ៊ីល ម្នាក់ប៉ុណ្ណោះ។

គេបញ្ចុកអាហាររាវដល់នាង និងនៅក្បែរគ្រប់ពេល រហូតដល់នាងធូរស្រាល។

"ទ្រង់...មិនទៅធ្វើការទេឬ?" នាងសួរពេលនឹកឃើញ។

"ផ្ទេរឲ្យសម្តេចព្រះមហាក្សត្រីអស់ហើយ សល់តែតួនាទីមួយប៉ុណ្ណោះ...នាងជាហើយត្រឡប់ទៅកូរ៉េខាងត្បូងវិញ" គេឆ្លើយ និងមើលមុខនាងមិនដាក់ភ្នែក បន្ទាប់មកក៏ងើបមកឱនថើបសៀតផ្កា និងចាប់ដៃនាងក្តោបបែបនោះ។

"សម្តេចព្រះមហាក្សត្រីមានរដ្ឋមន្ត្រីចាំជួយហើយ ខ្ញុំមិនបាច់ទៅចេះដឹងទេ ទុកឲ្យទ្រង់ធ្វើដោយខ្លួនឯងទៅ ទ្រង់ឆ្លាត"

"លោកមិនបារម្ភទេឬ?"

"ព្រោះតែបារម្ភហ្នឹងហើយ ទើបសម្តេចព្រះមហាក្សត្រីមិនព្រមធ្វើជាមនុស្សធំសោះ ត្រូវបណ្តោយឲ្យវាបែបនេះ ទើបទ្រង់មានទំនួលខុសត្រូវ"

"ទ្រង់ស្រឡាញ់លោក" នាងនិយាយតាមការគិត ចង់ឲ្យគេដឹងដូចដែលនាងដឹង។

"មិនយូរប៉ុន្មានទ្រង់នឹងភ្លេច សម្តេចព្រះមាតារបស់ទ្រង់ខ្លាចខ្ញុំដណ្តើមយកគ្រប់យ៉ាង បណ្តោយឲ្យវាបែបនេះល្អហើយ"

"លោកមិនស្រឡាញ់ទ្រង់ទេឬ?"

"ស្រឡាញ់ដូចបងប្អូន មិនធ្លាប់ស្រឡាញ់ជាអ្វីផ្សេង ទ្រង់ដឹងច្បាស់"



នាងស្តាប់គេហើយក៏ដកដង្ហើមធំ ខណៈដែលគេឱនមកជិត ថើប

ថ្ពាល់នាងខ្សឹតៗ បញ្ចប់ការចរចាត្រឹមហ្នឹង។

**ទម្រាំតែ ហេយ្យូ រឹងមាំអាចត្រឡប់មកដំណាក់វិញបាន ប្រើពេល**
មួយខែពេញនៅមន្ទីរពេទ្យ។

"ស្អីហ្នឹង ?" នាងក្រមុំសួរ ពេល មិខាអ៊ីល ដើរចូលមកដោយមានសម្លៀកបំពាក់នៅក្នុងដៃ។

"ខោអាវស្លៀកត្រឡប់ទៅវាំងវិញ"

គេប្រាប់ព្រមទាំងហុចឲ្យ ទើបនាងយកមកបើកមើល និងលួចមើលមុខគេដោយការងឿងឆ្ងល់។

"វាស្អាតពេកហើយ ខ្ញុំត្រឡប់ទៅវិញសម្រាក មិនមែនត្រឡប់ទៅវិញដើម្បីចូលរួមកម្មវិធីជប់លៀងរាត្រីទេ" នាងប្រាប់ ព្រមទាំងដាក់ប្រអប់សម្លៀកបំពាក់នៅលើគ្រែ។

"ពាក់ទៅ នាងប្រហែលមិនគិតថាពាក់ឯកសណ្ឋានមន្ទីរពេទ្យត្រឡប់ទៅផ្ទះទេមែនទេ"

គេដើរមកជិតដោយកាយវិការមិនគួរឲ្យទុកចិត្ត ធ្វើឲ្យនាងត្រូវគេចតែមិនផុត។

ចង្កេះត្រូវក្រសោបឱបដោយរង្វង់ដៃរឹងមាំ ត្រូវទាញទៅថើបថ្ងាសអូសបបូរមាត់មករកថ្ពាល់ដល់បបូរមាត់ ហើយថើបជញ្ជក់ដោយមិនខ្វល់ពីការរើបម្រះ ឯបាតដៃក៏សង្កត់កញ្ចឹងក បង្គាប់ឲ្យនាងបង្កើបបបូរមាត់ទទួលយកការថើបនោះទាល់តែពេញចិត្ត។

ហេយ្យូ ទៅជាជ្រមិលពេលគេដកបបូរមាត់ចេញ ហើយងាកទៅយកប្រអប់ខោអាវមកហុចឲ្យម្ដងទៀត។

"តែងខ្លួនទៅ នឹងអាលទៅផ្ទះ"

នាងក្រមុំមើលសម្លៀកបំពាក់ដោយភាពរារែក មិនពេញចិត្តអីបន្តិច ប៉ុន្តែពេលឃើញគេមើលមកដោយកាយវិការមិនគួរឲ្យទុកចិត្ត ក៏ស្ទុះស្ទាចូលបន្ទប់ទឹក ទុកឲ្យគេតាមមើលដោយការពេញចិត្តតែម្នាក់ឯង។

មិនយូរប៉ុន្មាននាងក៏ចេញមកវិញ ដោយគ្រងឈុតកាឡាបៃយ៉ាពណ៌ស្រស់ មើលទៅមិនសមជាឈុតពាក់ត្រឡប់ទៅវាំងវិញធម្មតាៗ វាប៉ាក់ឌិនមាសស្អាតពេញមួយតួខ្លួន តែមិនឃ្លុំក្បាល ទម្លាក់សក់វែងរំសាយដែលទើបតែកក់ហើយថ្មីៗបែបនោះ មុខមាត់ក៏មិនបានតុបតែង។

ទ្វារបន្ទប់ត្រូវគោះ និងបើកចូលមកដោយ ហ៊ុលសែន រុញកៅអីពិសេសដែលយកមកពីវាំង រង់ចាំនាងឡើងអង្គុយ ហើយគេក៏រុញវាចេញពីបន្ទប់តាមព្រះអង្គម្ចាស់។

"អ្នកបើកឡាននោះ"

នាងនឹកឃើញ ពេលនៅក្នុងឡានកំពុងធ្វើដំណើរត្រឡប់ទៅវាំង។

"វាងាប់តាំងពីថ្ងៃនោះម្ល៉េះ ហ៊ុលសែន ប្រាប់ថាយើងគួរតែជឿនាងតាំងពីថ្ងៃដំបូងមិនគួរណាបណ្ដោយឲ្យកើតរឿង ទើបពេលនេះយើងប្ដូរអ្នកធ្វើការនៅក្នុងអគារថ្មីទាំងអស់ ដោយស៊ើបសួរប្រវត្តិលម្អិតគ្រប់ដំណាក់កាល"

មិខាអ៊ីល និយាយឲ្យស្ដាប់ ព្រមទាំងដកដង្ហើមធំនឹងការប្រមាទរបស់ខ្លួន ឬថាទៅគឺភ្លេចនោះឯង ព្រោះមានរឿងច្រើនឲ្យធ្វើ ឯ ហ៊ុលសែន ក៏មើលរំលងសុវត្ថិភាពត្រង់នេះបានដោយមិនគួរឲ្យជឿ លេងឲ្យនាងរិះតែស្លាប់។

ពេលមកដល់វាំង ហេយ្យូ ក៏ងឿងឆ្ងល់ ពេលឃើញមនុស្សម្នាច្រើនសន្ធឹក ហើយពេលដែលពួកគេចុះពីឡាន ក៏មានអ្នកមកទទួល។



"មានអីកើតឡើង...អ្នកណាមក...ឬសម្ដេចមហាក្សត្រី?"

នាងសួរ តែព្រះអង្គម្ចាស់មិនឆ្លើយ គេហុចដៃឲ្យនាង គ្រាហ៍ឡើងជណ្ដើរម្ដងមួយកាំម្ដងមួយកាំ ចូលបន្ទប់កញ្ចក់ដែលនៅជិតជាងគេ។

នៅក្នុងនោះ នាងឃើញខ្ញុំបម្រើដែលធ្លាប់ឃើញកាលមុនរបស់ព្រះអង្គម្ចាស់ក្សត្រី។

"អ្នកនាងចាំពួកយើងបានទេ ដែលធ្លាប់មកជួយតែងខ្លួនឲ្យ"

ម្នាក់នៅក្នុងចំណោមបួននាក់ រាក់ទាក់និងនាំនាងទៅអង្គុយលើកៅអីដែលរៀបចំរួចជាស្រេច។

"ចង់ធ្វើអីថ្ងៃនេះ?" នាងសួរដោយការសង្ស័យ ពេលឃើញឧបករណ៍ជាច្រើន។

"ផាត់មុខតែងខ្លួនឲ្យកូនក្រមុំ ថ្ងៃនេះជាថ្ងៃមង្គលការរបស់អ្នកនាង និង ហ្សុីក មិខាអ៊ីល អ្នកនាងមិនដឹងទេឬ ហ្សុីក មិនបានប្រាប់ទេឬ?"

ទឹកមុខមិងមាំងរបស់នាងក្រមុំ ក្លាយជាចម្លើយដល់ស្រីៗខ្ញុំបម្រើបានច្បាស់។

"ហ្សុីក មិនចង់រង់ចាំ បានឮទ្រង់ទូលថ្វាយសម្ដេចព្រះមហាក្សត្រីថារៀបការហើយនឹងធ្វើដំណើរទៅប្រទេសកូរ៉េខាងត្បូង ទៅធ្វើតួនាទីឲ្យក្រសួងការបរទេសនៅទីនោះ ពេលនេះព័ត៌មានត្រូវផ្សព្វផ្សាយហើយ ថាកាន់ការក្រសួងការបរទេស ព្រោះស្គាល់ទូតច្រើនប្រទេស និងចេះការងារផ្នែកនេះ"

ការរៀបរាប់នោះ ធ្វើឲ្យអ្នកស្ដាប់ពេញចិត្ត មែនហើយ មនុស្សពូកែដូចគេមិនអាចថាមិនជួយសម្ដេចព្រះមហាក្សត្រីមួយរឿងពីរទេ។

ការរៀបការប្រហែលជាវត្ថុដំបូងដែលជួយមិនឲ្យសម្ដេចព្រះមាតាគិតថាព្រះអង្គម្ចាស់ចង់ចាប់ព្រះមហាក្សត្រីដើម្បីរាជបល្ល័ង្កទៀត និងការ



ទទួលបម្រើនៅក្រសួងការបរទេស មិនមែនក្រសួងហិរញ្ញវត្ថុ ថែមទាំងមិនព្រមនៅក្នុងស្រុកក្នុងទេសបែបនេះ វាគ្រប់គ្រាន់ហើយនឹងជួយកាត់បន្ថយការប្រុងប្រយ័ត្នបានមួយកម្រិត។

ខ្ញុំបម្រើរបស់ព្រះមហាក្សត្រី រៀបចំគ្រប់យ៉ាងរួចរាល់ហើយ មួយម៉ោងក្រោយមក ហេឃ្សូ ក៏អាចចូលរួមពិធីមង្គលការបាន ទើបព្រះអង្គម្ចាស់ដើរចូលមក ដោយមានប្រអប់មួយនៅក្នុងដៃ ជាប្រអប់ដាក់ខ្សែ-កដាំពេជ្រធំ មានទំហំពីរធ្នាប់ដៃ សមនឹងឈុតកងដៃទាំងសងខាង រួមទាំងកងជើង មិនទាន់បូករួមក្រវិលផង ធ្វើឲ្យធ្ងន់ខ្លួនតែម្ដង។





Scanned by CamScanner

## ១៥

"ខ្ញុំទើបតែចេញពីមន្ទីរពេទ្យ ចង់ឲ្យពន់រែកទម្ងន់ដល់ថ្នាក់នេះឬ"

នាងលើកជើងដែលពាក់កងជើងមាសដាំពេជ្រឲ្យគេមើល និងសម្លឹងមើលមុខគេដោយការសង្ស័យ។

មិខាអ៊ីល មានទឹកមុខដូចចង់ញញឹមតែមិនញញឹម ធ្វើជម្មតាក៏មិនមែន ហើយមើលស្នាមខ្ចួចជាប់ថ្ពាល់របស់គេ វាប្រាប់ថាគេកំពុងញញឹមច្រើនជាង។

"កុំទាន់អាលប្រកែកគ្នា ព្រះប្រធានកិត្តិយសទ្រង់យាង សម្តេចព្រះមហាក្សត្រីក៏យាង"

ប្រយោគនោះធ្វើឲ្យព្រះអង្គម្ចាស់ ដើរមកគ្រាហ៍នាងក្រមុំចេញទៅទទួលព្រះរាជដំណើរ របស់សម្តេចព្រះមហាក្សត្រីដែលយាងមកដល់ទីនេះ។

ពេលទ្រង់ប្រថាប់លើបល្ល័ងដែលរៀបចំឲ្យរួចរាល់ កូនកំលោះក៏ចូលអង្គុយ ចំណែកកូនក្រមុំក៏ត្រូវគ្រាហ៍ឲ្យទៅអង្គុយទល់មុខ។

ប្រមុខសាសនាថ្មីថ្វាយព្រះពរដល់កូនកំលោះកូនក្រមុំបន្ទាប់មកជាការចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខប្រមុខដឹកនាំសាសនា ហើយយកទៅថ្វាយឲ្យសម្តេចព្រះមហាក្សត្រីបានដឹងឮជាសាក្សី។

ពិធីនានាដំណើរការយ៉ាងស្ងប់ស្ងាត់តែមានរបៀប រហូតដល់ព្រះពិធីនៅក្នុងកម្មពិធីស្តេចយាងត្រឡប់ទៅវិញ ដោយបាននិយាយជាមួយបងប្រុសពីរបីម៉ាត់។

ហេឃ្យូ តាមមើលសម្តេចព្រះមហាក្សត្រីនិងបុរសដែលនាងរៀបមង្គលការជាមួយដោយការសង្ស័យ ដែលព្រោះអារម្មណ៍នេះទេដឹងដែលធ្វើឲ្យនាងមិនទុកចិត្តគេមួយរយភាគរយ ទោះបណ្តោយឲ្យគ្រប់យ៉ាងដំណើរការតាមប្រពៃណីសាសនារបស់គេក៏ដោយ។

នាងនៅតែមានអារម្មណ៍ច្របូកច្របល់ជឿខ្លះមិនជឿខ្លះរហូតដល់ត្រូវនាំទៅបន្ទប់ស្នាក់នៅថ្មីដែលធំទូលាយជាងមុន ពេលចូលទៅហើយត្រូវបើកភ្នែកធំៗ ប៉ុន្តែបន្ទាប់មកក៏ចាំបានថាវាជាដំណាក់ចាស់របស់គេនោះឯង ទាស់ត្រង់ពេលនេះត្រូវរៀបចំតុបតែងជាថ្មីឲ្យស្អាតប្លែកភ្នែកដោយគ្រឿងសង្ហារឹមថ្មីទាំងអស់តាំងពីមុខបន្ទប់ បន្ទប់ខាងក្រៅ បន្ទប់ខាងក្នុង មិនទុករបស់ចាស់ឲ្យឃើញ។

រាជបរិវាររបស់ព្រះអង្គម្ចាស់ក្សត្រីដែលនៅសេសសល់នាំនាងទៅអង្គុយលើគ្រែដែលត្រូវកុម្ម៉ង់ធ្វើជាពិសេសឲ្យមានក្បូរក្បាច់រចនាល្អវិចិត្រ និងធំទូលាយជាងមុន ស៊ីនឹងគ្រឿងសង្ហារឹមទាំងអស់នៅក្នុងបន្ទប់។

"ទ្រង់ត្រូវនៅតែក្នុងនេះ ចេញទៅណាមិនបានទាល់តែហ្ស៊ីកចូលមក"

ស្រីបម្រើដែលមានអាយុចាស់ជាងគេនៅក្នុងចំណោមនោះប្រាប់នាង។



"ទ្រាំអង្គុយយូរមិនបានទេ សូមដេកបានទេ ?"

Scanned by CamScanner

សំណួររបស់នាង ធ្វើឲ្យស្រីៗទាំងនោះសើចខឹកៗ ប៉ុន្តែនាងមិនខ្វល់ ព្រោះរាងកាយមិនអាចអង្គុយយូរបានច្រើនម៉ោងបែបនេះ ការពិតគ្រាន់តែមកដល់នាងក៏ចង់សម្រាកទៅហើយ តែនេះត្រូវធ្វើពិធីពេញមួយរសៀលរហូតដល់ល្ងាច និងនៅពេលព្រលប់ទៀត នាងទ្រាំមិនបាន។

គ្មានអ្នកណាឲ្យចម្លើយបាន តែនាងផ្តួលខ្លួនដេក ហើយអ្នកបម្រើទាំងអស់ដែលយល់ថាហៃ្យកាទើបតែចេញពីមន្ទីរពេទ្យ មិនទាន់មានកម្លាំងកំហែងក៏នាំគ្នាចេញពីបន្ទប់អស់។

ហេយ្យូ ដេកលក់យូរប៉ុណ្ណាក៏មិនដឹង រហូតដល់ចុងជើងត្រូវប៉ះថ្នមៗ ដាស់ឲ្យភ្ញាក់មកមើលមុខអ្នកដែលអង្គុយក្បែរ។

មើលចុះ គេចូលមកជិតប៉ុណ្ណឹងហើយនាងនៅមិនដឹងខ្លួនទៀត មានន័យថាល្ងើយមែនទែនស្មារតីដែលតែងតែមានគ្រប់ពេលវេលាពេលលង់លក់ទៅណាបាត់ក៏មិនដឹង។

នាងនឹកដល់ខ្លួនឯងពេលនៅជាមួយគេតែពីរនាក់ វាខុសពីកន្លងមកដែលធ្វើជាអង្គរក្ស។ ពេលនៅជាមួយ មិខាអ៊ីល អ្វីម្យ៉ាងចេញពីខ្សែភ្នែករបស់គេអាចបំផ្លាញស្មារតីនឹងធឹងរបស់នាង ឲ្យខ្ចេចខ្ចីបានដែលវាអាចទៅរួចតាំងពីដំបូងដែលជួបគ្នារហូតមកដល់ពេលនេះ។

អ្នកកំលោះចូលមកក្នុងបន្ទប់យូរហើយ ប៉ុន្តែពេលឃើញកូនក្រមុំដែលគួរតែអង្គុយចាំគេ បែរជាដេកលក់ស្រួលដាស់ក៏មិនព្រមភ្ញាក់ ទាញភួយចេញក៏មិនព្រមកម្រើកក៏ធ្វើឲ្យគេព្រមដកថយ។

អាការៈជំងឺរបស់នាងលើកនេះធ្ងន់ធ្ងរជាងការវះយកគ្រាប់កាំភ្លើងចេញ ប៉ុន្តែនៅត្រូវកាត់ឆ្អឹងជំនីខាងក្រោមបំផុតចេញមួយទៀតផង ព្រោះវាត្រូវគ្រាប់បាញ់បំបែកមិនអាចទុកឲ្យនៅបែបនោះបានទើបនាងត្រូវដេកពេទ្យយូរ ហើយពេទ្យក៏មិនអនុញ្ញាតឲ្យត្រឡប់មកផ្ទះទៀតបើឋានៈជាព្រះអង្គម្ចាស់របស់គេគ្មានឥទ្ធិពល។

ទើបការយកនាងមកចូលពិធីនៅចំពោះព្រះភក្ត្រ សម្តេចព្រះមហាក្សត្រីរាប់ម៉ោងក្លាយជាការបង្ខិករាងកាយរបស់នាង សំណាងដែលនាងត្រូវបង្ខិកឲ្យមានការអត់ធ្មត់ចំពោះស្ថានភាពគ្រប់យ៉ាង ការអង្គុយស្ងៀមៗ ដោយប្រើពេលច្រើនម៉ោងទោះអាចទ្រាំបាន ប៉ុន្តែពេលមានឱកាសសម្រាក នាងក៏មិរារែក។

មិខាអ៊ីល ងូតទឹកផ្លាស់សម្លៀកបំពាក់រួចរាល់ ដើរមកអង្គុយក្បែរអ្នកដែលដេកលើគ្រែ។

ខ្សែភ្នែកមុតស្រួចសម្លឹងមើលក.ជើង ដែលមានកងជើងមាសដាំពេជ្រដែលនាងរអ៊ូរទាំថាធ្ងន់ ទើបលូកដៃទៅអង្អែលត្រង់នោះថ្នមៗ។ គេពេញចិត្តដែលនាងពាក់កងជើងទាំងសងខាង ដែលបញ្ជាក់ប្រាប់ថានាងជារបស់គេ។

អ្នកកំលោះឱនទៅរកអ្នកដែលបើកភ្នែកមើលមកមួយភ្លែត ហើយក៏បិទម្តងទៀតតាមសភាពរាងកាយដែលនៅត្រូវការការសម្រាក គេបង្ខំនាងឲ្យចូលពិធីមង្គលការក្នុងគ្រួសារដោយអញ្ជើញភ្ញៀវសំខាន់គឺសម្តេចព្រះមហាក្សត្រីតែមួយអង្គគត់ ព្រោះកូនក្រមុំមិនរឹងមាំអាចប្រារព្ធពិធីធំបាន។

ពេលនាងលង់លក់ម្តងទៀត ទើបគេដកដង្ហើមធំ លូកដៃទៅចាប់សក់រលោងនោះដាក់ឲ្យត្រូវកន្លែងរបស់វាដោយការប្រុងប្រយ័ត្ន ហើយអង្គុយមើលនាងបែបនោះយ៉ាងយូរ បន្ទាប់មកក៏ផ្តួលខ្លួនដេកឱប ដោយអារម្មណ៍ធូរស្រាលជាលើកដំបូង នៅក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ។



ហេយ្យូ ភ្ញាក់ដឹងខ្លួនបើកភ្នែកស្រឡះល្អនៅមេឃជិតភ្លឺ ពេលក្រឡេកមើលនាឡិកាឃើញថាម៉ោងជិតបួន អីចឹងមានន័យថានាងដេកលក់ច្រើនម៉ោងតែម្តង ហើយពេលមើលក្បែរខ្លួនឃើញអ្នកដែលលង់លក់ស្រួល ដោយដៃរបស់គេដាក់លើចង្កេះរបស់នាងទើបនាងងាកខ្លួនដោយការប្រុងប្រយ័ត្ន តែក៏ត្រូវពេបមាត់ព្រោះឈឺមុខរបួស។

ហេតុអីបានជាឈឺដល់ថ្នាក់នេះ នាងសួរខ្លួនឯងពេលងើបទៅអង្គុយនៅមុខតុគ្រឿងសម្អាង ឃើញគ្រឿងលម្អនៅលើដងខ្លួនទើបដោះវាចេញម្តងមួយៗយ៉ាងលំបាក ព្រោះកម្រើកខ្លួនត្រង់ណាវាក៏ឈឺ។ នាងដោះមាសទម្ងន់ចង់មួយគីឡូក្រាមដាក់លើតុ ហើយដើរចូលបន្ទប់ទឹកងូតទឹកងូតភក់ ព្រោះពីម្សិលដេកលក់ទាំងមិនបានសម្អាតខ្លួនប្រាណ។ នាងឈ្ងោកមើលរបួសដែលត្រូវបិទដោយបង់ផ្លាស្ទិកបង្ការត្រូវទឹកដោយការចាប់អារម្មណ៍ វាវែងគួរសមទាំងដែលវាគួរតែតូចតែមួយប៉ុនមុខគ្រាប់កាំភ្លើង តែហេតុអីក៏ធំម្លេះ និងប្រហែលជាហូរឈាមច្រើនគួរសមទើបធ្វើឲ្យនាងល្វើយយូរដល់ថ្នាក់នេះ។

ប៉ុន្តែពេលចេញពីបន្ទប់ទឹកក៏ត្រូវជ្រួញចិញ្ចើមពេលឃើញអ្នកកំលោះដើរចេញពីផ្ទះបាយដែលនៅជ្រុងម្ខាងទៀត មានកែវទឹកក្នុងដៃ។

គេឈរមើលនាង ខណៈដែល ហេយ្យូ ដើរទៅឈរនៅមុខកញ្ចក់ យកគ្រឿងលម្អទាំងអស់ដាក់ប្រអប់ ហើយប្រាប់គេដោយមិនងាកមកមើលមុខ។

"ឲ្យវិញ"

ព្រះអង្គម្ចាស់រូបសង្ហាដើរមកឈរក្រោយកៅអី និងមើលនាងក្នុងកញ្ចក់។

"វាជារបស់នាងខ្ញុំប្រគល់ឲ្យនាងហើយ បូករួមទាំងគ្រឿងពេជ្រ



ដទៃទៀតនៅក្នុងទូនិងក្នុងធនាគារ"

នាងក្រមុំស្ងប់ស្ងាត់ពេលដែលគេប្រាប់បែបនេះ ភ្នែកនៅតែសម្លឹងមើលមុខសង្ហា មួយសន្ទុះទើបងាកទៅប្រឈមមុខ និងសម្លឹងមើលកែវភ្នែកមុតស្រួចនោះ។

"ម៉េចក៏មើលបែបនេះ ?" មិខាអ៊ីល សួរដោយទឹកមុខប្រាកដប្រជា បន្ទាប់មកក៏ងាកទៅមើលគ្រឿងលម្អ និងលូកដៃយកកងជើង។

"អង្គុយចុះ ចង់ឲ្យនាងពាក់កងជើងនេះ តែមួយក៏បានដែរ"

នាងគ្រវីក្បាល មិនធ្វើតាមសម្តីរបស់គេ ថែមទាំងដើរចេញទៀតផង ប៉ុន្តែត្រូវគេស្រវាចាប់ដៃជាប់ និងបង្ខាប់ឲ្យអង្គុយនៅលើគ្រែ ឯខ្លួនឯងក៏លុតជង្គង់នៅចំពោះមុខ ដោយក្នុងដៃមានកងជើង។

ប៉ុន្តែ ហេយ្យូ មិនព្រមឲ្យគេបោះត្រាងាយៗ នាងលើកជើងមកដាក់លើគ្រែ ពេលនោះឯងដែលអ្នកកំលោះមានឱកាសឡើងមកលើគ្រែ និងឱនទៅសួរព្រោះនាងឈឺមុខរបួស ត្រូវពេបមាត់នៅស្ងៀម។

"ឈឺហើយមែនទេ គ្រាប់កាំភ្លើងវាបោះឆ្អឹងជំនីខាងក្រោមល្មមទើបត្រូវកាត់មួយចោល នាងនឹងធ្វើអីមិនសូវស្រួលយូរគួរសម រួមទាំងធ្វើតួនាទីជាអង្គរក្សដែរ ធ្វើបានត្រឹមតែតួនាទីជាភរិយាមួយប៉ុណ្ណោះ"

មុខសង្ហាឱនទៅនិយាយឲ្យឮតែពីរនាក់ ហើយទាញដៃចេញពី.កជើងរបស់នាងសង្កត់ជាប់។

ការធ្វើបែបនេះធ្វើឲ្យជីវអាវឃ្លុំងូតទឹកញែកចេញពីគ្នា ដោយស្វ័យប្រវត្ត បង្ហាញឲ្យឃើញជើងស្រឡូនគួរឲ្យមើល ប៉ុន្តែទោះជាដូច្នោះក៏នាងនៅតែមិនព្រមតាមសម្រួល នៅតែប្រឹងទាញជើងចេញ ទើបត្រូវមិខាអ៊ីល ស្រវាចាប់ជើងម្ខាងនោះបំពាក់កងជើងឲ្យរួចរាល់ ហើយយកវាទៅកេរចង្កេះរបស់ខ្លួន ធ្វើឲ្យនាងមានអារម្មណ៍ថាចាញ់ដៃគេហើយពេល



នេះ។

នាងក្រមុំនៅស្ងៀម ខណៈដែលគេលោមកជិត ដេញនាងឲ្យអែនខ្លួនបន្តិចម្តងៗ ទាល់តែក្បាលដល់ខ្នើយ ដោយមានមុខសង្ហាតាមមកនៅជិតបង្កើយ។

មិខាអ៊ីល ដឹងច្បាស់ថានាងឈឺត្រង់ណា ដែលគេមិនគួរនៅជិតឬចូលមកក្បែរ ប៉ុន្តែក៏មិនគិតថានឹងដកថយ ឬបោះបង់សិទ្ធិដែលទើបតែមាន ឬសូម្បីតែរង់ចាំមួយរយៈទៀត។

កែងដៃរឹងមាំទ្រាននឹងពូកក្បែររាងកាយស្រឡៅស្រឡូន ទម្លាក់ទម្ងន់ខ្លួននៅលើពូក ដោយមិនឲ្យប៉ះពាល់ដល់មុខរបួសរបស់នាង។

"នាងជាអ្នកប្រាប់មិនអីចឹង ថាត្រូវតែរៀបការប៉ុណ្ណោះទើបមានសិទ្ធិចំពោះនាង" គេខ្សឹបប្រាប់ និងមើលនាងមិនដាក់ភ្នែក។

"នៅមានរឿងមួយទៀតដែលខ្ញុំមិនទាន់ប្រាប់"

"ស្អីគេ ?"

"លោកត្រូវមានក្តីស្រឡាញ់ដែរ លោកមិនបានស្រឡាញ់ខ្ញុំ លោកយកខ្ញុំធ្វើជាឧបករណ៍កាល់ខ្លួនឯងចេញពីព្រះនាង"

ហេតុផលរបស់នាងធ្វើឲ្យព្រះអង្គម្ចាស់ព្រិចភ្នែក ដោយមិនចង់ជឿ បន្ទាប់មកក៏សួរ។

"ម៉េចក៏គិតអីចឹង ?" គេសួរនិងស្រវាចាប់ដៃដែលលូកមករុញមុខគេចេញ។

"ហើយវាពិតដែរទេ" នាងត្បកសួរនិងសម្លឹងមុខគេមិនដាក់ភ្នែក។

"មិនពិត" គេបដិសេធ ហើយសម្លឹងមុខនាងវិញ។

"អីចឹងលោករៀបការជាមួយខ្ញុំព្រោះស្រឡាញ់អស់ពីបេះដូង !"

សំណួររបស់នាងធ្វើឲ្យព្រះអង្គម្ចាស់មើលមក ដោយខ្សែភ្នែក



ប្លែកៗ ដែលនាងមិនធ្លាប់ឃើញ។

គេមិនឆ្លើយ តែបែរជាត្បកសួរ ថែមទាំងលោមុខមកជិតទៀតផង។

"បើមិនស្រឡាញ់អីចឹងបង្ហាញក្តីស្រឡាញ់ដាក់នាងមិនបានឬ ?"

"មែន"

"គ្មានផ្លូវទេហ្សេកា អាប់ឌុលឡោះ ឧស្មាន់ នាងជារបស់ខ្ញុំត្រឹមត្រូវតាមប្រពៃណី និងចាប់តាំងពីពេលនេះទៅ មិនបាច់មកបបួលឈ្លោះ ខ្ញុំមិនឈ្លោះនឹងនាង"

និយាយចប់ គេក៏ជ្រប់មុខនឹងប្រឡោះ.ក ដោយមិនខ្វល់ពីការតតាំងប្រឆាំងរបស់នាង ថែមទាំងត្រដុសបបូរមាត់ខ្លាំងៗ អូសវាមករកស្លឹកត្រចៀក ខាំជញ្ជប់តិចៗ បន្ទាប់មកអូសកាត់ថ្ពាល់មករកបបូរមាត់ និងបិទវាមិនឲ្យនិយាយបានតទៅទៀត។

ហេយ្សា ទើបតែដឹងថាការត្រូវថើបលើកនេះវាដាស់រាងកាយគ្រប់ផ្នែករបស់នាងឲ្យភ្ញាក់ទទួលយកការថើបដ៏ក្តៅគគុកនិងមានដៃក្តៅឧណ្ហត្រួតពិនិត្យរាងកាយដោយមិនក្រែងរអែងចិត្ត ធ្វើឲ្យនាងស្លឹកខ្លួន ដូចត្រូវគេទាញយកគ្រប់យ៉ាងដែលជារបស់នាងទៅធ្វើជារបស់គេ បំផ្លាញភាពជាខ្លួនឯងរបស់នាងអស់រលីង មិនដឹងថាខ្សែចងចង្កេះរបូតតាំងពីពេលណា នៅសល់តែរាងកាយនទលគក។

បបូរមាត់ពណ៌ស្រស់ របស់គេអូសកាត់រាងកាយនទលគកហាក់ដូចខ្លួនឯងជាម្ចាស់ ដោយមិនឲ្យរំលងសូម្បីតែបន្តិច រំញោចឲ្យនាងញាប់ញ័របានដឹងពីអារម្មណ៍ជាច្រើនរបស់ខ្លួន ដែលមិនធ្លាប់បានស្គាល់ ម្រាមដៃស្រឡូនដូចមនុស្សស្រីក៏ត្រួតពិនិត្យសព្វសាច់ ធ្វើឲ្យនាងត្រូវព្រមទទួល ព្រមឲ្យគេគ្រប់គ្រងដោយមិនអាចបដិសេធបាន។



មិខាអ៊ីល នាំនាងឡើងជណ្ដើរនៃអារម្មណ៍ដែលនាងមិនធ្លាប់ស្គាល់ ឡើងកាន់តែខ្ពស់ទៅៗ រហូតដល់ដែនដីនៃការប្រាថ្នាដែលនាងមិនធ្លាប់ឆ្លងកាត់។

គេដឹកនាំនាងឲ្យទៅដល់ទីនោះ ដោយភាពកក់ក្ដៅនិងទន់ភ្លន់តាមបែបផែនរបស់គេ បែបដែលនាងមិនអាចប្រឆាំងបាន ក្រៅពីព្រមទទួលយកគ្រប់ដំណាក់កាល ស្រេចតែគេដឹកនាំ និងសម្ងំនៅក្នុងរង្វង់ដៃរឹងមាំនៅពេលបន្ទាប់។



# ១៦

ពេលភ្ញាក់ដឹងខ្លួនម្ដងទៀត នាឡិកានៅក្នុងបន្ទប់ក៏វាយឲ្យឮសំឡេងម្ដង ទើបនាងឈ្ងោកមើលថាវាម៉ោងប៉ុន្មានទៅហើយ។

*នេះម៉ោងមួយរសៀលហើយឬ!*

នាងប៉ប្រិចភ្នែក ងឿងឆ្ងល់ ព្រមទាំងងើបអង្គុយយឺតៗ។ នាងចាំអ្វីដែលកើតឡើងបាន ហើយវាកាន់តែច្បាស់ពេលឃើញអាវសស្ដើងនៅលើដងខ្លួន បន្ទាប់មកក៏នឹកដល់អ្នកជួយពាក់អាវនេះឲ្យ។

នាងចាំសំឡេងរអ៊ូរង៉ូវៗតែចាំន័យមិនបានរបស់គេ។

ដៃរបស់នាងត្រូវចាប់ឲ្យឱបករឹងមាំ និងប៉ះសាច់ដុំតឹងណែនត្រង់ស្មាធំទូលាយរបស់អ្នកដែលស្រវាឱបនិងថើបកប់សាច់របស់នាង ប៉ុន្តែក្នុងពេលដែលនាងមិនព្រមកម្រើក គិតតែបិទភ្នែកព្រោះរាងកាយមិនទាន់រឹងមាំ ទើបព្រះអង្គម្ចាស់ត្រូវព្រមចុះចាញ់ ស្រវាយកអាវរបស់គេមកពាក់ឲ្យនាង ទាញភួយមកពាក់ឲ្យ ឯខ្លួនឯងក៏ងើបដើរចេញទៅ។

"មានអារម្មណ៍យ៉ាងម៉េចដែរ ហៃ្យកា...ងើបរួចទេព្រះមេ?"

គិលានុបដ្ឋាយិកាត្រូវហៅឲ្យមកមើលថែនាង តាំងពីពេលណាក៏



មិនដឹង ដើរចូលមកជិត ធ្វើឲ្យនាងដឹងថាខ្លួនមិនបាននៅតែម្នាក់ឯងក្នុងបន្ទប់នេះ។

"ចាំ បាន"

នាងឆ្លើយ និងចុះពីគ្រែឃើតៗ ព្រោះវាគ្មានអីក្រៅពីនៅល្ងើយ។

គិលានុបដ្ឋាយិកាដើរតាមដល់បន្ទប់ទឹក ហើយថយមកវិញពេលឃើញនាងជួយខ្លួនឯងបាន ឯង ហេឃ្យូ ក៏នឹកដល់ការនិយាយស្ដី និងការហៅនាងថា ហៃ្យកា ដែលមានន័យដល់ភរិយារបស់នាង ហ្សុីក នោះឯង។

វាប្លែកត្រចៀក តែក៏ឲ្យអារម្មណ៍ម្យ៉ាងដល់នាង វាដូចបញ្ជាក់ឲ្យដឹងថាវេលានេះនាងមិនមែន គីម ហេឃ្យូ កាលពីមុន នាងក្លាយជារបស់គេទាំងខ្លួនទាំងប្រាណ លើកលែងបេះដូង បេះដូងដែលប្រាប់ខ្លួនឯងថានៅតែជារបស់នាង និងអាចទាញផ្នែកខ្លះដែលគេយកទៅ ត្រឡប់មកវិញបានដែរ។

នាងពិនិត្យមើលបន្ទប់ទឹកធំទូលាយ ដែលមានទូសម្លៀកបំពាក់ជាប់នឹងជញ្ជាំងនៅជ្រុងម្ខាង មានតុគ្រឿងសម្អាង មានកញ្ចក់ឆ្លុះមុខ ឆ្លុះមួយកំណាត់ខ្លួន និងឆ្លុះមួយជំហរខ្លួន មានក្បូរក្បាច់រចនាប្រណីត ទាំងបន្ទប់ខាងក្នុង និងបន្ទប់ខាងក្រៅ មានពណ៌ផ្ទៃមេឃឆ្លាស់ពណ៌ស និងពណ៌មាស ធ្វើឲ្យដឹងថាជាបន្ទប់នៅបរមរាជវាំង ដែលខុសពីបន្ទប់ឈុតនៅទីកន្លែងផ្សេងៗហៅមិនឮតែម្ដង លើកលែងតែត្រាប្រចាំព្រះអង្គប៉ុណ្ណោះដែលមាននៅតែក្នុងព្រះរាជដំណាក់របស់សម្ដេចព្រះមហាក្សត្រី។

នាងក្រមុំដើរទៅបើកទូខោអាវនៅចុងបន្ទប់ ឃើញថាមានរបស់របរតែងខ្លួនសម្រាប់មនុស្សស្រីច្រើនគរគោក មានគ្រប់យ៉ាងដែលគេរៀបចំទុកឲ្យនាង។



ហេឃ្យូ ឱនមើលអាវនៅលើដងខ្លួន និងមើលវាហាក់ដូចរបស់ប្លែក ខណៈដែលដៃក៏ស្ទាបអង្អែលវា ពេលនឹកដល់អ្នកពាក់ឲ្យកាលពីមិនប៉ុន្មានម៉ោងមុន។

គេពាក់អាវឲ្យរួចរាល់ នាងក៏ប្រែខ្លួនទៅស្ដាំ ឲ្យខ្លួនឯងដេកឲ្យបានស្រួលភ្លាម ទុកឲ្យគេតាមមកបើបក្បាល និងសាច់ខ្នងរបស់នាងខ្សឹតៗ។ នាងចាំបាន និងមានអារម្មណ៍ថាមិនចង់ដោះវាចេញពីខ្លួន បន្ទាប់មកក៏មើលកងជើងដែលជាប់កជើង ហើយគិតថាមិនអាចពាក់អាវនេះពេញមួយថ្ងៃបាន។

នាងគិតថាប្រហែលពាក់អាវមួយនេះពេញមួយថ្ងៃមិនបានទេ រឿងសំខាន់មានគិលានុបដ្ឋាយិកានៅជាមួយបែបនេះ កាន់តែមិនអាចធ្វើតាមអំពើចិត្តខ្លួនឯង ទើបត្រូវងូតទឹកតែងខ្លួនជាថ្មី ហើយដើរចេញពីបន្ទប់ ដែលពេលនោះ អាហារថ្ងៃត្រង់ត្រូវបានរៀបចំលើតុចាំទៅហើយ រហូតដល់ពេលល្ងាច និងពេលព្រលប់។

នាងនៅក្នុងបន្ទប់ដេកធំល្វឹងល្វើយមួយតួអគារ និងបែងចែកជាផ្នែកដូចលើកផ្ទះមួយមកដាក់ក្នុងបន្ទប់នេះ ពេញមួយថ្ងៃ។

ហេឃ្យូ កំពុងតែអង្គុយលើសាឡុងវែង ពេលទ្វារបន្ទប់ត្រូវបើកដោយមាន ហ៊ុលសែន អើតមុខមកមុនគេ និងញញឹមដាក់ ហើយបើកទ្វារឲ្យជំឲ្យចៅហ្វាយនាយចូល។

មិខាអ៊ីល ងាកទៅនិយាយជាមួយ ហ៊ុលសែន ដែលនាងស្ដាប់មិនឮ ហើយអង្គរក្សជំនិតក៏ដើរចេញទៅ រួមទាំងគិលានុបដ្ឋាយិកាដែលនៅកំដរនាងពេញមួយថ្ងៃ ក៏ដើរចេញទៅដែរ ទុកឲ្យនាងនៅជាមួយព្រះអង្គម្ចាស់តែពរនាក់។

"យ៉ាងម៉េចហើយ ឮថាសុខសប្បាយពេញមួយថ្ងៃ គ្រាន់តែដេក



ទ្រមក់ តែរកាលពីថ្ងៃត្រង់ នៅតែមិនព្រមភ្ញាក់ទៀត"

ព្រះអង្គម្ចាស់ដើរមកសួរ និងរាក់ទាក់នាងដោយការថើប ហើយប្រុងលើកនាងទៅដាក់លើភ្លៅ តែត្រូវនាងស្រែកឃាត់។

"សុំទោសៗ ភ្លេចទៅ"

ពេលនឹកដល់មុខរបួសត្រង់ឆ្អឹងជំនីរបស់នាង ព្រះអង្គម្ចាស់ក៏លែងដៃភ្លាម។

ពេលនោះទ្វារបន្ទប់ត្រូវគោះម្តងទៀត និងត្រូវបើក ដោយមានរទេះអាហារជំត្រូវរុញចូលដោយដៃ ហ៊ុលសែន។

"ខ្ញុំត្រួតពិនិត្យហើយ អូខេទាំងអស់"

គេរាយការណ៍ ហើយរុញរទេះអាហារទៅដាក់នៅតុដែលនៅមិនឆ្ងាយប៉ុន្មាន។

"ទៅញ៉ាំបាយ មិនទាន់បានញ៉ាំអី កូរពោះគ្រប់គ្នា"

"នាំគ្នាទៅណា ?"

"នាំរដ្ឋមន្ត្រីក្រសួងសេសសល់ចូលគាល់សម្តេចមហាក្សត្រី ថ្វាយការងារនិងថ្វាយបញ្ហាទាំងអស់ដែលមាន និយាយពីវិធីដោះស្រាយ និងមុនពេលធ្វើដំណើរទៅកូរ៉េខាងត្បូង"

"លោកច្បាស់ហើយឬ ?"

"ច្បាស់អី ?" គេសួរដោយការសង្ស័យ។

"ទុកគ្រប់យ៉ាង ទៅកូរ៉េខាងត្បូង ទាំងដែលពេលនេះគ្មានអ្នកណារារាំង សូម្បីតែ អ៊ីម៉ាម"

"គេមិនបានរត់ទៅណាទេ នៅក្រវែលក្នុងប្រទេសហ្នឹង ល្បួងឲ្យគេឯងចូលដៃចូលជើង ត្រៀមកម្ចាត់យើងនៅថ្ងៃក្រោយបើយើងភ្លាត់ស្នៀត"

"ហើយលោកទៅយ៉ាងម៉េច មិនបារម្ភពីស្រុកទេសទេ ឬលោករៀបការរួចហើយ គ្មានអ្នកណាគិតរឿងឡើងគ្រងរាជ្យទេដឹង"



"អ្នកណាប្រាប់ ពេលនេះគេកំពុងប្រឌិតព័ត៌មានថ្មីទៅវិញទេ"

"ព័ត៌មានថ្មី ? ព័ត៌មានអី ?"

"មុនរៀបការ ប្រឌិតថារកវិធីតោងព្រះអង្គម្ចាស់ក្សត្រី តែពេលនេះមកចោទថាចង់ជ្រែករាជ្យ ចង់ឡើងធ្វើជាស្តេចដោយខ្លួនឯង ធ្ងន់ធ្ងរណាស់"

នាងក្រមុំទៅជាភាំង។

"ហើយដែលចង់ទៅ ព្រោះពេលនេះសម្តេចព្រះមាតាអញ្ជើញភ្ញៀវបរទេសថ្មីម្នាក់ទៀតមក គឺព្រះអង្គម្ចាស់ អាឌែល គិតថានឹងមកទីនេះនៅខែក្រោយ អញ្ជើញមកឲ្យសម្តេចព្រះមហាក្សត្រីជ្រើសរើសជាគូអភិសេក"

ព្រះអង្គម្ចាស់ដឹកដៃនាងមកដល់តុអាហារ ដែលត្រូវរៀបចំរួចរាល់។

នាងក្រមុំសម្លឹងមើលបុរសដែលជាម្ចាស់របស់ខ្លួនដោយមិនមាត់មិនក រហូតដល់គេងាកមកមើល និងលោមុខមកជិត ពេលអង្គុយក្បែរមិនព្រមឲ្យនាងទៅអង្គុយកៅអីទល់មុខ។

"មើលបែបនេះ មានបញ្ហាមែនទេ ?"

សំណួរនោះធ្វើឲ្យនាងនៅស្ងៀមមួយដង្ហើមទើបឆ្លើយ។

"ញ៉ាំបាយសិនទៅ ឮថាកូរពោះត្រឡប់មកវិញ មិនអីចឹង ? សម្តេចព្រះមហាក្សត្រីមិនប្រទានអាហារពេលល្ងាចឬ ?"

"មានឬបណ្តោយឲ្យអត់ ត្រៀមឲ្យគ្រប់ពេលវេលា ឲ្យប្តូរវេនគ្នាទៅញ៉ាំ តែខ្ញុំដែលមិនទាន់បានញ៉ាំព្រោះនឹកនាងទៅវិញទេ"

ចម្លើយនោះ ធ្វើឲ្យនាងក្រមុំត្រូវស្ងប់ស្ងាត់ លែងមាត់លែងក។



**បន្ទាប់ពីទទួលទានអាហាររួចរាល់** ហ៊ុលសែន ក៏ចូលមករាយការណ៍ថាមានដំណឹងសំខាន់ ធ្វើឲ្យ មិខាអ៊ីល ដាក់ពែងកាហ្វេចុះភ្លាម ប៉ុន្តែពេលគេងើបឈរ នាងក៏ងើបតាម។

"នេះចង់ទៅណា?"

អ្នកកំលោះងាកមកសួរភ្លាម ធ្វើឲ្យនាងឈប់មិនទាន់ បុកគេមួយទំហឹង តែត្រូវគេក្រសោបឱបជាប់។

"គឺ..."

នាងរកហេតុផលមិនបាន។

"ខ្ញុំបណ្តេញនាងចេញពីតួនាទីអង្គរក្សហើយ ពេលនេះជា ហ្សែកាតែមួយមុខ"

គេប្រាប់ពីតំណែងដែលនាងកំពុងតែគ្រប់គ្រង ហើយឱនថើបថ្ងាសមួយខ្សឹត។

"តែខ្ញុំចង់ដឹង" នាងនិយាយដោយភ្លេចខ្លួន ធ្វើឲ្យពួកគេសម្លឹងមើលមុខគ្នាមួយខណៈ។

ពេលនោះនាងខ្លាចខ្លាំងណាស់ថាគេបិទបាំងមិនឲ្យនាងដឹងរឿងដែលពាក់ព័ន្ធ និងការងារដែលគេធ្វើ ដូចដែលមនុស្សប្រុសភាគច្រើនតែងតែបិទបាំងភរិយា ប៉ុន្តែបន្ទាប់ពីប្រសព្វភ្នែកគ្នាមួយខណៈ មិខាអ៊ីលក៏ព្រមងក់ក្បាលជាការអនុញ្ញាត និងហៅ ហ៊ុលសែន រួមទាំងអង្គរក្សទាំងអស់ចូលមកក្នុងបន្ទប់។

"មានរឿងអី?"

មិខាអ៊ីល សួរ ហ៊ុលសែន ក៏ត្រូវមើលមុខចៅហ្វាយប្រុស បន្ទាប់មកក៏មើលមុខចៅហ្វាយស្រី ហើយឆ្លើយ។

"បានដំណឹងថា អ៊ីម៉ាម ត្រឡប់មកវិញហើយ ពេលនេះចូលមកនៅក្នុងក្រុង...ចង់ឲ្យធ្វើយ៉ាងណា?"

"បើបណ្តោយយូរ វានឹងក្រឡុកយកមនុស្សម្នាធ្វើជាបក្ខពួក"

មិខាអ៊ីល ចងចិញ្ចើមរិះគិត។

"កៀងសិនទៅ" គេបញ្ជា។

"ចុះបើលោកទៅ...គេនឹងមិនចូលមកទៀតទេឬ?"

"បណ្តោយឲ្យសម្តេចព្រះមាតាចាត់ការដោយខ្លួនឯង បន្ទាប់ពីនេះ" ព្រះអង្គម្ចាស់បោះបន្ទុកឲ្យអ្នកដែលមិនពេញចិត្តគេ។

"តើធ្វើឲ្យមានបញ្ហាដល់សម្តេចមហាក្សត្រីឬអត់?"

"ឲ្យទ្រង់និយាយជាមួយសម្តេចព្រះមាតាដោយខ្លួនឯង"

"ចុះបើ អ៊ីម៉ាម ដណ្តើមរាជបល្ល័ង្ក?"

"ទុកឲ្យសម្តេចព្រះមាតាចាត់ការទៀតទៅ"

"អីចឹងដែលលោកខំជ្រោមជ្រែងសម្តេចព្រះមហាក្សត្រី ទាល់តែបានឡើងគ្រងរាជ្យ វាមិនឥតន័យទៅហើយឬ"

សំណួរនេះធ្វើឲ្យ មិខាអ៊ីល ភាំងយ៉ាងយូរទម្រាំតែរកចម្លើយបាន។

"វាស្ថិតនៅលើសម្តេចព្រះមហាក្សត្រីថាចាត់ការយ៉ាងណាចំពោះសម្តេចព្រះមាតារបស់ទ្រង់ទៅវិញទេ ពេលដល់វេលានោះសហការគ្នាប្រឆាំងនឹង អ៊ីម៉ាម ឬបណ្តោយឲ្យគេដណ្តើមយករាជ្យបល្ល័ង្កបានយ៉ាងស្រួល ឲ្យទ្រង់ជាអ្នកសម្រេចព្រះទ័យ"

ព្រះអង្គម្ចាស់និយាយ ដូចសម្រេចចិត្តរលាស់ដៃដើរចេញហើយបន្ទាប់ពីប្រឹងប្រទាញប្រទង់វាយ៉ាងយូរ។



"លោកនិយាយដូចចាប់ពីពេលនេះទៅ លោកនឹងថយចេញឲ្យ

ឆ្ងាយពីអំណាចទាំងអស់ រលាស់ដៃដើរចេញ ដោយមិនជួយសម្ដេចព្រះមហាក្សត្រី លោកធ្វើបានឬអត់?"

ហេយ្យ នៅតែសង្ស័យ រហូតដល់ពេលដែលគួរសម្រាក ក៏នាងនៅតែអង្គុយចាំដើម្បីនិយាយជាមួយគេ។

វេលានោះ តាមពិតនៅក្នុងទូខោអាវ មានអាវដេកស្អាតៗទាន់សម័យច្រើនព្យួរឲ្យជ្រើសរើស តែនាងបែរជាស្រវាយកតួប អាវពណ៌សម៉ូដមនុស្សប្រុស តែមានទំហំតូចសក្ដិសមនឹងដងខ្លួន។

មិខាអ៊ីល ដើរមកឈរទល់មុខ និងមើលនាងដោយខ្សែភ្នែកស្រទន់ បន្ទាប់មកក៏លូកដៃមកប៉ះអាវនៅលើដងខ្លួនរបស់នាង។

"មានឈុតស្អាតៗឲ្យរើសគរគោក ម៉េចក៏រើសអាវបែបនេះ?" គេសួរ និងដាក់គូថក្បែរ មើលមុខស្រស់ស្អាតនិងសរសៃសក់វែងរំសាយដែលធ្លាក់គ្របស្មា។

"បន្ទាប់ពីត្រឡប់ទៅកូរ៉េខាងត្បូង ទៅនៅផ្ទះរបស់នាងហើយ ទើបដឹងថាខ្លួនឯងត្រូវការអី ខ្ញុំចង់រស់នៅស្ងប់ស្ងាត់ដូចនាង រស់នៅដោយមិនចាំបាច់រត់គេចពីការតាមសម្លាប់របស់អ្នកណា រយៈពេលជាច្រើនឆ្នាំមកនេះ គ្មានថ្ងៃណាដែលខ្ញុំដេកលក់ពេញភ្នែក រហូតដល់យប់មិញជាយប់ដំបូង"

គេនិយាយខ្សឹបៗ និងសម្លឹងមើលនាងមិនដាក់ភ្នែក គ្របកភ្នែកដែលលម្អដោយរោមភ្នែកងវែងមិនចាញ់មនុស្សស្រី ញ័រតិចៗពេលសម្លឹងមើលនាងដោយមានន័យលាក់បង្កប់។

"លោកនិយាយដូចមិនបារម្ភពីស្រុកទេស"

"បារម្ភ តែពេលនេះមានសម្ដេចមហាក្សត្រីហើយ ទ្រង់មានបញ្ញាវាងវៃ យ៉ាងហោចណាស់ពេលឃើញខ្ញុំមើលនាង ទ្រង់ដឹងភ្លាម"



សម្ដីរបស់គេធ្វើឲ្យ ហេយ្យ មិនចង់ជឿ។

"មែនឬ?"

"មែនតើ ហើយទ្រង់ធ្វើតាមការគិត គឺបណ្ដេញនាងចេញឲ្យឆ្ងាយ មិនព្រមឲ្យចូលមកជិតព្រោះទ្រង់ខ្លាច តែនាងនៅតែត្រូវមកនៅជាមួយខ្ញុំដដែល"

"ទ្រង់ត្រូវការឲ្យលោកបញ្ជូនខ្ញុំត្រឡប់ទៅវិញ"

"បើបញ្ជូននាងត្រឡប់ទៅវិញ ប្រហែលមិនអាចសុំឲ្យនាងមក..."

ពេលស្ដាប់ហើយ នាងក៏បិទភ្នែក។

"គិតអី?"

"អត់មានទេ"

"មិនពិត"

"និយាយដល់សម្ដេចព្រះមហាក្សត្រីបន្តទៅ ខ្ញុំចង់ដឹងថាលោកជឿជាក់ចំពោះទ្រង់កម្រិតណា ទើបទុកគ្រប់យ៉ាងចោលបានបែបនេះ"

"តាមរយៈការនិយាយគ្នាជាមួយទ្រង់ពីរបីដង ធ្វើឲ្យឃើញព្រះរាជតម្រិះ និងគំនិតផ្ទាល់ព្រះអង្គជាច្រើន ដែលគិតថាទ្រង់នឹងដឹកនាំឲ្យរីកចម្រើនបាន"

"អ៊ីចឹងផងឬ"

"អ៊ីចឹងឯង ទ្រង់មានព្រះរាជបញ្ញាញាណ និយាយសាមញ្ញៗ គឺទ្រង់ពូកែ"

"ចុះសម្ដេចព្រះមាតា និង អ៊ីម៉ាម?"

"បើទ្រង់មិនស្ដាប់ច្រើនពេក គឺអាចធ្វើការបន្តបាន និងគិតថាទ្រង់មិនស្ដាប់ប៉ុន្មានទេ ព្រោះមិនស្និទ្ធស្នាលតាំងពីតូច"

"ហើយទ្រង់នៅជិតអ្នកណា?"



"ព្រះមហាក្សត្រនិងខ្ញុំ..."

"អេ៎ មិនឃើញទ្រង់នៅជិតលោកប៉ុន្មានផង"

"ពេលធំឡើង ទ្រង់ចូលចិត្តដើរលេង ទើបឆ្ងាយគ្នាទៅ ធ្វើឲ្យខ្ញុំត្រូវធ្វើការជ្រែកដៃ ខណៈដែលទ្រង់គិតតែដើរលេងស្រួលខ្លួន"

"អ៎! បែបនេះឯង"

"មិនបានបោះបោលទាំងស្រុងទេ ប្រាប់ហើយតើថាបើធ្ងន់ធ្ងរ គឺអាចតេរសួរគ្នាបាន ពិភាក្សាគ្នាបាន ទៅមករកគ្នាបាន គ្រាន់តែត្រូវនៅឆ្ងាយគ្នាព្រោះខ្ញុំមាននាង មានក្រុមគ្រួសារហើយ ហើយទ្រង់ក៏គួរមានរបស់ទ្រង់ដែរ"

"ទ្រង់ស្រឡាញ់លោក" នាងនៅតែអះអាងជំនឿរបស់ខ្លួន។

"អេ៎! និយាយបែបនេះច្រើនដងហើយ ចុះនាង ស្រឡាញ់ខ្ញុំខ្លះដែរទេ ឬថាដែលរៀបការនេះព្រោះគេចមិនផុត?"

គេសួរ និងមើលមកមិនដាក់ភ្នែក ធ្វើឲ្យនាងត្រូវគេចមុខ ប្រាប់ខ្លួនឯងថាគេនិយាយត្រូវពាក់កណ្តាល មិនត្រូវពាក់កណ្តាល តែដែលនិយាយថានាងគេចមិនផុតនោះ វាជារឿងពិត។

នាងចេញពីមន្ទីរពេទ្យហើយក៏ត្រូវចាប់រៀបការ របួសធ្ងន់ធ្ងរបែបនេះគេចទៅណាបាន ហើយការរៀបការនៅចំពោះព្រះភក្ត្រសម្តេចមហា-ក្សត្រី ដែលមនុស្សទូទាំងគោរពលើកតម្កើន មិនមែនជារឿងគួរបដិសេធដែលសំខាន់ គេរឹបអូសបេះដូងរបស់នាងបានពាក់កណ្តាលទៅហើយ ចំណែកពាក់កណ្តាលទៀតនៅនឹងនាង ដែលត្រូវសម្រេចចិត្តថាគួរប្រគល់ឲ្យគេឬអត់។

ពេលឆ្លើយមិនបាន និងមិនចង់ឆ្លើយ ទើបនាងផ្តួលខ្លួនដេក ធ្វើឲ្យគេតាមមើលដោយការភ្ញាក់ផ្អើល។



"ឈប់...ឈប់សិន ចង់ដេកឬ?"

"ខ្ញុំជាអ្នកជំងឺ ពេទ្យប្រាប់ឲ្យសម្រាកឲ្យបានច្រើន" នាងធ្វើជាមិនដឹងមិនឮ។

"ថ្ងៃនេះសម្រាកពេញមួយថ្ងៃហើយតើ...ឈប់..."

គេឡូឡាពេលឃើញនាងបិទភ្នែក ហើយក៏មិនព្រមបើកម្តងទៀតដែរ។

មិខាអ៊ីល មើលនាងក្រមុំមួយសន្ទុះ ក៏កើតគំនិតថ្មី ផ្តួលខ្លួនដេកក្បែរ ជ្រប់មុខនឹងខ្នងតូចស្តើង ហើយអូសបបូរមាត់ក្តៅតាំងពីត្រង់នោះរហូតដល់ចុងជើង។

នាងក្រមុំភ្ញាក់ព្រើត ពេលបបូរមាត់ក្តៅនោះប៉ះសាច់ភ្លៅរបស់ខ្លួន បន្ទាប់មកក៏អូសឡើងមកលើជាថ្មី ដោយជាយអាវដំណេកត្រូវលើកឡើងលើជារឿយៗ។

ឃើញទេ គេមានព្រមតាមសម្រួលឯណា នាងគួរតែដឹង។

ទីបំផុតនាងត្រូវប្រែខ្លួនទៅរក ពេលបបូរមាត់ក្តៅនោះអូសសព្វសាច់ ដោយមិនព្រមឲ្យនាងគេចទៅណាបាន។

ហេយ្យូ ដឹងថាខ្លួនភ្លាត់ស្នៀតហើយ ពេលបណ្តោយឲ្យគេថើបកន្លែងដែលឆាប់មានរំញោច និងគ្រប់គ្រងនាងបានសម្រេច។

ដៃទាំងពីរប្រឹងរុញច្រានរាងកាយរឹងមាំនោះចេញឲ្យផុត ប៉ុន្តែបែរជាត្រូវទាញឲ្យទៅឱបករឹងមាំ ខណៈដែលបាតដៃក្តៅឧណ្ហៗអូសសព្វសាច់របស់នាង ទាំងដើមទ្រូងណែនក្បំ ចង្កេះតូច និងពោះរាបស្មើ ធ្វើឲ្យនាងស្រៀវ អស់ផ្លូវនឹងបដិសេធបានតទៅទៀត ក្រៅពីដើរតាមទាល់តែដល់គោលដៅដែលព្រះអង្គម្ចាស់ត្រូវការ។



Scanned by CamScanner

# ១៧

ប្អូនប្រាំថ្ងៃក្រោយមក មិខាអ៊ីល ក៏រៀបចំខ្លួនធ្វើដំណើរចាកចេញពីសាគីស្ថាន។ ការពិតទៅវាគ្មានស្អីគួរឲ្យមានបញ្ហាទៀតទេបើ ហ៊ុលសែន មិនចូលមករាយការណ៍។

"អ៊ីម៉ាម បាត់ខ្លួន វាមិនត្រូវកៀងឲ្យត្រូវចេញក្រៅក្រុងដូចលើកមុនទេ"

មិខាអ៊ីល នៅស្ងៀមច្រើនដង្ហើមតែម្តងទើបនិយាយ។

"មើលខុសត្រូវវេនយាមឲ្យបានល្អ តឹងរ៉ឹងគ្រប់ដំណាក់កាល ឲ្យអង្គរក្សទៅទូលសម្តេចមហាក្សត្រីផង"

"បាទទាន"

"លោកគិតថាគេនឹងមកប្រឈមនឹងពួកយើងទេ?" នាងអត់សួរមិនបានពេលដឹងរឿង។

"អ៊ីម៉ាម មិនធ្វើដោយខ្លួនឯង តែប្រើកូនចៅ"

"គេនឹងសម្រុកចូលមកក្នុងនេះទេ?"



"មិនច្បាស់ បារម្ភឬ?" ព្រះអង្គម្ចាស់ងាកទៅសួរនិងទាញនាងមកអង្អុយលើភ្លៅឱបថ្នមៗ។

"មិនបារម្ភទេ"

នាងតបដោយទឹកមុខរាបស្មើ ខណៈដែលគេទៅជានៅមិនសុខអង្អែលភ្លៅរបស់នាង ហើយក៏ចងចិញ្ចើមពេលប៉ះរបស់ម្យ៉ាងដែលនាងលាក់។

មិខាអ៊ីល ព្រិចភ្នែក ហើយចាប់លាត់អាបាយ៉ាដែលនាងពាក់ឡើងលើភ្លាមដោយមិនក្រែងរអែងចិត្ត ខណៈដែល ហេយ្យូ តាមសង្រ្គុបមិនទាន់។

ពេលឃើញខ្សែស្បែកសម្រាប់ដាក់កាំភ្លើងខ្នាតតូចដែលនាងមានតែមិនធ្លាប់ប្រើ គេក៏ងើយមើលមុខ និងអង្អែលជើងម្ខាងនោះ ហើយពេលប៉ះកូនកាំបិត ក៏សម្លឹងមើលមិនដាក់ភ្នែក។

"ខ្ញុំបណ្តេញនាងចេញហើយ...នាងជា **ហៃរ្យកា** មិនមែនអង្គរក្ស"

គេប្រាប់ និងប្រុងទាញខ្សែស្បែកនោះចេញ តែត្រូវនាងរុញដៃដោយកំហឹង ដែលគេលាត់អាវរបស់នាងដោយមិនក្រែងរអែងចិត្ត។

"ខ្ញុំទុកការពារខ្លួនឯង ក្នុងស្ថានការណ៍បែបនេះលោកឲ្យខ្ញុំទុកអាវុធនៅឆ្ងាយខ្លួនមិនបានទេ"

អ្នកកំលោះទៅជាភាំងពេលនាងឲ្យហេតុផល។

"លោកមិនឲ្យខ្ញុំសល់ក្រញាំការពារខ្លួនឯងខ្លះវាមិនបានទេ"

នាងបញ្ជាក់ និងលោតថយឲ្យឆ្ងាយ ទោះការលោតនោះធ្វើឲ្យឈឺមុខរបួសខ្លាំងក៏ដោយ។

"ខ្ញុំជាអង្គរក្ស មិនបានត្រៀមខ្លួនមកធ្វើជា **ហៃរ្យកា** ដើរដកដង្ហើមចោលនោះទេ មិនធ្វើ"



"នាងនៅខ្សោយណាស់មិនអាចធ្វើអីបែបនោះបាន"

គេស្តីឲ្យ តែមើលមុខនាងដោយការព្រួយបារម្ភ។

"ខ្ញុំនឹងធ្វើតាមដែលខ្លួនឯងធ្វើបាន" នាងប្រាប់ហើយដើរចេញ មិនឲ្យគេចូលមកជិតទៀត។ នាងដឹងខ្លួនហើយថាច្រើនថ្ងៃកន្លងមកខ្លួនឯងខ្សោយខ្លាំង ជាពិសេស **បេះដូង** ទើបបណ្តោយឲ្យគេធ្វើតាមអំពើចិត្តញឹកញាប់ព្រោះគ្មានកម្លាំងកំហែងតតាំង។

មិខាអ៊ីល តាមមើលមនុស្សស្រីដែលខ្លួនសម្រេចចិត្តរៀបការជាមួយដោយមិនមាត់មិន.កនិងដឹងថាបើប្រៀបធៀបនាងនិង វ៉ននី ដែលជាសម្តេចមហាក្សត្រី ទ្រង់មិនធ្លាប់ធ្វើឲ្យគេជាប់ចិត្តដូចស្រីជម្មតាម្នាក់នេះ តាំងពីឃើញនាងលើកដំបូងរហូតមកដល់ថ្ងៃនេះ។

**ហ្សែកា**របស់គេមិនដូចនរណាជាពិសេសសញ្ចាតិញ្ញាណពិសេសរបស់នាងដែលជួយគេបានច្រើនដង រួមទាំងសេចក្តីសុខពីនាងដែលធ្វើឲ្យគេមានអារម្មណ៍ថាបេះដូងរបស់ខ្លួនត្រូវបានបំពេញបន្ថែមគ្រប់ពេលដែលបានបបោសអង្អែលនាងសមតាមបំណងប្រាថ្នា។

ណ្ហើយបើនាងនៅតែរឹងក្បាលនិងមិនព្រមឲ្យយកឈ្នះងាយៗនៅពេលនេះ អីចឹងចាំឈ្នះពេលក្រោយក៏បានដែរ...មិខាអ៊ីល លួចញញឹមដាក់ខ្លួនឯងពេលគិតទៅដល់ណាទៅដល់ណី។

**ពេលដល់ថ្ងៃធ្វើដំណើរ សម្តេចមហាក្សត្រីក៏ជូនដំណើរដល់**យន្តហោះ និយាយជាមួយយ៉ាងយូរទម្រាំតែព្រះអង្គម្ចាស់ជូនដំណើរឡើងព្រះរាជរថនៅព្រលានយន្តហោះមួយនោះ បន្ទាប់មកទើបគេដើរមករកហ្សែការបស់ខ្លួន ហើយនាំឡើងយន្តហោះ។

ពេលនោះកាពីទែន និងបុគ្គលិកទាំងអស់តម្រង់ជួរគ្នាចាំទទួលរហូតដល់ព្រះអង្គម្ចាស់មកដល់និងបានណែនាំនាងឲ្យស្គាល់។

ហេយ្សូ ដើរតាមគេដោយមិនមាត់មិន.ក និងមិនគិតអីច្រើនរហូតដល់ឃើញកាពីទែនគេចភ្នែកនាងដោយចៃដន្យមុនគេ បន្ទាប់មកក៏មើលទៅអែហូតេសចុងក្រោយ ដែលគេចភ្នែកនាងភ្លាមទាំងដែលមិនគួរណាគេច ធ្វើឲ្យនាងព្រិចភ្នែកមើលម្តងទៀត ហើយក៏ត្រូវដឹកដៃឡើងជណ្តើរ។

ការមើលឃើញអាការៈទាំងនេះ ធ្វើឲ្យនាងមានអារម្មណ៍ថាអសុវត្ថិភាពភ្លាម។ វាត្រូវតែមានអ្វីម្យ៉ាងលាក់នៅក្នុងនេះ តើចង់ឲ្យជាអ្វីទៀតបើមិនមែនការរឹបអូសយកយន្តហោះមួយនេះ។

ពេលគិតឃើញដូច្នោះហើយ នាងក៏មានអារម្មណ៍ថាព្រីវងាត្រូវទាញអាវរងានៅក្នុងកាបូបមកពាក់មួយជាន់ទៀត។

"រងាឬ គ្រុនឬអត់?"

ព្រះអង្គម្ចាស់ឃ្លាំមើល **ហ្សែកា** របស់ខ្លួនគ្រប់ពេលវេលា។

គេសួរនិងលូកដៃទៅស្ទាបថ្ងាស ក្រោមខ្សែភ្នែកគ្រប់គ្នាដែលមើលមក ហើយដឹងថានាងមិនទាន់រឹងមាំ នៅតែមានជំងឺ។

វេលានោះ ហេយ្សូ អង្អែលហោប៉ៅអាវរងារបស់ខ្លួនគ្រប់ហោប៉ៅដោយចិត្តត្រជាក់ និងដឹងថាគ្រប់យ៉ាងនៅកន្លែងរបស់វាដដែល ហើយក្រឡេកមើល ហ៊ុលសែន។

ប្រធានក្រុមអង្គរក្សសម្លឹងមើលនាងដោយអចេតនា ហើយក៏ភាំងដូចនឹកឃើញ បន្ទាប់មកក៏ងាកទៅមើលកូនចៅរបស់ខ្លួននិងទាហានរបស់សម្តេចមហាក្សត្រីដែលតាមមកការពារ ព្រះអង្គម្ចាស់ជាពិសេសតាមរាជបញ្ជាជាការដាស់តឿនដោយស្វ័យប្រវត្ត ដោយមិនបាច់និយាយឲ្យខាតពេល។



បន្ទាប់មកពួកគេក៏ចូលអង្គុយ ត្រៀមខ្លួនធ្វើដំណើរ ដោយមាន

អ៊ែហូតេសដើរមកណែនាំ បើកវីដេអូបង្ហាញពីវិធីប្រើប្រាស់ឧបករណ៍ដែលមាននៅជុំវិញខ្លួន។

ពេលចប់ យន្តហោះទ្វារខាងកាពីទែនក៏ត្រូវបើក ដោយមានបុរសមាឌធំមានពុកមាត់ស្រមូមដើរចេញមក។

ពេលឃើញមុខដែលស្អុកដោយពុកមាត់ប៉ុណ្ណឹង អង្គរក្សទាំងឡាយដូចបានឮគាំងប្រកាសអាសន្ន ព្រោះគ្មានកាពីទែនយន្តហោះផ្ទាល់ខ្លួនណា ត្រូវអនុញ្ញាតឲ្យទុកពុកមាត់ពុកចង្កាស្រមូមបែបនេះសូម្បីតែកាពីទែនយន្តហោះឯកជន។

ការពិត ហេយ្ស៊ូ ស្មានថាវាជាការតែងខ្លួនលើយន្តហោះពេលផុតពីវ៉ាន់វ៉េតើ ប៉ុន្តែពេលនឹកឃើញនៅពេលនេះ និងគិតថាប្រហែលជាពេលនេះឯងដែលមុនពេលគ្រប់គ្នាបានងាកខ្លួន អ៊ែហូតេសនិងស្ប៉ុតក៏ទាញកាំភ្លើងមកភ្ជង់គំរាមបានមុន។

"កុំកម្រើក មិនអីចឹងងាប់ទាំងអស់គ្នា"

កាពីទែនពុកមាត់ស្រមូមប្រាប់ និងសម្លឹងមើលគ្រប់គ្នាដោយមើលនាងក្រោយគេ តែមិនចាប់អារម្មណ៍អីណាស់ណា ដែលវាធ្វើឲ្យនាងសប្បាយចិត្តហួសហេតុ។

"យើងមិនត្រូវការអ្នកណាក្រៅពី ហ្ស៊ីក ដូច្នេះហើយអនុញ្ញាតឲ្យគ្រប់គ្នាចុះពីយន្តហោះនេះលើកលែងហ្ស៊ីកហើយកុំលេងល្បិចបើមិនចង់ងាប់"

កាពីទែននិយាយមិនទាន់ចប់ស្រួលបួលផង ហ៊ុលសែន ក៏បាញ់ចំក្បាលមុនគេនិងអ្នកបន្តបន្ទាប់ក៏ត្រូវបាញ់ដោយអង្គរក្សដែលត្រៀមខ្លួនរួចជាស្រេច ចំណែក ហេយ្ស៊ូ មិនចាំបាច់និយាយ ក៏មិនអែអង់ជួយចាត់ការពួកនោះដូចគ្នា ខណៈដែលព្រះអង្គម្ចាស់ចាត់ការអាពុកមាត់



ស្រមូមឲ្យផ្ងារក្រោយទៅហើយ។

ពេលស្ងាត់សំឡេងកាំភ្លើងបុគ្គលិកក្លែងក្លាយទាំងអស់ក៏ស្លាប់ក្នុងថ្លុកឈាម ហើយពេលងាកទៅមើល មិខាអ៊ីល ក៏ឃើញឈាមជ្រាបចេញពីទ្រូងអាវរបស់គេ។

"អ៊ូយ...កុំ..."

ហេយ្ស៊ូ ស្រែកភ្ញាក់មាត់ស្ទុះទៅរកគេ និងលាត់មើលកន្លែងដែលគ្រាប់កាំភ្លើងទម្លុះ វាក្រហមរងាំងពេញដើមទ្រូង ធ្វើឲ្យមើលមិនដឹងថាត្រូវត្រង់ណា ទើបនាងស្រែកសួរដដែល។

"មិខាអ៊ីល...លោកត្រូវត្រង់ណា...ត្រូវត្រង់ណា!"

នាងស្ទាបពេញដើមទ្រូងនោះដូចមនុស្សឡប់សតិមិនបានឮសូម្បីសំឡេង ហ៊ុលសែន ទូរសព្ទហៅឡានពេទ្យ។



## ១៨

សម្តេចព្រះមហាក្សត្រី ស្តេចយាងមកសួរសុខទុក្ខអ្នកជំងឺដល់មន្ទីរពេទ្យជាងមួយម៉ោងទម្រាំយាងត្រឡប់ទៅវិញ ទើប ហេយ្យូ ចូលទៅមើលអាការៈអ្នកជំងឺ ដែលគ្រូពេទ្យមិនទាន់ធានាថាមានសុវត្ថិភាពឬយ៉ាងណា ព្រោះគ្រាប់កាំភ្លើងមួយគ្រាប់នោះឆាសបេះដូង។

ពេលពេទ្យប្រាប់បែបនេះ ហៃ្យកា ទៅជាអែនក្បាលពិតនឹងជញ្ជាំងមន្ទីរពេទ្យដោយគ្មានកម្លាំងកំហែង ពេលដឹងថាមនុស្សសំខាន់នៅក្នុងជីវិតដែលនាងបានការពារគេមួយរយៈហើយ អាចនឹងគ្មានជីវិតរស់នៅតទៅទៀត និងឈឺចាប់ដោយមិនអាចកាត់ថ្លៃបាន ពេលប្រាប់ខ្លួនឯងថានាងមិនអាចការពារគេបានតាមតួនាទី។

នាងធ្លាប់មានបទពិសោធបាត់បង់រួចទៅហើយ តែលើកនេះឈឺចាប់ជាង ត្រូវប្រាប់ខ្លួនឯងថាចង់ស្លាប់ដោយខ្លួនឯងជាងរស់នៅបន្តដោយគ្មានគេ។

នេះជាអ្វី... នេះនាងទើបតែដឹងថាស្រឡាញ់គេអស់ពីបេះដូងនៅ



ពេលដែលគេមិនអាចងើបមកទទួលដឹងឮទៀតឬ?

នាងក្រមុំបិទភ្នែក ពិតក្បាលនឹងជញ្ជាំងបែបនោះដោយគ្មានកម្លាំងកំហែង អស់កម្លាំងខ្សោះពីខ្លួន។

ពេលនេះ នាងមិនបានចាប់អារម្មណ៍ទេថាសម្តេចព្រះមហាក្សត្រីស្រឡាញ់គេប៉ុណ្ណាឬគេស្រឡាញ់ទ្រង់បែបណា ស្រឡាញ់ឬមិនស្រឡាញ់ ក្រៅពីចង់ឲ្យគេនៅមានជីវិតរស់នៅជាមួយនាង ជារបស់នាង យកចិត្តទុកដាក់នាង ព្រមឲ្យនាងមានចំណែករួមគ្រប់ការងារដែលគេធ្វើ...ដូចមុន។

មិខាអ៊ីល សន្លប់បីយប់បីថ្ងៃហើយទម្រាំដឹងខ្លួន ដោយមាន ហៃ្យកា អង្គុយកំដរនៅក្បាលគ្រែរហូត មិនព្រមទៅណា។

"ហៃ្យកា" គេហៅនាងដោយសព្វនាមនេះភ្លាម ពេលឃើញមុខព្រមទាំងទាញនាងទៅរក ដោយកម្លាំងកំហែងដែលមាននៅពេលនេះ ធ្វើឲ្យនាងក្រមុំដឹងថា មិខាអ៊ីល ពេញចិត្តប្រើពាក្យនេះហៅនាង ហៃ្យកា ភរិយារបស់គេ ជាងពាក្យឯទៀត មិនថាជាឈ្មោះរបស់នាង ឬពាក្យផ្អែមល្ហែម ក៏គេមិនធ្លាប់ប្រើមកលើនាង។

ពេលដឹងដំណឹងព្រះអង្គម្ចាស់ដឹងខ្លួន សម្តេចព្រះមហាក្សត្រីក៏យាងមកម្តងទៀត។

ហេយ្យូ ដឹងច្បាស់ថានៅវេលានេះ អ្នកជំងឺនិយាយអីមិនទាន់បានច្រើន អ្វីដែលធ្វើបានគឺការដែលទ្រង់មកទតមើលថាគេធូរស្រាលហើយ ដើម្បីឲ្យសប្បាយព្រះទ័យតែប៉ុណ្ណោះ ហើយស្តេចយាងត្រឡប់ទៅវិញ។

លើកនេះនាងតាមមើលទ្រង់ដោយនឹកអាណិតប្លែកៗ។នាងមើលឃើញមនុស្សស្រីខ្ពង់ខ្ពស់ ធំជាងគេបំផុតនៅក្នុងដែនដីនេះ ដើរចេញទៅ



ដោយអារម្មណ៍កណ្ដោចកណ្ដែង គ្មានអ្នកយល់និងអាចជួយបាន ហើយមើលមកខ្លួនឯង។

នាងសំណាងល្អជាងសម្ដេចព្រះមហាក្សត្រី ត្រង់នាងមានគេបុរសសង្ហាបំផុតនៅដែនដីនេះ ដែលនាងមានឱកាសបាននៅក្បែរ បានធ្វើជាម្ចាស់។

ទោះមិនច្បាស់ចំពោះក្ដីស្រឡាញ់របស់គេ តែពេលនេះនាងច្បាស់ចំពោះក្ដីស្រឡាញ់របស់ខ្លួនថាបានប្រគល់ឲ្យគេតែម្នាក់គត់អស់ពីបេះដូង ដោយមិនត្រូវការអ្វីពីគេទៀត។

នាងចូលទៅមើលថៃគេ ពេលសម្ដេចព្រះមហាក្សត្រីស្ដេចយាងត្រឡប់ទៅវិញ ឃើញ មិខាអ៊ីល ងាកមកមើល ហើយលូកដៃមករកទើបដើរទៅឈរជិតគ្រែ តែគេនៅតែទាញឲ្យនាងឡើងទៅអង្គុយលើគ្រែតូចចង្អៀតនោះ។

"យ៉ាងម៉េចហើយ ធូរស្រាលច្រើនមែនទេ ?"

នាងឱនទៅសួរ តែគេមិនយកចិត្តទុកដាក់នឹងសំណួរនោះ ក្រៅពីទាញនាងឲ្យទ្រោបទៅរក ទាល់តែមុខរបស់នាងផ្អឹបនឹងមុខសុទ្ធតែពុកមាត់ពុកចង្កា ហើយខ្សឹបពាក្យដែលនាងមិនធ្លាប់គិតថានឹងបានឮចេញពីមាត់របស់គេ។

"បងស្រឡាញ់អូន ហ្សែកា ម្ចាស់ស្នេហ៍"

ហើយគេក៏នៅស្ងៀម មិននិយាយអីទៀត ទាល់តែនាងងើយប្រសព្វភ្នែកជាមួយ មើលគេដោយមិនចង់ជឿ តែវេលានេះគេប្រហែលមិនកុហក វាមានប្រយោជន៍អីទៅដែលត្រូវកុហក។

"ព្រោះអូនមិនដូចគេ អូនធ្វើឲ្យជីវិតដែលត្រូវតស៊ូយ៉ាងកណ្ដោច-កណ្ដែងរបស់បងមានន័យ បងមិនធ្លាប់ស្រឡាញ់ព្រះអង្គម្ចាស់ក្សត្រីទ្រង់ដឹង"

"បងមិនបាច់ប្រាប់នៅពេលនេះក៏បាន" នាងនិយាយរអ៊ូៗឲ្យគេឮ។

"បងចង់ឲ្យអូនដឹង"

គេនិយាយតែប៉ុណ្ណឹង ហើយក៏បិទភ្នែកម្ដងទៀត មានតែខ្យល់ដង្ហើមថេរតែប៉ុណ្ណោះដែលប្រាប់ឲ្យនាងដឹងថាគេនៅមានជីវិតរស់។

**ច្រើនថ្ងៃកន្លងផុតទៅ មិខាអ៊ីល នៅតែដេកលក់បែបនោះ ភ្ញាក់ដឹង**ខ្លួនម្ដងៗប៉ុណ្ណោះ ហើយក៏លង់លក់ដូចពេលដែលនាងត្រូវគ្រាប់ដែរ។

អង្គរក្សទាំងអស់នៅការពារខាងក្រៅមិនទៅណា រង់ចាំស្ដាប់អាការៈរបស់ចៅហ្វាយដោយមិនមាត់មិនក។

សម្ដេចមហាក្សត្រីទ្រង់មិនបានយាងមកទៀត រហូតដល់ពេលដែលពេទ្យអនុញ្ញាតឲ្យអ្នកជំងឺត្រឡប់ទៅវាំងវិញ ពេលអាការៈធូរស្រាល។

"មកនេះ"

មិខាអ៊ីល ហៅ និងសម្លឹងមើលមិនដាក់ភ្នែក ខណៈដែលនាងក្រមុំរាវែក ព្រោះត្រឹមមើលកែវភ្នែកមានពន្លឺផ្លេកៗនោះក៏ដឹងទៅហើយ។

"បងមិនទាន់ស្រួលខ្លួន"

នាងដាស់តឿន និងមិនចង់ចូលទៅជិត។ មិខាអ៊ីល មិនតប តែទះពូកក្បែរ ទើបនាងងាកទៅមើលម៉ោង ហើយងាកមកប្រាប់។

"យប់ជ្រៅហើយ បងត្រូវសម្រាក"

អ្នកកំលោះមិននិយាយ តែកែវភ្នែកដែលមើលមកគួរឲ្យខ្លាច។

"ចង់មកតាមសម្រួល ឬឲ្យងើបទៅបី"



ពេលឮដូច្នេះ ហ្សែកា ដ៏ស្រស់ស្អាតក៏រាវែកម្ដងទៀត។

"ឆាប់ឡើង"

លើកនេះមិនត្រឹមតែនិយាយទេ នៅប្រុងចុះពីគ្រែទៀតផង ធ្វើឲ្យនាងក្រមុំត្រូវដើរទៅរកតាមសម្រួលដោយការព្រួយបារម្ភ និងឃ្នើសចិត្តនឹងខ្លួនឯងដែលត្រូវគេបង្គាប់។

ពេលចាប់នាងបាន គេក៏ឱបណែនដៃ ទាញរាងតូចស្តើងមកអង្គុយលើគ្រែជាមួយ ថើបបបូរមាត់របស់នាងយ៉ាងយូរ ថើបស្ទើរតែដាច់ខ្យល់។

"ឃើញទេ រឹងមាំហើយ ដេករាប់ខែហើយ ចង់បែកទ្រូង"

គេរអ៊ូរទាំ ពេលអូសច្រមុះនិងបបូរមាត់មករកក ដៃក៏រវើមរវាម នៅមិនសុខ បបោសអង្អែលដើមទ្រូងណែនក្បាំរបស់នាងក្រមុំ។

អាការៈឈឺធ្ងន់ធ្ងររបស់ មិខាអ៊ីល ធ្វើឲ្យ ហេយ្យូ មិនចង់ជំទាស់ចិត្តគេទៀត កាន់តែឮពាក្យថាស្រឡាញ់នៅថ្ងៃដែលទើបតែដឹងខ្លួនដំបូង ធ្វើឲ្យនាងដឹងពីអារម្មណ៍ដែលខ្លួនឯងមានចំពោះគេ។

តួបពណ៌សដែលនាងចូលចិត្តយកមកពាក់របូតពីរាងកាយដោយការពេញចិត្តជាលើកដំបូងព្រមទាំងឱនមកថើបដើមទ្រូងដោយអារម្មណ៍ឈ្លក់វង្វេង ដៃក៏ស្ទាបអង្អែលខ្នងជំទូលាយ អូសទៅដល់ត្រគាកហាប់ណែនសុទ្ធតែសាច់ដុំដោយការប្រាថ្នា។

"ថ្ងៃនេះចិត្តល្អម្ល៉េះ"

មិខាអ៊ីល និយាយរអ៊ូៗ ពេលស្រង់យកក្លិនក្រអូបរបស់ស្បែកទន់ល្មើយទៅទុកក្នុងដើមទ្រូង បបូរមាត់និងច្រមុះអូសតាមដើមទ្រូងនលគកទ្រលុកទ្រលន់ ដួសដងយកភាពផ្អែមល្ហែមទៅចិញ្ចឹមចិត្តទុកក្នុងការចងចាំដែលគ្មានថ្ងៃបំភ្លេច។

នាងក្រមុំបិទភ្នែកពេលតាំងចិត្តហើយថាមិនបដិសេធ ឬរុញច្រាន



ក្តីស្រឡាញ់របស់គេទៀត។ ការបាត់បង់គេជារៀងរហូត ធ្វើឲ្យនាងដឹងចិត្តខ្លួនឯងច្រើនតែម្តង។

បបូរមាត់ទន់ល្មើយ បង្ហើបទទួលការថើបជញ្ជក់ដោយការពេញចិត្តបណ្តោយឲ្យគេបង្ហាញក្តីស្រឡាញ់ចំពោះនាងមិនជំទាស់ឬបដិសេធដូចរាល់ដង។

រាងតូចច្រឡឹងញ័រខ្លួនទទ្រើតនៅក្នុងរង្វង់ដៃកក់ក្តៅ ព្រមឲ្យព្យុះអារម្មណ៍របស់អ្នកកំលោះបោកបក់នាំទៅតាមការប្រាថ្នា មិនថាខ្លាំងក្លាយ៉ាងណា ឬទន់ភ្លន់ ទំនើងបែបណា ពេលនេះនាងក្លាយជា **ហ្សេកា** របស់គេហើយ ហើយនឹងនៅតែបែបនោះជារៀងរហូត ដោយមិនគិតថានឹងប្តូរចិត្តរត់ទៅណាទៀត។

ហេយ្យូ ដកដង្ហើមធំពេល មិខាអ៊ីល គ្រប់គ្រង ផ្ញើក្តីស្រឡាញ់នឹងរាងកាយនិងបេះដូង។

កែវភ្នែកពីដួងសម្លឹងមើលគ្នាយ៉ាងយូរ និងព្រមទទួលយកគ្នាដោយមិនបដិសេធនិងរុញច្រានតទៅទៀត។

បញ្ហាទាំងអស់ដែលមាននៅក្នុងចិត្តរលាយអស់ ពេលពួកគេដឹងចិត្តខ្លួនឯងច្បាស់។

នាងសុំនៅក្នុងរង្វង់ដៃកក់ក្តៅនេះ និងប្រាប់ខ្លួនឯងថាមិនថារស់នៅក្នុងទឹកដីណាក៏ដោយ សុំត្រឹមមានគេនៅជាមួយ មិនបោះបង់នាង នាងក៏ពេញចិត្តទៅហើយ។

ហេយ្យូ ប្រាប់ខ្លួនឯងពេលលង់លក់ក្នុងរង្វង់ដៃរបស់ម្ចាស់បេះដូងនៅវេលាបន្ទាប់។



**ព្រះអង្គម្ចាស់ អាឌែល នៃឃីនយ៉ា គូអភិសេករបស់ព្រះអង្គម្ចាស់-**

ក្សត្រី ស្ដេចយាងមកដល់សាគីស្ថានមុនការកំណត់តាមរបាយការណ៍ ទើបសម្ដេចព្រះមាតាស្ដេចយាងមក **អូស** សម្ដេចព្រះមហាក្សត្រីឲ្យយាងទៅស្វាគមន៍ព្រះអង្គម្ចាស់ តែសម្ដេចមហាក្សត្រីមិនព្រមស្ដេចយាង ប៉ុន្តែជំទាស់នឹងព្រះមាតាមិនបាន ទើបត្រូវមកទទួលព្រះរាជដំណើររបស់ព្រះអង្គម្ចាស់ អាឌែល ដល់យន្តហោះ។

ពេលស្ដេចយាងឡើងទៅដល់ ព្រះអង្គម្ចាស់មិនបានគង់ប្រថាប់នៅបន្ទប់ពិសេស ប៉ុន្តែយាងចេញពី បន្ទប់ អ្នកបញ្ជាការហោះហើរ តាមដោយកាពីទែនដែលឈរគោរពនៅមុខបន្ទប់។

សម្ដេចព្រះមាតាមិនដឹងរឿងអីច្រើន ប៉ុន្តែសម្ដេចមហាក្សត្រី រ៉ននី ទ្រង់ **ស្ញើច** គួរសម ដែលព្រះអង្គម្ចាស់ គូអភិសេក ទ្រង់បញ្ជាការយន្តហោះដោយអង្គឯង និងពេលទតឃើញព្រះភក្ត្រដែលងើយមកប្រសព្វភ្នែកគ្នា ទ្រង់ក៏ភាំងកាន់តែខ្លាំង ព្រោះតាំងពីណាពីណីមកម្ល៉េះ ទ្រង់មិនធ្លាប់ឃើញបុរសណាសង្ហាដូច **បងប្រុស** រហូតមកដល់ពេលនេះ។

ព្រះអង្គម្ចាស់ អាឌែល ដើរកាត់មុខកាពីទែន មកគង់នៅទល់មុខសម្ដេចព្រះមាតា ឱនគំនាប់ធ្វើការគោរពតាមប្រពៃណី ហើយងាកទៅរកសម្ដេចមហាក្សត្រី និងសម្លឹងមើលគ្នាដោយការពិចារណាជាលើកដំបូង។

"សូមស្វាគមន៍ អាឌែល ម៉េចក៏យាងមកម្នាក់ឯង ?"

សម្ដេចព្រះមាតារាក់ទាក់ និងទតមើលព្រះអង្គម្ចាស់ដោយការសរសើរដោយមិនបិទបាំង។

"ព្រះបិតា ព្រះមាតា នឹងយាងមកនៅថ្ងៃអភិសេកក្រាបទូល ពេលនេះបញ្ជូនទូលបង្គំមោសិន"



ព្រះអង្គម្ចាស់ងាកទៅតបសំណួរសម្ដេចព្រះមាតា ហើយងាកមកទតសម្រស់របស់ **គូអភិសេក** ម្ដងទៀត។

"ហើយនេះជាសម្ដេចព្រះមហាក្សត្រី រ៉ននី មែនទេក្រាបទូល ?"

ពេលទ្រង់ត្រាស់សួរដោយមិនព្រមងាកមុខចេញ សម្ដេចព្រះមហាក្សត្រីក៏ងក់ក្បាលជាការស្វាគមន៍ ហើយសម្លឹងមើលព្រះអង្គម្ចាស់មិនដាក់ព្រះនេត្រ ធ្វើឲ្យម្ចាស់ខ្សែភ្នែកមុតស្រួចដែលសម្លឹងមើលមកជម្មតាៗ ប្ដូរទៅជា **ប្រាកដប្រជា** ព្រមទាំងត្រាស់សួរលេងៗ។

"ហើយយើងចង់ឈរមើលគ្នាបែបនេះយូរទៀតទេ ក្រាបទូល ?"

ពេលនោះឯងទើបព្រះអង្គម្ចាស់ក្សត្រីបែរព្រះវរកាយ ស្ដេចយាងនាំចុះពីយន្តហោះដោយគ្មានព្រះសវនីយ៍អីមួយម៉ាត់។

"ព្រះមាតាទូលបង្គំ ឃ្វីនឡៃឡា ទ្រង់មានសវនីយ៍ថាសម្ដេចមហាក្សត្រី រ៉ននី ជានារីគួរឲ្យស្រឡាញ់ តែទូលព្រះបង្គំដូចជាសង្ស័យ..."

ព្រះអង្គម្ចាស់ទូលសួរសម្ដេចព្រះមាតានៅតាមផ្លូវ ត្រឡប់ទៅព្រះរាជវាំង។

"សម្ដេចព្រះមាតារបស់ទូលបង្គំ ប្រហែលយល់ច្រឡំ ឬមិនអីចឹងព្រះនេត្រមិនល្អ"

ព្រះអង្គម្ចាស់ត្រាស់ ព្រមទាំងទតមើលព្រះភក្ត្រស្រស់ស្អាត តែព្រងើយកន្តើយ មិនញញឹមញញែមពេលគង់នៅព្រះរាជរថតែមួយ ធ្វើឲ្យសម្ដេចមហាក្សត្រីទ្រង់ងាកខ្ទាប់មកទតអ្នកអង្គុយទល់មុខភ្លាម។

ពេលទ្រង់ឃើញ ព្រះនេត្រ ដែលសម្លឹងមើលមកដោយមានចេតនា ត្រឹមប៉ុណ្ណឹងព្រះអង្គម្ចាស់ក៏យល់ច្បាស់ហើយថា គូអភិសេកប្រហែលមិន **ពេញព្រះទ័យ** នឹងការអភិសេកដូចទ្រង់ដែរ។



ពេលទ្រង់ដឹងបែបនេះ ព្រះនេត្រមុតស្រួចគួរឲ្យមើលក៏មើលពន្លឺ



Scanned by CamScanner

ផ្លែកៗ ដោយនឹកដល់រឿងសប្បាយ បបូរមាត់ស្អាតលម្អព្រះភក្ត្រសង្ហា ប្រភេទដែលធ្វើឲ្យបេះដូងស្រីៗគ្រប់គ្នាបានឃើញហើយកាន់តែចង់មើល ក៏មានស្នាមញញឹម។

សម្តេចព្រះមាតាទ្រង់ពេញព្រះទ័យណាស់ ដែលបានទទួលព្រះអង្គម្ចាស់គូអភិសេនៅថ្ងៃនេះ ប៉ុន្តែសម្តេចមហាក្សត្រីបែរជាមានសវនីយ៍ថាទ្រង់គ្មានព្រះទ័យអី ទ្រង់ចូលចិត្តឬមិនចូលចិត្តព្រះភក្ត្រសង្ហា មានតែស្នាមញញឹមដោយមានអារម្មណ៍ល្អគ្រប់ពេលវេលានោះ ជាពិសេសសម្តីដៀមដាមដល់ទ្រង់អម្បាញ់មិញ ដូចចង់ញ៉ោះឲ្យក្រេវក្រោធ។

ញ៉ោះឲ្យទ្រង់ក្រេវក្រោធហើយក៏បិទមាត់ បែរព្រះភក្ត្រចេញ វាគួរឲ្យឆ្អឹះឆ្អៀលយកគ្រាប់ភ្នែកនោះមកបោះលេងណាស់។

សម្តេចមហាក្សត្រី ទ្រង់ចង់ប្រទូសរ៉ាយរាងកាយរបស់ព្រះអង្គម្ចាស់នៅចំពោះមុខជាលើកដំបូង ទាំងដែលទើបតែជួបគ្នាថ្ងៃដំបូង។

"រ៉ននី...រ៉ននី..."

សម្តេចព្រះមាតាទ្រង់ស្រែកហៅនិងយាងតាមពេលសម្តេចមហាក្សត្រីយាងចុះពីរាជរថ ក៏យាងចេញទៅយ៉ាងលឿន មិនងាកក្រោយ មិនចាប់អារម្មណ៍ទេថាគូអភិសេកទៅគង់ប្រថាប់នៅឯណា។

"ម៉េចក៏ធ្វើបែបនេះ បុត្រីធំហើយ ជាកំពូលផែនដី យកតែព្រះទ័យខ្លួនឯងបែបនេះមិនបានទេ"

ព្រះសវនីយ៍របស់សម្តេចព្រះមាតា ធ្វើឲ្យសម្តេចមហាក្សត្រីទប់រាជដំណើរបានភ្លាម។

"កុំគិតតែខ្វាល់ យ៉ាងណាក៏ត្រូវអភិសេកទ្រង់នឹងរស់នៅជាមួយព្រះអង្គម្ចាស់មួយជីវិត ត្រូវសិក្សាស្វែងយល់ពីគ្នា"

សម្តេចមហាក្សត្រីចង់ងាកទៅប្រកែកជាមួយសម្តេចព្រះមាតា តែពេលទ្រង់នឹកភ្នកឃើញក៏នៅស្ងៀម។

"មាតាបញ្ជាឲ្យអង្គរក្សរបស់ទ្រង់ និងមន្ត្រីរាជវាំង ទៅមើលការខុសត្រូវជំនួសហើយ តែស្អែកទ្រង់ត្រូវទៅដោយអង្គឯង ទុកចោលដូចថ្ងៃនេះមិនបានទេ"

សម្តេចព្រះមាតាចេញបញ្ជាដោយព្រះសវនីយ៍ និងព្រះភក្ត្រប្រាកដប្រជា ហើយស្តេចយាងចេញទៅ ទុកឲ្យម្ចាស់ផែនដីខ្វាល់តែម្នាក់ឯង។





Scanned by CamScanner

## ១៩

ថ្ងៃបន្ទាប់មកសំឡេងគោះទ្វាររបស់ស្រីបម្រើ ធ្វើឲ្យសម្ដេចមហាក្សត្រី រ៉ននី ងើយព្រះភក្ត្រពីរាជកិច្ចភ្លាម។

"ព្រះអង្គម្ចាស់ អាឌែល សុំចូលគាល់ព្រះមេ"

ការទូលថ្វាយនោះ ធ្វើឲ្យព្រះហស្ដដែលកំពុងឡាយព្រះហត្ថលេខាត្រូវផ្អាក ហើយសួរ។

"យើងកំពុងធ្វើការ ទៅប្រាប់ទ្រង់ទៅថា..."

"មិនហ៊ានសូម្បីតែប្រឈមមុខគ្នាឬ"

ព្រះសូរសៀងដែលបន្លឺឡើងភ្លាមៗធ្វើឲ្យសម្ដេចមហាក្សត្រីងើយព្រះភក្ត្រទៅទត ហើយដកដង្ហើមធំ ព្រោះព្រះអង្គម្ចាស់ចូលមកក្នុងបន្ទប់នេះទៅហើយ។

"ចេញសិនទៅ" ទ្រង់បញ្ជាស្រីបម្រើ ហើយងើបឈរប្រឈមព្រះភក្ត្រនឹងអ្នកដែលចូលមកដោយគ្មានរាជានុញ្ញាត ដោយមិនពេញព្រះទ័យ។

"ហេតុអីយើង **មិនហ៊ាន** ?"

ទ្រង់សួរ និងសម្លឹងអ្នកទល់មុខដោយមិនរអែង ដោយទ្រង់មិនដឹងទេថា ព្រះនេត្រថ្លាយង់មួយគូនោះគួរឲ្យមើលប៉ុណ្ណានៅក្នុងអារម្មណ៍របស់ព្រះអង្គម្ចាស់នាពេលនេះ។

"បើ **ហ៊ាន** គឺត្រូវតែនិយាយគ្នាខ្លះ មានពីអង្កាល់គូដណ្ដឹងមកដល់ផ្ទះហើយតែទ្រង់បែរជាមមាញឹកនឹងរាជកិច្ចខ្លះ រឿងនេះខ្លះរឿងនោះខ្លះ"

"ព្រោះយើងមានរាជកិច្ច គ្មានពេល **ទំនេរ** ដូចអ្នកខ្លះ" ទ្រង់តបតនិងសម្លឹងមុខរាជបុត្រដោយមិនខ្លាចក្រែង សម្លឹងព្រះភក្ត្រសង្ហាដែលមិនធ្លាប់គិតថាមាននរណាគួរឲ្យទតដូច **បងប្រុស** តែហេតុអីពេលនេះបែរជាមានបុរសម្នាក់ទៀតដែលក្មេងជាង និងគួរឲ្យមើលមិនចាញ់ មិនថាជាចិញ្ចើម ភ្នែក ច្រមុះ ឬមាត់។

"បើទំនេរឬមិនទំនេរក៏ទ្រង់ធ្វើឲ្យ **ទំនេរ** បានមិនអីចឹង ឬបើមានច្រើនយកមកឲ្យជួយខ្លះក៏បានដែរក្រាបទូល"

"ទ្រង់ជួយមិនបាន"

"អីចឹងអធិប្បាយមក គ្មានអីលើសពីខួរក្បាលនិងសមត្ថភាពរបស់យើងទាំងពីរទេ បើជួយគ្នាបាន...ព្រះរៀម របស់ទ្រង់ក៏ធូរទ្រូងច្រើនហេតុអីមិនធ្វើឲ្យគេមានអារម្មណ៍បែបនោះ"

សំណួរនោះធ្វើឲ្យសម្ដេចមហាក្សត្រី រ៉ននី ទ្រង់ឲ្យចម្លើយមិនបានបានតែយាងទៅឲ្យឆ្ងាយ ទៅស្ថិតនៅមាត់បង្អួចធំទូលាយ មើលឃើញឧទ្យានដ៏វិចិត្រនៅខាងក្រៅ។

"ប្រាប់មកថាចង់ឲ្យជួយ នឹងបានជួយ កុំគិតតែស្រ្ពេស គិតតែក្រមុំគិតតែខ្វាល់ ហើយវាបានស្អីមក យ៉ាងណាក៏យើងត្រូវរៀបការនឹងគ្នា"



ព្រះសូរសៀងដែលបន្លឺឡើងនៅក្រោយខ្នង ធ្វើឲ្យទ្រង់ដឹងថាព្រះអង្គម្ចាស់យាងមកតាម។

"គិតមើលទៅបញ្ហាស្រុកទេសណាក៏ដូចគ្នាដែរ បើចង់ជួយ... តើឲ្យជួយទេ?"

"ខ្លាចទ្រង់ធុញទ្រាន់"

"រឿងនោះសុំសម្រេចចិត្តដោយខ្លួនឯងល្អទេ យ៉ាងណា ព្រះរៀមរបស់ព្រះអង្គម្ចាស់ក្សត្រីក៏នៅមិនអីចឹង សុំព្រះរាជទានទោសដែលហៅសម្ដេចមហាក្សត្រី ស្ដាប់ហើយមានអារម្មណ៍ដូចនិយាយជាមួយមនុស្សចាស់ មិនមែនក្មេងស្រីបែបនេះ"

សម្ដេចមហាក្សត្រី រ៉ននី ទ្រង់សណ្ដាប់ហើយ ក៏ត្រូវងាកមកសម្លឹងព្រោះជ្រេញ តែព្រះអង្គម្ចាស់បែរជាធ្វើព្រងើយ។

"យ៉ាងម៉េចដែរឲ្យជួយទេ?"

ព្រះអង្គម្ចាស់ត្រាស់សួរ និងទតមើលដោយការចង់ដឹង។

"អូខេ"

សម្ដេចមហាក្សត្រីព្រមទទួលហើយយាងទៅតុព្រះរាជកិច្ច ទាញឯកសារឲ្យព្រះអង្គម្ចាស់ម្ដងមួយៗ យកទៅដាក់លើតុធ្វើការធំកណ្ដាលបន្ទប់ ហើយជួយធ្វើការគ្នាជាលើកដំបូងចាប់តាំងពីនាទីនោះ។

"អាព្រះអង្គម្ចាស់ដែលមកថ្មី វានឹងក្ដោបក្ដាប់យកអំណាចទៀតហើយ"

អ៊ីម៉ាម ទូលថ្វាយដល់សម្ដេចព្រះមាតា ពេលលួចជួបគ្នាម្ដងទៀត។

"ហើយលោកចង់ឲ្យធ្វើយ៉ាងណា មិខាអ៊ីល ក៏លោកមិនពេញចិត្តមកដល់ អាឌែល ក៏លោកមិនពេញចិត្តទៀត"

សម្ដេចព្រះមាតាសួរ និងទតមើលប្រមុខសាសនាដែលធ្លាប់សទ្ធា



ដោយយល់ពីគំនិតរបស់គេហើយនៅពេលនេះ។

មែនហើយ អ៊ីម៉ាម មិនធ្លាប់ត្រូវការនរណាទៅវិញទេ ក្រៅពីមានអំណាចតែម្នាក់ឯង ដោយមានសម្ដេចព្រះមាតានិងសម្ដេចមហាក្សត្រីជាទីងមោងប៉ុណ្ណោះ។

ពេលមកដល់វេលានេះ សម្ដេចព្រះមាតាក៏យល់កាន់តែច្បាស់ដូច្នេះហើយពេលយាងត្រឡប់មកវិញទ្រង់ក៏គិតតែដកដង្ហើមធំ សួរខ្លួនឯងថាគួរធ្វើយ៉ាងណាបន្តទើបល្អសម្រាប់ អ៊ីម៉ាម អ្នកដែលមិនធ្លាប់ស្កប់ស្កល់នឹងអំណាចដែលទទួលបានបែបនេះ។

ពេលស្ដេចយាងមកពីបន្ទប់រាជកិច្ច របស់សម្ដេចព្រះមហាក្សត្រី រាជអង្គរក្សដែលមកជាមួយបីនាក់ក៏ចូលមកថ្វាយរបាយការណ៍។

"ខាងយើងបានដំណឹងរបស់ អ៊ីម៉ាម ប្រមុខសាសនាដែលត្រូវព្រះប្រមុខរដ្ឋស្ដីទីបណ្ដេញកាលពីច្រើនអាទិត្យកន្លងមក"

"ថាម៉េច?"

"គេចូលមកប្រមូលមនុស្ស ថ្លែងសន្ទរកថាដែលគ្មានប្រយោជន៍ចំពោះព្រះរាជវង្ស គិតថាបើបណ្ដោយឲ្យបែបនេះ នឹងក្លាយជាគ្រោះភ័យក្រាបទូល"

"ព្រោះហេតុផលនេះមែនទេ ដែលធ្វើឲ្យត្រូវព្រះប្រមុខរដ្ឋស្ដីទីបណ្ដេញកាលណោះ"

"ក្រាបទូល"

"ស៊ើបឲ្យច្បាស់លាស់បើបែបនោះមែនមានតែការបណ្ដេញក៏គ្មានប្រយោជន៍ដែរ"



ព្រះអង្គម្ចាស់ប្រាប់ ព្រមទាំងសម្លឹងមើលមុខរាជអង្គរក្ស ដែលត្រឹម

មើលភ្នែកគ្នាក៏ដឹងហើយថាគួរធ្វើយ៉ាងណាបន្ត។

"ក្រាបទូល ទូលបង្គំនឹងធ្វើតាមព្រះរាជបញ្ជា"

ពេលទទួលរាជបញ្ជាហើយ រាជអង្គរក្សក៏ដើរចេញទៅវិញ។

នេះជាលើកដំបូងដែលព្រះអង្គម្ចាស់អាឌែល ចង់ជួយត្រួសត្រាយបន្លាឲ្យអនាគតព្រះជាយា និងជាការត្រួសត្រាយដោយប្រាកដប្រជា មិនមែនលេងសើច។

**ថ្ងៃបន្ទាប់មក**

ព្រះអង្គម្ចាស់ អាឌែល ស្ដេចយាងមកឈប់នៅបន្ទប់រាជកិច្ចរបស់សម្ដេចព្រះមហាក្សត្រីម្ដងទៀត ហើយត្រាស់សួរស្រីបម្រើដែលចាំបម្រើនៅមុខបន្ទប់។

"ទ្រង់កំពុងបំពេញរាជកិច្ច ?"

"ព្រះពរ" ស្រីបម្រើវ័យចាស់ទូលតាមត្រង់ ហើយគោះទ្វារ ចូលទៅទូលថ្វាយជាដំណឹង ប៉ុន្តែព្រះអង្គម្ចាស់បែរជាដើរចូលទៅដែរដោយមិនរង់ចាំឲ្យអ្នកនៅខាងក្នុងរាជានុញ្ញាត។

សម្ដេចព្រះមហាក្សត្រីងើយព្រះភក្ត្រមើល ហើយឲ្យសញ្ញាស្រីបម្រើចេញពីបន្ទប់។

"នេះបើរៀបការហើយ ពេលជួបគ្នាម្ដងៗត្រូវសុំរាជានុញ្ញាតជាមុនរហូតទេ ?"

ព្រះអង្គម្ចាស់ត្រាស់សួរ និងដៀងមើល **អនាគតព្រះជាយា** ដោយការសង្ស័យ តែទ្រង់មិនមាត់.ក។

"មិនមែនឲ្យសុំអនុញ្ញាតជួប ប្រពន្ធ គ្រប់ពេលទេ"

ប្រយោគបន្ទាប់របស់ព្រះអង្គម្ចាស់ ធ្វើឲ្យអ្នកស្ដាប់ព្រិចភ្នែកញាប់ស្អេក ព្រោះមិនបានគិតរឿងនេះ។

"ហើយឲ្យយើងធ្វើយ៉ាងណា វាជាប្រពៃណីទំនៀមទម្លាប់"

"មិនអីទេ.... ចាំប្រាប់អ្នកយាមទ្វារឲ្យ...ហើយថ្ងៃនេះចង់បបួលចេញទៅក្រៅវាំង"

"អ្វី ចង់ទៅណា ?"

"ទៅមើលប្រជារាស្ត្រដោយផ្ទាល់ ទៅឲ្យសព្វនគរជាឯកជន គ្មានអង្គរក្សគ្មានអ្នកដើរតាម"

ការបបួលបែបនេះធ្វើឲ្យសម្ដេចព្រះមហាក្សត្រីព្រិចភ្នែកម្ដងទៀតព្រោះមិនធ្លាប់គិតថានឹងធ្វើ។

"ពេលឡើងគ្រងផែនដីទាំងមូល ទ្រង់នៅតែជាមួយការងារក្នុងវាំងបែបនេះម៉េចនឹងបាន ត្រូវចុះទៅជួបប្រជារាស្ត្រដោយផ្ទាល់ខ្លះ នឹងបានដឹងបញ្ហាពិតប្រាកដរបស់កូនចៅ មិនមែនចេះតែត្រូវទូលថ្វាយរបាយការណ៍ដោយឆ្លងកាត់ច្រើនដំណាក់កាល ដែលពេលមកដល់ដៃយើង វាតែងតែរកជឿមិនបាន"

សំណើរបស់ព្រះអង្គម្ចាស់ធ្វើឲ្យទ្រង់មិនអាចបដិសេធបានព្រោះវាមានហេតុផលល្អ។

"ទម្លាក់គំនរក្រដាសនោះចោលសិនទៅ ហើយទៅជាមួយគ្នា"

"ទៅណា ?"

"ចេះតែទៅៗ ទៅមើលថាគេរកស៊ីចិញ្ចឹមជីវិតយ៉ាងម៉េច បញ្ហានៅពេលនេះមានអីនៅត្រង់ណាខ្លះ និងជួយយ៉ាងម៉េចយ៉ាងម៉ា ជួយបានប៉ុណ្ណា ទៅមើលបញ្ហា និងវិធីដោះស្រាយរបស់មន្ត្រីរាជការទាំងឡាយ"



"ទ្រង់គិតបែបហ្នឹង ?" សម្ដេចព្រះមហាក្សត្រីងាកមកទតអ្នកឈរក្បែរដោយព្រះតម្រិះពីគេជាលើកដំបូង។

"មែន..." ព្រះអង្គម្ចាស់តប និងសម្លឹងមើលព្រះភក្ត្រស្រស់ស្អាត ដែលធ្វើឲ្យទ្រង់ប្ដូរព្រះទ័យនៅទីនេះមួយរយៈទៀត។

អាកប្បកិរិយានោះទាក់ទាញព្រះទ័យសម្ដេចព្រះមហាក្សត្រីយ៉ាងខ្លាំង ធ្វើឲ្យទ្រង់ត្រូវរកមើលការពិតនៅក្នុងព្រះនេត្រមួយគូនោះ បន្ទាប់មកក៏យាងចេញ ដោយបេះដូងលោតខុសចង្វាក់ និងមិនធ្លាប់មានព្រះទ័យបែបនេះ។

"ហើយចង់ចេញទៅពេលណា ?"

បន្ទាប់ពីប្រើពេលគិតយ៉ាងយូរ សម្ដេចព្រះមហាក្សត្រីក៏មានសវនីយ៍សួរបន្ត។

"រសៀលនេះ" ព្រះអង្គម្ចាស់នៅតែប្រើពាក្យសាមញ្ញដដែល ដូចចង់ **ទាញ** សម្ដេចព្រះមហាក្សត្រីចេញពីទីខ្ពស់មកទីទាបសាមញ្ញ។

"ប្រើអូដ្ឋ ចង់ឲ្យតែងខ្លួនជាមនុស្សប្រុសដើម្បីឲ្យវាមានសុវត្ថិភាពបំផុត ពណ៌ខ្មៅមួយឈុតដូចពួកបេឌូអ៊ីនក៏ល្អ កុំឲ្យមានអ្នកណាចាប់អារម្មណ៍"

ពេលនិយាយហើយ ព្រះអង្គម្ចាស់ក៏ដើរចេញពីបន្ទប់ភ្លាម ទុកឲ្យសម្ដេចព្រះមហាក្សត្រីរវើរវាយនៅត្រង់នោះ ព្រោះតាំងពីណាពីណីមកម្ល៉េះ មិនធ្លាប់ព្រះតម្រិះដល់រឿងនេះ។

ស្រីបម្រើដែលជិតដិតបំផុត ត្រូវហៅចូលគាល់នៅវេលាបន្ទាប់ សម្លៀកបំពាក់ដែលធ្លាប់ឃើញប្រជាជនធម្មតាស្លៀកពាក់ ក៏ត្រូវហៅរក និងត្រូវរៀបចំជាបន្ទាន់។

"ល្អឬព្រះមេ ចេញទៅដោយអង្គឯងបែបនេះវាគ្រោះថ្នាក់"

**'តែគ្មានអ្នកណាដឹងហ្នឹងណា៎ ហើយ អ្នកបបួល ក៏ពូកែ'**

សម្ដេចព្រះមហាក្សត្រីទ្រង់ព្រះចិន្ដា និងប្ដូររូបរាងកាយជាបន្ទាន់



ក្លាយជាក្មេងប្រុសធម្មតាម្នាក់នៅវេលាបន្ទាប់។

មិនយូរប៉ុន្មាន បុរសគ្រងឈុតបេឌូអ៊ីនពីរនាក់ ក៏ជិះសត្វអូដ្ឋចេញពីព្រះរាជដំណាក់ ដោយមានអង្គរក្សទៅតាមតែពីរនាក់ប៉ុណ្ណោះ។

**អូដ្ឋទាំងអស់ដែលដើរតាមគ្នាចេញពីបរមរាជវាំង បន្ថយល្បឿន** ពេលចូលទៅក្នុងទីប្រជុំជន ដោយការដើរយឺតៗតាមផ្លូវថ្នល់ ដើម្បីមើលមនុស្សម្នាដែលកំពុងលក់ដូរនៅតាមសងខាងផ្លូវ។

ការលក់ដូរដែលឃើញរាងអ៊ូអរ មានមនុស្សម្នាចេញចូលទិញលក់ដោះដូរច្រើន ធ្វើឲ្យនឹកដល់ស្ថានភាពសេដ្ឋកិច្ចដែលមានលំនឹងល្អរបស់ស្រុកទេស។

កុលសម្ព័ន្ធបេឌូអ៊ីនទាំងបួនត្រួតពិនិត្យ មើលស្ថានការណ៍រកស៊ីជំនួញចិញ្ចឹមជីវិតរបស់ប្រជារាស្ត្រ មើលឃើញក្មេងៗរត់លេងយ៉ាងរីករាយ ដោយមនុស្សធំមិនព្រួយបារម្ភ ឬទៅរំខាន រហូតដល់ហាងទំនិញមួយនៅមាត់ផ្លូវ។

"ចូលផឹកកាហ្វេមួយពែងយ៉ាងម៉េចដែរ ?"

សំណួរនោះធ្វើឲ្យសម្ដេចព្រះមហាក្សត្រី ងាកទៅមើលក្នុងហាងដែលពេលនេះភ្ញៀវចុងក្រោយគេកំពុងគិតប្រាក់ ទើបងក់ក្បាលភ្លាម។

"ធ្លាប់ផឹកកាហ្វេអ្នកស្រុកទេ បើល្វីងល្វីងង៉ាត បើផ្អែមផ្អែមស្និត"

ព្រះអង្គម្ចាស់ខ្សឹបប្រាប់ហើយចុះពីខ្នងអូដ្ឋមុន និងរង់ចាំទទួលអ្នកដែលមិនធ្លាប់ជិះអូដ្ឋ ធ្លាប់ជិះតែឡាន ដូច្នេះហើយមិនប្លែកទេដែលទ្រង់ធ្លាក់មកនៅក្នុងរង្វង់ដៃអ្នកដែលចាំទទួល ហើយបណ្ដើរគ្នាចូលហាងកាហ្វេ។



ព្រះអង្គម្ចាស់កុម្ម៉ង់កាហ្វេពីម្ចាស់ហាងដែលជាប្រុសក្មេង មុខមាត់

សង្ហា តែងខ្លួនទាន់សម័យ គឺខោខូវប៊យរឹបជើង និងអាវសឺមិក្រឡាការ៉ូពណ៌ខៀវ។

ខណៈពេលរង់ចាំកាហ្វេ ទ្រង់ក៏សម្លឹងមើលទៅជុំវិញខ្លួន ហើយចាប់អារម្មណ៍មនុស្សមួយក្រុមដែលមានគ្នាបួនប្រាំនាក់កំពុងតែប្រជុំគ្នា បន្ទាប់មកក៏បណ្ដើរគ្នាទៅកន្លែងមួយដែលនៅមិនឆ្ងាយ។

សម្ដេចព្រះមហាក្សត្រីតាមមើលដោយការសង្ស័យរហូតដល់បាត់ពីភ្នែក បន្ទាប់មកក៏មានមនុស្សជាច្រើនទៀតដើរទៅតាម។

"ពួកនោះនិយាយគ្នាពីអី ?"

"គេនឹងទៅនិយាយគ្នាបន្តនៅកន្លែងផ្សេង"

ចម្លើយនោះធ្វើឲ្យសម្ដេចព្រះមហាក្សត្រី ងាកទៅមើលអ្នកឆ្លើយដោយការសង្ស័យ។

"ទ្រង់ដឹង ?"

ព្រះអង្គម្ចាស់មិនឆ្លើយ តែងាកមកមើលមុខ។

"ដឹងតាំងពីអង្កាល់ ?"

"ថ្មីៗនេះឯង នៅគិតថាចង់បបួលទ្រង់ទៅសួរ ព្រះរៀម ផង"

សម្ដីនោះធ្វើឲ្យអ្នកស្ដាប់ព្រិចភ្នែក នឹកខ្មាសមែនទែនដែលព្រះអង្គម្ចាស់ប្រទេសផ្សេងសោះ បែរជាដឹងរឿងស្រុកទេសច្បាស់ជាងម្ចាស់ប្រទេសទៅទៀត។

"ចាប់អារម្មណ៍ស្ដាប់ទេ តែកុំល្អជាង វាគ្រោះថ្នាក់ពេកហើយ បញ្ជូនមនុស្សរបស់យើងទៅស្ដាប់ជំនួសទៅចុះ ថាថ្ងៃនេះពួកគេនិយាយស្អីគ្នាខ្លះ យើងចាំនៅម៉្លុំនេះ"

"អត់ទេ ចង់ចូលទៅដោយខ្លួនឯង"

និយាយហើយ ទ្រង់ក៏ដើរសំដៅទីនោះភ្លាម ដោយមិនស្ដាប់ការ



ជំទាស់ ធ្វើឲ្យព្រះអង្គម្ចាស់ត្រូវទៅតាមជាបន្ទាន់។

បុរសឈុតខ្មៅឃ្លុំមុខសល់តែប្រឡង់ភ្នែកចូលទៅអង្គុយពែនភ្នែនលើកម្រាល រង់ចាំទាល់តែអ្នកចូលរួមមកកាន់តែច្រើន ធ្វើឲ្យណែនបន្ទប់ទាំងមូល ហើយមនុស្សម្នាក់រាងជាត់ ពាក់តូបពណ៌ស្រស់ មានអាវផាយពណ៌ដូចគ្នា ឆ្នូតក្បាលដោយក្រណាត់សាច់ជម្មតាៗក៏ចេញទៅឈរនៅកណ្ដាលបន្ទប់ ហើយបរិយាយការងារដែលប្រមុខសាសនាធ្វើដើម្បីព្រះជាម្ចាស់ ធ្វើដើម្បីប្រជាជន និងណែនាំឲ្យស្គាល់ប្រមុខសាសនាម្នាក់នោះ។



## ២០

សម្តេចព្រះមហាក្សត្រី ដែលបន្លំខ្លួនជាកំលោះប៉េឌូអ៊ីនព្រិចភ្នែកញាប់ស្អេកពេលឃើញប្រមុខសាសនា ដែលបង្ហាញខ្លួននៅពេលនេះដោយមិនដឹងទេថាកំលុងពេលស្តាប់ការបរិយាយរបស់ អ៊ីម៉ាម ទ្រង់ទាំងពីរក្លាយជាមុខសញ្ញារបស់ពួកវាទៅហើយ។

ព្រះអង្គនៅសណ្តាប់ទាល់តែចប់ មនុស្សម្នាក៏នាំគ្នាចេញពីសាលប្រជុំនោះជាបន្តបន្ទាប់ ទើបទ្រង់ធ្វើតាមដែរដោយមិនឲ្យមានអ្នកណាសង្ស័យ។

ព្រះអង្គម្ចាស់ អាខែល នាំទៅកន្លែងទុកអូដ្ឋដែលនៅឆ្ងាយពីទីនោះគួរសម ខណៈនោះមនុស្សមួយក្រុមក៏រត់មកឡោមព័ទ្ធដោយមានអាវុធគ្រប់ដៃ ធ្វើឲ្យសម្តេចព្រះមហាក្សត្រីទ្រង់ស្រឡាំងកាំងធ្វើអ្វីមិនត្រូវមួយខណៈ ហើយពេលនោះឯងមនុស្សម្នាក់នៅក្នុងចំណោមពួកនោះក៏ដើរមករកបំណងទាញស្បៃឃ្លុំចេញពីមុខឲ្យឃើញច្បាស់ ប៉ុន្តែដៃរបស់វាមិនទាន់បានប៉ះស្បៃផង ព្រះអង្គម្ចាស់ក៏រលាស់របស់មួយប្រភេទត្រូវដើមទ្រូងរបស់វា ធ្វើឲ្យវាភាំងមួយខណៈ បន្ទាប់មកក៏ដួលខ្ពោក ដាច់ខ្យល់



ស្លាប់ភ្លាមៗ ហើយអាវុធតូចនោះក៏រត់ទៅប៉ះចំខ្លួន បំពង់.ក មុខមាត់របស់ពួកនោះឲ្យដួលខ្ពោកអស់រលីង ដាច់ខ្យល់ស្លាប់តាមគ្នា។

សម្តេចព្រះមហាក្សត្រីត្រូវចាប់ទាញដៃរត់ចេញពីត្រង់នោះលឿនដូចព្យុះ តែរត់មិនបានឆ្ងាយប៉ុន្មាន ក៏ត្រូវពួកវាមួយក្រុមទៀតតាមមកឡោមព័ទ្ធ។

អាខែល ទាញសម្តេចព្រះមហាក្សត្រីមកឈរក្រោយខ្នង ហើយប្រើអាវុធដដែល ធ្វើឲ្យពួកវាដួលម្តងទៀត តែលើកនេះទ្រង់ត្រូវលោតគេចពីគ្រាប់កាំភ្លើងពួកនោះ។

រ៉ននី ស្រែកភ្លាត់មាត់ព្រោះភ័យពេលព្រះអង្គម្ចាស់ត្រូវគ្រាប់ចំស្មាធ្វើឲ្យដួលខ្ពោកភ្លាម។

វេលានោះ ពួកវាដែលនាំគ្នាតាមមកសុទ្ធតែត្រូវអាវុធសម្ងាត់របស់ព្រះអង្គម្ចាស់ដួលស្តូកស្តឹងអស់ទៅហើយ បើកឱកាសឲ្យសម្តេចព្រះមហាក្សត្រី អូសអ្នកដែលសន្លប់បាត់ទៅហើយចូលហាងមួយនៅជិតនោះ។

ខណៈដែលទ្រង់កំពុងអស់កម្លាំង អូសអ្នកដែលសន្លប់ក៏មានដៃមួយលូកមកជួយ ទាញព្រះអង្គម្ចាស់ឲ្យផុតពីខ្សែភ្នែកពួកនោះបាន។

ទ្រង់ទាំងពីរបានតែដកដង្ហើមធំ ពេលចេញផុតពីខ្សែភ្នែកពួកនោះបាន ដោយព្រះអង្គម្ចាស់ក្សត្រីទាញក្បាលរបស់ព្រះអង្គម្ចាស់ដាក់លើភ្លៅរបស់ខ្លួន ខណៈដែលអ្នកមកជួយធ្វើការត្រួតពិនិត្យមុខរបួសភ្លាម។

"គ្រាប់នៅខាងក្នុងត្រូវវះកាត់"

បុរសដែលមកជួយងើយមកប្រាប់។

"ហើយលោកចេះវះកាត់ទេ?"

"ចេះ ខ្ញុំនឹងវះកាត់ឲ្យ ហើយអ្នកទាំងពីរមកតែពីរនាក់ទេឬ?"



"យើងមានមនុស្សរបស់យើង ប៉ុន្តែគេនៅឆ្ងាយគួរសមត្រូវទៅតាម"

"ខ្ញុំត្រូវការជំនួយការវះកាត់ ជួយគេសិន លើកគេដាក់លើតុនោះ"

អ្នកសន្លប់ត្រូវលើកទៅដាក់លើតុទំនេរមួយនោះ បន្ទាប់មកអ្នកជួយក៏ទាញកាំបិតមុតស្រួចរបស់ខ្លួន ព្រមទាំងរកមើលថ្នាំជួយសម្លាប់មេរោគបាន សំណាងល្អណាស់ដែលឃើញដបអាល់កុលនៅម្ដុំនោះ និងដបថ្នាំច្រើនប្រភេទទៀត ធ្វើឲ្យសម្ដេចព្រះមហាក្សត្រីដឹងថាផ្ទះដែលទ្រង់នាំព្រះអង្គម្ចាស់មកពួនជាហាងថ្នាំ។

បន្ទាប់ពីទតមើលជុំវិញនោះហើយ ក៏ឱនទៅមើលអ្នកជំងឺដោយការព្រួយបារម្ភ ដែលដឹងខ្លួនបន្តិចហើយនិងដឹងថាទ្រង់កំពុងប្រយុទ្ធនឹងការឈឺចាប់ ដោយសារមានគ្រាប់ញើសផុសពេញថ្ងាស។

"យើងកំពុងតែវះកាត់ឲ្យលោក បើឃីតយ៉ាវមិនបានទេ"

អ្នកជួយគឺជាម្ចាស់ហាងថ្នាំ ឈ្ងោកមកប្រាប់បុរសដែលខ្លួនមិនដឹងថាជាព្រះអង្គម្ចាស់។

"អត់ធ្មត់បន្តិច" គេប្រាប់ហើយងាកទៅរកថ្នាំស្ពឹក ថ្នាំសន្លប់ ថ្នាំសម្លាប់មេរោគនិងថ្នាំនានាមកដាក់ក្បែរដៃ។

"ប្រឡេះឡេវអាវគេទៀត" ពេទ្យចាំបាច់បញ្ជាស្ដេចផែនដី ទើបទ្រង់ត្រូវប្រឡេះឡេវអាវ ហើយទាញអាវនោះចេញ ធ្វើឲ្យឃើញដើមទ្រូងធំទូលាយ មានរោមពេញនោះចំណែកស្មាដែលត្រូវគ្រាប់ឡើងក្រហមងាំងឈាមហូរមិនឈប់ បើទុកយូរ ឈាមនឹងហូរអស់ពីខ្លួន។

"យកថ្នាំនេះឲ្យហិត" គេបញ្ជាខណៈដែលកំពុងលាងកាំបិតវះកាត់ដែលទើបតែបើកពីប្រអប់ថ្មីៗ "យកអានេះលាបមុខរបួស ជាថ្នាំស្ពឹក"

"លោកធ្លាប់វះកាត់ទេ ?"



អ្វីក៏មិនដឹងធ្វើឲ្យទ្រង់សួរបែបនេះ។

"មិនធ្លាប់...ធ្លាប់តែលក់ថ្នាំ"

បានព្រះចម្លើយនោះទ្រង់ក៏ដកដង្ហើមធំ។

"អីចឹងបញ្ជូនគេទៅឲ្យពេទ្យល្អទេ ?"

"មិនដល់ដៃពេទ្យទេ ពួកវានៅត្រៀបត្រាពេញនេះ ច្បាស់ជាត្រូវស្លាប់នៅត្រង់ហ្នឹងមិនខាន" គេឲ្យហេតុផលហើយឈរស្ងៀម រង់ចាំឲ្យថ្នាំស្ពឹកបញ្ចេញប្រតិកម្ម ទើបចាត់ការ។

"ហើយលោកជាអ្នកណា ម៉េចក៏ជួយយើង ?"

"គ្រាន់តែចង់ជួយ អ្នកជំងឺមកដល់មាត់ទ្វារទៅហើយមិនឲ្យជួយយ៉ាងម៉េច"

គេតប ព្រមទាំងវះសាច់ម្ដងបន្តិចៗ តែអ្នកជំងឺមិនឡូឡាព្រោះសន្លប់បាត់ទៅហើយ។

សម្ដេចព្រះមហាក្សត្រីលើកដៃបាំងភ្នែកពេលពេទ្យធ្វើការរបស់គេ ហើយមិនយូរប៉ុន្មានក៏រួចរាល់ ដែលពេលនោះអង្គរក្សក៏លេចមុខ។

"ម៉េចក៏ដឹងថាយើងនៅទីនេះ ?"

"ស្មាន ពួកខ្ញុំឆែកឆេរគ្រប់ផ្ទះនៅម្ដុំនេះ"

"ចុះពួកនោះ ?"

"ទៅអស់ហើយ មុនពេលប៉ូលិសមកដល់" ចម្លើយរបស់អង្គរក្សខ្លីរឹងកំព្រឹសតាមបញ្ជាដែលបានបញ្ជាក់ ច្បាស់លាស់ហើយថាមិនឲ្យបង្ហាញសមាសភាពពិតឲ្យអ្នកណាដឹងជាដាច់ខាត។

"នាំគេទៅបាន អរគុណច្រើនដែលជួយ"

"មិនអីទេ" ពេទ្យចាំបាច់ប្រាប់គ្រប់គ្នា និងមើលអង្គរក្សដែលសែងព្រះអង្គម្ចាស់ចេញពីទីនោះដោយការចាប់អារម្មណ៍។



មិនយូរប៉ុន្មានសម្តេចព្រះមហាក្សត្រី និងអង្គរក្សក៏នាំព្រះអង្គម្ចាស់មកដល់រាជវាំង ឯរាជពេទ្យក៏ត្រូវហៅជាបន្ទាន់។

"ទៅមើលពេទ្យនោះផង ពួកវាអាចដឹងថាគេជួយយើង ហើយនឹងមានគ្រោះថ្នាក់ យកអានេះទៅឲ្យ ហើយប្រាប់ឲ្យគេចេញពីតំបន់នោះ"

ទ្រង់ប្រាប់អង្គរក្សរបស់ខ្លួន ដោយឲ្យប្រាក់សុទ្ធច្រើនគួរសមជាការតបស្នងទឹកចិត្តរបស់គ្រូពេទ្យវះកាត់ចាំបាច់។

**រាជពេទ្យពិនិត្យមើលអាការៈរបស់ព្រះអង្គម្ចាស់រួចរាល់ ក៏ទូលថ្វាយ។**

"ទ្រង់ផុតគ្រោះថ្នាក់ហើយក្រាលទូល"

សម្តេចព្រះមហាក្សត្រីមិនមាត់មិន.ក គ្រាន់តែងក់ក្បាល រង់ចាំទាល់តែគ្រប់គ្នាចាកចេញពីក្រឡាបន្ទំនោះអស់ ទើបទ្រង់យាងទៅស្ថិតនៅក្បែរគ្រែ ទតមើលអ្នកដែលលង់លក់ហើយក៏ដកដង្ហើមធំ។

ទោះមកពីដែនឆ្ងាយ តែថ្ងៃនេះព្រះអង្គម្ចាស់បង្រៀនឲ្យទ្រង់បានដឹងថាទ្រង់កំពុងប្រឈមនឹងអ្វី ហើយមានវិធីណាដែលអាចដោះស្រាយបានល្អជាងការបណ្តោយឲ្យមនុស្សម្នាយល់ច្រឡំកាន់តែខ្លាំង។

ថ្ងៃនេះទ្រង់ធ្វើឲ្យដឹងថាក្រៅពីបងប្រុសហើយនៅមានមនុស្សម្នាក់ទៀត ទោះមិនទាន់ស្គាល់គ្នាច្បាស់ តែព្រមចូលមកជួយដោយមិនស្តាយជីវិត។

សម្តេចព្រះមហាក្សត្រី នឹកដល់ពេលដែលទ្រង់ត្រូវទាញទៅឈរនៅក្រោយខ្នង ដោយម្ចាស់ខ្នងប្រយុទ្ធនឹងពួកនោះដោយអាវុធសម្ងាត់ដែលទ្រង់មិនស្គាល់។

ថ្ងៃនេះបានធ្វើឲ្យទ្រង់ដឹងថា ព្រះអង្គម្ចាស់ការពារទ្រង់បាន ទោះ



ជិតស្លាប់ខ្លួនឯងក៏ដោយ។ ក្នុងពេលដែលពិសោធន៍ឲ្យទ្រង់ឃើញបែបនេះហើយ តើទ្រង់បដិសេធបន្តធ្វើអី។

**ពេលព្រះអង្គម្ចាស់ទ្រង់ភ្ញាក់ដឹងខ្លួននៅថ្ងៃបន្ទាប់ អ្វីដំបូងដែល**មានអារម្មណ៍គឺឈឺចាប់ពេញដៃនិងស្មា តែដែលធ្វើឲ្យងឿងឆ្ងល់នោះគឺបានឃើញម្ចាស់ផែនដីប្រថាប់លើកៅអីក្បែរនោះ និងសម្លឹងមើលមកទ្រង់។

"អុំយ!" ទ្រង់ថ្ងូចថ្ងូរតិចៗ ធ្វើឲ្យអ្នកអង្គុយមើលស្ទុះមករកភ្លាមព្រមទាំងទាញទូរសព្ទហៅរាជពេទ្យ។

វេលាបន្ទាប់មក រាជពេទ្យនិងជំនួយការក៏ចូលមកដល់ ទើបទ្រង់ថយចេញឲ្យឆ្ងាយ។

ព័ត៌មាននៃការត្រូវបាញ់របស់ព្រះអង្គម្ចាស់ត្រូវបានបិទមិនឲ្យមានលេចឮជាដាច់ខាត រហូតដល់ព្រះរាជសុខភាពទ្រង់ធូរស្រាល ដែលកំលុងពេលនោះ ពេលបើកភ្នែកឡើង ឃើញគូអភិសេករបស់ខ្លួនអង្គុយនៅកៅអីក្បែរគ្រែជានិច្ច រហូតដល់ថ្ងៃមួយ ពេលបើកភ្នែកឡើង ឃើញស្តេចផែនដីលង់លក់ទាំងអង្គុយ។

ព្រះអង្គម្ចាស់ងើបថ្នមៗ មិនឲ្យអ្នកនៅក្បែរដឹងខ្លួន លូកដៃទៅយកកែវទឹកមកផឹកដោយខ្លួនឯង ហើយសម្លឹងមើល អ្នកកំដរ យ៉ាងយូរបន្ទាប់មកក៏ក្អកគ្រហែមឲ្យដឹងខ្លួន។

"បើទ្រង់នឿយណាស់ ម៉េចក៏មិនយាងទៅក្រឡាបន្ទំ"

ព្រះអង្គម្ចាស់សួរ និងសម្លឹងមើលមិនដាក់ភ្នែក។

"ព្រះអង្គម្ចាស់យ៉ាងម៉េចហើយ ?"

"សុខសប្បាយហើយ" ព្រះអង្គម្ចាស់តប និងសម្លឹងមើលកែវភ្នែក



ថ្លាយង់របស់អ្នកដែលងើបចេញពីកៅអីដើរមកដាក់គូថលើគ្រែ ធ្វើឲ្យម្ចាស់គ្រែចងចិញ្ចើមងឿងឆ្ងល់។

"យើងសប្បាយចិត្តដែលទ្រង់មានសុវត្ថិភាព"

"ច្បាស់ហើយថាសប្បាយចិត្ត បើទូលបង្គំស្លាប់ទ្រង់នឹងសប្បាយព្រះទ័យ"

"ហើយសប្បាយបានយូរប៉ុណ្ណាបន្តិចទៀតសម្តេចព្រះមាតាគង់តែរកអ្នកថ្មីឲ្យ ឈប់និយាយរឿងនេះទៅព្រោះពេលនេះយើងសម្រេចចិត្តរួចហើយ"

"សម្រេចព្រះទ័យរឿងអី ?"

ព្រះអង្គម្ចាស់សួរ និងសម្លឹងមើលព្រះភក្ត្រស្រស់ស្អាតនោះដោយការចង់ដឹង។

"យើងនឹងរៀបអភិសេកជាមួយទ្រង់ មិនចាំបាច់មានការបោកប្រាស់ស្អីទាំងអស់ ចុះព្រះអង្គម្ចាស់គិតយ៉ាងណា ?"

"ច្បាស់ហើយឬទើបមានព្រះសវនីយ៍បែបនេះ ?"

"ច្បាស់ហើយ ចុះទ្រង់វិញ បើមិន..."

"ទូលបង្គំតាមចិត្តព្រះអង្គម្ចាស់ក្សត្រី រ៉ននី"

សព្វនាមនេះត្រូវហៅជាលើកដំបូង ព្រោះព្រះអង្គម្ចាស់មានអារម្មណ៍ថានឹងធ្វើឲ្យធូរចិត្ត ព្រោះមានឋានៈស្មើគ្នា។

"ទ្រង់ប្រាថ្នាអីមានព្រះសវនីយ៍មក ទូលបង្គំមិនជំទាស់"

"យុត្តិធម៌ចំពោះទ្រង់ទេ ?"

"ទូលបង្គំសម្រេចចិត្តដោយខ្លួនឯង សរុបទៅពេលនេះយើងនឹងអភិសេក ដោយគ្មានលក្ខខណ្ឌមែនទេ ?"

"អឹម ហើយនៅមានរឿងមួយទៀត យើងនៅតែគិតដល់



ហេតុការណ៍ដែលកើតឡើង"

សម្តេចព្រះមហាក្សត្រីដកដង្ហើមធំពេលនឹកដល់មនុស្សទាំងនោះត្រូវអប់រំដោយវិធីមិនត្រឹមត្រូវ ឲ្យធ្វើខ្លួនប្រឆាំងនឹងរាជានិយម។

"ហេតុការណ៍បែបនេះកើតឡើងយូរប៉ុណ្ណាហើយ ?"

"វាមានយូរមកហើយ....ទូលបង្គំគិតថា **ព្រះរៀម** របស់ទ្រង់ដឹងច្បាស់"

ពេលព្រះអង្គម្ចាស់និយាយដល់សម្តេចព្រះរៀម ទ្រង់ក៏ស្ងួរភ្លាម។

"ព្រះរៀម...មិនធ្លាប់និយាយឲ្យស្តាប់"

"ព្រោះព្រះរៀមដឹងតែម្នាក់ឯង កែខៃតែម្នាក់ឯង ប៉ុន្តែចាប់ពីពេលនេះទៅពេលគ្មាន សម្តេចព្រះរៀមរបស់ទ្រង់ យើងត្រូវដោះស្រាយបញ្ហានេះដោយខ្លួនឯង"

ព្រះអង្គម្ចាស់សង្កត់ធ្ងន់ទៅលើពាក្យថា **យើង** ធ្វើឲ្យសម្តេចព្រះមហាក្សត្រីទ្រង់យល់។

"ហើយយើងត្រូវធ្វើយ៉ាងណា ?"

"យើងត្រូវមើលថែប្រជាជនដោយការយកចិត្តទុកដាក់ ជួយប្រជាជនគ្រប់រឿង ឲ្យប្រជាជនបានឃើញច្បាស់រវាងអ្នកដែលត្រូវវាយប្រហារ និងអ្នកវាយប្រហារថាខុសគ្នាកម្រិតណា រវាងអ្នកដែលធ្វើការងារ និងអ្នកដែលគិតតែនិយាយដោយមិនធ្វើ ដែលប្រាកដណាស់ថាយើងត្រូវហត់នឿយខ្លាំង តែក៏ត្រូវព្រមហត់នឿយ"

សម្តេចព្រះមហាក្សត្រីទ្រង់សណ្តាប់ សំណើដែលព្រះអង្គម្ចាស់ទូលថ្វាយ។



"ត្រូវប្រាស្រ័យទាក់ទងឲ្យជិតដិត ជួយគ្រប់រឿងដែលទ្រង់ជួយបាន បង្កើតការការពារក្នុងចិត្តប្រជាជនឲ្យមានលំនឹងដោយគ្មានអ្នកណា

ឬអ្វីមកធ្វើឲ្យរង្គោះរង្គើបាន ដែលត្រូវប្រើពេលវេលានិងការហាត់នឿយពេញមួយជីវិត ទ្រង់ធ្វើបានទេ?"

សម្ដេចព្រះមហាក្សត្រីមើលមុខអ្នកណែនាំហើយស្ងប់ស្ងាត់យ៉ាងយូរតែម្ដង។

សកម្មភាពរបស់សម្ដេចព្រះមហាក្សត្រីគ្រប់រឿង ត្រូវរាយការណ៍ដល់អតីតព្រះប្រមុខរដ្ឋស្ត្រីទីបានដឹងទាំងអស់នៅវេលាបន្ទាប់ ដែលមិខាអ៊ីល ស្ដាប់ហើយក៏ដកដង្ហើមធំ ប៉ុន្តែខណៈនោះខួរក្បាលរបស់គេក៏ដាក់ផែនការការពារទ្រង់ជាបន្ទាន់។



# ២១

ពេលព្រះវរកាយរាងធូរស្រាលហើយ ព្រះអង្គម្ចាស់ក៏យាងតាមស្រីបម្រើចូលបន្ទប់ធ្វើការដោយមិនរង់ចាំរាជានុញ្ញាតដូចរាល់ដង។

"ថ្ងៃនេះចង់បបួលទៅពេទ្យ ទៅមើលអ្នកជំងឺ ទៅមើលពេទ្យ ទៅមើលថាប្រជាជនត្រូវការជំនួយតិចឬច្រើនប៉ុណ្ណា ប៉ុន្តែទៅបែបផ្លូវការ"

"ចុះស្នេកទៅណា?" ទ្រង់សួរទុកឲ្យហើយដើម្បីឲ្យដឹងជាមុន។

"ចង់ទៅនិយាយជាមួយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប៉ុន្តែមុនទៅនិយាយគ្នាត្រូវរកទិន្នន័យជាមុនសិន យកប្រភេទច្បាស់លាស់ មិនមែនបិទបាំង"

"បើធ្វើបែបនោះត្រូវតែហាត់នឿយ" ទ្រង់រអ៊ូ។

"ប្រាប់ឲ្យដឹងមុនហើយតើថាត្រូវហាត់នឿយមួយជីវិត"

"ហើយទៅរួចឬ?"

"សួរអ្នកណា"

"សួរទ្រង់"



"ទូលបង្គំជាមនុស្សប្រុស ជាព្រះស្វាមីនាពេលអនាគត ត្រូវតែទៅ

រួចទើបបានមកបបួល ចុះទ្រង់ ទៅរួចទេ?"

"បើម្តងម្កាលអាចអូខេ តែបើញឹកញាប់ ឯកសារការងារអ្នកណាគេធ្វើអ្នកណាគេមើលម៉េចនឹងទុកចិត្តអ្នកដទៃបានទៅ"ទ្រង់សួរនិងងាកមកសម្លឹងមើលមុខដៃគូសន្ទនាចំៗ។

"បើចាំបាច់ យើងបំបែកគ្នាធ្វើការ បង្កើតក្រុមដែលទុកចិត្តឲ្យមកជួយ មិនបណ្តោយឲ្យទ្រង់នៅម្នាក់ឯង"

ព្រះអង្គម្ចាស់តប ហើយយាងទៅអង្គុយទល់មុខ។

"បើទុកចិត្តទូលបង្គំនឹងជួយគ្រប់យ៉ាង"

ព្រះអង្គម្ចាស់យកអាសាដោយទឹកមុខមាំ។

"មែនឬ?"

"មែន ដឹងថាការងារវាធ្ងន់ធ្ងរកម្រិតណា ទោះមានព្រះបញ្ញាញាណយ៉ាងណាក៏ធ្វើតែមួយព្រះអង្គឯងមិនរួច"

ខណៈដែលត្រាស់ ព្រះនេត្រពណ៌ខ្មៅដែលសម្លឹងមើលនោះប្រាប់ឲ្យដឹងពីព្រះទ័យប្រាកដប្រជា ធ្វើឲ្យសម្តេចមហាក្សត្រីត្រូវបែរព្រះភក្ត្រចេញ។

"ច្បាស់ឬថាជួយ មិនមែនពេលមិនពេញព្រះទ័យ ក៏រត់ទៅផ្ទះ"

"ច្បាស់ហើយ តែត្រូវលុបចោលទំនៀមទម្លាប់មិនកើតជាការច្រើនចំណុច មិនយកដាច់ខាតប្រភេទដែលនឹកប្រពន្ធហើយត្រូវសុំអនុញ្ញាតចូលទៅរក មិនឲ្យមានទេប្រពៃណីហ្នឹង ត្រូវលុបចោលគ្រប់រឿង ព្រោះវាជារឿងរបស់យើង អ្នកដទៃហាមមកពាក់ព័ន្ធ ទ្រង់ជាព្រះមហាក្សត្រីនៅខាងក្រៅប៉ុន្តែនៅក្នុងផ្ទះទ្រង់ជា **របស់ទូលបង្គំ** តែម្នាក់អ្នកដទៃគ្មានសិទ្ធិ"

ខណៈដែលព្រះអង្គម្ចាស់ត្រាស់ពាក្យថា **របស់ទូលបង្គំ** ច្បាស់ៗក៏យាងមកឈរបៀតនឹងព្រះវរកាយតូចស្តើង ធ្វើឲ្យទទួលបានចំហាយ



កក់ក្តៅរបស់គ្នា។

សម្តេចមហាក្សត្រីទ្រង់ព្រះសណ្តាប់និងគង់បែបនោះមិនងាកទៅណាព្រះភក្ត្រឡើងពណ៌ផ្កាឈូកពេលព្រះអង្គម្ចាស់ត្រាស់ពាក្យថាប្រពន្ធត្រង់ៗដោយមិនបង្វែរបង្វៀន ជាពិសេសប្រយោគក្រោយ ទ្រង់បែរព្រះភក្ត្រដែលឈរបែរខ្នងដាក់ទៅរកសម្តេចមហាក្សត្រីចំៗ ទតព្រះនេត្រថ្លាយង់ដោយមិនព្រមគេច ចង់បញ្ជាក់ឲ្យច្បាស់ចំពោះអ្វីដែលទ្រង់ត្រាស់។

"យល់ទេដែលនិយាយនេះ?"

ទ្រង់សួរឲ្យច្បាស់ ហើយលោព្រះភក្ត្រទៅជិតព្រះភក្ត្រពណ៌ផ្កាឈូកនោះ តែសម្តេចមហាក្សត្រីដឹងទាន់ ទើបឈានថយក្រោយភ្លាមដែលពេលនោះទ្វារបន្ទប់ក៏ត្រូវគោះ។

"ព្រះប្រមុខរដ្ឋស្តីទីស្តេចយាងព្រះមេ"

ស្រីបម្រើចូលមកថ្វាយការណ៍ ធ្វើឲ្យព្រះអង្គទាំងពីរងាកទៅស្វាគមន៍អ្នកមកដល់ថ្មី។

"ព្រះរៀមមានអីឬ...ទើបមកដល់ទីនេះ?"

សម្តេចមហាក្សត្រីសួរដោយចម្លែកព្រះទ័យ ពេលឃើញ មិខាអ៊ីលចូលគាល់ដោយមិនជូនដំណឹងជាមុន។

"ទើបនាំគ្នាមកពីណា ដឹងទេថាគ្រោះថ្នាក់"

ប្រយោគនេះធ្វើឲ្យស្តេចទាំងពីរអង្គដឹងថា អាថ៌កំបាំងគ្មានទេនៅក្នុងលោកនេះ។

"មិនបានហាមទេដែលចេញទៅជួបប្រជារាស្ត្រ ទៅរកការពិតឬស្អីក៏ដោយប៉ុន្តែត្រូវម៉ត់ចត់ មិនទុកចោលបញ្ហាពេលនេះពួកវាដឹងខ្លួនហើយថាមានមនុស្សរបស់យើងលួចទៅបន្លំក្នុងនោះ គ្រាន់តែមិនដឹងថាជា



អ្នកណាប៉ុណ្ណោះ ដូច្នេះហើយលើកក្រោយត្រូវម៉ត់ចត់ជាងនេះនិងមិនត្រូវស្តែងយាងទៅដោយអង្គឯង"

ប្រយោគក្រោយ មិខាអ៊ីល ដើរមកឈរទល់មុខម្ចាស់ផែនដី និងមើលទ្រង់ដោយការស្តីបន្ទោសដោយបើកចំហ។

"បើកើតអីនោះ ស្រុកទេសនឹងទៅជាយ៉ាងណា ទូលបង្គំចង់ដាស់តឿនទ្រង់ទាំងពីរ"

ពេលនេះព្រះអង្គម្ចាស់ក៏ត្រូវស្តីបន្ទោសដែរ ដោយមិនទុកព្រះភក្ត្រ។

"ហើយរឿងមួយទៀត..."

មិខាអ៊ីល និយាយហើយមើលព្រះភក្ត្ររបស់ស្តេចទាំងពីរមិនដាក់ភ្នែក។

"ទូលបង្គំពន្លឿនថ្ងៃអភិសេកហើយ មិនចង់ទុកឲ្យយូរ ពីរអាទិត្យក្រោយ"

"ពីរអាទិត្យ!" សម្តេចមហាក្សត្រីភ្ញាក់ព្រះទ័យ "ប្រញាប់ទៅណាព្រះរៀម"

"មិនប្រញាប់ទេ តែឃើញថាសមគួរបើទ្រង់មានព្រះទ័យដូចគ្នាចង់បម្រើស្រុកទេសជាមួយគ្នាបានដល់ថ្នាក់ចេញទៅក្រៅវាំងដោយមិនប្រាប់ជាមុន សក្តិសមនឹងអភិសេកឆាប់ៗ ព្រោះបើឃើតយ៉ាវជាងនេះទ្រង់ទៅណា ទ្រង់កើតអីនៅក្រៅវាំង ស្រុកទេសនឹងជ្រួលច្របល់ អីចឹងហើយសក្តិសមនឹងអភិសេកមុនពេលដែលមានអ្នកណាកើតស្ទីបានមុនទូលបង្គំមកទូលថ្វាយឲ្យទ្រង់ជ្រាបតែប៉ុណ្ណឹង ហើយបើនាំគ្នាចេញទៅណាទៀត សូមទ្រង់មេត្តាប្រាប់ខ្ញុំទូលបង្គំជាមុន"

មិខាអ៊ីល និយាយចប់ក៏បែរខ្នងដើរចេញពីបន្ទប់ព្រះរាជកិច្ចនោះ



ទុកឲ្យព្រះអង្គម្ចាស់ អាឌែល និងសម្តេចមហាក្សត្រីនៅជាមួយគ្នាពេញមួយថ្ងៃមិនព្រមចេញទៅណាដោយការពិចារណា។

ថ្ងៃបន្ទាប់មកក៏មានការរាយការណ៍ទៅខាងមន្ទីរពេទ្យ មណ្ឌលកុមារកំព្រានិងគ្រប់ទីកន្លែងដែលទ្រង់ចង់ស្តេចយាងចុះទៅឲ្យដឹងជាមុនមួយថ្ងៃ ឲ្យប្រជាជនទូទាំងប្រទេសបានដឹង។

"យើងត្រូវទៅគ្រប់កន្លែងក្នុងប្រទេស សិក្សាបញ្ហាប្រជាជនដោយផ្ទាល់ឲ្យច្បាស់លាស់និងម៉ត់ចត់ ជួយមន្ត្រីរាជការល្អធ្វើការ"

ព្រះអង្គម្ចាស់ត្រាស់ពេលគង់ប្រថាប់នៅក្នុងរាជរថ យាងត្រឡប់ទៅរាជវាំងខណៈដែល **អ្នកស្តាប់** ដកដង្ហើមធំពេលដឹងពីបញ្ហាទាំងឡាយ។

កាលមុនពេលបណ្តោយឲ្យ **បងប្រុស** ធ្វើគ្រប់យ៉ាងដោយខ្លួនឯងមិនធ្លាប់ដឹងអី ទើបមិនធ្លាប់មានព្រះទ័យតានតឹងដូចពេលនេះ។

"យើងមិនបានធ្វើការតែពីរនាក់ទេ នឹងរកមនុស្សមកជួយ"

ព្រះអង្គម្ចាស់ត្រាស់ បន្ទាប់ពីត្រួតពិនិត្យព្រះភក្ត្ររបស់ព្រមហាក្សត្រីដែលត្រឹមងក់ព្រះកេសាជាការទទួលដឹង។

"ដឹងឬថាឲ្យអ្នកណាជួយ" ព្រះអង្គម្ចាស់សើចញឹមៗ ខណៈដែលលូកព្រះហស្តទៅចាប់ព្រះហស្តតូចស្តើងក្តោបផ្តល់ភាពកក់ក្តៅ ធ្វើឲ្យព្រះនេត្រថ្លាយង់ដែលទតទៅក្រៅរាជរថ ត្រូវងាកមករកព្រះភក្ត្ររបស់ព្រះអង្គម្ចាស់។

"ម៉េចក៏មិនដឹង មន្ត្រីរាជការរបស់យើងហ្នឹងអី"

"ខុស មិនមែនទេ ពួកគេត្រូវធ្វើការតាមតួនាទីស្រាប់ហើយ ប៉ុន្តែអ្នកដែលយើងនិយាយម្នាក់នេះជាក្រុមថ្មីដែលត្រូវប្រើពេលវេលា **បង្កើត** និង **អប់រំទូន្មាន**ជាពិសេស ដើម្បីឲ្យគេដើរតាមយើងឲ្យបានសម្រេច"



"ក្រុមណា ?" ទ្រង់សួរនិងចងចិញ្ចើមដាក់ ពេលទតមើលព្រះនេត្រមុតស្រួច មានរោមភ្នែកងរវែងស្អាតមិនចាញ់មនុស្សស្រី ធ្វើឲ្យទ្រង់ភ្លើតភ្លើនមួយខណៈ។

អាកប្បកិរិយាមិនសង្រួមនោះធ្វើឲ្យព្រះអង្គម្ចាស់ញញឹម ហើយត្រាស់។

"កូនរបស់យើងហ្នឹងអី"

លើកនេះសម្ដេចមហាក្សត្រី ឬ ព្រះអង្គម្ចាស់ អាឌែល ចង់ហៅថា **ព្រះអង្គម្ចាស់ក្សត្រីរបស់ព្រះអង្គ** ក៏ព្រិចព្រះនេត្រដោយការភ្ញាក់ព្រះទ័យ ព្រះភក្ត្រឡើងក្រហមមួយរំពេច រាលទៅដល់ព្រះការណ៍ បន្ទាប់មកក៏បែរព្រះភក្ត្រចេញ គ្មានព្រះសវនីយ៍អីតទៅទៀត។

ព្រះហស្តតូចស្តើងត្រូវលើក មកជំពិតដោយព្រះឱស្ឋស្អាតជាលើកដំបូង ជំពិតខ្លាំងៗ ហើយត្រូវក្តោបបែបនោះយ៉ាងយូរ។

សម្ដេចមហាក្សត្រី ឬព្រះអង្គម្ចាស់ក្សត្រី រ៉ននី ទ្រង់ទាញព្រះហស្តមកវិញភ្លាមប៉ុន្តែត្រូវ **ចាប់ជាប់** មិនព្រមលែងរហូតដល់ត្រូវ **បណ្តោយ** ឲ្យរឹបអូសបែបនោះ រហូតដល់ព្រះបរមរាជវាំង។

ស្រីបម្រើដែលមករង់ចាំទទួលព្រះរាជដំណើរក៏នាំមើលដោយការភ្ញាក់ផ្អើល ពេលឃើញព្រះអង្គម្ចាស់ អាឌែល ស្ដេចយាងចុះពីព្រះរាជរថ ដោយមានព្រះហស្តរបស់សម្ដេចមហាក្សត្រីនៅក្នុងព្រះហស្តរបស់ទ្រង់ ហើយដឹកដៃគ្នាយាងចូលដំណាក់រាជកិច្ច ដោយមិនយកចិត្តទុកដាក់នឹងខ្សែភ្នែករបស់អ្នកណា។

**សម្ដេចព្រះមាតាទ្រង់សព្វព្រះទ័យជាខ្លាំង ពេលសម្ដេចមហាក្សត្រី** ទ្រង់មានគូអភិសេកដែលសក្តិសម បន្ទាប់ពីត្រូវខ្វល់ព្រះទ័យយូរមក



ហើយថាអ្នកដែលទ្រង់មិនត្រូវការ នឹងឡើងអង្គុយលើរាជបល្ល័ងនេះ។ ចាប់តាំងពីថ្ងៃដែលជួប អ៊ីម៉ាម លើកចុងក្រោយទ្រង់ក៏មិនយាងទៅជួបទៀត ព្រោះដឹងថាបើជួបគ្នាបន្ត អ៊ីម៉ាម នឹងមាន **ព័ត៌មាន** ព្រះរាជធីតុបតីដែលទ្រង់មិនពេញព្រះទ័យមករាយការណ៍ឲ្យទ្រង់ធុញទ្រាន់ទៀត ទើបទ្រង់សម្ងំរហូតដល់ថ្ងៃរៀបអភិសេក ដោយមានក្តីសង្ឃឹមនិងពេញព្រះទ័យជាខ្លាំង។

មិខាអ៊ីល និងហ្វៃប្រការបស់គេមើលសម្ដេចព្រះស្វាមីដែលស្ដេចយាងបណ្តើរសម្ដេចមហាក្សត្រីដោយការសរសើរផង ជូរទ្រូងផងនៅថ្ងៃអភិសេកដ៏អធិកអធម។

គេសប្បាយចិត្តណាស់ដែលសម្ដេចមហាក្សត្រីទ្រង់មានអ្នកដែលសក្តិសមនៅក្បែរ មិនធ្វើឲ្យព្រួយបារម្ភទៀត។

ទោះថ្ងៃនេះ ទ្រង់នៅថ្មីចំពោះការគ្រប់គ្រងរាជាណាចក្រដ៏ធំល្វឹងល្វើយនេះ ប៉ុន្តែពេលវេលានិងបទពិសោធន៍ដែលទទួលបានដោយព្រះអង្គឯងនិងបង្កើតបានសម្ដេចព្រះមហាក្សត្រី និងសម្ដេចព្រះស្វាមីដែលពោរពេញទៅដោយទសពិធរាជធម៌នាថ្ងៃអនាគត។

ប្រជាជនជាកម្លាំងដ៏សំខាន់ដែលនឹងធ្វើឲ្យទ្រង់ទាំងពីររឹងមាំ និងមានវិសាលភាព។ មានតែប្រជាជនប៉ុណ្ណោះដែលប្រកាសឲ្យពិភពលោកដឹងថាទ្រង់ទាំងពីរសក្តិសមនឹងរាជបល្ល័ងនេះយ៉ាងណា។

មិខាអ៊ីល គិតពេលឱនគំនាប់សម្ដេចមហាក្សត្រីនិងសម្ដេចព្រះស្វាមី ខណៈដែលទ្រង់ស្ដេចយាងកាត់មុខ។ គេឃើញព្រះនេត្ររបស់សម្ដេចមហាក្សត្រីដែលមើលមក បងប្រុស មិនដូចកាលមុន ហើយពេលទ្រង់បែរព្រះភក្ត្ររកអ្នកដែលនៅក្បែរគេដឹងថាព្រះនេត្រមួយគូនោះមានពន្លឺនៃក្តីសង្ឃឹម មិនហេងហាង ឯការ ធ្វើឲ្យគេព្រួយបារម្ភទៀត។



អ្នកកំលោះញញឹមរីករាយ ខណៈដែលដៃរបស់ខ្លួនក្តោបដៃហេឃ្យ ហើយងាកទៅប្រសព្វភ្នែកនឹងនាងដោយអារម្មណ៍ធូរទ្រូងដែលមិនធ្លាប់មាន។

**ការដោះម្ជុលចេញពីព្រះកេសារមិនបាន ធ្វើឲ្យអ្នកដែលទើបតែ**ដើរចេញពីបន្ទប់ស្រង់ទឹកដើរមកឈរក្រោយខ្នង និងលើកដៃទាញព្រះហស្តតូចស្តើងនោះធុញថប់ និងជួយដោះម្ជុលឲ្យដោយការប្រុងប្រយ័ត្ន បន្តដោយព្រះសុវងធូន់កណ្តុក រួមទាំងកងដៃទាំងសងខាងមិនបូករួមកងជើងដែល គ្រឿងលម្អទាំងនេះ ទ្រង់យកមកថ្វាយដល់គូអភិសេកដោយផ្ទាល់ព្រះ អង្គ។

ព្រះអង្គម្ចាស់ដោះតែម្ខាង សល់ម្ខាងទៀតនឹងកជើង ឲ្យសម្តេចមហាក្សត្រីទ្រង់ដឹងថាទ្រង់មានម្ចាស់ តាមប្រពៃណីនិងច្បាប់ហើយបន្ទាប់មកក៏ថយចេញឲ្យឆ្ងាយដើម្បីបើកឱកាសឲ្យទ្រង់ចូលស្រង់ទឹក។

ពេលទ្រង់ចេញមកវិញ ឃើញសម្តេចព្រះស្វាមីផ្ទុំលើក្រឡាបន្ទំធំល្វឹងល្វើយ ហាក់ដូចលង់លក់ តែមិនច្បាស់ ទោះយ៉ាងទៅឈរជិត រហូតដល់គង់នៅលើគ្រែឲ្យជិតបំផុត ទតមើលព្រះភក្ត្ររបស់អ្នកនៅចំពោះមុខ។ ហើយខណៈដែលកំពុងទតដោយព្រះទ័យភ្លើតភ្លើន ម្ចាស់ព្រះភក្ត្រសង្ហាក៏បើកព្រះនេត្រមើលមកល្មម ឲ្យបានដឹងនៅវេលានោះថាមិនបានលង់លក់ដូចទ្រង់គិត ធ្វើឲ្យសម្តេចមហាក្សត្រីព្រិចព្រះនេត្រញាប់ស្អេកធ្វើជាលង់លក់ភ្លាម តែលែងទាន់ទៅហើយ ព្រោះនាទីបន្ទាប់មកព្រះហស្តរឹងមាំក៏លូកទៅចាប់ព្រះហស្តទន់ល្មើយ ទៅជំពិតថ្នមៗ ហើយត្រាស់ឲ្យសណ្តាប់។

"ប្រាប់ហើយមែនទេថា ពេលនៅក្នុងផ្ទះយើងមានគ្នាតែពីរនាក់



មិនបាច់សុំអនុញ្ញាតអ្នកណាដើម្បីចូលជួបសម្តេចមហាក្សត្រី"

ទ្រង់ខ្សឹបប្រាប់ ហើយប្តូរពីការជំពិតព្រះហស្ត ជាការជំពិតព្រះនលាតថ្នមៗដោយការប្រុងប្រយ័ត្ន។

ចំហាយកក់ក្តៅ និងក្លិនព្រះវរកាយដែលទ្រង់មិនធ្លាប់ស្គាល់សាយភាយពេញអាកាស ឱបក្រសោបព្រះវរកាយតូចស្តើងតាមដោយវង្វង់ដៃរឹងមាំ និងដើមទ្រូងហាប់ណែនដោយសាច់ដុំ ប្រាប់ឲ្យដឹងថាមិនត្រឹមតែព្រះទ័យទេដែលរឹងមាំ សូម្បីតែព្រះវរកាយដែលឱបក្រសោបទ្រង់នាពេលនេះក៏រឹងមាំ។

"មិនសុំអនុញ្ញាត...ប្រាប់ហើយមែនទេ"

ទ្រង់ខ្សឹបដាក់ព្រះកាណ៌ដែលពេលនេះឡើងពណ៌ផ្កាឈូក ហើយជំពិតវាថ្នមៗ។

បបូរមាត់ស្អាតអូសមករកថ្ពាល់ ជំពិតថ្នមៗ ប្រាប់ឲ្យទ្រង់ដឹងថាចាប់ពីពេលនេះទៅព្រះវរកាយនៅក្នុងវង្វង់ដៃមួយនេះជាទំនួលខុសត្រូវដ៏ធំធេងពេញមួយជីវិតទ្រង់ ដោយគ្មានថ្ងៃបោះបង់។

អ្វីដែលនឹងបានទទួល នឹងឲ្យគ្នានៅវេលាបន្ទាប់ពីនេះគឺសន្យាដោយព្រះវរកាយ ដែលកំពុងឱបក្រសោបសម្តេចមហាក្សត្រីនៅពេលនេះ។

"បងសន្យា...រ៉ននី"

ព្រះហស្តឱបក្រសោបចង្កេះតូចស្តើង ព្រះហស្តម្ខាងទៀតក្រសោបព្រះភក្ត្រស្រស់ស្អាត។

"បងជារបស់អូនតែម្នាក់...យើងជារបស់គ្នាតែប៉ុណ្ណោះ ពេញមួយជីវិត"



ព្រះភស្ត្រាពណ៌ស ត្រូវទាញចេញថ្នមៗបង្ហាញឲ្យឃើញព្រះវរកាយ

ស្រទៀវស្រទ្បូនពេញព្រះនេត្រ នៅក្រោមរាត្រីងងឹង។

ព្រះហស្តកក់ក្ដៅអូសកាត់.ក ស្មា ដើមទ្រូងទ្រលុកទ្រលន់ អូសទៅដល់ពោះ ចង្កេះ ចុះទៅក្រោមជាងនោះ បន្ទាប់មកក៏អូសមករករន្ធផ្ចិត ខណៈដែលព្រះហស្តទន់ល្មើយស្ទាបអង្អែលដើមទ្រូងហាប់ណែនដោយសាច់ដុំដោយពេញព្រះទ័យ។

សម្ដេចមហាក្សត្រី ញ័រព្រះវរកាយពេលត្រូវជំពិតសព្វសាច់បែបនេះ តាំងពីកណ្ដាលក្បាល ថ្ងាស ប្រជុំចិញ្ចើម ច្រមុះ បបូរមាត់ ចុងចង្កា ប្រឡោះ.ក ដើមទ្រូង ចុះមកដល់ចុងជើង បន្ទាប់មកក៏ត្រូវគ្រប់គ្រងឲ្យរលាយក្លាយជាសាច់មួយ។

# ២២

មួយសប្ដាហ៍ក្រោយមក

សម្ដេចព្រះស្វាមីទ្រង់ នឹងយាងទៅសួរសុខទុក្ខប្រជារាស្ត្រនៅតំបន់ជាយដែនសមុទ្រខ្សាច់ដ៏ក្ដៅគគុក ក្រោមការមិនពេញព្រះទ័យរបស់សម្ដេចមហាក្សត្រី។

"ម៉េចចាំបាច់ទៅដល់ទីនោះ?"

"ពួកគេជាមនុស្សរបស់យើង ចង់ទៅមើលបន្តិចថារស់នៅយ៉ាងម៉េចយ៉ាងម៉ា"

"វាឆ្ងាយពេកហើយ"

"ឆ្ងាយសម្រាប់សម្ដេចមហាក្សត្រី តែមិនមែនសម្រាប់សម្ដេចព្រះស្វាមី អូខេ អូនធ្វើការរបស់អូន បងធ្វើការរបស់បង អូនសម្លាញ់"

សម្ដេចព្រះស្វាមីត្រាស់ហើយឱនជំពិតព្រះនលាត ហើយយាងចេញពីទីគង់ប្រថាប់ ដែលនៅខាងក្រៅមានក្បួនរាជអង្គរក្ស រាជបរិវាររង់ចាំត្រៀបត្រា។



ដែលទ្រង់ត្រូវយាងទៅតំបន់ជាយដែន ព្រោះមានការរាយការណ៍

ច្រើនដងហើយថាមានការជួបជុំគ្នាជាញឹកញាប់ពីក្រុមមនុស្សដែលមិនស្គាល់សញ្ជាតិ ជនជាតិដែលជាហេតុធ្វើឲ្យទ្រង់ចង់យាងទៅមើលដោយផ្ទាល់។

**ខណៈដដែលនោះ មិខាអ៊ីល ក៏បានដំណឹងដូចគ្នា។**

"សម្តេចព្រះស្វាមីស្តេចយាងទៅទីនោះ"

"អ្ហឺម ? ទៅធ្វើអី ?"

"ទ្រង់ទូលព្រះរាជនីថាទ្រង់ទៅសួរសុខទុក្ខប្រជារាស្ត្រតែតាមពិតទៅត្រង់នោះគ្មានប្រជារាស្ត្ររបស់យើងប៉ុន្មានទេ មានតែក្រុមចោរដែលមកប្រជុំគ្នាប៉ុណ្ណោះ"

ពេលបានឮការរាយការណ៍ដ៏លម្អិតហើយ មិខាអ៊ីល ក៏ញញឹមមិនចេញ។

"រៀបចំកងកម្លាំងទៅឲ្យទាន់ ឲ្យលឿន បញ្ជាក់! ចូលទៅឲ្យទាន់ហើយយាងព្រះអង្គត្រឡប់មកវិញឲ្យបាន បើចាំបាច់គឺវាយលុកពួកវា តែត្រូវយាងសម្តេចព្រះស្វាមីមកវិញជាមុនសិន"

"បាទទាន"

ទោះអង្គរក្សទទួលបញ្ជាហើយក៏ដោយ តែ មិខាអ៊ីល នៅតែខ្វល់ខ្វាយ ធ្វើឲ្យហ្វៀកាសួរនាំ។

"មានអីកើតឡើង ?"

"សម្តេចព្រះស្វាមីស្តេចយាងទៅតំបន់ចោរ ដែលយើងសង្កេតការណ៍ពួកវាយូរហើយ"

"ទ្រង់យាងទៅតែអង្គឯងឬ ?"

"មានសេនាទាហានទៅដែរ តែវានៅតែគ្មានសុវត្ថិភាពដដែល ព្រោះពួកវាប្រជុំគ្នាយូរហើយ មានមនុស្សច្រើនកុលសម្ព័ន្ធទៅផ្តុំគ្នាត្រង់នោះមិនមែនជាប្រជារាស្ត្ររបស់យើងសុទ្ធសាធទេ"

"អីចឹងប្រថុយពេកហើយ"

"មែន ប្រថុយពេកហើយ"

"យាងទ្រង់មកវិញមក"

"នេះបញ្ជូនកងកម្លាំងទៅតាមហើយ"

**"ទីបំផុតវាមកក៏មក"**

អ៊ីម៉ាម សាឌីន និយាយរអ៊ូៗដោយការពេញចិត្តពេលបានទទួលការរាយការណ៍ពីកូនចៅ ដែលបញ្ជាឲ្យឃ្លាំមើលសកម្មភាពរបស់សម្តេចព្រះស្វាមីតាំងពីថ្ងៃរៀបអភិសេក។

"ពេលនេះមកដល់ណាហើយ ?"

"ពាក់កណ្តាលផ្លូវហើយទាន"

"អីចឹងមិនបាច់ចាំវាមកដល់ទីនេះទេ ចេញទៅទទួលវានៅកណ្តាលផ្លូវ កម្ទេចវាឲ្យខ្ទេចនៅត្រង់នោះ កប់វានៅក្នុងខ្សាច់ មិនឲ្យវារស់បានត្រឡប់ទៅវិញសូម្បីតែម្នាក់"

បញ្ជានោះធ្វើឲ្យកូនចៅ ដែលឆ្លងដែនមកពីប្រទេសជទៃនាំគ្នាស្រែកជ័យយោដោយការពេញចិត្តដែលបាន ធ្វើសង្គ្រាមបន្ទាប់ពីប្រមូលផ្តុំគ្នាយ៉ាងយូរ ហើយកងកម្លាំងទាំងអស់របស់ អ៊ីម៉ាម សាឌីន គូសត្រូវរបស់ មិខាអ៊ីល ក៏នាំគ្នាធ្វើដំណើរសំដៅទៅ ស្វាគមន៍ សម្តេចព្រះស្វាមីដោយមិនរង់ចាំឲ្យទ្រង់មកដល់កន្លែងរបស់ខ្លួន។



**សម្តេចព្រះស្វាមីមិនបានស្តេចយាងជាមួយនឹងកងអង្គរក្ស ដែល**

មានតែបន្តិចបន្តួចដូចគ្រប់គ្នាគិត ព្រោះកងកម្លាំងរបស់ព្រះអង្គដែលតាមមកការពារនៅព្រះរាជាណាចក្រសាគីស្ថាន ត្រូវបញ្ជាឲ្យទៅលាក់ខ្លួននៅសមុទ្រខ្សាច់ ដើម្បីរង់ចាំទទួលរាជបញ្ជាតាំងពីយូរម្ល៉េះ។

នេះគឺដើម្បីរក្សាការពារសម្ដេចព្រះស្វាមី និងការពារយុំគ្រងពេលមានអាសន្ននោះឯង ហើយកងកម្លាំងទាំងនោះក៏មកចូលរួមនឹងកងកម្លាំងដែលមកជាមួយទ្រង់ ប្រជុំគ្នានៅកន្លែងណាត់ជួបកណ្ដាលសមុទ្រខ្សាច់។

ដូច្នេះហើយពេលកងកម្លាំងរបស់ អ៊ីម៉ាម សាឌីន មកជួបនឹងកងកម្លាំងរបស់សម្ដេចព្រះស្វាមីក៏នាំគ្នាភ្ញាក់ផ្អើល និងងឿងឆ្ងល់ជាខ្លាំងដែលវាមានច្រើនហួសពីការស្មាន។ កងកម្លាំងទាំងពីរប្រឈមមុខគ្នានៅកណ្ដាលសមុទ្រខ្សាច់ និង ប៉ានប្រមាណកងកម្លាំងគ្នាដោយមិនច្បាស់ប៉ុន្មានជាពិសេសអ៊ីម៉ាមសាឌីនដែលប៉ានប្រមាណខុសមួយរយភាគរយតែវាដកថយមិនបានពេលដើរមកដល់ចំណុចនេះទៅហើយ ក្រៅពីច្បាំងគ្នាឲ្យដឹងឈ្នះចាញ់ ហើយកងកម្លាំងរបស់សម្ដេចព្រះស្វាមីក៏បោលសម្រុកវាយបំបែកក្រុមចោររបស់ អ៊ីម៉ាម សាឌីន ដោយមិនញញើត។

កងកម្លាំងរបស់ មិខាអ៊ីល មកទាន់វេលាដែលកងកម្លាំងទាំងពីរកំពុងតែប្រយុទ្ធគ្នា និងបញ្ជាដែលទទួលបានគឺយាងសម្ដេចព្រះស្វាមីចេញពីកន្លែងច្បាំង និងការពារទ្រង់ត្រឡប់ទៅព្រះបរមរាជវាំងដោយសុវត្ថិភាព។

បុគ្គលទីបី ដែលលេចមុខមកជ្រៀតជ្រែកធ្វើឲ្យសម្ដេចព្រះស្វាមីទ្រង់ងឿងឆ្ងល់ រហូតដល់អង្គរក្សជំនិតរបស់ មិខាអ៊ីល ចូលគាល់ និងបង្ហាញភ័ស្តុតាង។

"ព្រះអង្គម្ចាស់ មិខាអ៊ីល អ៊ីចឹងឬ?" ទ្រង់ត្រាស់សួរដោយការសង្ស័យ។

"មែនហើយក្រាបទូល សម្ដេចព្រះស្វាមីយាងតាមទូលបង្គំសិនមក នេះជារាជបញ្ជារបស់ព្រះប្រមុខរដ្ឋស្ដីទី"

អង្គរក្សរបស់ មិខាអ៊ីល នាំសេះរបស់ខ្លួនរត់នាំមុខសម្ដេចព្រះស្វាមីចេញពីកន្លែងប្រយុទ្ធគ្នាដ៏ក្ដៅគគុកនោះ មកមើលពីចម្ងាយ។

ពួកគេមើលឃើញថាកងកម្លាំងរបស់អ៊ីម៉ាមសាឌីនប្រយុទ្ធនឹងកងកម្លាំងដែលត្រូវបង្វឹក និងឆ្លងកាត់ការធ្វើសង្គ្រាមយ៉ាងជោកជាំរបស់សម្ដេចព្រះស្វាមីមិនបាននៅនាទីនោះ បន្ទាប់មកក៏បាក់ទ័ពដកថយប៉ុន្តែត្រូវដេញតាមរហូត។

ពេលសម្ដេចព្រះស្វាមីយាងមកដល់បរមរាជវាំងវិញ មិខាអ៊ីល ក៏រង់ចាំរួចទៅហើយ ពេលទ្រង់ចុះពីខ្នងសេះ។

"ទ្រង់ធ្វើស្អី ម៉េចមិនពិភាក្សាជាមួយទូលបង្គំជាមុនសិន" មិខាអ៊ីល សួរភ្លាមដោយមិនចាំឲ្យសម្ដេចព្រះស្វាមីបាននិយាយអី។

"យើងគ្រាន់តែចង់កម្ចាត់បន្លារបស់ រ៉ននី ឲ្យអស់"

"ទាំងដែលទ្រង់នៅមានរបួសកាលពីលើកមុនឬ ទ្រង់មិនទាន់ជាស្រួលបួលផង បើទ្រង់កើតអីទៅនោះ តើ រ៉ននី នឹងទៅជាយ៉ាងណា"

មិខាអ៊ីល សួរត្រង់ៗនិងបាញ់ខ្សែភ្នែកស្ដីបន្ទោសដាក់។

"ទ្រង់ទុកព្រះទ័យបានដោយរបៀបណា ថាគូអភិសេកថ្មីនឹងស្រឡាញ់ រ៉ននី ដូចដែលទ្រង់ស្រឡាញ់"

មិខាអ៊ីល នៅតែសួរបញ្ហាដែលសម្ដេចព្រះស្វាមីឆ្លើយមិនបាន។

"អ៊ីម៉ាម សាឌីន ជារឿងដែលទូលបង្គំត្រូវជម្រះឲ្យស្អាតមុនពេលចាកចេញ សូមទ្រង់ទុកព្រះទ័យ"



ការអធិប្បាយនេះធ្វើឲ្យសម្ដេចព្រះស្វាមីដកដង្ហើមធំ។

"សរុបទៅយើងសុំទោសព្រះប្រមុខរដ្ឋស្តីទីទៅចុះ"

ប្រយោគនេះធ្វើឲ្យ មិខាអ៊ីល ដកដង្ហើមធំ ហើយនិយាយបន្ត។

"ស្តេចយាងទៅរក រ៉ននី ទៅក្រាបទូល ហើយទ្រង់ធ្វើព្រះទ័យឲ្យត្រជាក់ ទូលបង្គំនឹងចាត់ការ អ៊ីម៉ាម សាឌីន មិនឲ្យនៅសល់សាកសពមិនបណ្តោយឲ្យវាមករំខានសម្តេចព្រះមហាក្សត្រីជាដាច់ខាត"

មិខាអ៊ីល និយាយហើយក៏ដើរចេញទៅ។

"អេាំ!" សម្តេចព្រះមហាក្សត្រីព្រិចព្រះនេត្រដោយការងឿងឆ្ងល់ពេលឃើញសម្តេចព្រះស្វាមីត្រឡប់មកវិញនៅពេលអាធ្រាត្រ។

"បងមិនទៅជាយដែន?"

"ទៅរួចហើយតែទៅមិនដល់ ទៅប៉ះទង្គិចនឹងក្រុមចោររបស់អ៊ីម៉ាម នៅកណ្តាលផ្លូវ"

ការអធិប្បាយនោះធ្វើឲ្យ រ៉ននី ចំហមាត់ឆ្ងង។

"នេះមានន័យថាបងទៅ ច្បាំង ឬ?" អាឌែល មិនតបតែដើរចូលបន្ទប់ស្រង់ទឹក ព្រោះទ្រង់ហត់នឿយពេញមួយថ្ងៃទៅហើយ។

មិខាអ៊ីល និយាយត្រូវទាំងអស់ សូម្បីតែរឿងព្រះវរកាយ។ ពេលស្តេចយាងចេញមកវិញ ក៏ឃើញស្តេចផែនដីគង់លើក្រឡាបន្ទំរង់ចាំការអធិប្បាយ។

"ហើយឈ្នះឬចាញ់?"

"មនុស្សរបស់វាតិចជាងរបស់យើង"

"ប៉ុន្មាននាក់ បើបងនាំគ្នាទៅមិនដល់ហាសិបនាក់ផង"

លើកនេះ អាឌែល ដកដង្ហើមធំ ហើយប្រាប់ការពិត។

"មានកងកម្លាំងរបស់បងរង់ចាំនៅកណ្តាលសមុទ្រខ្សាច់"

លើកនេះ រ៉ននី ទៅជាភាំង និយាយមិនចេញយ៉ាងយូរ ភ្នែកសម្លឹងមើលព្រះស្វាមីដោយមិនចង់ជឿ។

"នេះមានន័យថាបងលាក់កងកម្លាំងរបស់បងឬ?"

"បើទីនេះព្យាយាមសម្លាប់ឬកម្ចាត់បង មិនថាដោយប្រការណា"

ចម្លើយរបស់ព្រះអង្គម្ចាស់ ធ្វើឲ្យព្រះមហាក្សត្រីដកដង្ហើមធំ ហើយយាងចុះពីក្រឡាបន្ទំភ្លាម តែយាងមិនបានប៉ុន្មានជំហាន ក៏ត្រូវលើកបីយកទៅដាក់កន្លែងវិញ។

"សូមមេត្តា រ៉ននី សុំឲ្យអូនយល់ពីបង បងគ្រាន់តែត្រូវការកម្ចាត់ពួកចោរ អ៊ីម៉ាម ឲ្យអស់ប៉ុណ្ណោះមិនត្រូវការឲ្យមានបន្លាមករំខានអូនព្រះប្រមុខរដ្ឋស្តីទីក៏យល់"

"ពាក់ព័ន្ធអីព្រះរៀម?"

ទ្រង់ប្រែព្រះកាយ ងាកមកសួរភ្លាម។

"ទ្រង់ដឹង និងបញ្ជូនកងកម្លាំងទៅនាំបងត្រឡប់មកវិញ ដោយមានកងកម្លាំងរបស់សាគីស្ថានទៅដែរ រំពឹងកងកម្លាំងរបស់បងក៏ច្រើនជាងកងកម្លាំងចោរទៅហើយ នៅមានកងកម្លាំងរបស់ព្រះប្រមុខរដ្ឋស្តីទីតាមទៅទៀត ទើបវានាំគ្នារត់ ពេលត្រឡប់មកវិញកងកម្លាំងរបស់បងនិងកងកម្លាំងរបស់ព្រះប្រមុខរដ្ឋស្តីទីដេញវាទៅដល់ជាយដែនតែម្តង"

សម្តេចព្រះមហាក្សត្រីសណ្តាប់ហើយនៅស្ងៀម ទ្រង់និយាយអីមិនចេញរហូតដល់សម្តេចព្រះស្វាមីផ្ទុំក្បែរ។

"សូមមេត្តាទុកចិត្តបង បងគ្រាន់តែត្រូវការការពារអូន និងការពារខ្លួនឯងប៉ុណ្ណោះ"



ទ្រង់ក្រសោបដៃទន់ល្មើយរបស់មនុស្សស្រីជាទីស្រឡាញ់ តែសម្តេចព្រះមហាក្សត្រីទាញចេញ និងខិតទៅឲ្យឆ្ងាយ សម្លឹងមើលមក



Scanned by CamScanner

ដោយការសង្ស័យ។

"អូនមិនច្បាស់ ថាបងបារម្ភពីអូនឬបារម្ភពីខ្លួនឯងឲ្យប្រាកដ"

"រ៉ែននី អូនភ្លេចហើយឬថាបងបារម្ភពីអូនជាងជីវិត"

សម្តេចព្រះមហាក្សត្រីនៅស្ងៀមយ៉ាងយូរ មុននឹងយាងចេញពីក្រឡាបន្ទំ សំដៅព្រះរាជដំណាក់របស់សម្តេចព្រះមាតាទាំងយប់អាធ្រាត្រ និងផ្ទុំនៅទីនោះ។

យូរៗ ម្តងទើបព្រះប្រមុខរដ្ឋស្តីទីចូលគាល់សម្តេចព្រះមហាក្សត្រី អាចនិយាយបានថាបើមិនចាំបាច់គឺគ្មានផ្លូវចូលគាល់។

"មកទាំងព្រឹកតែម្តង សោយអីហើយឬនៅ ?"

"នៅទេ"

ព្រះប្រមុខរដ្ឋស្តីទីតប ហើយដើរមករួមតុព្រះស្ងោយដោយមិនរង់ចាំរាជានុញ្ញាត ធ្វើឲ្យសម្តេចព្រះមាតាងើបចេញភ្លាម តែ មិខាអ៊ីល មិនរវល់។

"យប់មិញសម្តេចព្រះស្វាមីទៅរក"

"អុំ! ទៅរកបក្ខពួក"

"គេមិនចាំបាច់ប្រាប់រឿងកងកម្លាំងរបស់គេក៏បានដែរ ម៉េចចាំបាច់ខឹង"

"គេមិនទុកចិត្តយើង"

"ចង់ឲ្យទុកចិត្តអ្នកណាបាន នឹកដល់ចិត្តគេចិត្តយើងសិនទៅ"

"ព្រះរៀមចង់ថាអនុជឬ ?"

"ព្រះស្វាមី ដែលស្លាប់ជំនួសបានមិនមែនរកបានងាយៗទេ... នេះជាការដាស់តឿន"

មិខាអ៊ីល ផឹកតែកាហ្វេមួយកែវ ហើយចាកចេញទៅ ទុកឲ្យសម្តេចព្រះមហាក្សត្រីដកដង្ហើមធំ និងយាងត្រឡប់ទៅព្រះរាជដំណាក់វិញ។

ទីនោះសម្តេចព្រះស្វាមីមើលមកដោយទឹកមុខធម្មតា មិនយកចិត្តទុកដាក់។

"បងបានដំណឹងរឿង អ៊ីម៉ាម ហើយឬនៅ ?"

"ស្លាប់ហើយ...យប់មិញ បន្ទាប់ពីរត់ត្រឡប់ទៅវិញបានតែទ្រាំនឹងពិសមុខរបួសមិនបាន ចប់ហើយភាពចលាចលច្របូកច្របល់ទាំងឡាយ"

"អរគុណដែលបងជួយ"

"បើព្រះប្រមុខរដ្ឋស្តីទីមិនមកនិយាយឲ្យប្រហែលមិនព្រមយល់ទេមែនទេ"

សំណួរនេះធ្វើឲ្យសម្តេចព្រះមហាក្សត្រីនិយាយមិនចេញតែម្តង។

"អូនជឿបងប្រុសណាស់មែនទេ និងមិនជឿ អ្នកដទៃ"

សម្តេចព្រះមហាក្សត្រីគិតតែនៅស្ងៀម មិនតបត។

"បងយល់ ដែលរង់ចាំនេះ បងរង់ចាំប្រាប់ថា បងនឹងត្រឡប់ទៅផ្ទះហើយថ្ងៃនេះ តែប៉ុណ្ណឹង"

និយាយចប់ សម្តេចព្រះស្វាមីក៏យាងចេញពីព្រះរាជដំណាក់ដោយមិនងាកមើលក្រោយ ទុកឲ្យសម្តេចព្រះមហាក្សត្រីស្ថិតនៅត្រង់នោះយ៉ាងយូរ ទាំងអួលដើម.ក តែព្រះកន្សែងមិនចេញ តែមិនយូរប៉ុន្មានក៏សម្រូតព្រះវរកាយ។

...

ហេឃ្យូ ដើររកស្វាមី បន្ទាប់ពីទ្រង់ចូលគាល់សម្តេចព្រះមហាក្សត្រីរួចរាល់ និងឃើញ មិខាអ៊ីល នៅក្នុងសួន មិនមែននៅក្នុងបន្ទប់ធ្វើការ



ដូចរាល់ដង។

អ្នកកំលោះអង្គុយ សម្លឹងមើលទៅអ្វីវែងឆ្ងាយ មិនមែនគយគន់ផ្កាដែលនៅជិតភ្នែក។

"ភ្លើតភ្លើនដល់ហើយកំពុងគិតអី ?"

"កំពុងសប្បាយចិត្តដែលបានប្រគល់ការងារតួនាទីឲ្យសម្តេចព្រះមហាក្សត្រីរួចរាល់ សល់តែមួយប៉ុណ្ណោះ"

"ស្អីគេ ?"

"សម្តេចព្រះស្វាមីទៅយូរពេកហើយ ពីរខែហើយមែនទេ"

"ចង់ទៅយាងទ្រង់មកវិញឬ ?"

"អត់ទេ លើកនេះបណ្តោយឲ្យសម្រេចចិត្តខ្លួនឯង មិនទៅចេះដឹងអូនត្រៀមខ្លួនធ្វើដំណើរបានហើយ បងនឹងទៅប្រចាំការនៅស្ថានទូតទីនោះ"

"ល្អដល់ហើយ អ៊ីចឹងកូនដំបូងរបស់យើងនឹងសម្រាលនៅទីនោះ"

"អ្វី ? មែនឬ ?"

សំឡេងនោះទាំងសប្បាយចិត្តទាំងរំភើប លូកដៃទៅទាញភរិយាឲ្យមកអង្គុយលើភ្លៅ ឱបរឹតណែនដៃ។

"នេះជាដំណឹងល្អបំផុតនៅក្នុងជីវិត អរគុណច្រើនហៃ្សកាជាទីស្រឡាញ់"

គេឱ្យបខ្សៀវដាក់នាង និងឲ្យរង្វាន់អ្នកម៉ាក់ថ្មោងថ្មីដោយការថើបដ៏ផ្អែមល្ហែម ធ្វើឲ្យនាងឱប.កគេ និងថើបតបវិញដោយក្តីស្រឡាញ់ពេញបេះដូងដូចគ្នា។

ពេលរាជពេទ្យ បញ្ជាក់ប្រាប់ថាសម្តេចព្រះមហាក្សត្រីទ្រង់មាន



ព្រះគភ៌ សម្តេចព្រះមាតាក៏ញញឹមញញែមដោយក្តីរីករាយ តែស្នាមញញឹមនោះរលាយបាត់អស់ ពេលគិតដល់រឿងមួយ ហើយម្ចឹម្តាយកទូរសព្ទពីស្រីបម្រើតេរឆ្លងប្រទេសទៅរកឃ្វីនឡៃឡាដែលជាព្រះសហាយរបស់ទ្រង់។

"អាឌែល អាឌែល"

សំឡេងហៅរបស់ព្រះមាតា ធ្វើឲ្យអ្នកដែលឈរនៅមាត់បង្អួចសម្លឹងមើលទៅទីដ៏ឆ្ងាយសែនឆ្ងាយងាកមករក។

"មានអីឬក្រាបទូល ?"

"រ៉ននី មានផ្ទៃពោះ ចាញ់ខ្លាំងណាស់ ខាងណោះឲ្យដំណឹងមក"

ទ្រង់ត្រាស់បែបនោះ ធ្វើឲ្យបុត្រាទៅជាព្រិចភ្នែកញាប់ស្នេកដោយក្តីរីករាយ ឈានជើងបានមួយជំហានក៏ត្រូវនៅស្ងៀមវិញ។

"កុំរវល់តែគិតច្រើន អាឌែល ទៅចុះបុត្រ បើនៅជិតនាងហើយមានសេចក្តីសុខ អ៊ីចឹងទៅៗ កុំមកដាក់ទណ្ឌកម្មខ្លួនឯងបែបនេះ មាតាដឹងថាបុត្រនឹកដល់ទ្រង់នឹកទាំងថ្ងៃទាំងយប់ ទៅចុះបុត្រ ឆាប់ទៅ កុំបណ្តោយឲ្យការមិនទុកចិត្តការមិនយល់ពីគ្នា វាដាក់ទណ្ឌកម្មយើងបែបនេះ នេះជាឱកាសរបស់បុត្រ ទៅចុះ ទៅទាមទារយកក្តីស្រឡាញ់របស់យើងមកវិញ ហើយនាំសម្តេចចៅមកលេងមាតាផង"

សម្តេចព្រះមាតាមានសវនីយ៍ ព្រមទាំងឱបបុត្រាជាការលួងលោម។



# ភាគបញ្ចប់

ពេលដឹងថាគ្រែដែលកំពុងផ្ទុំទ្រុឌ ដូចមានអ្នកណាឡើងមកអង្គុយជាមួយ សម្ដេចព្រះមហាក្សត្រីទ្រង់ក៏ប្រែព្រះវរកាយ ងាកមកទតភ្លាម។

ពេលឃើញព្រះភក្ត្ររបស់សម្ដេចព្រះស្វាមី ដែលប្រថាប់នៅក្បែរ និងមើលមកទ្រង់ក៏បែរទៅវិញព្រោះនៅខ្វាល់ប៉ុន្តែត្រូវព្រះហស្តដ៏កក់ក្ដៅទាញទៅឱបជាប់ដើមទ្រូងធំទូលាយ ត្រឹមប៉ុណ្ណឹងក៏ធ្វើឲ្យទ្រង់និយាយអីមិនចេញក្រៅពីអណ្ដឺតអណ្ដកព្រោះតូចចិត្ត។

"បងស្រឡាញ់អូនសម្ដេចព្រះមហាក្សត្រី រ៉េននី បងស្រឡាញ់អូន"

សម្ដីនេះធ្វើឲ្យសម្ដេចព្រះមហាក្សត្រី អណ្ដឺតអណ្ដកកាន់តែខ្លាំងព្រះវរកាយរញ្ជួយ។

"ទោះត្រឡប់ទៅវិញតែបងមិនធ្លាប់មានក្ដីសុខ បងនឹកអូនរាល់ថ្ងៃរាល់យប់"

ទ្រង់ប្រាប់ និងឱបរឹតអ្នកដែលខ្លួនស្រឡាញ់ជាប់ដើមទ្រូង។

"ហើយម៉េចក៏ទើបតែមក ចង់ចាំឲ្យអូនសម្រាលកូនសិនឬយ៉ាងម៉េច" ទ្រង់ខ្សឹបតវ៉ា។

"គឺខ្លាចត្រូវបណ្ដេញទៅវិញទៀត ទាយចិត្តអូនបានឯណា ចង់ប្រាប់ការពិតក៏ខឹង ធ្វើអីក៏ខឹង"

ពេលនិយាយហើយ ក៏ឱនទៅថើបមុខស្រស់ស្អាតតែស្លេកស្លាំងមើលទៅគួរឲ្យអាណិតនៅពេលនេះ។

"ប៉ុន្តែមិនត្រឡប់មកវិញក៏នឹកស៊ឹងដាច់ខ្យល់"

"ពីរខែនេះ ចង់ដាច់ខ្យល់ អ្នកណាជឿ បងមានអ្នកផ្សេងទេ"

"ធ្លាប់សន្យាហើយថានឹងគ្មាន មិនធ្លាប់ធ្វើខុសសន្យាទេ"

"ច្បាស់ហើយ"

"ច្បាស់"

ចម្លើយនោះប្រាកដប្រជាធ្វើឲ្យអ្នកស្ដាប់ដកដង្ហើមធំ។

"ណេក្ខីយ ជឿម្ដងចុះ"

"បងមិនធ្លាប់កុហក កុំប៉ុនខឹងបានទេ"

រាងកាយរបស់អ្នកដែលនៅក្នុងរង្វង់ដៃរឹងមាំស្ងប់ មិននិយាយអីទៀតវេលានេះ ទើប អាឌែល ដកដង្ហើមធំ ធូរទ្រូងខ្យាក ទើបឱនមកថើបតែមមាត់របស់មនុស្សស្រីជាទីស្រឡាញ់។

ពេលបែកគ្នាធ្វើឲ្យពួកគេដឹងចិត្តខ្លួនឯងថាស្រឡាញ់គ្នា ស្រឡាញ់តាំងពីថ្ងៃដំបូងដែលបានឃើញគ្នា រហូតមកដល់ពេលនេះពេលដឹងថាមានចំណងនៃក្ដីស្រឡាញ់កើតឡើង ក៏កាន់តែស្រឡាញ់ រហូតដល់ត្រូវសន្យាចំពោះខ្លួនឯងថានឹងមិនព្រមបែកគ្នាទៀត។

សម្ដេចព្រះមហាក្សត្រីឱប.កសម្ដេចព្រះស្វាមីដោយភ្លេចខ្លួន និងទទួលយកការថើបដ៏ទន់ភ្លន់នោះដោយក្ដីនឹករឭកអស់ពីបេះដូង បើមិនបែកគ្នាព្រោះរឿងដែលមិនយល់ពីគ្នា អាចនឹងគ្មានអារម្មណ៍នឹករឭកគ្នាដល់ថ្នាក់នេះ តែចាប់ពីពេលនេះទៅគ្មានថ្ងៃដែលទ្រង់ធ្វើអ្វីល្ងង់ៗទៀតទេ។

ពួកគេឱបរឹតគ្នាដោយក្ដីស្រឡាញ់ សម្ដេចព្រះមហាក្សត្រីមិនជំទាស់ពេលដែលត្រូវ ដោះព្រះពស្ត្រាចេញពីព្រះវរកាយម្ដងមួយៗ រហូតដល់មិននៅសល់។





Scanned by CamScanner

ទ្រង់តបទទួល ក្ដីស្រឡាញ់របស់សម្ដេចព្រះស្វាមីដោយភាពកក់ក្ដៅ ខុសពីព្រះអង្គដែលញាប់ញ័ររហូតតាំងពីស្ដេចយាងមកកាន់ទីនេះ ថានឹងត្រូវស្ដីបន្ទោស បដិសេធដោយមិនស្រណោះទៀត។

ទ្រង់បង្ហាញក្ដីស្រឡាញ់ចំពោះគ្នាដោយភាពផ្អែមល្ហែម ទន់ភ្លន់យកចិត្តយកថ្លើម។

ទោះសម្ដេចព្រះមហាក្សត្រីទ្រង់អឹមអៀន តែមិនបានជំទាស់ព្រះទ័យព្រះអង្គ សម្ដេចព្រះស្វាមីត្រូវការអ្វីក៏ព្រមប្រទានឲ្យ។

"យើងនឹងមិនបែកគ្នា រ៉ននី យើងនឹងមិនចាកចេញពីគ្នាទៀត"

ទ្រង់និយាយរអ៊ូៗ ពេលគ្រប់គ្រងព្រះវរកាយស្រឡៅស្រឡូន បើបសព្វសាច់របស់អ្នកដែលមានឈ្មោះជាព្រះជាយា បន្ទាប់ពីនៅឆ្ងាយគ្នាយូរខែ។

គ្មានពាក្យពេចន៍អីជាការតបត ក្រៅពីការសម្ងំនៅនឹងដើមទ្រូងរឹងមាំ ស្ដាប់ពាក្យសន្យាដោយព្រះភក្ត្រញញឹម។

មិខាអ៊ីល នៅតែជាទីប្រឹក្សាសម្ដេចព្រះស្វាមី និងសម្ដេចព្រះមហាក្សត្រី រហូតដល់ទ្រង់ទាំងពីរអាចបំពេញរាជកិច្ចសំខាន់ៗបាន ទើបធ្វើដំណើរទៅប្រទេសកូរ៉េខាងត្បូង កាន់តំណែងជាឯកអគ្គរាជទូតរាជាណាចក្រសាគីស្ថានប្រចាំប្រទេសកូរ៉េខាងត្បូង តាំងពីពេលនោះរហូតដល់បច្ចុប្បន្ន ដោយមិនបានត្រឡប់ទៅប្រទេសកំណើតដែលជាដែនដីសមុទ្រខ្សាច់នោះទៀត។

**( ចប់ដោយបរិបូរណ៍ )**

Scanned by CamScanner